ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ
(២០២០-២០២៤)

ខេត្តកោះកុង

បានទទួលការអនុម័តពីក្រុមប្រឹក្សាខេត្ត ក្នុងកិច្ចប្រជុំសាមញ្ញលើកទី១១ ឆ្នាំទី១ អាណត្តិទី៣
ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
កោះកុង.ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១៤៧៧ សរបក

ថ្ងៃ ចន្ទ ៤កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២០

ជម្រាបមក

លោកជំទាវអភិបាល នៃគណៈអភិបាលខេត្តកោះកុង

កម្មវត្ថុ : ស្តីពីការផ្តល់អនុលោមភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង។

យោង : -ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-អនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-ប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការ

-ប្រកាសអន្តរក្រសួងលេខ ០៨៤ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្តរវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការ

-លិខិតលេខ ២៣២/២០ ល.ស ចុះថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកោះកុង។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន**លោកជំទាវអភិបាល នៃគណៈអភិបាលខេត្តកោះកុង** ជ្រាបថា ក្រសួងមហាផ្ទៃ បានពិនិត្យចប់សព្វគ្រប់លើទម្រង់ អត្ថន័យ និងខ្លឹមសារទាំងមូលនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលខេត្តកោះកុង ដោយបានធ្វើការវាយតម្លៃខ្ពស់ចំពោះការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) ដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្តក្នុងកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ នាថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ របស់ក្រុមប្រឹក្សាខេត្ត មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងទម្រង់ អត្ថន័យ និងខ្លឹមសារសមស្របតាមក្របខ័ណ្ឌច្បាប់ និងមានសង្គតិភាពជាមួយគោលនយោបាយជាតិ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានាដែលមានជាធរមាន។ ទន្ទឹមនេះ កិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្តក៏បានអនុវត្តស្របតាមប្រកាសអន្តរក្រសួងលេខ០៨៤ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ រវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ខេត្ត ផងដែរ។ ប៉ុន្តែការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) របស់រដ្ឋបាលខេត្តកោះកុងនៅមានចំណុចខ្វះខាតមួយចំនួនដែលចាំបាច់ត្រូវធ្វើការកែតម្រូវដូចខាងក្រោម៖

១-ត្រូវដាក់ផែនទីក្នុងផែនការអភិវឌ្ឍន៍ខេត្តទំហំក្រដាស A3 ស្របតាមការណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្តដែលបានដាក់ឱ្យប្រើប្រាស់តាមរយៈប្រកាសអន្តរក្រសួងលេខ០៨៤ផក. ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ។

២-ត្រូវបរិយាយឲ្យបានច្បាស់លាស់នៃខ្លឹមសារជំពូកទី៤ អំពីយន្តការតាមដាន និងវាយតម្លៃ វិធីសាស្ត្រតាមដាន និងវាយតម្លៃ និងសូចនាករតាមដាន និងវាយតម្លៃ។

៣-ត្រូវរៀបចំខ្លឹមសារ ទម្រង់ រចនាសម្ព័ន្ធ និងឈ្មោះនៃមាតិកាមួយចំនួនក្នុងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្តឲ្យស្របតាមសៀវភៅណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្តដែលបានដាក់ឲ្យប្រើប្រាស់តាមរយៈប្រកាសអន្តរក្រសួងលេខ០៨៤ផក. ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ និងត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ខេត្ត។

៤-គ្រប់ដំណាក់កាលនៃការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងការរៀបចំគម្រោងអភិវឌ្ឍ និងផែនការថវិកាប្រចាំឆ្នាំ រដ្ឋបាលខេត្តកោះកុងត្រូវប្រើប្រាស់ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) ធ្វើជាឯកសារមូលដ្ឋានក្នុងការរៀបចំស្របតាមគោលការណ៍ច្បាប់ដែលបានកំណត់ជាធរមាន។

៥-ត្រូវធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឲ្យបានរួចរាល់មុននឹងធ្វើការបោះពុម្ព និងប្រកាសដាក់ឲ្យប្រើប្រាស់នូវសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) ជាផ្លូវការ។

ដើម្បីគាំទ្រដល់កិច្ចដំណើរការ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋានប្រកបដោយចីរភាព និងបរិយាប័ន្នឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់ក្រុមប្រឹក្សាខេត្តកោះកុងក្នុងអាណត្តិទី៣នេះ ឲ្យទទួលបានជោគជ័យ ក្រសួងមហាផ្ទៃសម្រេចទទួលស្គាល់ និងផ្តល់អនុលោមភាពនូវផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) ដែលក្រុមប្រឹក្សាខេត្តកោះកុងបានអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ នាថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ ជាផ្លូវការចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

អាស្រ័យហេតុនេះ សូម **លោកជំទាវអភិបាល** ជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម **លោកជំទាវ** ទទួលនូវការរាប់អានពីខ្ញុំ។

ឲ្យបានាយកវដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងផែនការ
-ខុទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

មាតិកា

សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខេត្តកោះកុង i
អារម្ភកថា iii
សេចក្តីផ្តើម iv
ផែនទីខេត្ត v

ជំពូកទី១ ៖ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច
- ១.១.ស្ថានភាពព័ត៌មានទូទៅរបស់ខេត្ត ១
- ១.១.១. ស្ថានភាពភូមិសាស្ត្រ ១
- ១.១.២. សេចក្តីសង្ខេបព័ត៌មាន និងសេដ្ឋកិច្ច សង្គមកិច្ច ១
- ១.២.ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ៣
  - ១.២.១.ស្ថានភាពសេដ្ឋកិច្ច ៣
  - ១.២.២.ស្ថានភាពសង្គមកិច្ច ២៥
  - ១.២.៣.ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ ៤៦
  - ១.២.៤.ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ៥៣

ជំពូកទី២ ៖ ក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា
- ២.១. ចក្ខុវិស័យអភិវឌ្ឍន៍ ៥៨
- ២.២. គោលបំណងអភិវឌ្ឍន៍ ៥៨
- ២.៣. គោលដៅអភិវឌ្ឍន៍ ៦៥
- ២.៤.យុទ្ធសាស្ត្រអភិវឌ្ឍន៍ ៧៤
- ២.៤.១.យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច ៧៤
- ២.៤.២.សាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច ៨១
- ២.៤.៣.យុទ្ធអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ៨៨
- ២.៤.៤.យុទ្ធសាស្ត្រការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ៨៩
- ២.៥.តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ ៩៣

ជំពូកទី៣ ៖ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ
- ៣.១.ក្របខ័ណ្ឌវិនិយោគ ១៨៤
- ៣.២.ក្របខ័ណ្ឌផ្តល់សេវា ២៨៥
- ៣.៣.ការចេញលិខិតបទដ្ឋានគតិយុត្តិ ២៩៩
- ៣.៤.ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ៣០៣

ជំពូកទី៤ ៖ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃផែនការអភិវឌ្ឍន៍
- ៤.១.តារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ ៣០៧
- ៤.២.តារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំ ៣៩១
- ៤.៣.តារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផ្តល់សេវាសម្រាប់រយៈពេលប្រាំឆ្នាំ ៤៩១
- ៤.៤.តារាងលិខិតបទដ្ឋានគតិយុត្តិដែលត្រូវរៀបចំនិងដាក់ឱ្យអនុវត្តសម្រាប់រយៈពេលប្រាំឆ្នាំ ៥១២

ឧបសម្ព័ន្ធនានា
- ឧបសម្ព័ន្ធទី១៖ សេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយ សម្រាប់ការកសាងផែន ការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តកោះកុង
- ឧបសម្ព័ន្ធទី២៖ សេចក្តីសម្រេចស្តីពីការប្រកាសទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការ សម្របសម្រួលបច្ចេកទេស របស់ក្រុមប្រឹក្សាខេត្តកោះកុង
- ឧបសម្ព័ន្ធទី៣៖ សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារកសាងផែនការអភីវឌ្ឍន៍ខេត្ត
- ឧបសម្ព័ន្ធទី៤៖ ប្រតិទិនការងារកសាងផែនការអភិវឌ្ឍន៍ខេត្តកោះកុង
- ឧបសម្ព័ន្ធទី៥៖ គោលដៅ និងចំណុចដៅ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(ត.អ.ច.ក)
- ឧបសម្ព័ន្ធទី៦៖ តារាបូកសរុបការវិភាគស្ថានភាពខេត្ត
- ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យនានា
- ឧបសម្ព័ន្ធទី៨៖ កំណត់ហេតុស្តីពីកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកោះកុង
លេខ ០៣៧/២០ ស.ស.រ

សេចក្តីសម្រេច
ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២០-២០២៤) របស់រដ្ឋបាលខេត្តកោះកុង

ក្រុមប្រឹក្សាខេត្តកោះកុង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងប្រកាសអន្តរក្រសួងលេខ ០៨៤ ប្រ.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ខេត្ត
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង នាថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០។
- យោងលិខិតលេខ ១៤៧៧ ស.ជ.ណ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្តល់អនុលោមភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង។

សម្រេច

ប្រការ១.-

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវ **សៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២០-២០២៤)** របស់រដ្ឋបាលខេត្តកោះកុង ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាខេត្ត នាកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០។

ប្រការ២.-

គណៈអភិបាលខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍នេះដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តកោះកុង។

គណៈអភិបាលខេត្ត ត្រូវចាត់ចែងសម្របសម្រួល និងកៀរគរធនធាននានាក្នុងការអនុវត្តផែនការអភិវឌ្ឍន៍នេះ ដោយមានការចូលរួម តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ ។

ប្រការ៣.-

គណៈអភិបាលខេត្ត ត្រូវរៀបចំយន្តការ និងប្រព័ន្ធសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផែនការអភិវឌ្ឍន៍នេះ ដោយមានការចូលរួមពីគ្រប់ភាគីអ្នកពាក់ព័ន្ធនានាដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការ។

គណៈអភិបាលខេត្ត ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ នៅពាក់កណ្តាលអាណត្តិ និងចុងអាណត្តិរបស់ក្រុមប្រឹក្សា ។

គណៈអភិបាលខេត្តត្រូវរៀបចំ និងដាក់ជូនក្រុមប្រឹក្សាខេត្ត អំពីរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍នេះ ។

ប្រការ៤.-

គណៈអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ដោយផ្តល់អនុសាសន៍ចាំបាច់នានាសម្រាប់ការលើកកម្ពស់ការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា។

ក្រុមប្រឹក្សាត្រូវពិនិត្យពិភាក្សាលើរបាយការណ៍របស់គណៈអភិបាល ដើម្បីវាយតម្លៃលទ្ធផលសម្រេចបានស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍នេះ នៅពាក់កណ្តាលអាណត្តិ និងចុងអាណត្តិរបស់ក្រុមប្រឹក្សាខេត្ត ដោយធៀបទៅនឹងគោលដៅ និងគោលបំណងដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត ។

ប្រការ៥.-

គណៈអភិបាល នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្នុងខេត្ត ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅខេត្តកោះកុង,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២០

ជំ.ក្រុមប្រឹក្សា
ប្រធាន

ចម្លងជូន៖
-ក្រសួងមហាផ្ទៃ
"ដើម្បីគោរពជូនជ្រាប"
-ដូចប្រការ៥
-ឯកសារ-កាលប្បវត្តិ

អគារលេខ ៦៧៧ ផ្លូវលេខ ៩០០ ភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ទូរស័ព្ទ : ០១២ ២០០ ៨៥៨ / ០១៦ ៨៤២ ២២៨
www.kohkong.gov.kh Facebook Page : រដ្ឋបាលខេត្តកោះកុង Email : kohkongprovincialadm@gmail.com

អារម្ភកថា

ក្រុមប្រឹក្សាខេត្តកោះកុង រៀបចំផែនការអភិវឌ្ឍន៍ខេត្ត ប្រាំឆ្នាំចាប់ពី២០២០ ដល់២០២៤ ដោយផ្តល់ឱកាសឱ្យមានការចូលរួមដោយផ្ទាល់ពីគណៈកម្មាធិការនានា មន្ទីរ អង្គភាពជំនាញជុំវិញខេត្ត ទីចាត់ការ និងអង្គភាពចំណុះសាលាខេត្ត ក្រុមប្រឹក្សាក្រុង-ស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា នៅក្នុងដំណើរការនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍នេះ ។ ផែនការអភិវឌ្ឍន៍ខេត្ត ដែលបានបង្កើតឡើងនេះត្រូវបានអនុវត្តតាមគោលការណ៍ណែនាំផ្នែកគោលនយោបាយ ដើម្បីតម្រង់ទិសរដ្ឋបាលខេត្ត ក្នុងការអភិវឌ្ឍវិស័យនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងការលើកកម្ពស់គុណភាពសេវាសាធារណៈសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខេត្ត ។ ផែនការអភិវឌ្ឍន៍ខេត្តនេះទៀតសោត គឺជាផែនទីបង្ហាញប្រាប់ផ្លូវ ដើម្បីប្រើប្រាស់ជាមូលដ្ឋានដ៏សំខាន់ក្នុងការធ្វើសេចក្តីសម្រេចអំពីការអភិវឌ្ឍន៍ខេត្ត និងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្របខ័ណ្ឌចំណាយមធ្យម (បីឆ្នាំ) និងថវិកាប្រចាំឆ្នាំរបស់ខេត្ត។

ក្នុងនាមក្រុមប្រឹក្សាខេត្តអាណត្តិទី៣ ខ្ញុំសូមថ្លែងអំណរគុណដល់ គណៈអភិបាលខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិង កុមារខេត្ត មន្ទីរ អង្គភាព ជំនាញជុំវិញខេត្ត ទីចាត់ការនិងអង្គភាពចំណុះសាលាខេត្ត ក្រុមប្រឹក្សាក្រុង-ស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្ត។ ខ្ញុំក៏សូមថ្លែងអំណរគុណ ដល់ក្រុមការងារ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដែលបានជួយគាំទ្រ ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្តនេះ។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អភិបាលខេត្ត និងក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដែលបានដឹកនាំ និងសម្របសម្រួលដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្តរហូតសម្រេចជាស្ថាពរ។

ខ្ញុំសូមអំពាវនាវដល់ ក្រសួង ស្ថាប័នជាតិ មន្ទីរ អង្គភាពជំនាញ វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងសប្បុរសជននានា ជួយគាំទ្រគម្រោងផែនការសកម្មភាព សំដៅឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ ដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍នេះ ។

ក្នុងនាមក្រុមប្រឹក្សាខេត្ត ខ្ញុំមានជំនឿយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និង អ្នកនាងកញ្ញាទាំងអស់នឹងចាត់ទុកថា ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំនេះ ជាត្រីវិស័យក្នុងការរួមគ្នាអភិវឌ្ឍន៍ខេត្តកោះកុងជាក់ជាពុំខាន ។

ថ្ងៃសុក្រ ១៥កើត ខែមាឃ ឆ្នាំជូត ឆស័ក ព.ស ២៥៦៤
ធ្វើនៅខេត្តកោះកុង,ថ្ងៃទី២៧ ខែ.មករា ឆ្នាំ២០២០

ជ.ក្រុមប្រឹក្សា
ប្រធាន

ការយ សំរួម

សេចក្តីផ្តើម

ខេត្តកោះកុង ជាខេត្តមួយស្ថិតនៅទិសនីរតី ចម្ងាយពីរាជធានីភ្នំពេញ២៩០គីឡូម៉ែត្រ ខេត្តមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ខាងលិច និងខាងត្បូងជាប់នឹងឈូងសមុទ្រ នៃព្រះរាជាណាចក្រថៃឡង់ដ៍(មួយផ្នែកនៃខេត្តត្រាត) ខាងជើងជាប់នឹងខេត្តពោធិ៍សាត់។ ខេត្តកោះកុង ស្ថិតក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា សណ្ឋានដីមានលក្ខណៈ ជាភ្នំខ្ពង់រាប វាលរាប និងឆ្នេរសមុទ្រដែលមានប្រវែង២៣៧គីឡូម៉ែត្រ លាតសន្ធឹងជាប់នឹងខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប។ ដីតំបន់នេះមានលក្ខណៈជាដីខ្សាច់ច្រើនអាចប្រែកបដំណាំដូងប្រេង កៅស៊ូ ដូង ម្រេច ធូរ៉ែន។ល។ ជាពិសេសតំបន់នេះសំបូរទៅដោយដើមកោងកាងជាច្រើនប្រភេទ។ ក្រៅពីនេះគេសង្កេតឃើញមានកោះចំនួន២៣ និងកោះនៅតាមដែព្រែកចំនួន១២កោះ ។

ខេត្តចែកចេញជា១ក្រុង ៣សង្កាត់ ៦ស្រុក ២៦ឃុំ និង១១៩ភូមិ មានផ្ទៃដីសរុប ១០.០៤៥,៥៨ គីឡូម៉ែត្រការ៉ែ មានប្រជាជនសរុប ១៣៦.៦៧៥ នាក់ ស្រី ៦៧.៨៤៦ នាក់ មានដង់ស៊ីតេប្រជាជន១២ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉ែ។ ប្រជាជនប្រមាណ ៥៧.៥% ជាកសិកររស់នៅពឹងផ្អែកលើ វិស័យកសិកម្ម ដែលជាវិស័យចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងខេត្ត។ ក្រៅពីវិស័យកសិកម្ម ដែលជាស្នូលក៏មានវិស័យផ្សេងៗទៀតដូចជាវិស័យ ឧស្សាហកម្ម ០,២% និង វិស័យសេវាកម្មប្រមាណ ៤២,៣% ដែលជាមូលដ្ឋានបង្កើតការងារជូនប្រជាពលរដ្ឋ ។ វិស័យសេដ្ឋកិច្ចសំខាន់ៗទាំងបីរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម និង វិស័យសេវាកម្មបានជម្រុញដល់សេដ្ឋកិច្ចរបស់ខេត្តទាំងមូលមានអត្រាកំណើនគួរអោយកត់សំគាល់។ ជាក់ស្តែងតាមរយៈវិជ្ជាស្ថានជាតិស្ថិតិនៃក្រសួងផែនការនៅឆ្នាំ២០១៨ បានបង្ហាញថាផលិតផលក្នុងស្រុកសរុប នៃសេដ្ឋកិច្ចខេត្តកោះកុងទាំងមូលមានតម្លៃប្រមាណ ៩៤៦.៦៣៣ លានរៀល ឬស្មើនឹង ២៣៤លានដុល្លារសហរដ្ឋអាមេរិក។ បើធៀបទៅនឹងសេដ្ឋកិច្ចជាតិមានអត្រាស្មើនឹង ០.៩ %នៅឆ្នាំ២០១៨ ។ បើគិតជាចំណូលសម្រាប់មនុស្សម្នាក់ៗគឺស្មើនឹង ១.៤១៩ ដុល្លារឆ្នាំ២០១៧ និងឆ្នាំ២០១៨ ស្មើនឹង ១.៥៤៣ដុល្លារ ។

នៅខែឧសភា ឆ្នាំ២០១៩ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៣ បាន ប្រព្រឹត្តទៅប្រកបដោយជោគជ័យក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្រុមប្រឹក្សាខេត្តរួមជាមួយគណៈអភិបាលខេត្ត បានអនុវត្តនូវតួនាទី ភារកិច្ចរបស់ខ្លួនដើម្បីអភិបាលកិច្ច និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ស្របតាមច្បាប់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តិនានា ។

ក្រុមប្រឹក្សាខេត្តអាណត្តិទី៣ បានរៀបចំផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំពីឆ្នាំ ២០២០-២០២៤ ដោយយោងមាត្រា៣៨ និង មាត្រា៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធី វិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្ត-ក្រុង-ស្រុក-ខណ្ឌ។

ផែនការអភិវឌ្ឍន៍ខេត្តបានរៀបចំឡើងស្របតាមសេចក្តីណែនាំបច្ចេកទេស ស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយមានការចូលរួមនិងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ក្រុមតំណាងផលប្រយោជន៍ ជាពិសេសក្រុមយុវជន និងកុមារ ក្រុមប្រឹក្សា ស្រុក ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ទីរ អង្គភាពជំនាញជុំវិញ ខេត្ត ទីចាត់ការ អង្គភាពចំណុះសាលាខេត្ត អង្គការ សង្គមស៊ីវិល វិស័យឯកជននិងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ច របស់ខេត្តក្នុងការវិភាគស្ថានភាព សក្តានុពល បញ្ហាប្រឈម និង តម្រូវការនានា។

ផែនការអភិវឌ្ឍន៍ខេត្ត បានកំណត់អំពីចក្ខុវិស័យ គោលដៅ គោលបំណង សូចនាករជាក់លាក់ និងយុទ្ធសាស្ត្រ ដែលជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធាន និងសក្តានុពលនានា ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់គុណភាពសេវា សំដៅឆ្លើយតបតម្រូវការប្រជាពលរដ្ឋ និងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។

ផែនការអភិវឌ្ឍន៍ខេត្តមានបួនជំពូក គឺ ជំពូកទី១ បរិយាយអំពីស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ជំពូកទី២ បរិយាយអំពីក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ជំពូកទី៣ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ និងជំពូកទី៤បរិយាយអំពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ផែនការអភិវឌ្ឍន៍ខេត្តសម្រាប់រយៈពេល៥ឆ្នាំខាងមុខ៕


ផែនទីរដ្ឋបាល ខេត្តកោះកុង
Administrative Map of Koh Kong Province
LEGEND
Province Office
District Office
Commune Office
Village
Pagoda
School
Mosque
Post Office
Port
Health Center
Hospital
Sealed Road
Laterite Road
Unsealed Road
Street
Ferry
River_clip_2009_1_09
National Boundary
Province Boundary
District Boundary
Commune Boundary
Proposed Boundary
KKG_Sea
មាត្រដ្ឋាន ១ : ១៨០,០០០
0
10,000
20,000
Meters





ចម្ងាយពីក្រុងខេមរភូមិន្ទ		From Khemerak Phumin Town		ចំណាំ - Note
1 ឆ្នេរចាំយាម និងកោះកុងរីសត Cham Yeam Beach and Koh Kong Resort	8 KM	6 សហគមន៍អេកូទេសចរណ៍ស្ទឹងអារើង Steung Areng Community-Based Ecotourism	80 KM	ផ្លូវជាតិ National Road
2 ឆ្នេរឌ៉ាក់ខ្ពង ឬ កោះយំ Pak Klong Beach	8 KM	7 សហគមន៍អេកូទេសចរណ៍ជីផាត Chi Phat Community-Based Ecotourism	125 KM	
3 រមណីយដ្ឋានប្រវត្តិសាស្ត្រចេតិយឃុនឆាង Khun Chhang Stupa	2 KM	8 ឆ្នេរកោះកុងក្រៅ Koh Kong Island Beach (ផ្លូវទឹក By Boat)	30 KM	ផ្លូវត្រួសក្រហម Dusty Road
4 សហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប Peam Krasaop Wildlife Sanctuar	7 KM	9 ឆ្នេរនេសាទ Nesart Beach	165 KM	
5 សហគមន៍អេកូទេសចរណ៍តាតៃក្រោម Ta Tai Kraom Community-Based Ecotourism	17KM	10 តំបន់វិស្សមកាលតាភសាគរ Darasakor	166 KM	

ជំពូកទី១

ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

១.១. ស្ថានភាពទូទៅរបស់ខេត្ត

១.១.១.ស្ថានភាពភូមិសាស្ត្រ

ខេត្តកោះកុង ជាខេត្តមួយស្ថិតនៅទិសនិរតី ចម្ងាយពីរាជធានីភ្នំពេញ២៩០គីឡូម៉ែត្រ ខេត្តមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ខាងលិចនិងខាងត្បូងជាប់នឹងឈូងសមុទ្រនៃព្រះរាជាណាចក្រថៃឡង់ដ៍ (មួយផ្នែកនៃខេត្តត្រាត) ខាងជើងជាប់នឹងខេត្តពោធិ៍សាត់។ ខេត្តកោះកុង ស្ថិតក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា សណ្ឋានដីមានលក្ខណៈ ជាភ្នំខ្ពង់រាប វាលរាបនិងឆ្នេរសមុទ្រដែលមានប្រវែង២៣៧គីឡូម៉ែត្រ[1] ។ ខេត្តកោះកុងមានកោះចំនួន២៣ និងកោះនៅតាមដៃព្រែកចំនួន១២កោះ។

ខេត្តចែកចេញជា១ក្រុង ៣សង្កាត់ ៦ស្រុក ២៦ឃុំ និង១១៩ភូមិ មានផ្ទៃដីសរុប ១០.០៤៥,៥៨ គីឡូម៉ែត្រការ៉ែ មានប្រជាជនសរុប ១៣៦.៦៧៥ នាក់ ស្រី ៦៧.៨៤៦ នាក់ មានដង់ស៊ីតេប្រជាជន១២ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉ែ។ ប្រជាជនប្រមាណ ៥៧,៥% ជាកសិកររស់នៅពឹងផ្អែកលើ វិស័យកសិកម្ម ដែលជាវិស័យចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងខេត្ត។ក្រៅពីវិស័យកសិកម្ម ដែលជាស្នូលក៏មានវិស័យផ្សេងៗទៀតដូចជា វិស័យឧស្សាហកម្ម០,២%និងវិស័យសេវាកម្មប្រមាណ៤២,៣%ដែលជាមូលដ្ឋានបង្កើតការងារជូនប្រជាពលរដ្ឋ[2] ។

តាមរយៈវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនៅឆ្នាំ២០១៨ បានបង្ហាញថាផលិតផលក្នុងស្រុកសរុបនៃសេដ្ឋកិច្ចខេត្តកោះកុងទាំងមូលមានតម្លៃប្រមាណ ៩៤៦.៦៣៣ លានរៀល ឬស្មើនឹង ២៣៤ លានដុល្លារសហរដ្ឋអាមេរិក។ បើធៀបទៅនឹងសេដ្ឋកិច្ចជាតិមានអត្រាស្មើនឹង ០,៩% នៅឆ្នាំ២០១៨ ។បើគិតជាចំណូលសម្រាប់មនុស្សម្នាក់ៗគឺស្មើនឹង ១.៤១៩ ដុល្លារ ឆ្នាំ២០១៧ និងឆ្នាំ២០១៨ ស្មើនឹង១.៥៤៣ដុល្លារ [3]។

១.១.២.សេចក្តីសង្ខេបព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

ល.រ	បរិយាយ	ឆ្នាំ ២០១៧	ឆ្នាំ ២០១៨	ឆ្នាំ ២០១៩
ព័ត៌មានទូទៅ				
១	ផ្ទៃដីខេត្ត (គ.ម២)	១០.០៤៥,៥៨	១០.០៤៥,៥៨	១០.០៤៥,៥៨
២	ចំនួនក្រុង ស្រុក	៧	៧	៧
៣	ចំនួនឃុំ សង្កាត់	២៩	២៩	២៩
៤	ចំនួនភូមិ	១១៩	១១៩	១១៩
៥	ចំនួនគ្រូសារ	២៨.៦៣៨	២៩.១៩៩	២៩.៨៩៤
៦	% មេគ្រួសារជាស្ត្រី	១៦,៦៣	១៧,៦២	១៦,០៨
៧	ចំនួនប្រជាជនសរុប	១៣០.៨៦៨	១៣៣.៣៨៦	១៣៦.៦៧៥
៨	ចំនួនស្រី	៦៥.១៥០	៦៦.៤៧១	៦៧.៨៤៦
៩	ចំនួនបុរស	៦៥.៧១៨	៦៦.៩១៥	៦៨.៨២៩

[1] *ផែនការរូបវន្តឆ្នាំ២០០០-២០០២(DANIDA-ក្រសួងបរិស្ថាន)*

[2] *ព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចខេត្ត កោះកុង ឆ្នាំ២០១៩ (មន្ទីរផែនការខេត្តកោះកុង)*

[3] *វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនៅឆ្នាំ២០១៨*

១០	% អ្នកមានអាយុពី ០-១៧ឆ្នាំ	៣៨,៤៦	៣៨,០៦	៣៧,១៨
១១	% អ្នកមានអាយុពី១៨-៦០ឆ្នាំ	៥៥,៦១	៥៥,៩១	៥៦,២៩
១២	% អ្នកមានអាយុពី៦១ឆ្នាំឡើង	៥,៩២	៦,០៤	៦,៥២
១៣	កំណើនប្រជាជនប្រចាំឆ្នាំ (%)	០,៨៤	១,៩២	២,៤៧
១៤	អាត្រាភាពក្រីក្រ(%)	១៣,៤៦	១៣,១៨	៩,៦២
១៥	% អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម	៦១,១០	៦០,៦០	៥៧,៥០
១៦	% អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម	០,៣០	០,៥០	០,២០
១៧	% អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម	៣៨,៧០	៣៨,២០	៤២,៣០
១៨	% មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស	៥,៩០	៧.១០	៦,៥០
១៩	% មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស	៣,៩០	៣,៧០	៣,៥០
២០	% ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់	៦២,៤២	៦៦,១៧	៧៣,១៧
អប់រំ				
២១	% កុមារអាយុ៣-៥ឆ្នាំ បានចូលរៀន	៤៤,៧១	៤៤,០៨	៤៧,១០
២២	% កុមារអាយុ៦ឆ្នាំ បានចូលរៀន	៧៧,៩១	៧២,៧៣	៨១,៤០
២៣	% កុមារអាយុ៦-១១ឆ្នាំ បានចូលរៀន	៧៨,៦៣	៧៥,៨២	៨០,២០
២៤	% កុមារអាយុ១២-១៤ឆ្នាំ នៅរៀន	៨៦,៨០	៨៤,៩៨	៨៧,១០
២៥	% អ្នកចេះអក្សរអាយុ ១៥-១៧ឆ្នាំ	៩៧,៤២	៩៧,៥៣	៩៧,៧០
២៦	% អ្នកចេះអក្សរអាយុ ១៨-៤៥ ឆ្នាំ	៩១,៣៦	៩២,៩២	៩៣,៩០
សុខភាព				
២៧	ចំនួនមណ្ឌលសុខភាព	១៣	១៣	១៣
២៨	% ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ	៩២,០៥	៩៥,២៦	៩៤,៤០
២៩	អាត្រាស្លាប់របស់មាតាក្រោយពេលសម្រាល(០-១ ខែ)ក្នុង១ពាន់កំណើត	១២,៦២	២,១៣	១៤,៦០
៣០	អាត្រាស្លាប់របស់កុមារក្រោយពេលកើត (0-១ខែ) ក្នុង១ពាន់កំណើត	៣,២៦	៥,៨០	១
៣១	% កុមារអាយុពី៩-១២ខែ បានចាក់ថ្នាំគ្រប់ចំនួន	៩៧,៩៨	៩៧,៨១	៨២,៣០
៣២	ចំនួនគ្រូសារមានសមាជិកកើតជំងឺអេដស៍	១៣៧	៥៩	៩៦
ភាពងាយរងគ្រោះ				
៣៣	ចំនួនជនពិការ	១៧	១២	៦

៣៤	% ជនពិការអាយុ១៨ឆ្នាំ ឡើងមិនអាចរកចំណូលបាន	៥០	៧១,៤៣	២០
៣៥	ចំនួនកុមារកំព្រាឪពុកម្តាយស្លាប់ដោយជំងឺអេដស៍	៥៣	៩	៣៨
៣៦	ចំនួនចាស់ជរាគ្មានទីពឹង (អាយុ៦១ឆ្នាំឡើង)	១១៣	១២៤	១៤៧
ធនធានធម្មជាតិ បរិស្ថាន និងការប្សាំនឹងការប្រែប្រួលអាកាសធាតុ				
៣៧	ចំនួនគ្រួសាររងគ្រោះដោយខ្យល់ព្យុះ/កន្ត្រាក់	២០	៩៦	៩១
៣៨	ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់	០	០	៥២៤
៣៩	ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត	២៣៨	១៣	០
៤០	% គ្រួសារមានសេវាប្រមូលសម្រាមតាមផ្ទះ	១០,៤២	១១,៦១	១៧,៧០
៤១	% គ្រួសារមានទឹកស្អាតប្រើប្រាស់	៧២.៥៧	៧១,៧៦	៦៩,៦០
ក្នុងនោះ	% គ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់	៤១,៥៨	៤៣,៨៦	៤៩,៦០
	% គ្រួសារមានទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះ	២៤,១១	២៣,៥៤	២០,២៣
	% គ្រួសារប្រើទឹកអណ្តូងជីកមានការការពារ	២៤,៦០	២៣,២៣	២៤,៥៩
	% គ្រួសារប្រើទឹកភ្លៀងមានការការពារ	៩,៦៨	៩,៣៦	៥,៥៦
៤២	% គ្រួសារមានបង្គន់អនាម័យប្រើប្រាស់	៥៦,៨៤	៦១,០៦	៦៣,២០
រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ				
៤៣	% កុមារបានចុះសំបុត្រកំណើត (0-៣០ថ្ងៃ)	៧១,៦៣	៧៦,៥៤	៨១
៤៤	ចំនួនគ្រួសារមានអំពើហឹង្សាក្នុងគ្រួសារ	១៧៨	១២៩	១០៤
៤៥	ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍	១៤	២៧	២៣
៤៦	ចំនួនអ្នកស្លាប់ដោយអំពើហឹង្សានានា	១	១	១
៤៧	ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន	១១៧	៧៣	១០៦

(ប្រភពទិន្នន័យឯកសារព័ត៌មានស្ថានសេដ្ឋកិច្ច សង្គមកិច្ចខេត្ត កោះកុង ឆ្នាំ២០១៩)

១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

១.២.១ ផ្នែកសេដ្ឋកិច្ច

១.២.១.១ វិស័យកសិកម្ម

ការសម្រេចល្បឿនអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចប្រកបដោយនិរន្តរភាព និងការចូលរួមចំណែកកាត់បន្ថយ-ភាពក្រីក្របានខ្លាំង ជាពិសេសនៅជនបទ អាស្រ័យជាបឋមលើការលើកកម្ពស់ការចូលរួមចំណែករបស់វិស័យកសិកម្ម និងអនុវិស័យឬផ្នែកនានារបស់វិស័យនេះ ដូចជាផ្នែកចិញ្ចឹមសត្វ ការដាំដុះដំណាំស្រូវនិងដំណាំចម្ការ ការងារជលផល និងព្រៃឈើ ក៏ដូចជាឧស្សាហកម្មកែច្នៃផលិតផលក្នុងស្រុក ជាពិសេសជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសថ្មីៗក្នុងវិស័យកសិកម្មឲ្យបានដល់កសិករ។ ខេត្តកោះកុងមានគ្រួសារសរុបប្រមាណ ៥៧,៥០% ប្រកបរបរកសិកម្មជាចម្បងហើយ

ក្នុងនោះ៖ គ្រួសារដែលធ្វើស្រែចំការមាន២៨,៤0% ដាំដំណាំរយៈពេលវែងមាន៥,៥0% ដាំដំណាំរយៈពេលខ្លីមាន ២,៥0%ដាំបន្លែមាន១,៨0%ចិញ្ចឹមសត្វមាន៣,៥0% រកអនុផលព្រៃឈើមាន១%និងមុខរបរនេសាទមាន១៤,៧0% ។

ក.<u>ផ្ទៃកដំណាំស្រូវ</u>

ផ្ទៃដីដែលមានសក្តានុពលអាចធ្វើស្រែបានមានចំនួន១២.៨៨៥ហិកតា ប៉ុន្តែនៅឆ្នាំ២០១៥ អនុវត្តបាន ប្រមាន ៧៧,៩៦%នៃផ្ទៃដីសរុប និងឆ្នាំ២០១៩ អនុវត្តបានប្រមាណ ៧៨,៣២% នៃផ្ទៃដីសរុប រីឯទិន្នផល ទទួលបានពី២,៦៣៨ ទៅ២,៦៨៤តោន/ហិកតា ដោយសារមានការផ្សព្វផ្សាយ និងកសិករមួយចំនួននៅតាមបណ្តាស្រុកបានទទួលយកពូជស្រូវមួយចំនួន (ផ្កាំរដូល រាំងជ័យ សែនពិជោរ) ក្នុងចំណោមពូជស្រូវទាំង១0មុខ ដែលក្រសួងកសិកម្មជំរុញឲ្យផលិតសម្រាប់ធ្វើការនាំចេញ ហើយនៅតំបន់ខ្លះទិន្នផលស្រូវដែលទទួលបាននៅមាន កម្រិតទាបដោយសារកសិករធ្វើតាមទំលាប់(ទាំងពូជ និងបច្ចេកទេស) ដីស្រែមួយចំនួនមានជាតិជូរ-ប្រៃ និងទទួល រងការបំផ្លាញពីសមាសភាពចង្រៃ ។ ដីស្រែមួយចំនួនត្រូវទុកទំនេរចោល មួយចំនួនបានក្លាយជាដីសម្រាប់ សាងសង់លំនៅដ្ឋាន មួយចំនួនស្ថិតនៅក្នុងតំបន់អភិរក្សការពារ និងអភិវឌ្ឍគម្រោងវិនិយោគ។ នៅឆ្នាំ២០១៥ នៅទូទាំងខេត្តថយចុះស្បៀងចំនួន ១.៩៤៦ តោនអង្ករ និងឆ្នាំ២០១៩ ថយចុះចំនួន៤.៣៧៦តោនអង្ករ មូលហេតុបណ្តាលមកពីប្រជាពលរដ្ឋផ្លាស់ប្តូរមុខរបរទៅបំរើការងារវិស័យសេវាកម្មផ្សេងៗ មានដូចជា អាជីវករ កម្មកររោងចក្រ ក្រុមហ៊ុនសហគ្រាស ដីពុះឡូត៍... ។

តារាងទី១៖ ស្តីពីការបង្កបង្កើនផលស្រូវនៅខេត្តកោះកុង ពីឆ្នាំ២០១៥–២០១៩

បរិយាយ	ឯកត្តា	២០១៥	២០១៦	២០១៧	២០១៨	២០១៩
ផ្ទៃដីស្រូវស្រាល	ហ.ត	២.0៣២	២.២៣៧	២.៩៤៥	២.៦៨៦	១.៤៦៦
ផ្ទៃដីស្រូវកណ្តាល	ហ.ត	៦.១៦១	៦.0៧៩	៥.៧១៦	៥.៩២១	៤.២១៨
ផ្ទៃដីស្រូវធ្ងន់	ហ.ត	៩៩២	៩៧១	៦៤៣	៥៨៨	៣៧៨
ផ្ទៃដីស្រូវចម្ការ	ហ.ត	១.២២0	១.២១៦	១.២១១	១.២២២	៩.៨៣៥
ផ្ទៃដីសរុប	ហ.ត	១0.៤0៥	១0.៥0៣	១0.៥១៥	១0.៤១៧	៩.៨៣៥
ទិន្នផលមធ្យម	តោន/ហ.ត	២.៨៥0	២.៦៣៨	២.៦៨៤	២.៩៣៥	២.៦៨៤
បរិមាណផលស្រូវសរុប	តោន	២៩.៦៥៩	២៧.៧0៤	២៨.២២៥	៣0.៥៧៣	២៦.៣៩៧
កាត់១៣%ទុកពូជចិញ្ចឹមសត្វនិងបាត់បង់ពេលប្រមូលផល	តោន	៣.៨៥៦	៣.៦0២	៣.៦៦៩	៣.៩៧៤	៣.៤៣១
បរិមាណផលស្រូវនៅសល់	តោន	២៥.៨0៣	២៤.១0៣	២៤.៥៥៥	២៦.៥៩៨	២២.៩៦៦
បរិមាណផលស្រូវគិតជាអង្ករ(៦៤%)	តោន	១៦.៥១៤	១៥.៤២៦	១៥.៧១៥	១៧.0២៣	១៤.៦៩៨
ចំនួនប្រជាជនសរុប	នាក់	១២៩.0៩0	១២៩.៧៧៦	១៣0.៨៦៨	១៣៣.៣៨៦	១៣៣.៣៨៦
តម្រូវការស្បៀងជាអង្ករ ១៤៣គ.ក្រ/នាក់	តោន	១៨.៤៦0	១៨.៥៥៨	១៨.៧១៤	១៩.0៧៤	១៩.0៧៤
តុល្យភាពស្បៀងគិតជាអង្ករ	តោន	–១.៩៤៦	–៣.១៣២	–២.៩៩៩	–២.0៥១	–៤.៣៧៦

ខ.ដំណាំរួមផ្សំ-ដំណាំអចិន្ត្រៃយ៍ និងដំណាំឧស្សាហកម្ម

ក្រៅពីដំណាំស្រូវ កសិករបានដាំដុះដំណាំចម្ការរយៈពេលខ្លី និងដំណាំរយៈពេលវែងដែលបានរួមចំណែក យ៉ាងច្រើនក្នុងការធានាស្ថានភាពចំណូល-ចំណាយប្រចាំថ្ងៃ។ មានដំណាំជាច្រើនដែលអាចផ្តល់ផលយ៉ាងល្អប្រសើរ បើប្រៀបធៀបទៅនឹងស្រូវ ដូចជាដំណាំចេក ធុរេន និងសាវម៉ាវជាដើម។ ផ្ទៃដីនៅតាមបណ្តាស្រុក ក្នុងខេត្តដូចជា ស្រុកបូទុមសាគរ ស្រុកស្រែអំបិល ស្រុកថ្មបាំង និងស្រុកកោះកុង មានសក្តានុពលសម្រាប់ដាំដំណាំឈើហូបផ្លែ និងដំណាំកសិឧស្សាហកម្មផ្សេងៗ។ យ៉ាងណាក៏មានបញ្ហាប្រឈមមួយចំនួនដែលជះឥទ្ធិពលដល់ផលិតផលដំណាំ របស់កសិករដូចជា

បញ្ហាបច្ចេកទេស ការប្រែប្រួលអាកាសធាតុ បញ្ហាផ្លូវគមនាគមន៍ មានការលំបាក។ តម្លៃផលិតផលត្រូវបានឈ្មួញកណ្តាលជាអ្នកកំណត់ ការនាំចូលបន្លែ ផ្លែឈើពីប្រទេសថៃ និងពីខេត្តនានា នៅតែមានកម្រិតខ្ពស់សម្រាប់បំពេញឲ្យតម្រូវការក្នុងខេត្ត។

តារាងទី២៖ ស្តីពីដំណាំរួមផ្សំ-ដំណាំអចិន្ត្រៃយ៍ និងដំណាំឧស្សាហកម្មនៅខេត្តកោះកុងពីឆ្នាំ២០១៥–២០១៩

បរិយាយ	ឯកត្តា	២០១៥	២០១៦	២០១៧	២០១៨	២០១៩
ដំណាំរួមផ្សំ	ហិកតា	៧៦១	៦៤៦	៥៤៩	៤៦២	៤៩៩
ដំណាំអចិន្ត្រៃយ៍	ហិកតា	៣៧០	៨៤៦	៧១៤	៦០៨	១.០៨៥
ដំណាំឧស្សាហកម្ម	ហិកតា	១.១៦៨	៨២០	១.១២៦	១.២០២	១.៤៧០

ក្រៅពីដំណាំដាំជាលក្ខណៈគ្រួសារ ខេត្តកោះកុងមានក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ចចំនួន០៧ ដែលមកដល់ឆ្នាំ២០១៨ បានធ្វើការឈូសឆាយ និងដាំដុះតាមប្រភេទមុខដំណាំបានដូចក្នុងតារាងខាងក្រោម៖

តារាងទី៣៖ ស្តីពីក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ច

ឈ្មោះក្រុមហ៊ុន	ទីតាំង	ប្រភេទដំណាំ	ទំហំផ្ទៃដីទទួលបានសម្បទានពីរដ្ឋ (ហិកតា)	ផ្ទៃដីបានដាំដុះមកដល់ឆ្នាំ២០១៨ (ហិកតា)
CAMAGRA INDUSTRY	ស្រុកស្រែអំបិល ស្រុកកំពង់សិលា	អាកាស្យា ប្រេងខ្យល់	៤.០៩៦ ១.៤២៩	១.៣៨០ ១.៣៣៤
KOHKONGPLANTATION	ស្រុកស្រែអំបិល	អំពៅ	៩.៤០០	២.៣៨៨
KOHKONG SUGAR INDUSTRY	ស្រុកស្រែអំបិល	អំពៅ	៩.៧០០	២.៣២៨
GREENRICH GROUP	ស្រុកកោះកុង	អាកាស្យា	១១.១១៧	៥.៨៧៧
LIM LONG	ស្រុកស្រែអំបិល	កៅស៊ូ	៣២១	២៨០
CN ASIA AGRICULTER	ស្រុកបូទុមសាគរ	កៅស៊ូ	៤.១០០	២.៥៧៣
KOHKONG RUBBER PLANTATION	ស្រុកគិរីសាគរ	កៅស៊ូ	៩.៩៧៧	១.១៥៨

គ.ផ្នែកចិញ្ចឹមសត្វ

បើទោះបីជាគ្រឿងចក្រកសិកម្មមានការប្រើប្រាស់ច្រើននៅគ្រប់មូលដ្ឋានដាំដុះក៏ដោយ ក៏ប្រជាកសិករនៅ ក្នុងខេត្តកោះកុងនៅប្រើប្រាស់សត្វពាហនៈជាកម្លាំងអូសទាញសម្រាប់ការងារកសិកម្ម និងសកម្មភាពផ្សេងទៀត។ សត្វពាហនៈនិងបសុបក្សីជាប្រភពផ្តល់ចំណូលនិងប្រូតេអ៊ីនយ៉ាងសំខាន់ផងដែរសម្រាប់ប្រជាជន។ បញ្ហាប្រឈម មួយចំនួនដែលធ្វើឲ្យការចិញ្ចឹមសត្វរបស់កសិករទទួលបានប្រាក់ចំណូលទាបក៏ដោយសារការចិញ្ចឹមសត្វ តាមទម្លាប់មិនត្រឹមត្រូវតាមបច្ចេកទេស ខ្វះបច្ចេកទេសក្នុងការជ្រើសរើសពូជដែលផ្តល់ទិន្នផលខ្ពស់ ការផ្តល់សេវាបសុពេទ្យនៅមានកម្រិតនៅតាមតំបន់ដាច់ស្រយាល និងមានកសិករមួយចំនួនមិនទាន់យល់ពីអត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំងការពារលើសត្វពាហនៈរបស់ពួកគាត់ ដែលជាហេតុធ្វើឲ្យសត្វងាប់ដោយជម្ងឺ ដូចជាជម្ងឺសាទឹក អុតក្តាម ជាដើម។ ប៉ុន្តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះដោយមានការណែនាំពីមន្ត្រីជំនាញកសិកម្ម នៅតាមមូលដ្ឋានមានការយល់ដឹងច្រើនអំពីអត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំង។

តារាង៣៖ ស្តីពីស្ថិតិសត្វពាហនៈនិងបក្សីនៅខេត្តកោះកុងពីឆ្នាំ២០១៥-២០១៩

បរិយាយ	ឯកត្តា	២០១៥	២០១៦	២០១៧	២០១៨	២០១៩
គោ	ក្បាល	៦.៣៧៦	៦.៤៩៩	៦.៦១៨	៨.៤៥៨	៨.៧០២
ក្របី	ក្បាល	៧.៨៧៥	៧.៧២៨	៨.៧៨១	៩.៨៧៦	៩.៧៩១
ជ្រូក	ក្បាល	១៥.៨៨៧	១៧.១៨២	៩.២០៥	១១.៦៦៩	១៣.១១៤
មាន់	ក្បាល	៤៤.៤០៤	៤៤.៨៨២	៥០.៦៨០	៧៧.៧១២	៤៨.៦១៦

ទា	ក្បាល	៦.១១៤	២៤.៩៨៥	២៤.៦៨០	២១.៤៤៦	១៥.២៩០
ក្ងាន	ក្បាល	១០២	១៣៣	៣៧៥	៦៥៨	៣៧២
ព្រាប	ក្បាល	៤៩១	៥៤២	៣៩៦	៥៨១	៧៦៩
ពពែ	ក្បាល	១០៦	១៧១	២០៧	២៥៧	២៤៨

(ប្រភពទិន្នន័យមន្ទីរកសិកម្មខេត្ត)

១.២.១.២ វិស័យជលផល

ខណ្ឌរដ្ឋបាលជលផល បានរៀបចំផែនការនេះឡើងស្របតាមទិសដៅ និងគោលនយោបាយរបស់រដ្ឋាភិបាល ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ជាពិសេសស្របតាមសក្តានុពលស្ថានភាពភូមិសាស្ត្រ សេចក្តីត្រូវការ និងបញ្ហាដែលកើតមានឡើងក្នុងវិស័យជលផលខេត្តកោះកុង ។

ខណ្ឌរដ្ឋបាលជលផលខេត្តកោះកុង បានកំណត់យកការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងពង្រឹងការគ្រប់គ្រងធនធានជលផលថ្នាក់ខេត្ត ដែលជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធានមនុស្ស ថវិកា មធ្យោបាយ សម្ភារ និងសក្តានុពលដែលមានក្នុងខេត្តតាមរយៈការបញ្ចូលបច្ចេកទេសជលផលដល់ប្រជានេសាទ ចំពោះការធ្វើវារីវប្បកម្ម ការកែច្នៃ និងបង្កើតកន្លែងបង្កាត់ភ្ញាស់កូនត្រី ការពង្រឹងស្ថាប័ន និងការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ។

ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ ធានាឱ្យមានម្ហូបអាហារគ្រប់គ្រាន់ប្រកបដោយសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋគ្រប់រូប តាមរយៈការធ្វើទំនើបកម្មការងារវារីវប្បកម្ម និងជំរុញកំណើនជលផលក្នុងរង្វង់ប្រមាណ ៧ %ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតកម្មនេសាទ វារីវប្បកម្ម ផ្អែកលើអភិក្រមថ្មីមួយ ដើម្បីពន្លឿនកំណើនសេដ្ឋកិច្ចវិស័យកសិកម្ម និងការគ្រប់គ្រងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ទន្ទឹមនឹងនេះ វិស័យជលផលនៅមានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការធ្វើនេសាទដោយខុសច្បាប់នៅតែកើតមាន
- ការគ្រប់គ្រងតំបន់អភិរក្សនៅមិនទាន់បានល្អ
- ការចូលរួមរបស់សហគមន៍នេសាទក្នុងការការពារ និងអភិរក្សនៅមានកម្រិត
- ខ្វះការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគោរពច្បាប់ស្តីពីជលផល
- ប្រជាពលរដ្ឋកង្វះជម្រើសមុខរបរ
- ខ្វះការយល់ដឹងចំពោះឧបករណ៍នេសាទដែលអនុញ្ញាតឲ្យប្រើប្រាស់ក្នុងដែននេសាទ
- ខ្វះការយល់ដឹងអំពីការងារអភិរក្សធនធានជលផល
- សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទលើការដឹកនាំ និងគ្រប់គ្រង ក៏នៅមានកម្រិត

❖ **បញ្ហាអាទិភាពសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខ**

1. បង្កើនការទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទ
2. ផ្សព្វផ្សាយច្បាប់ស្តីពីជលផល
3. ផ្សព្វផ្សាយប្រកាសស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឲ្យប្រើក្នុងដែននេសាទ
4. បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដល់គណៈកម្មការសហគមន៍នេសាទ
5. បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ
6. បណ្តុះបណ្តាលបច្ចេកទេសកែច្នៃផលនេសាទ
7. ផ្សព្វផ្សាយអំពីសារៈសំខាន់ការងារអភិរក្ស និងតំបន់អភិរក្ស
8. ដាំកូនកោងកាង

១.២.១.៣ វិស័យធនធានទឹក និងឧតុនិយម

ធនធានទឹក គឺជាវិស័យមួយដ៏សំខាន់ នៃមូលដ្ឋានធនធានធម្មជាតិ និងបរិស្ថានជាតិ វាគឺជាធនធានធម្មជាតិសំខាន់បំផុតមួយ ដែលមិនអាចខ្វះបាន ក្នុងចំណោមធនធានធម្មជាតិសំខាន់ៗទាំងឡាយ សម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍ

ន៍សង្គមជាតិទាំងមូល ជាពិសេសសម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ។

តាមលក្ខណៈភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយដែលមានប្រភពទឹកសាបដ៏ស្តុកស្តម្ភ ជាក់ស្តែងដូចជានៅក្នុងខេត្តកោះកុង អាចអោយយើងទាញយកផលប្រយោជន៍នៃសក្តានុពលទាំងនោះដើម្បីអភិវឌ្ឍន៍ខេត្ត និងប្រទេសជាតិអោយបានរីកចម្រើន ប៉ុន្តែទាមទារអោយមានការរៀបចំ ពង្រឹងការគ្រប់គ្រងធនធានទឹកអោយបានត្រឹមត្រូវល្អ ដោយក្រសួង ស្ថាប័ន មន្ទីរជំនាញនានា ដែលមានការពាក់ព័ន្ធ ត្រូវមានទស្សនវិស័យរួមមួយដែលមានការឯកភាពគ្នា ជាពិសេសក្រសួងធនធានទឹក និងឧតុនិយមដែលត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងលើវិស័យធនធានទឹក និងត្រូវដើរតួសំខាន់ឈានមុខគេ ។

ការងារជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រសម្រាប់បម្រើដល់ការស្រោចស្រព ការងារគ្រប់គ្រងនិងផ្គត់ផ្គង់ទឹកសម្រាប់វិស័យកសិកម្ម និងការប្រើប្រាស់ទឹកស្អាត គឺជាគោលដៅចម្បង ដែលក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំងមន្ទីរជំនាញកំពុងតែអនុវត្តដោយមានសន្ទុះខ្លាំងក្លា ដោយឡែកខេត្តកោះកុង មានដីស្រែ ភាគច្រើនត្រូវបានយាយីដោយការជោរ នាចនៃទឹកប្រៃនោះ វាគឺជាឧបសគ្គដល់ការងារដាំដុះរបស់កសិករ។ ដូច្នេះការជួសជុល និងការសាងសង់ប្រព័ន្ធធារាសាស្ត្រ ជាពិសេសប្រព័ន្ធទំនប់ការពារទឹកប្រៃ និងទឹកជំនន់ វាគឺជាអាទិភាពដ៏សំខាន់បំផុតក្នុងការបង្កើនផលិតផលកសិកម្ម ការបង្កើនប្រាក់ចំណូល ចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនក្នុងខេត្ត ។ គិតមកទល់បច្ចុប្បន្ន សមិទ្ធផលដែលសម្រេចបានមាន៖ ការជួសជុល-សាងសង់ប្រព័ន្ធទំនប់ការពារទឹកប្រៃសរុបប្រវែង **៥៥.៦៩០ម** និងប្រឡាយដោះទឹកជំនន់ សរុបប្រវែង **១៩.៣៦០ម** ដោយមានលទ្ធភាពការពារទឹកប្រៃមិនអោយហូរចូលដីស្រែលើផ្ទៃដី **៥.៩១៨ ហិកតា** និងបានរៀបចំសហគមន៍កសិកររប្រើប្រាស់ទឹក(ស.ក.ប.ទ) បាន០២កន្លែងទៀតផង។

ក). សក្តានុពល

បរិមាណទឹកភ្លៀងជាមធ្យមពី **៣.០០០មម-៤.០០០មម** ក្នុង០១ឆ្នាំ មានទឹកគ្រប់គ្រាន់សម្រាប់ការងារដាំដុះដំណាំគ្រប់ប្រភេទ ដែលអាចបម្រើដល់វិស័យកសិកម្ម និងកសិឧស្សាហកម្ម ព្រមទាំងទេសចរណ៍ទៀតផង។គ្មានជំនន់ធំដុំ(ដោយមានព្រៃកធម្មជាតិធំៗចំនួន០៥ ដូចជាព្រៃកកោះប៉ោ ព្រៃកតាតៃ ព្រៃកត្រពាំងរូង ព្រៃកអណ្តូងទឹក និងព្រៃកស្រែអំបិល) ។ ដែលព្រៃកទាំងនេះគឺជាប្រឡាយដោះទឹកជំនន់ដ៏សំខាន់ចាក់ចូលទៅសមុទ្រ ។ នាពេលអនាគត ការទាញយកទឹកសាបពីក្បាលឆាយនៃព្រៃកទាំង០៥នេះមកធ្វើការស្រោចស្រពកំពុងត្រូវបានពិចារណា និងជាប្រភពផលិតថាមពលវារីអគ្គិសនីដ៏សំខាន់ទៀតផង ។

ខ). បញ្ហាប្រឈម

- ជាទូទៅស្ថានភាពភូមិសាស្ត្រ ក្នុងខេត្តកោះកុងទាំងមូលមានភាពស្មុគស្មាញ សម្បូរទៅដោយដៃព្រៃអូរ បឹងបួរ ពុំទាន់មានផ្លូវគោកធ្វើដំណើរទៅដល់។ការធ្វើដំណើរ និងការដឹកជញ្ជូនសម្ភារសំណង់ផ្សេងៗ និងគ្រឿងចក្រ ធ្វើឡើងដោយការជួលទូក-កាណូត-សាឡង់...។ល។ ដែលមានការចំណាយទុនច្រើនទៅលើសោហ៊ុយដឹកជញ្ជូន។
- ខ្វះខាតបុគ្គលិកបម្រើការងារនិងបំពេញភារកិច្ចជូនក្រសួងនិងខេត្តដែលបានដាក់ផែនការអោយអនុវត្ត។ ខ្វះខាតធនធានមនុស្សក្នុងការអនុវត្តភារកិច្ច ដែលកិច្ចការវិស័យធនធានទឹក និងឧតុនិយមទាមទារបច្ចេកទេសខ្ពស់និងពុំទាន់មានភ្នាក់ងារធនធានទឹក និងឧតុនិយមប្រចាំការនៅតាមបណ្តាស្រុក
- ខ្វះខាតធនធានថវិកា ដើម្បីដំណើរការការងារវិស័យធនធានទឹក និងឧតុនិយម ដែលជាហេតុធ្វើឲ្យដំណើរការការងារ ពុំបានសម្រេចតាមផែនការដែលក្រសួង និងខេត្តដាក់អោយអនុវត្ត
- ខ្វះខាតសម្ភារគ្រឿងចក្រផ្ទាល់ខ្លួន ដែលបណ្តាលអោយមានការយឺតយ៉ាវក្នុងការងារជួសជុល-សាងសង់សំណង់ប្រព័ន្ធធារាសាស្ត្រ និងចំណាយថវិកាច្រើនទៅលើការជួលគ្រឿងចក្រឯកជន
- កសិករមិនព្រមផ្លាស់ប្តូរទម្លាប់ចាស់(ធ្វើស្រែតែម្តងក្នុង១រដូវ,មិនព្រមប្តូរពូជនិងទទួលបានទិន្នផលទាប)
- កសិករ និងអាជ្ញាធរមូលដ្ឋានមិនទាន់ម្ចាស់ការបាន ក្នុងការចូលរួមចំណែកការពារ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ ដែលមានស្រាប់ដើម្បីធានាបាននិរន្តរភាពក្នុងការប្រើប្រាស់

- ភូមិសាស្ត្រខេត្តកោះកុង ភាគច្រើនគ្របដណ្តប់ដោយតំបន់អភិរក្សដែលធ្វើអោយមានការលំបាកក្នុងការពង្រីកផ្ទៃដីដាំដុះ
- បម្រែបម្រួលអាកាសធាតុនាពេលបច្ចុប្បន្ន គឺជាបញ្ហាចម្បងដែលត្រូវតែមានការគិតគូរ ព្រោះប្រឈមទៅនឹងគ្រោះរាំងស្ងួត និងទឹកជំនន់ជាដើម ។

ជារួមមានឧបសគ្គជាច្រើនទៀត ដែលប៉ះពាល់ដល់ការបង្កើនផលិតផលកសិកម្ម និងបង្កើនប្រាក់ចំណូលនៅតាមតំបន់ជនបទ ដូចជាសិទ្ធិគ្រប់គ្រងដីធ្លី ប្រព័ន្ធដឹកជញ្ជូនលទ្ធភាពហិរញ្ញវត្ថុជនបទ ការផ្សព្វផ្សាយកសិកម្ម និងកម្រិតនៃការអប់រំជាដើម ដែលទាំងនេះសុទ្ធតែជាបញ្ហាប្រឈម ដែលទាមទារអោយមានការធ្វើកំណែទម្រង់ជាចាំបាច់។

១.២.១.៤ វិស័យរ៉ែ និងថាមពល

ក.ការងារធនធានរ៉ែ

ការងារធនធានរ៉ែ និងថាមពល បន្តខិតខំជម្រុញស្រាវជ្រាវរុករក និងត្រួតពិនិត្យការធ្វើអាជីវកម្មធនធានរ៉ែ ប្រេង កាត និងឧស្ម័ន ជាពិសេសស្រាវជ្រាវរុករករ៉ែផ្សេងៗ ជាច្រើនទៀតដើម្បីឲ្យវិស័យនេះអាចចូលរួមចំណែកបន្ថែមដល់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍន៍ឲ្យស្របទៅតាមសក្តានុពល ដែលខេត្តកោះកុងយើងមាន។ ការងាររ៉ែ និងថាមពលបន្តត្រួតពិនិត្យ និងពង្រឹងការអនុវត្តកិច្ចព្រមព្រៀងលើអាជ្ញាប័ណ្ណស្រាវជ្រាវរុករក និងធ្វើអាជីវកម្មផ្សេងៗនៅទូទាំងខេត្ត ដើម្បីធានាការប្រកបអាជីវកម្មធនធានរ៉ែទាំងនោះឲ្យស្របតាមច្បាប់ និងការពារបរិស្ថានឲ្យបានគង់វង្ស។

ខ. ការងារថាមពល

បន្តការអភិវឌ្ឍន៍វិស័យថាមពលជាពិសេសលើវិស័យថាមពលវារីអគ្គិសនីខ្នាតតូច និងថាមពលអគ្គិសនីកកើតឡើងវិញដើម្បីធានាឆ្លើយតបដោយប្រសិទ្ធភាព និងមានតម្លៃថោកសមរម្យឲ្យត្រូវទៅនឹងតម្រូវការប្រើប្រាស់ ដែលចេះតែមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ នៅក្នុងបរិការណ៍នេះ ការផ្តល់អាទិភាពខ្ពស់ទៅលើការទាក់ទាញឲ្យមានការចូលរួមរបស់ផ្នែកឯកជនក្នុងការផលិត និងផ្គត់ផ្គង់អគ្គិសនីពិសេសនៅទីរួមខេត្ត ស្រុក និងទីប្រជុំជនសំខាន់ៗ និងការអនុវត្តន៍គម្រោងអគ្គិសនីភាវូបនីយកម្មតំបន់ជនបទប្រកបដោយគុណភាព និងមានតម្លៃទាបព្រមទាំងគម្រោងភ្ជាប់ខ្សែបញ្ជូនថាមពលពីប្រទេសជិតខាង ។

វិស័យរ៉ែ និងថាមពល បានផ្តល់ភាពទូលំទូលាយដល់អ្នកវិនិយោគទាំងឡាយ ដើម្បីអភិវឌ្ឍ វារីអគ្គិសនីខ្នាតតូច និងជម្រុញការអភិវឌ្ឍន៍បច្ចេកវិទ្យាប្រកបដោយគុណភាពខ្ពស់ស្របតាមស្តង់ដាអន្តរជាតិមានតម្លៃថោកសមរម្យ និងមានសេវាកម្មទំនើបគ្របដណ្តប់ទូទាំងខេត្ត ដូចខាងក្រោម៖

១. វារីអគ្គិសនី ស្ទឹងឫស្សីជ្រុំក្រោម មានអានុភាពតម្លើង ៣៣៨ មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន China Huadian Lower Stung Russei Chrum Hydro-Electric Project (Cambodia) Company Limited ស្ថិតនៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។

២. វារីអគ្គិសនីគិរីរម្យ៣ មានអានុភាពតម្លើង ១៨ មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន CETIC International Hydropower Development Co.,Ltd ស្ថិតនៅឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង។

៣. វារីអគ្គិសនីស្ទឹងតាតៃមានអានុភាពតម្លើង២៤៦មេហ្គាវ៉ាត់វិនិយោគដោយក្រុមហ៊ុនCambodiaTatayHydropower Limited (CTHL) ដែលមានទីតាំងស្ថិតនៅក្នុងឃុំឫស្សីជ្រុំ និងឃុំទទៃលើ ស្រុកថ្មបាំងខេត្តកោះកុង

ក្រៅពីវារីអគ្គិសនីខាងលើ ក្រសួងបានសិក្សាបុរេសមិទ្ធលទ្ធភាពទៅលើតំបន់ និងទីតាំងដែលអាចធ្វើវារីអគ្គិសនីបានរួមមាន៖

១. វារីអគ្គិសនីស្ទឹងជាយអារ៉ែង មានអានុភាព ១០៨ មេហ្គាវ៉ាត់ (សិក្សាបុរេសមិទ្ធលទ្ធភាព) ស្ថិតនៅឃុំថ្មដូនពៅ ឃុំប្រឡាយ ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង

២. វារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្តាល មានអានុភាព ១២៥ មេហ្គាវ៉ាត់ (សិក្សាបុរេសមិទ្ធលទ្ធភាព) ស្ថិតឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

៣. វារីអគ្គិសនីស្ទឹងមេទឹកទី១ មានអានុភាព ៥០ មេហ្គាវ៉ាត់(សិក្សាបុរេសមិទ្ធលទ្ធភាព) ស្ថិតឃុំប៉ាក់ខ្លង ស្រុក

មណ្ឌលសីមា ខេត្តកោះកុង

៤. វារីអគ្គិសនីស្ទឹងមេទឹកទី២ មានអានុភាព ២១០ មេហ្គាវ៉ាត់ (សិក្សាបុរេសមិទ្ធលទ្ធភាព) ស្ថិតឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

៥. វារីអគ្គិសនីស្ទឹងមេទឹកទី៣ មានអានុភាព ១៧៥ មេហ្គាវ៉ាត់ (សិក្សាបុរេសមិទ្ធលទ្ធភាព) ស្ថិតឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

៦. វារីអគ្គិសនីអ៊ូស្លា មានអានុភាព ២ មេហ្គាវ៉ាត់ (សិក្សាបុរេសមិទ្ធិលទ្ធភាព) ស្ថិត ស្រុកស្រែអំបិល ខេត្តកោះកុង

៧. វារីអគ្គិសនីស្ទឹងវាលថ្មកំបុក មានអានុភាព ៧០ មេហ្គាវ៉ាត់(សិក្សាបុរេសមិទ្ធលទ្ធភាព) ស្ថិតឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

៨. វារីអគ្គិសនីស្ទឹងតូចលើ មានអានុភាព ៥៦ មេហ្គាវ៉ាត់ (សិក្សាបុរេសមិទ្ធលទ្ធភាព) ស្ថិតឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

៩. វារីអគ្គិសនីស្ទឹងតូចក្រោម មានអានុភាព ២៤ មេហ្គាវ៉ាត់ (សិក្សាបុរេសមិទ្ធលទ្ធភាព) ស្ថិតឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

១០.ស្ថានីយប្រេងឥន្ធនៈក្នុងខេត្តកោះកុងមានចំនួន ៣២ស្ថានីយ

ជាមួយគ្នានេះដែរ វិស័យរ៉ែ និងថាមពល កំពុងជួបនូវបញ្ហាមួយចំនួនដូចខាងក្រោម៖

- អាជីវករធ្វើអាជីវកម្មមួយចំនួនពុំទាន់យល់ពីច្បាប់ស្តីពីការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ
- ក្រុមហ៊ុនមួយចំនួនពុំទាន់បានបំពាក់នូវប្រអប់ការពារកុងទ័រឲ្យបានគ្រប់ចំនួន
- ការពង្រីកបណ្តាញអគ្គិសនីក្រុមហ៊ុនមានការយឺតយ៉ាវ និងការផ្គត់ផ្គង់អគ្គិសនីពុំទាន់មានស្ថិរភាព
- ការផ្តល់របាយការណ៍ផ្គត់ផ្គង់ថាមពលអគ្គិសនីពីក្រុមហ៊ុនមានភាពយឺតយ៉ាវនិងមិនសូវសហការ
- ការដឹកជញ្ជូនដីគ្របតង់មិនបានត្រឹមត្រូវដោយមានការធ្លាក់រាយប៉ាយនៅលើផ្លូវ
- ការដឹកជញ្ជូនលើសចំណុះហួសពីទ្រុងរថយន្ត។

១.២.១.៥ វិស័យឧស្សាហកម្ម និងសិប្បកម្ម

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ទិសដៅក្នុងការប្រែក្លាយប្រទេសកម្ពុជា ឲ្យក្លាយទៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមក្នុងឆ្នាំ២០៣០ និងមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ដូចបានកំណត់ក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨។ ទិសដៅនេះ បញ្ជាក់ពីតួនាទីនៃវិស័យឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម ដែលជាកត្តាជំរុញដ៏សំខាន់ ចំពោះកំណើននាពេលអនាគត។ កាលពីខែមីនា ឆ្នាំ២០១៥ រដ្ឋាភិបាល បានរៀបចំ និងអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ដែលជាមគ្គុទេសក៍មួយ ដើម្បីផ្តល់នូវដំណោះស្រាយជាលក្ខណៈប្រព័ន្ធក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មឱ្យមានភាពប្រកួតប្រជែង នៅក្នុងប្រទេស កម្ពុជា។

វិស័យឧស្សាហកម្ម និងសិប្បកម្មខេត្ត ក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារមានការវិនិយោគពីក្រុមហ៊ុនឯកជនមួយចំនួនមានជាអាទិ៍៖ ឧស្សាហកម្មកាត់ដេរ គ្រឿងអេឡិចត្រូនិច ផលិតបាល់ បង្គុំខ្សែភ្លើង និងដំឡើងរថយន្ត នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងមានសិប្បកម្មជាច្រើនទៀតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស។ ផ្អែកតាមទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានបង្ហាញឲ្យឃើញថា វិស័យឧស្សាហកម្ម និងសិប្បកម្មនៅខេត្តកោះកុង មានអត្រា២៩,៤% នៅឆ្នាំ២០១៨ ធៀបទៅនឹងឆ្នាំ២០១៦ដែលមាន អត្រា២៧,៧% នៃផលិតផលក្នុងស្រុកសរុប។

ជាមួយគ្នានេះដែរ វិស័យនេះនូវមានបញ្ហាប្រឈមដែលត្រូវដោះស្រាយដូចខាងក្រោម៖

- កង្វះធនធានមនុស្ស មូលដ្ឋានចំណេះដឹងផ្នែកបច្ចេកទេសនៅមានកម្រិត
- ខ្វះមធ្យោបាយធ្វើដំណើរដើម្បីចុះអនុវត្តការងារ
- គោលនយោបាយលើកទឹកចិត្តពុំទាន់ឆ្លើយតប និងតម្រូវការរបស់សហគ្រាស
- មានហានិភ័យក្នុងផលិតកម្ម ប៉ះពាល់សុវត្ថិភាពលើផលិតផល បរិស្ថាន សង្គម និងផលចំណេញ

- ហានិភ័យនៃការប្រើប្រាស់ និងទទួលទាន ផលិតផលដែលមានសារធាតុគីមី និងគ្មានគុណភាព
- ផលិតផលសិប្បកម្ម មិនអាចប្រកួតប្រជែង លើទីផ្សារបាន
- ប្រជាពលរដ្ឋនៅតាមជាយក្រុង និងនៅតាមជនបទខ្វះទឹកស្អាតប្រើប្រាស់ និងមិនយល់អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត
- ការយល់ដឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិរបស់ប្រជាពលរដ្ឋមិនទាន់បានទូលំទូលាយ

១.តារាងស្ថិតិតាមស្ថានទឹកស្អាតក្នុងខេត្តកោះកុង (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩)

ល.រ	ឈ្មោះម្ចាស់ក្រុមហ៊ុន ឬអាជីវករ	ទីតាំងផលិតទឹកស្អាត	មានច្បាប់ ឬ អត់ច្បាប់	ប្រវែងបណ្តាញមេសរុប Km	សមត្ថភាពផលិត/ឆ្នាំ	ប្រភពទឹក	ចំនួនឡាំកាសរុប	ថ្លៃភ្ជាប់បណ្តាញ	តម្លៃទឹកក្នុង១ម^3	សេវាកម្មម៉ោង/ថ្ងៃ
១	ក្រុមហ៊ុន L.Y.P Group	ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា	ប្រកាសក្រសួង	៥៨.៧៨០ម	១.០៩៨.៩០០ម^3	ស្រះ	៥.៦៩៦	៣.៥០០បាត	១.៨០០រ	២៤ម៉ោង
២	លោក កើត ព្រហស្តវរៈ	ឃុំបឹងព្រាវ ស្រុកស្រែអំបិល	ប្រកាសក្រសួង	១៧គ.ម	៣៨.០៩៩ម^3	ស្រះ	៨២៤	៥០ដុល្លា	២,០០០រ	២៤ម៉ោង
៣	លោកស្រី ហុង មុំ	ឃុំថ្មស ស្រុកបុទុមសាគរ	ប្រកាសក្រសួង	១.៩៥៣ម	១៨.៩០០ម^3	ស្រះ	៨១០	៥០ដុល្លា	២.៩០០រ	២៤ម៉ោង
៤	លោកស្រី អាន់ សំឡាន	ឃុំកោះស្តេច ស្រុកគីរីសាគរ	កំពុងសិក្សាសម្ទិលទ្ធភាព	៤,៥គ.ម	៨៧០០ម^3	ស្រះ	៤០០	១០០,០០០រ	៧,០០០រ	២៤ម៉ោង
៥	លោក ស៊ាង អឿន	ឃុំអណ្តូងទឹក ស្រុកបុទុមសាគរ	ចុះបញ្ជីមន្ទីរ	៨០០ម	១.៩៥០ម^3	ស្រះ	១៤៨	១៥០,០០០រ	៥,០០០រ	២៤ម៉ោង
៦	លោក ជី ចេង	ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល	ចុះបញ្ជីមន្ទីរ			ស្រះ	៥០	១៥០,០០០រ	៥,០០០រ	២៤ម៉ោង
៧	លោក ប៉ាន ហៀវ	ឃុំជីខក្រោម ស្រុកគីរីសាគរ	ចុះបញ្ជីមន្ទីរ	២,៥គ.ម	៩០០ម^3	ស្រះ	៤០	០០រ	៥,០០០រ	២៤ម៉ោង
៨	លោក ហ៊ែល ហែម	ឃុំអណ្តូងទឹក ស្រុកបុទុមសាគរ	ចុះបញ្ជីមន្ទីរ	៥គ.ម	៧៣០ម^3	អណ្តូងស្ទប់	៨១	៥០ដុល្លា	៥,០០០រ	២៤ម៉ោង

២.តារាងស្ថិតិរោងចក្រ និង សហគ្រាសធុនតូច ធម្យម និង សិប្បកម្ម ឆ្នាំ២០១៧ ធៀបនឹង ឆ្នាំ២០១៨

ល.រ	ឧស្សាហកម្ម និង សិប្បកម្ម	ចំនួនសរុប		កម្លាំងពលកម្មសរុប		ទុនវិនិយោគសរុប*(ដុល្លារ)*	
		២០១៧	២០១៨	២០១៧	២០១៨	២០១៧	២០១៨
១	រោងចក្រ	០៧	០៧	៨.៩២៣	១០.៨៤៣	២៥៥.០៣៦.៧២៧	២៥៥.០៣៦.៧២៧

២	សហគ្រាសធុនតូចមធ្យម	១០	១២	២៧	៤៧	១.៧១០.៣៩១	២.០៣៤.៣០១
៣	សិប្បកម្ម	២៦៩	២៧៧	៦៨០	៧០៨	៦.៤០៧.៧០៣	៨៥០.៣០១
សរុបរួម		២៨៦	២៩៦	៩.៦៣០	១១.៥៩៨	២៥៧.៣៨៧.៨២១	២៥៧.៩២១.១៨១
កើនឡើង/ ថយចុះ		**កើន ១០**		**កើន ១.៩៦៨**		**កើន ៥៣៣.៣៦០**	

១.២.១.៦ វិស័យសាធារណការ និងដឹកជញ្ជូន

វិស័យសាធារណការ និងដឹកជញ្ជូន របស់ខេត្តដើរតួនាទីមុខងារជាសេនាធិការឲ្យគណៈអភិបាល និងក្រុមប្រឹក្សាខេត្តក្នុងបេសកកម្មដឹកនាំ គ្រប់គ្រងលើវិស័យសាធារណការ និងដឹកជញ្ជូន ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី និងសមធម៌សង្គម។

រដ្ឋបាលខេត្ត មានគោលដៅ បន្តការស្ថារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដោយផ្តោតអាទិភាពខ្ពស់លើការថែទាំផ្លូវជាតិ ផ្លូវខេត្ត ក្រុងស្រុក ឃុំសង្កាត់ និងការថែទាំខួប និងជំរុញឲ្យអនុវត្តការចូលរួមដេញថ្លៃដោយវិស័យឯកជន។ បន្តសាងសង់ផ្លូវខេត្ត និងផ្លូវជនបទ ការស្ថារនិងពង្រីកសមត្ថភាពរបស់កំពង់ផែ ការស្ថារ ព្រមទាំងបន្តលើកទឹកចិត្តដល់ការចូលរួមពីវិស័យឯកជនក្នុងការផ្តល់ការកសាង និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់សេវាដឹកជញ្ជូន ការអនុវត្តច្បាប់ស្តីពីផ្លូវថ្នល់ ព្រមទាំងលិខិតបទដ្ឋានផ្សេងៗទៀតសំរាប់ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែមានប្រសិទ្ធភាព។ រដ្ឋបាល ខេត្ត នឹងផ្តោតការយកចិត្តទុកដាក់ដល់ការងារសុវត្ថិភាពចរាចរណ៍និងមានវិធានការយ៉ាងម៉ឺងម៉ាត់ចំពោះបទល្មើសដឹកជញ្ជូនលើសទំងន់។ សកម្មភាពនិងលទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម៖

១.វិស័យសាធារណការ

- ផ្លូវជាតិលេខ៤៨ និងត្រូវធ្វើការផ្លាស់ប្តូរប្រភេទ DBST មកជាប្រភេទផ្លូវបេតុងកៅស៊ូ AC
- ផ្លូវក្រាលគ្រួសក្រហម និងត្រូវធ្វើការផ្លាស់ប្តូរមកជាប្រភេទផ្លូវ DBST
- ផ្លូវដី និងត្រូវធ្វើការផ្លាល់ប្តូរមកជាប្រភេទផ្លូវក្រាលគ្រួសក្រហម
- ការគ្រប់គ្រងដីចម្ការមផ្លូវការពារប្រព័ន្ធរំដោះទឹក

១.១ ការងារថែទាំជាប្រចាំ

- ការងារថែទាំប្រចាំផ្លូវជាតិលេខ៤៨ ក្រាលកៅស៊ូDBST ប្រវែង៨២.៨៧ គ.ម
- ការងារថែទាំប្រចាំផ្លូវខេត្តលេខ១៤៨៣ ក្រាលកៅស៊ូDBST ប្រវែង៨.៣៤០ គ.ម
- ការងារថែទាំប្រចាំផ្លូវខេត្តលេខ១៤៨៥អា ក្រាលកៅស៊ូDBST ប្រវែង៤.៣០ គ.ម
- ការងារថែទាំប្រចាំផ្លូវខេត្តលេខ១៤៨៩អា ក្រាលកៅស៊ូDBST ប្រវែង៨.៦៣០ គ.ម
- ការងារថែទាំប្រចាំផ្លូវខេត្តលេខ១៤៨៥អា ក្រាលគ្រួសក្រហម ប្រវែង២៩.៥០ គ.ម
- ការងារថែទាំប្រចាំផ្លូវខេត្តលេខ១៤៨៦ ក្រាលគ្រួសក្រហម ប្រវែង២៦.០០ គ.ម
- ការងារថែទាំប្រចាំផ្លូវខេត្តលេខ១៤៨៣ ក្រាលគ្រួសក្រហម ប្រវែង១២.៤០ គ.ម
- ការងារថែទាំប្រចាំផ្លូវក្នុងក្រុងខេមរភូមិន្ទ១២ខ្សែ ក្រាលកៅស៊ូ ប្រវែង២៥.០៥ គ.ម

១.២ ការងារជួសជុលខួប

- ជួសជុលផ្លូវជាតិលេខ៤៨ (ចាស់) ក្រាលកៅស៊ូDBST ប្រវែង២,២០០ម
- ក្រាលបេតុងសសៃដែកលើផ្លូវជាតិលេខ៤៨ ប្រវែង១៥,០០០ម២ កំរាស់0.២០ម

១.៣ ការងារជួសជុលបន្ទាន់

- ជួសជុល ស្ថាបនាជញ្ជាំងបេតុងការពារសុវត្ថិភាពលើផ្លូវជាតិលេខ៤៨ មានប្រវែង១៦០ម

- ជួសជុល ស្ថាបនាលូប្រអប់លើផ្លូវខេត្តលេខ១៤៨៦ ចំនួន ២កន្លែង
- ជួលជុលចញ្ចើម និងជើងទេរផ្លូវខេត្តលេខ១៤៨៩អា មានប្រវែង៨០០ម។

២. វិស័យដឹកជញ្ជូន

បន្តផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋបានឆាប់រហ័សទាន់ចិត្ត តម្លាភាព រយៈពេលនៃការផ្តល់សេវាខ្លីជាងមុន តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (ចុះបញ្ជីយានយន្ត ទោចក្រយានយន្ត ជលយានយន្ត ផ្តល់បណ្ណបើកបរ និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ឆៀកចល័ត)

- ផ្តល់សេវាការលក់លេខចុះបញ្ជីរថយន្តគ្រួសារ ចុះបញ្ជីលេខពិសេសផ្ទាល់ខ្លួន និងការដេញថ្លៃលេខពិសេសផ្ទាល់ខ្លួន
- មានជញ្ជីងសម្រាប់ថ្លឹងទម្ងន់រថយន្ត
- បន្តធ្វើការត្រួតពិនិត្យឧបករណ៍ទូកជាលក្ខណៈបច្ចេកទេសនៅតាមកំពង់ផែ
- បន្តចុះផ្សព្វផ្សាយ ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស តាមដងផ្លូវ និងតាមទីប្រជុំជន
- បន្តបង្កើតកម្មវិធីផ្សព្វផ្សាយនិងទទួលព័ត៌មានទាន់ពេលវេលាតាមរយៈកម្មវិធីទូរស័ព្ទដៃ (MobileApp) បង្កើតដោយក្រសួងសាធារណការ និងដឹកជញ្ជូន បច្ចុប្បន្នមានដូចជាCambodia Driving Rules Mobile App, MPWT News Mobile App និង Road Care Mobile App

២.១ ការផ្តល់សេវាយានយន្ត និងជលយានយន្ត

- សេវាផ្តល់ប័ណ្ណសំគាល់ស្លាកលេខ(ទោចក្រយានយន្ត ត្រីចក្រយានយន្ត រថយន្តទេសចរណ៍ រថយន្តដឹកអ្នកដំណើរធុនតូច រថយន្តដឹកទំនិញធុនតូច-ធំ រថយន្តដឹកស៊ីទែន និងក្បាលសណ្តោង) សរុបចំនួន ៧១៧ គ្រឿង
- សេវាផ្ទេរកម្មសិទ្ធក្នុងខេត្ត (ទោចក្រយានយន្ត ត្រីចក្រយានយន្ត រថយន្តទេសចរណ៍ រថយន្ត ដឹកទំនិញធុនតូច-ធំ) សរុបចំនួន ១៤៨ គ្រឿង
- សេវាផ្ទេរកម្មសិទ្ធក្រៅខេត្ត (ទោចក្រយានយន្តរថយន្តទេសចរណ៍ រថយន្តដឹកទំនិញធុនតូច-ធំ រថយន្ត ដឹកអ្នកដំណើរធុនធំ និងរថយន្តដឹកស៊ីទែនធុនធំ) សរុបចំនួន ៥២ គ្រឿង
- សេវាប្តូរប័ណ្ណ និងស្លាកសំគាល់យានយន្ត (ប្តូរប័ណ្ណទោចក្រយានយន្ត ប្តូរស្លាកលេខសំគាល់ទោចក្រយានយន្ត ប្តូរម៉ាស៊ីនរថយន្ត និងប្តូរស្លាកលេខរថយន្ត) សរុបចំនួន ២៦ គ្រឿង
- សេវាទុតិយតាប័ណ្ណ និងស្លាកសំគាល់យានយន្ត (ប័ណ្ណសំគាល់ទោចក្រយានយន្ត ស្លាកសំគាល់ទោចក្រយានយន្ត ទុតិយតាស្លាកសំគាល់រថយន្តធុនតូច) សរុបចំនួន ២៣ ប័ណ្ណ ស្លាក គ្រឿង
- សេវាប្តូរប័ណ្ណបើកបរ (ប្រភេទ ខ គ ឃ២) សរុបចំនួន ២៣៧ ប័ណ្ណ
- សេវាប្តូរទុតិយតាប័ណ្ណបើកបរ (ប្រភេទ ខ គ ឃ២ ងគ) សរុបចំនួន ១៨ ប័ណ្ណ
- សេវាចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត សរុបចំនួន ០២ យានដ្ឋាន
- សេវាចុះបញ្ជី ត្រួតពិនិត្យលក្ខណៈបច្ចេកទេស នាវានេសាទ និងនាវាដឹកទំនិញ សរុបចំនួន១២០ គ្រឿង

១.២.១.៧ វិស័យទេសចរណ៍

វិស័យទេសចរណ៍ គឺជាកម្លាំងចលករដ៏សំខាន់មួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច បង្កើនឱកាសការងារ បង្កើនប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅ ជំរុញកំណើនផលិតផលក្នុងស្រុក រក្សាលំនឹងពាណិជ្ជកម្ម និងជួយកាត់បន្ថយ

ភាពក្រីក្រ ចំណែកស្រុកជាពិសេសវិស័យនេះក៏បាននាំមកនូវកិត្យានុភាពប្រទេសជាតិ ជួយថែរក្សាមរតកវប្បធម៌ ប្រពៃណីវប្បធម៌សង្គម និងបូរណភាពទឹកដី ព្រមទាំងជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម។

*<u>សក្តានុពល</u>

ខេត្តកោះកុង សម្បូរទៅដោយធនធានធម្មជាតិជាច្រើន សម្រាប់អភិវឌ្ឍវិស័យទេសចរណ៍:

- តំបន់ខ្ពង់រាបជួរភ្នំក្រវ៉ាញ: សម្បូរទៅដោយទឹកធ្លាក់ សត្វស្លាប ថនិកសត្វគ្រប់ប្រភេទ តំបន់វប្បធម៌ ប្រវត្តិសាស្ត្រ ...។ល។
- តំបន់ឆ្នេរដែលលាតសន្ធឹងពីចាំយាម (ព្រំប្រទល់ប្រទេសកម្ពុជា-ថៃ) រហូតដល់ ព្រំប្រទល់ឃុំកែវធុស ខេត្តព្រះសីហនុ សម្បូរដោយឆ្នេរខ្សាច់ សត្វផ្សោតសមុទ្រ ព្រៃកោងកាង។
- តំបន់ប្រជុំកោះ៖មានផ្កាថ្ម ស្មៅសមុទ្រ និងសម្បូរទៅដោយធនធានជីវចម្រុះគ្រប់ប្រភេទនៅតាមដងព្រៃតំបន់រ៉ាំសា(RAMSA) ។
- ព្រៃធំៗទាំង០៥ រួមមាន៖ ព្រៃកោះប៉ោ ព្រៃតាតៃ ព្រៃត្រពាំងរូង ព្រៃអណ្តូងទឹក និងព្រៃស្រែអំបិល ហើយនៅតំបន់នោះទៀតសោត ជាប្រភពធនធានដ៏សម្បូរបែប ព្រៃកោងកាងដែលជាជម្រកសត្វស្លាប និងដែនជម្រកមច្ឆាជាតិជីវៈចម្រុះ ព្រមទាំងសម្រស់ធម្មជាតិដ៏ត្រកាលនិងស្រស់បំព្រង។

ទេសចរណ៍ត្រូវបានទទួលស្គាល់ថាជាមាសប៉ែតង និង ជាផ្នែកដ៏មានសារៈសំខាន់មួយនៃសេដ្ឋកិច្ចបែតងដែលចំណូលនៃវិស័យនេះ ត្រូវបានចាត់បញ្ចូលភ្លាមៗទៅក្នុងសេដ្ឋកិច្ចជាតិ រួមចំណែកជម្រុញកំណើនផលិតផលក្នុងស្រុកនិងធ្វើអោយមានលំនឹងផ្នែកជញ្ជីងពាណិជ្ជកម្មបានទៀត។

កន្លងមកភ្ញៀវទេសចរយ៉ាងច្រើនកុះករបានមកលេងកម្សាន្ត តាមបណ្តោយឆ្នេរខ្សាច់ស្រស់ស្អាត នៅតំបន់លំហែកាយវិស្សមកាលតារាសាគរ(ស្រុកគិរីសាគរ) ឆ្នេរខ្សាច់ប៉ាក់ខ្លង-ចាំយាម(ស្រុកមណ្ឌលសីមា) សហគមន៍អេកូទេសចរណ៍នានា។ សេវាកម្មផ្សេងៗទៀតក៏បានអភិវឌ្ឍក្លាយជារមណីយដ្ឋានកែច្នៃល្អប្រណីត និងមានចំណាត់ថ្នាក់ ស្តង់ដា។

តារាងប្រៀបធៀបកំណើនសេវាកម្មអាជីវកម្មនានា តាមសណ្ឋាគារ-ផ្ទះសំណាក់ -រមណីយដ្ឋាន
ខាវ៉ាអូខេ- ភោជនីយដ្ឋាន-សហគមន៍ទេសចរណ៍ ទូទាំង ខេត្តកោះកុង ឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

ល.រ	បរិយាយ	ឆ្នាំ២០១៧	ឆ្នាំ២០១៨	ឆ្នាំ២០១៩	សរុប បុគ្គលិក	ស្ថប័នគ្រប់គ្រង/គិតជាកន្លែង		
						ក្រុង	ខេត្ត	ក្រសួង
១	សណ្ឋាគារ	១១	១០	១០	៧៧	០០	០៤	០៦
	បន្ទប់	៨១៣	៨០៩	៨០៩				
២	ផ្ទះសំណាក់	៧៤	៨០	៧០	១៣៧	១១	៥៥	០៤
	បន្ទប់	៨៥៦	៨៩៥	៨៣០				
៣	ផ្ទះស្នាក់	១០	១០	២៦	១២៤	២៦	០០	០០
	បន្ទប់	១៩	១៩	១០៧				
៤	ភោជនីយដ្ឋាននិងអាហារដ្ឋាន	៧៥	៨៦	៩៩	៤២១	៥៥	៤៤	០០
៥	ក្លឹបកំសាន្ត	០២	០២	០១	១៨	០០	០១	០០
៦	ខាវ៉ាអូខេ	២៦	២៨	២៩	៣៤០	១៩	១០	០០
៧	ម៉ាស្សា	១៤	១៥	១៥	៧០	១៤	០០	០១
៨	ទីភ្នាក់ងារទេសចរ	០១	០១	០១	០៤	០០	០០	០១
៩	ស្នុកយ៉ា	០១	០១	០៣	១៣	២	១	០

១០	សហគមន៍ទេសចរណ៍	០៥	០៥	០៦	៥៧	០០	៦	០០
១១	ដឹកភ្ញៀវទេសចរផ្លូវគោក	០២	០២	០២	០៤	០០	០២	០០
១២	ដឹកភ្ញៀវទេសចរ ផ្លូវទឹក	០២	០២	០៣	០៧	០០	០១	០០
១៣	ការ្ហៀវីដេអូ	១០	១០	១១	៣៤	០០	១០	០០

តារាងប្រៀបធៀបកំណើនស្ថិតិភ្ញៀវជាតិ និង អន្តរជាតិស្នាក់នៅតាមសណ្ឋាគារ-ផ្ទះសំណាក់-រមណីយដ្ឋាន-ចេញ-ចូលតាមច្រក ព្រំដែនចាំយាម ក្នុងខេត្តកោះកុង ឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៩

ល.រ	បរិយាយ	២០១៧	២០១៨	២០១៩
០១	ភ្ញៀវទេសចរណ៍ជាតិ	២៥៣.៧៤១	២៩៩.០៩៦	២៥៥.១១១
០២	ភ្ញៀវទេសចរណ៍អន្តរជាតិ	៥៧.១៧៦	៧៦.៦៣៦	៧៣.៥៥១
០៣	ភ្ញៀវទេសចរណ៍ជាតិស្នាក់នៅតាមរមណីដ្ឋាន	១០៧.៣៩១	១២៤.៥១៨	១៣១.៥១៣
០៤	ភ្ញៀវទេសចរណ៍អន្តរជាតិស្នាក់នៅតាមរមណីដ្ឋាន	១១.០៨៤	១១.១២៤	៩.០៤៩
០៥	ភ្ញៀវទេសចរណ៍អន្តរជាតិចូលតាមច្រកទ្វារអន្តរជាតិចាំយាម	១៤៥.៨០៦	៨៤.១០០	៦៦.៣២៩
០៦	ភ្ញៀវទេសចរណ៍អន្តរជាតិចេញតាមច្រកទ្វារអន្តរជាតិចាំយាម	១៧៥.២៥៣	៩៨.៩៧៩	១០៣.៥៣៥

តារាងប្រៀបធៀបកំណើនស្ថិតិអាជីវកម្មនានានៅស្រុកស្រែអំបិល ឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

ល,រ	បរិយាយ	ឆ្នាំ២០១៧	ឆ្នាំ២០១៨	ឆ្នាំ២០១៩	ចំនួនបុគ្គលិក
០១	ផ្ទះសំណាក់	០៦	០៨	០៨	២៤
	បន្ទប់	១២៥	៣៣៨	២៣៨	
០២	ភោជនីយដ្ឋាន និងអាហារដ្ឋាន	១២	១៦	១៦	៩៣
	ចំណុះ	២៩៧	៦៥២	៦៥២	
០៣	ខារ៉ាអូខេ	០៦	០៧	០៧	៧២
	បន្ទប់	២០	២៨	២៨	

តារាងប្រៀបធៀបកំណើនស្ថិតិអាជីវកម្មនានា នៅស្រុកមណ្ឌលសីមា ឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

ល,រ	បរិយាយ	ឆ្នាំ២០១៧	ឆ្នាំ២០១៨	ឆ្នាំ២០១៩	ចំនួនបុគ្គលិក
១	សណ្ឋាគារ	០១	០១	០១	៩០
	បន្ទប់	៥៤០	៥៤០	៥៤០	
២	ផ្ទះសំណាក់	០៦	០៦	០៦	១៨
	បន្ទប់	១៨	១៨	៤៤	
៣	ភោជនីយដ្ឋាន និងអាហារដ្ឋាន	២៥	២៥	២៨	៩៨៧
៤	ខារ៉ាអូខេ	០១	០២	០២	៩២
៥	បន្ទប់	០៤	២៦	២៦	
៦	ម៉ាស្សា	០	០១	០១	០៩
៧	គ្រែ	០	០៨	០៨	
៨	ដឹកជញ្ជូនផ្លូវគោក	០២	០២	០២	០៤

៩	សហគមន៍ទេសចរណ៍	០១	០១	០១	១៥
១០	ការ្វៃ	០១	០១	០១	០៥
១១	ចំណុះ	២៥	២៥	២៥	

តារាងប្រៀបធៀបកំណើនស្ថិតិអាជីវកម្មនានា នៅស្រុកកោះកុង ឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

ល,រ	បរិយាយ	ឆ្នាំ២០១៧	ឆ្នាំ២០១៨	ឆ្នាំ២០១៩	ចំនួនបុគ្គលិក
១	ផ្ទះសំណាក់	០៧	០៧	០៧	២៩
	បន្ទប់	៥២	៥២	៥២	
២	ភោជនីយដ្ឋាន និងអាហារដ្ឋាន	១៧	១៧	១៧	៥៨
	ចំណុះ	៦៣៦	៦៣៦	៦៣៦	
៣	រមណីយដ្ឋានទេសចរណ៍	០១	០២	០២	៤៨
	បន្ទប់	៥៣	៦២	៦២	
៤	សហគមន៍អេកូទេសចរណ៍	០២	០២	០២	២៣
៥	ដឹកជញ្ជូនផ្លូវទឹក	០១	០១	០១	០២
៦	សហគមន៍ទេសចរណ៍				

តារាងប្រៀបធៀបកំណើនស្ថិតិអាជីវកម្ម នានានៅស្រុកថ្មបាំង ឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

ល,រ	បរិយាយ	ឆ្នាំ២០១៧	ឆ្នាំ២០១៨	ឆ្នាំ២០១៩	ចំនួនបុគ្គលិក
១	ផ្ទះសំណាក់	០២	០២	០២	០៤
	បន្ទប់	១៨	១៨	១៨	
២	ផ្ទះស្នាក់	២៦	២៦	២៦	៦៥
	បន្ទប់	១០៧	១០៧	១០៧	
៣	ភោជនីយដ្ឋាន និងអាហារដ្ឋាន	០១	០១	០១	០៤
	ចំណុះ	៣០	៣០	៣០	
៤	សហគមន៍អេកូទេសចរណ៍	០១	០២	០២	១៩
	បន្ទប់	១២	១៦	២៨	

តារាងប្រៀបធៀបកំណើនស្ថិតិអាជីវកម្មនានា នៅស្រុកបទុមសាគរ ឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

ល,រ	បរិយាយ	ឆ្នាំ២០១៧	ឆ្នាំ២០១៨	ឆ្នាំ២០១៩	ចំនួនបុគ្គលិក
១	ផ្ទះសំណាក់	៤	៥	៥	០៩
	បន្ទប់	២៥	៥៧	៥៧	
២	ភោជនីយដ្ឋាន និងអាហារដ្ឋាន	១២	១២	១២	៣២
	ចំណុះ	៤១០	៤១០	៤១០	
៣	ខាវ៉ាអូខេ	០១	០១	០១	០៧
	បន្ទប់	០៤	០៤	០៤	
៤	កីឡាទេសចរណ៍	០	០១	០១	០៣

តារាងប្រៀបធៀបកំណើនស្ថិតិអាជីវកម្ម នៅស្រុក គីរីសាគរ ឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៩

ល,រ	បរិយាយ	ឆ្នាំ២០១៧	ឆ្នាំ២០១៨	ឆ្នាំ២០១៩	ចំនួនបុគ្គលិក
១	ផ្ទះសំណាក់	០៧	០៩	០៩	២២
	បន្ទប់	៤៥	១០៣	១០៣	

២	ភោជនីយដ្ឋាន និងអាហារដ្ឋាន	០១	០១	០១	០៤
	ចំណុះ	៣០	៣០	៣០	
៣	សណ្ឋាគារ	០១	០១	០១	៨០
	បន្ទប់	២១៥	២១៥	២១៥	
៤	ខារ៉ាអូខេ	០១	០១	០១	០៥
	បន្ទប់	០២	០២	០២	
៥	រមណីយដ្ឋាន	០១	០១	០១	៨០
	កែឡែបន្ទប់	៨២	៨២	៨២	
៦	ដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក	០១	០១	០១	០៣

១.២.១.៨ វិស័យពាណិជ្ជកម្ម

វិស័យពាណិជ្ជកម្ម បំពេញមុខងារពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មនៅថ្នាក់ក្រោមជាតិ ដូចជាការគ្រប់គ្រងអាជីវកម្ម និងអភិវឌ្ឍន៍ពាណិជ្ជកម្ម។

សកម្មភាពការងារនានា ដែលបានអនុវត្តកន្លងមករួមមាន៖

១. <u>ការងារគ្រប់គ្រងអាជីវកម្ម</u>

ក.<u>ការងារផ្តល់សេវាសាធារណៈ</u>

ការផ្តល់សេវាសាធារណៈត្រូវបានផ្តោតជាសំខាន់លើការអនុវត្តនយោបាយវិមជ្ឈការ និង វិសហមជ្ឈការដើម្បីបម្រើសំណូមពរប្រជាពលរដ្ឋ តាមរយៈការបង្កើតសេវាឲ្យនៅជិតប្រជាពលរដ្ឋ និងអនុវត្តបែបបទរដ្ឋបាល តាមយន្តការច្រកចេញ-ចូលតែមួយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការធ្វើប្រតិភូកម្មការងារពាណិជ្ជ-កម្មមួយចំនួនជូនអង្គភាពការិយាល័យ និងយន្តការច្រកចេញ-ចូលតែមួយថ្នាក់ក្រោមជាតិដូចជា៖

ក.១). ការផ្តល់លិខិតអនុញ្ញាតច្បាប់ពាណិជ្ជកម្មជូនពាណិជ្ជករ អាជីវករ សេវាករដែលមានសញ្ជាតិខ្មែរ និងដែលមិនស្ថិតនៅក្នុងការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

ក.២). ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម លោហៈធាតុត្បូងថ្ម មានតម្លៃជាគ្រឿងអលង្ការ

ក.៣). ការចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទជារូបិយប័ណ្ណបរទេសសម្រាប់ទីតាំងពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មមិនជាប់ពន្ធ (Duty Free Shop)។

លទ្ធផលកន្លងមក ខាងវិស័យនេះបានចេញលិខិតអនុញ្ញាតច្បាប់ប្រកបអាជីវកម្មបាន**ចំនួន១៥៤**នៅឆ្នាំ២០១៩

ខ.<u>ការងារចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងសុំវិញ្ញាបនបត្រប្រភពដើមទំនិញ</u>

ជាផ្នែកមួយនៃកិច្ចសម្រួលពាណិជ្ជកម្ម ដែលនឹងធ្វើឲ្យមានភាពងាយស្រួល និងមានទំនុកចិត្តក្នុងការប្រកបអាជីវកម្ម ឬកិច្ចការពាណិជ្ជកម្មរបស់ធុរជន និងអ្នកវិនិយោគ។ វិស័យនេះបានចូលរួមផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងសុំវិញ្ញាបនបត្រប្រភពដើមទំនិញ (C.O ទម្រង់D) តាមប្រព័ន្ធស្វ័យ ប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម។ ចំពោះការចុះបញ្ជីពាណិជ្ជកម្មដល់ក្រុមហ៊ុន-សហគ្រាសឯកត្តបុគ្គលសារឡើងវិញ និងចុះបញ្ជីពាណិជ្ជកម្មបើកក្រុមហ៊ុនថ្មី ឬសហគ្រាសឯកត្តបុគ្គលបើកថ្មី។ គិតត្រឹមឆ្នាំ២០១៩នេះមានក្រុមហ៊ុននិងសហគ្រាសឯកត្តបុគ្គលសរុបចំនួន ១៤៤។

គ. <u>ផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម</u>

ការផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកបញ្ជ្រាបការយល់ដឹង និងបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់របស់ពាណិជ្ជករ អាជីវករ។ ច្បាប់ដែលបានផ្សព្វផ្សាយកន្លងមករួមមាន ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងចុះបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មក្របខណ្ឌអន្តរជាតិ។ បានផ្សព្វផ្សាយ ប្រកាសផ្សេងៗរួមមាន៖ ការបិទស្លាកថ្លៃលើមុខទំនិញនិងសេវាកម្ម ការគ្រប់គ្រងលើការរៀបចំនិងចាត់ចែងពិព័រណ៍ពាណិជ្ជកម្ម ការគ្រប់គ្រងអាជីវកម្ម និងសេវាកម្ម។

<u>២. ការងារអភិវឌ្ឍន៍ពាណិជ្ជកម្ម</u>

<u>ក.អភិវឌ្ឍន៍ផលិតផល និងទីផ្សារ</u>

ការអភិវឌ្ឍន៍ផលិតផល និងទីផ្សារគឺសំដៅដល់ការនាំផលិតផលរបស់ខេត្ត ចូលរួមការតាំងពិព័រណ៌ពាណិជ្ជកម្ម ថ្នាក់ជាតិ ថ្នាក់តំបន់ និងរៀបចំការតាំងបង្ហាញផលិតផលនៅក្នុងខេត្ត ក្នុងគោលបំណងបង្ហាញផលិតផល និងសេវា ដើម្បីស្វែងរកទីផ្សារសម្រាប់ផលិតផល និងសេវាទាំងនោះ និងជួយបង្កើតឱកាសឲ្យ សហគ្រិន ពាណិជ្ជករ និងអាជីវករ អាចធ្វើការផ្លាស់ប្តូរគំនិតយោបល់ បង្ហាញផលិតផលថ្មីៗ សេវាកម្ម និងរបកគំហើញនូវទស្សនទានពាណិជ្ជកម្ម។ ផលិតផលមានសក្តានុពលក្នុងខេត្តរួមមាន៖ កាពិធម្មជាតិ បង្គាក្រៀម មឹកក្រៀម ត្រីងៀតសាំប៉ាន់ ទឹកឃ្មុំតំបន់ឆ្នេរ ប្រេងខ្លឹមចន្ទន៍គ្រឹស្នា ស្រាចេកថ្មបាំង ម្រេចអារ៉ែង សំបុកត្រចៀកកាំ ផ្លែឈើចម្រុះ ទឹកត្រីបុកកោះកុង ទឹកត្រីសុទ្ធ ផលិតផលកែច្នៃពីភោគផលសមុទ្រ ។ល។ ជាក់ស្តែង វិស័យនេះបានជំរុញ និងដឹកនាំអាជីវករ សិប្បករយកផលិតផលរបស់ខ្លួនចូលរួមការតាំងពិព័រណ៌ពាណិជ្ជកម្មថ្នាក់ជាតិ និងតំបន់ជារៀងរាល់ឆ្នាំ បានចំនួន៩លើក (៩ខែឆ្នាំ២០១៩)។ ក្រៅពីទីផ្សារក្នុងស្រុក មន្ទីរក៏បានសម្របសម្រួលបង្កើតជាជំនួបពាណិជ្ជកម្មក្នុងការពង្រីកទីផ្សារផលិតផលក្នុងខេត្តទៅកាន់ទីផ្សារក្រៅប្រទេសដូចជា ការនាំយកស្រាចេកស្រុកថ្មបាំងទៅកាន់ប្រទេសកូរ៉េ។ ផលិតផលខាងលើនេះមន្ទីរកំពុងពិនិត្យលទ្ធភាពដាក់បញ្ចូលក្នុងចលនាភូមិមួយផលិតផលមួយ និងទំនិញសម្គាល់ភូមិសាស្ត្រ (GI)។

<u>ខ.ការងារអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម និងវិស័យឯកជន</u>

ការយកចិត្តទុកដាក់ពង្រឹងកិច្ចសហការរវាងស្ថាប័នរដ្ឋ និងវិស័យឯកជនលើផ្នែកពាណិជ្ជកម្ម បានធ្វើឲ្យមានទំនុកចិត្ត និងភាពកក់ក្តៅនៃការធ្វើពាណិជ្ជកម្ម ពីសំណាក់វិនិយោគិន និងពាណិជ្ជករ អាជីវករ និងភ្នាក់ងារពាណិជ្ជកម្មទាំងអស់។ ការពង្រឹងស្ថាប័នឯកជន តាមរយៈការបង្កើតឲ្យមានសភាពាណិជ្ជកម្មខេត្ត និងសមាគមអាជីវកម្ម គឺការជំរុញឲ្យវិសាលភាពនៃការធ្វើពាណិជ្ជកម្ម និងរបៀបរបបនៃការអនុវត្តប្រតិបត្តិការពាណិជ្ជកម្មកាន់តែមានភាពប្រសើរឡើង។ មន្ទីរបានសហការរៀបចំការបង្កើត និងបោះឆ្នោតសភាពាណិជ្ជកម្មខេត្តកោះកុងចាប់តាំងពីឆ្នាំ២០០៧ រហូតដល់បច្ចុប្បន្នបានចំនួន៤លើក (សភាពាណិជ្ជកម្មខេត្តបច្ចុប្បន្នគឺអាណត្តិទី២លើកទី២)។ ហើយក៏បានសម្របសម្រួលបង្កើតសមាគមអាជីវកម្មចំនួន២ គឺសមាគមស្ត្រីផលិតស្រាបុរាណស្រុកថ្មបាំង (ស្រាចេក) និងសមាគមម្រេចអារ៉ែងស្រុកថ្មបាំង ខេត្តកោះកុង។

<u>គ.ការត្រួតពិនិត្យគុណភាពទំនិញ</u>

ការត្រួតពិនិត្យគុណភាពទំនិញ គឺសកម្មភាពការងារដែលមន្ទីរសហការជាមួយសាខាកាំកុងត្រួលខេត្ត ដើម្បីធានាឲ្យបាននូវផលិតកម្មមានលក្ខណៈច្បាស់លាស់ ទំនិញមានគុណភាព ចំណីអាហារមានសុវត្ថិភាព ការធ្វើពាណិជ្ជកម្មបានត្រឹមត្រូវ ប្រកបដោយសីលធម៌ និងគិតគូរពីប្រយោជន៍ទាំងអ្នកផលិត និងអ្នកប្រើប្រាស់។ ការសហការគ្នា បានចុះត្រួតពិនិត្យគុណភាពទំនិញ និងផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញនិងសេវា នៅតាមទីផ្សារ សាលារៀន និងហាងទំនិញ ជាគោលដៅយុទ្ធសាស្ត្រការពារអ្នកប្រើប្រាស់បាន ចំនួន១៧លើក (៩ខែឆ្នាំ២០១៩)។

ទន្ទឹមនឹងនោះដែរ វិស័យពាណិជ្ជកម្មកំពុងជួបបញ្ហាប្រឈមដូចជា៖

- អាជីវករមួយចំនួនដែលជាប់ពន្ធស្ម័យប្រកាសមិនទាន់មកចុះបញ្ជីពាណិជ្ជកម្មឲ្យបានត្រឹមត្រូវតាមគោលការណ៍ច្បាប់កំណត់ ។
- អាជីវករមួយចំនួនដែលមិនជាប់ពន្ធស្ម័យប្រកាសមិនទាន់មកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម។
- អាជីករមួយចំនួនធំ មិនសូវយកចិត្តទុកដាក់លើការបិទស្លាកថ្លៃលើមុខទំនិញរបស់ខ្លួន ។
- អាជីវករនៅមានបញ្ហាខ្វះបច្ចេកទេសកែច្នៃ វេចខ្ចប់ផលិតផល និងធនធានហិរញ្ញវត្ថុពង្រីកអាជីវកម្ម។

<u>១.២.១.៩ វិស័យពន្ធដារ</u>

ដោយយោងទៅតាមបេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ សាខាពន្ធដារខេត្តកោះកុងបានអនុវត្តការប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាព ភាពជឿទុកចិត្ត ស្របតាមក្រមសីលធម៌និងវិជ្ជាជីវៈ ការផ្តល់សេវាជូនអ្នកជាប់ពន្ធប្រកបដោយគុណភាពជាមួយនឹងការអនុវត្តច្បាប់ប្រកបដោយភាពទន់ភ្លន់ និងការបន្តពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារដោយប្រកាន់ខ្ជាប់នូវភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព។ ដោយផ្អែកតាមចំនុចខាងលើនេះ ធ្វើឱ្យសាខាពន្ធដារ

ខេត្តកោះកុងទទួលបានលទ្ធផលដូចខាងក្រោម៖

អំពីចំណូលបង់ចូលថវិកាថ្នាក់ជាតិ

- ឆ្នាំ ២០១៣ បានចំណូលចំនួន ១.២៨៨.១២៣.១១៦ រៀល ស្មើនឹង ១២១% នៃផែនការ (កំណើន ២១%)
- ឆ្នាំ ២០១៤ បានចំណូលចំនួន ១.៩៥៤.៨៦១.៤០៧ រៀល ស្មើនឹង ១២៨% នៃផែនការ (កំណើន ២៨%)
- ឆ្នាំ ២០១៥ បានចំណូលចំនួន ៣.៤១៤.៤១៨.០៤០ រៀល ស្មើនឹង ១៥១% នៃផែនការ (កំណើន៥១%)
- ឆ្នាំ ២០១៦ បានចំណូលចំនួន ៣.៤១៤.៨៧៣.០៧៤ រៀល ស្មើនឹង ១០១% នៃផែនការ (កំណើន១%)
- ឆ្នាំ ២០១៧ បានចំណូលចំនួន ៥.៦៥៩.០៨០.៣២៦ រៀល ស្មើនឹង ១៤៧% នៃផែនការ (កំណើន៤៧%)
- ឆ្នាំ ២០១៨ បានចំណូលចំនួន ៥.០២៤.២៩៤.៩១៤ រៀល ស្មើនឹង ១២១% នៃផែនការ (កំណើន២១%)
- ឆ្នាំ ២០១៩ បានចំណូលចំនួន ៨.៣០៩.១៥៥.៨៣២ រៀល ស្មើនឹង ១៨០% នៃផែនការ (កំណើន៨០%)

អំពីចំណូលបង់ចូលថវិកាថ្នាក់ក្រោមជាតិ

- ឆ្នាំ ២០១៣ បានចំណូលចំនួន ១.៧៦៣.០១៧.៥៥៩ រៀល ស្មើនឹង ១០៨% នៃផែនការ (កំណើន៨%)
- ឆ្នាំ២០១៤ បានចំណូលចំនួន ១.៩០៩.២០២.៥២២ រៀល ស្មើនឹង ៩៩% នៃផែនការ (ថយចុះ ១%)
- ឆ្នាំ២០១៥ បានចំណូលចំនួន ១.៨៧៩.៤៨១.៨៧៧ រៀល ស្មើនឹង ៩៣% នៃផែនការ (ថយចុះ ៧%)
- ឆ្នាំ២០១៦ បានចំណូលចំនួន ២.៩១១.៥៤៣.៨១០ រៀល ស្មើនឹង ១៣៩% នៃផែនការ (កំណើន៣៩%)
- ឆ្នាំ២០១៧ បានចំណូលចំនួន ៥.៧៤៦.១៣៥.៥៩០ រៀល ស្មើនឹង ២៥១% នៃផែនការ (កំណើន១៥១)
- ឆ្នាំ២០១៨ បានចំណូលចំនួន ៨.៦១១.៧១២.៩២៥ រៀល ស្មើនឹង ៣០៧% នៃផែនការ (កំណើន២០៧%)
- ឆ្នាំ២០១៩ បានចំណូលចំនួន ១១.៣២៨.១៨២.៦៨០ រៀល ស្មើនឹង ៣២០% នៃផែនការ (កំណើន២២០%)

ចំណូលបានកើនចាប់ពីឆ្នាំ ២០១៣ មកដោយសារ៖

- ការផ្សព្វផ្សាយស្តីពីវិបុលធម៌បង់ពន្ធគ្រប់ប្រភេទជូនដល់អ្នកជាប់ពន្ធ
- កែសម្រួលកម្រិតផលរបរអ្នកជាប់ពន្ធទៅជាអ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ
- ជម្រុញការចុះបញ្ជីសហគ្រាសថ្មីទៅតាមកម្រិតផលរបររបស់អ្នកជាប់ពន្ធ
- ការកែសម្រួលរបបប្រមូលពន្ធតែមួយគឺរបបស្វ័យប្រកាស (លុបចោលរបបម៉ៅការ)
- ការបញ្ចូលសហគ្រាសពីរបបម៉ៅការទៅរបបស្វ័យប្រកាស(របបពិត)
- ការជម្រុញការបង់ពន្ធប្រចាប់ត្រា ផ្ទេរកម្មសិទ្ធអចលនទ្រព្យ (មិនទាន់ចុះបញ្ជី និងចុះបញ្ជី)ឱ្យមកបង់ពន្ធ
- ការធ្វើកំណែទម្រង់ប្រព័ន្ធរដ្ឋបាលសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ
- ការពង្រឹងការអនុវត្តច្បាប់សារពើពន្ធ
- ប្រជាពលរដ្ឋមានការយល់ដឹងច្រើនពីកាតព្វកិច្ចសារពើពន្ធ និងចំនួនអ្នកស្ម័គ្រចិត្តបង់ពន្ធមានការកើនឡើង

<u>បញ្ហាប្រឈម</u>

បើទោះបីជាមានកំណែទម្រង់ប្រព័ន្ធរដ្ឋបាលសារពើពន្ធ ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការផ្សព្វផ្សាយ ដើម្បីបង្កភាពងាយស្រួលដល់អ្នកជាប់ពន្ធយ៉ាងណាក៏ដោយ ក៏សាខាពន្ធដារខេត្តកោះកុងនៅមានបញ្ហាប្រឈមមួយចំនួនដូចជា ៖

- អ្នកជាប់ពន្ធមិនទាន់យល់ច្បាស់ពីកាតព្វកិច្ចសារពើពន្ធ
- សហគ្រាសថ្មីមួយចំនួនមិនទាន់បានមកចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត
- ម្ចាស់សហគ្រាសមួយចំនួនមានការយល់ដឹងពីសេវាពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅមានកម្រិត។

១.២.១.១០ វិស័យគយ និងរដ្ឋាករ

ផ្អែកលើផែនការប្រតិបត្តិនៃផែនការសកម្មភាពឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងវិធានការនានាដើម្បីប្រមូលចំណូលអោយបានគ្រប់ និងលើសផែនការតាមទិសដៅរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

ក.អំពីការងារកៀរគរចំណូលពន្ធ និង អាករ

លទ្ធផល ឆ្នាំ ២០១៩ នេះគឺ ៖(ឯកតាគិតលានរៀល)

ចំណូលសរុបឆ្នាំ២០១៨	ចំណូលឆ្នាំ២០១៩	ប្រៀបធៀប
៨៨.១៨២.២៩៦.៨០០រ	៩៩.១១៤.៥៤៥.៨០០រ	កើនឡើង១០.៩៣២.២៤៩.០០០រ

សាខាគយ និងរដ្ឋាករខេត្តកោះកុងអាចសម្រេចប្រមូលចំណូលបានដោយមូលហេតុសំខាន់ៗដូចខាងក្រោម ៖

- ការចូលរួមសម្របសម្រួល របស់រដ្ឋបាលខេត្ត ក្នុងការរៀបចំឱ្យពាណិជ្ជកម្មឆ្លងដែននៅមាត់ច្រកចាំយាមបានល្អប្រសើរជាងមុន ។
- ការបន្តផ្សព្វផ្សាយរំលឹកជាប្រចាំដល់វិស័យឯកជនពាក់ព័ន្ធ នូវនីតិវិធីគយ បែបបទគយ នីតិវិធីនៃការដឹកទំនិញ និងកាតព្វកិច្ចបង់ពន្ធអាករនាំចេញ នាំចូលតាមច្បាប់ជាធរមាន ។
- ការនាំចូលទំនិញប្រភេទទី៣ (គ្រឿងឧបភោគ បរិភោគ) បានកើនឡើង

ខ-អំពីការងារបង្ការ និងបង្ក្រាបបទល្មើសគយ (០៩ខែដើមឆ្នាំ២០១៩)

- ដោយមានកិច្ចសហការគាំទ្រពីកងកម្លាំងប្រដាប់អាវុធនៅមូលដ្ឋាន យើងបានធ្វើប្រតិបត្តិការចំនួន ១១៧ ករណី ក្នុងនោះករណីធំ ០១ករណី, ករណីតូច ១១៦ករណី បានចំណូលគឺ ៤២០.១០៨.៤០០រៀល។

គ-ការពង្រឹងអភិបាលកិច្ចអង្គភាពគយ

- កិច្ចប្រជុំបូកសរុបការងារគយ និងរដ្ឋាករជារៀងរាល់ខែ បានដាក់ចេញនូវទិសដៅការងារមួយចំនួន ជាពិសេសការបន្តការអនុវត្តឱ្យមានប្រសិទ្ធភាពនូវផែនការប្រតិបត្តិ ទន្ទឹមគ្នានឹងផែនការសកម្មភាពឆ្នាំ២០១៩ សកម្មភាពគ្រប់គ្រងជាមុន ក្នុងការចាត់វិធានការប្រកបដោយភាពជាម្ចាស់ ។
- ថ្នាក់ដឹកនាំគយ បានបន្តចុះឃ្លាំមើលជាប្រចាំរៀងរាល់សប្តាហ៍នូវអនុលោមភាពនៃការអនុវត្តន៍នីតិវិធីគយ តាមការិយាល័យត្រួតពិនិត្យបែបបទគយក្រោមឱវាទ តាមកម្មវិធីកំណត់ដែលមានចែងក្នុងផែនការសកម្មភាព។

ឃ-អំពីសក្តានុពលអង្គភាព

- ការងារពង្រឹងការកៀរគរចំណូលឱ្យបានគ្រប់ និងលើសផែនការកំណត់
- ការងារទប់ស្កាត់ បង្ការ និងបង្ក្រាបបទល្មើសបានល្អ
- ការពង្រឹងអភិបាលកិច្ចអង្គភាពបានប្រសើរ
- កិច្ចសហការបានល្អ ប្រសើរជាមួយអាជ្ញាធរមូលដ្ឋាន
- ការសម្រួលពាណិជ្ជកម្មបានរហ័សតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ទិន្នន័យគយ AYCUDA
- ការបន្តអភិវឌ្ឍន៍ពង្រឹងមុខងារស្វ័យប្រវត្តិកម្ម ទិន្នន័យហានិភ័យគយ (CRMDS) ដើម្បីតភ្ជាប់ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយចំណុចខាងលើគឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ដើម្បីបង្កើនសក្តានុពលរបស់អង្គភាព ។

ង-បញ្ហាប្រឈម

- មាត់ច្រកចាំយាមនៅពុំទាន់បានរៀបចំឱ្យមានសណ្តាប់ធ្នាប់មានស្តង់ដាជាអន្តរជាតិ
- ពុំទាន់មានម៉ាស៊ីនស្កែន(SCAN)សម្រាប់ត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូន និងអីវ៉ាន់អ្នកដំណើរចេញចូល
- ផ្លូវជាតិលេខ ៤៨ ប្រកបដោយចំណោតភ្នំខ្ពស់ៗ ធ្វើឱ្យថ្លៃសេវាដឹកជញ្ជូនជំនិញខ្ពស់ជាងកន្លែងដទៃទៀត
- អំពើរត់ពន្ធតាមរូបភាពមធ្យម និងតូច នៅតំបន់ឆ្នេរនៅតែមាន

ច-ផែនការ (ចំពោះមុខដើម្បីបង្កើនចំណូល)

អំពីរដ្ឋបាល CUSTOMS ADMINISTRATION	**ពេលវេលា**	**អ្នកទទួលខុសត្រូវ**
ពង្រឹងអនុលោមភាព និងសង្គត្តិភាពឯកសារនាំចេញ-នាំចូល	ប្រចាំឆ្នាំ	អង្គភាពពាក់ព័ន្ធ
ពង្រឹងប្រសិទ្ធិភាព និងបង្កើនការយកចិត្តទុកដាក់លើការត្រួតពិនិត្យរូបវន្ត	ប្រចាំឆ្នាំ	អង្គភាពពាក់ព័ន្ធ

ចុះឃ្លាំមើលការអនុវត្តបទប្បញ្ញត្តិរបស់មន្ត្រីគយនៅតាមអង្គភាពមូលដ្ឋាន	ប្រចាំឆមាស	ល.ធក-អង្គភាពពាក់ព័ន្ធ
លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបច្ច័យនៃបទល្មើស	ត្រីមាសទី១-ទី៣	ន.បប-អង្គភាពពាក់ព័ន្ធ
ចុះប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើរត់គេចពន្ធទំនិញបទល្មើសពាណិជ្ជកម្ម និងបទល្មើសឆ្លងដែនពាក់ព័ន្ធដោយប្រើប្រាស់គោលការណ៍វិភាគហានិភ័យនិងព័ត៌មានសម្ងាត់	ប្រចាំឆ្នាំ	ន.បប-អង្គភាពពាក់ព័ន្ធ
ធ្វើបច្ចុប្បន្នភាពទិន្នន័យអាជីវកម្មដ្ឋានឃ្លាំងស្តុកទំនិញមានវេទយិតភាព	ប្រចាំឆ្នាំ	ន.រក-អង្គភាពពាក់ព័ន្ធ
ប្រជុំទ្វេភាគីជាមួយរដ្ឋបាលគយផ្សេងទៀត	ប្រចាំឆ្នាំ	ន.សអ-អង្គភាពពាក់ព័ន្ធ
ពង្រឹងកិច្ចសហការប្រតិបត្តិការគយទាំងក្នុងតំបន់និងពហុភាគី	ប្រចាំឆ្នាំ	ន.សអ-អង្គភាពពាក់ព័ន្ធ
បន្តការអនុវត្តយន្តការភាពជាដៃគូគយ-ផ្នែកឯកជន	ប្រចាំឆ្នាំ	ន.ផប-អង្គភាពពាក់ព័ន្ធ
ពង្រឹងប្រសិទ្ធិភាពនៃការអនុវត្តក្រមសីលធម៌និងកិរិយាមារយាទមន្ត្រីគយ	ប្រចាំឆ្នាំ	គ្រប់អង្គភាព

១.២.១.១១ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត មានតួនាទី និងភារកិច្ចដឹកនាំគ្រប់គ្រង និងសម្របសម្រួលការងារពាក់ព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងធនធានវិសាលគមន៍ហ្វ្រេកង់ស៍ វិទ្យុនៅថ្នាក់ក្រោមជាតិក្រោមការដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រី ។

វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ មានវិស័យសំខាន់ធំៗចំនួនបី គឺ ៖

- វិស័យប្រៃសណីយ៍
- ទូរគមនាគមន៍
- បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ការិយាល័យ ប្រៃសណីយ៍ និងទូរគមនាគមន៍ស្រុកចំនួន ០៣គឺ: ស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកគិរីសាគរ រីឯស្រុកមួយចំនួនទៀតមិនទាន់មានបណ្តាញការិយាល័យរបស់ខ្លួននៅឡើយទេ។ ទោះបីមិនទាន់មានបណ្តាញឱ្យបានគ្រប់ស្រុកក៏ដោយ តែសព្វថ្ងៃវិស័យទាំងបីនេះ បាននឹងកំពុងដំណើរការផ្តល់នូវសេវារបស់ខ្លួន គ្របដណ្តប់ស្ទើរទូទាំងខេត្ត និងមានគុណភាពល្អ ទាំងសេវា និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានតាមរយៈការដាក់វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសហគ្រាសសាធារណៈ។ មិនតែប៉ុណ្ណោះ យើងមានក្រុមហ៊ុនទូរស័ព្ទ ចល័ត-អចល័ត និងអ៊ិនធើណេត ចំនួន ០៩ ក្រុមហ៊ុន គឺ: Telecom Cambodia (TC), Camintel, Metfone, Cell Card, Smart, Seatel, ONLINE, Ezecom និងNTC បានពង្រឹង និងពង្រីកគុណភាពសេវា ស្របតាមស្តង់ដារអន្តរជាតិប្រកបដោយភាពប្រកួតប្រជែង និងមានតម្លៃថោក។ ដោយឡែកនៅតំបន់ដាច់ស្រយាលមួយចំនួនតូចនៃស្រុកខ្លះក្នុងខេត្ត មិនទាន់មានសេវាទូរស័ព្ទសម្រាប់ប្រើប្រាស់គ្រប់គ្រាន់នៅឡើយ ។

វឌ្ឍនភាពដែលមានលើវិស័យនេះ មានដូចខាងក្រោម៖

- បានខិតខំប្រឹងប្រែងសិក្សានៅតំបន់ដាច់ស្រយាលតាមបណ្តាស្រុកដែលគ្មានសេវា ទូរស័ព្ទប្រើប្រាស់គ្រប់គ្រាន់ ដើម្បីជម្រុញដល់ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទអោយពង្រីកសេវាបានដល់តំបន់ដាច់ស្រយាល មានការប្រើប្រាស់គ្រប់គ្រាន់ ។
- ក្រុមហ៊ុនទូរស័ព្ទ Metfone បានតម្លើងបង្គោលអង់តែន ដែលមានកម្ពស់៦៥ម៉ែត្រ ប្រើប្រាស់ដោយកាប្លិ៍អុបទិចមានសេវាទូរស័ព្ទគ្របដណ្តប់លើផ្ទៃដីទំនាបបាន ១០គីឡូម៉ែត្រ និងផ្ទៃដីខ្ពង់រាប(ភ្នំ) បាន០៥គីឡូម៉ែត្រ ដើម្បីពង្រីកសេវាទូរស័ព្ទអោយមានការប្រើប្រាស់ចំនួន០៣ឃុំ គឺ ឃុំជំនាប់ ឃុំថ្មដូនពៅ ឃុំប្រឡាយ នៃស្រុកថ្មបាំង។

ទន្ទឹមនឹងនេះក៏នៅជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា៖

- ក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍មួយចំនួននៅក្នុងខេត្ត មិនផ្តល់ទិន្នន័យការងារសាងសង់ និងរុះរើបណ្តាញរបស់ខ្លួន និងមិនបានសហការ ឬក៏ជូនដំណឹងមកមន្ទីរអោយបានជ្រាបដែលធ្វើអោយមានការពិបាកក្នុងការគ្រប់គ្រងទិន្នន័យ និងស្ថិតិប្រើប្រាស់បានច្បាស់លាស់ត្រឹមត្រូវ
- តំបន់ដាច់ស្រយាលមួយចំនួន នៅក្នុងខេត្តពុំទាន់មានសេវាទូរស័ព្ទប្រើប្រាស់គ្រប់គ្រាន់ នៅឡើយ
- ពុំទាន់មានភ្នាក់ងារប្រៃសណីយ៍ នៅគ្រប់ស្រុក ក្នុងខេត្ត ។

អាទិភាពសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខ

- បន្តត្រួតពិនិត្យ នៅតាមតំបន់ទីប្រជុំជនដាច់ស្រយាល ដែលគ្មានសេវាប្រើប្រាស់គ្រប់គ្រាន់ដើម្បីធ្វើរបាយការណ៍ជូនក្រសួង ជួយជម្រុញអោយក្រុមហ៊ុន ឬសហគ្រាសបន្តពង្រីកបណ្តាញ និងសេវារបស់ខ្លួនអោយមានវិសាលភាពគ្របដណ្តប់ដល់តំបន់ទីប្រជុំជនដាច់ស្រយាលក្នុងខេត្តមានការប្រើប្រាស់គ្រប់គ្រាន់ ។
- បន្តចុះផ្សព្វផ្សាយលិខិតលេខៈ ២៥០បទ.ប្រក ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់ព័ត៌មាន អំពីការសាងសង់ ដំឡើង និងរុះរើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅតាមភូមិសាស្ត្រខេត្តដល់បណ្តាក្រុមហ៊ុនសហគ្រាសនៅក្នុងខេត្ត ។
- បន្តផ្សព្វផ្សាយគោលនយោបាយច្បាប់ ប្រកាសរួមរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការិយាល័យ ប.ទ ស្រុកក្នុងខេត្ត នូវលិខិតលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដល់អាជីវករ ពាក់ព័ន្ធការបើកធ្វើ សេវាអាជីវកម្មប្រៃសណីយ៍ក្នុងខេត្ត ។

១.២.១.១២ វិស័យអភិវឌ្ឍន៍ជនបទ

អភិវឌ្ឍន៍ជនបទ គឺជាសកម្មភាពប្រទាក់ក្រឡាចម្រុះ និងអន្តរវិស័យ សំដៅកែប្រែជនបទ និងស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច របស់ប្រជាពលរដ្ឋនៅទីជនបទឲ្យមានភាពប្រសើរឡើង។ អភិវឌ្ឍន៍ជនបទ គឺសំដៅធ្វើយ៉ាងណាឲ្យទីជនបទក្លាយជាទីកន្លែងដែលមានប្រជាពលរដ្ឋរស់នៅ និងអាចទាញយកនូវផលចំណេញពីសក្តានុពលសេដ្ឋកិច្ច សង្គម ពេញបរិបូរណ៍។ ខេត្តបានសម្រេចយកវិធីសាស្ត្រ ដែលមានមុខព្រួញច្រើនដើម្បីជំរុញការអភិវឌ្ឍជនបទ និងផ្តល់សិទ្ធអំណាចដល់សហគមន៍មូលដ្ឋានក្នុងការរៀបចំផែនការ និងគ្រប់គ្រងការអភិវឌ្ឍមូលដ្ឋានរបស់ពួកគាត់។ នៅក្នុងចន្លោះពីឆ្នាំ ២០១៥-២០១៩ ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទសម្រេចបានលទ្ធផលដូចជា: ថែទាំផ្លូវជាលក្ខណៈខួបបានប្រវែង ៩៥.៥៥០ម៉ែត្រថែទាំផ្លូវជាលក្ខណៈប្រចាំបានប្រវែង ២១២.២០០ម៉ែត្រ សាងសង់អណ្តូងស្នប់បានចំនួន ៣៦អណ្តូង សាងសង់អណ្តូងលូបានចំនួន ៥៩អណ្តូង ជួសជុលអណ្តូងស្នប់បានចំនួន ៣៤ អណ្តូង ជួសជុលអណ្តូងលូបានចំនួន ២០៧អណ្តូង ផ្តល់សម្ភារសាងសង់បង្គន់អនាម័យបានចំនួន ៧០០សម្រាប់ និងផ្តល់ឥណទានជូនប្រជាពលរដ្ឋបានចំនួន២.៥៣០គ្រួសារ។ សមិទ្ធផលខាងលើបានជួយសម្រួលឲ្យមានសកម្មភាពសេដ្ឋកិច្ចមមាញឹកជាងមុនហើយថែមទាំងចូលរួមលើកស្ទួយកម្រិតជីវភាពប្រជាជន នៅជនបទទៀតផង។

ទន្ទឹងនឹងការអនុវត្តន៍ទទួលបានលទ្ធផលខាងលើ យើងក៏មានជួបការលំបាកមួយចំនួនដូចជាថវិកាដែលបានផ្តល់សម្រាប់ការថែទាំ ឬស្តារផ្លូវជនបទប្រចាំឆ្នាំមានចំនួនតិចតួចបើធៀបនឹងប្រវែងផ្លូវដែលមាននៅក្នុងខេត្ត ជាពិសេសផ្លូវដែលរងការខូចខាតដោយទឹកជំនន់ក្នុងឆ្នាំ២០១៩។ ការដឹកលើសទម្ងន់នៅលើផ្លូវជនបទក៏ជាបញ្ហាចោទ។

រដ្ឋបាលខេត្ត បានជំរុញ និងចាត់វិធានការអាទិភាពសំខាន់ៗមួយចំនួនដូចជា ការជួសជុល ថែទាំផ្លូវនៅជនបទ ការជីកស្រះ និងជីកអណ្តូងបន្ថែម សម្រាប់បង្ការទុកប្រើប្រាស់ក្នុងពេលមានគ្រោះរាំងស្ងួត និងធានាមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ និងការផ្តល់សម្ភារបង្គន់អនាម័យជូនប្រជាពលរដ្ឋ។

១.២.១.១៣ វិស័យធនាគារជាតិ

បច្ចុប្បន្ននៅខេត្តកោះកុង មានសាខាធនាគារពាណិជ្ជចំនួន០៥កំពុងប្រតិបត្តិការផ្តល់សេវាធនាគារនិងហិរញ្ញវត្ថុ រួមមាន សេវាប្រាក់បញ្ញើ សេវាឥណទាន សេវាផ្ទេរប្រាក់ សេវាប្តូរប្រាក់ និងសេវាធានារ៉ាប់រង ដល់ប្រជាពលរដ្ឋក្នុងការរក្សាទ្រព្យសម្បត្តិ ការពង្រីកអាជីវកម្ម ការពង្រីក និងកែលម្អលំនៅដ្ឋាន និងសម្រួលដល់ការទូទាត់របស់ប្រជាពលរដ្ឋ

កាន់តែឆាប់រហ័ស និងសន្សំសំចៃពេលវេលា។ ហើយធនាគារពាណិជ្ជបានដើរតួយ៉ាងសំខាន់ក្នុងការជួយសម្រួល និងផ្តល់ភាពងាយស្រួលដល់ការបើកប្រាក់បៀវត្សរបស់កម្មករ កម្មការិនី បុគ្គលិកក្រុមហ៊ុន អង្គការ និងមន្ត្រីរាជការនៅក្នុងខេត្ត តាមរយៈម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ (ATM) ។ ចំពោះធនាគារពាណិជ្ជមានម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិចំនួន ១៣ និងម៉ាស៊ីនដាក់ប្រាក់ចំនួន ៤ សម្រាប់បម្រើដល់សេវាដក ដាក់ប្រាក់ និងសេវាទូទាត់ផ្សេងៗ ។

ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ ក៏មានការរីកចម្រើនទាំងទំហំ និងដែនសេវាកម្មរបស់ខ្លួនផងដែរ ដែលបានរួមចំណែកក្នុងការជំរុញកំណើនជីវភាព និងកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋ តាមរយៈការបំពេញតម្រូវការហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ ដែលមិនទាន់មានលទ្ធភាពទទួលបានសេវាពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។ ជាក់ស្តែងនៅខេត្តកោះកុង មានសាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ០៨ និងប្រតិបត្តិករឥណទានចំនួន ០១ កំពុងធ្វើប្រតិបត្តិការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងសេវាធានារ៉ាប់រងខ្នាតតូច ក្នុងនោះមានសាខាគ្រឹះស្ថានមីក្រូហិញ្ញវត្ថុចំនួន០៣ ត្រូវបានអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើ និងដាក់ឱ្យដំណើរការម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិចំនួន០៣ ដើម្បីបំពេញតម្រូវការសាច់ប្រាក់របស់ប្រជាពលរដ្ឋ ។

តាមរយៈនៃការរីកចម្រើននេះ ប្រជាពលរដ្ឋមានលទ្ធភាពខ្ពស់ក្នុងការទទួលបានសេវាធនាគារ និងហិរញ្ញវត្ថុមួយប្រកបដោយគុណភាព និងស្ថិតក្នុងតម្លៃប្រកួតប្រជែង ដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យបានល្អប្រសើរ។ ទោះជាមានរីកចម្រើនយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា៖

- ប្រជាពលរដ្ឋនៅមិនទាន់យល់ដឹងពីការប្រើប្រាស់ និងអត្ថប្រយោជន៍ដែលទទួលបានសេវាធនាគារ និងមីក្រូហិរញ្ញវត្ថុ និងយល់ច្រលំពីការប្រើប្រាស់សេវារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឯកជន ថាជារបស់រដ្ឋ
- ប្រជាពលរដ្ឋនៅមិនទាន់យល់ដឹង និងមានជំនឿលើការប្រើប្រាស់ប្រាក់រៀល ។ ប្រជាពលរដ្ឋភាគច្រើននិយមប្រើប្រាស់រូបិយប័ណ្ណបរទេស (ដុល្លារអាមេរិក និងប្រាក់បាតថៃ) ក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន (ឯកតាតម្លៃ សន្សំ និងការទូទាត់) និង
- អាជីវករប្តូរប្រាក់នៅមិនទាន់យល់ពីច្បាប់ និងបទបញ្ជាត្តិផ្សេងៗក្នុងការគ្រប់គ្រងអាជីវកម្មប្តូរប្រាក់ ដែលតម្រូវត្រូវឲ្យយកចិត្តទុកដាក់ដោះស្រាយ និងរៀបចំផែនការអភិវឌ្ឍន៍ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ និងស៊ីជម្រៅ ដើម្បីជៀសវាងកើតមានហានិភ័យផ្សេងៗប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងខេត្ត ។

១.២.១.១៤ វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

វិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ជាអង្គភាពរដ្ឋបាលសេដ្ឋកិច្ច បំពេញមុខងារជាតំណាងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារសម្របសម្រួលអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួង ព្រមទាំងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានចែងស្របតាមប្រកាសលេខ ៩៥៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ វិស័យនេះបានអនុវត្តបំពេញតួនាទីភារកិច្ចរបស់ខ្លួនយ៉ាងសកម្មប្រកបដោយប្រសិទ្ធភាព និងភាពរស់រវើកជាសេនាធិការឱ្យក្រសួង និងអាជ្ញាធរដែនដី ដែលជាអាណាប័កផ្ទៃរសិទ្ធិបានពង្រឹងនិងអនុវត្តច្បាប់ផ្សព្វផ្សាយរាល់សារាចរណែនាំផ្សេងៗរបស់ក្រសួង ឬរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដល់អង្គភាព មន្ទីរ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានជ្រាបច្បាស់ដើម្បីរួមចំណែកក្នុងការអនុវត្តន៍ឱ្យបានត្រឹមត្រូវតាមនីតិវិធីបទដ្ឋានបច្ចេកទេស ។

ក្នុងន័យនេះដើម្បីចូលរួមចំណែក សម្រេចគោលបំណងគោលនយោបាយ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាខ្សែបណ្តោយរបស់ខ្លួន ការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត មានអ្នកទទួលខុសត្រូវនិងអ្នកគ្រប់គ្រង លើចង្កោមសកម្មភាព និងសកម្មភាព ឱ្យស្របតាមអនុកម្មវិធី កម្មវិធី និងគោលបំណងគោលនយោបាយ របស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

វឌ្ឍនភាពដែលសម្រេចបាននាពេលកន្លងមកធៀបសូចនាករដែលបានកំណត់

- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០១៩ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០ ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០ ដល់មន្ទីរជំនាញ ក្រុង-ស្រុក បានទាន់ពេលវេលាដូចដែលបានកំណត់ក្នុងសូចនាករ
- ការផ្តល់សន្យាចំណាយ ការផ្តល់ទិដ្ឋាការចំណាយលើសំណើសុំចំណាយថវិកា របស់មន្ទីរជំនាញ រដ្ឋបាលក្រុង-ស្រុក បានត្រឹមត្រូវ គ្មានការកកស្ទះ និងទាន់ពេលវេលាដូចដែលបានកំណត់ក្នុងសូចនាករ
- ការរៀបចំបូកសរុបកម្មវិធីចំណូល-ចំណាយថវិកាប្រចាំត្រីមាស របស់មន្ទីរជំនាញ មានភាពត្រឹមត្រូវ និងទាន់ពេលវេលាដូចដែលបានកំណត់ក្នុងសូចនាករ
- បានរៀបចំធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិកើនឡើង-ថយចុះប្រចាំឆ្នាំ របស់មន្ទីរជំនាញ រដ្ឋបាលក្រុង-ស្រុក បានត្រឹមត្រូវ និងទាន់ពេលវេលាតាមផែនការសកម្មភាពដូចដែលបានកំណត់ក្នុងសូចនាករ
- បានធ្វើការរៀបចំគម្រោងដេញថ្លៃភាស៊ីគ្រប់ប្រភេទប្រចាំឆ្នាំ២០១៩ បានត្រឹមត្រូវ និងទាន់ពេលវេលា តាមផែនការសកម្មភាពដូចបានកំណត់ក្នុងសូចនាករ
- បានធ្វើការចុះត្រួតពិនិត្យ ការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកការគ្រប់គ្រងប្រមូលចំណូលភាស៊ីប្រចាំឆ្នាំ ២០១៩ បានគ្រប់ផែនការ និងទាន់ពេលវេលាតាមដូចដែលបានកំណត់ក្នុងសូចនាករ
- បានធ្វើការជម្រះបញ្ជីសារពើភណ្ឌដែលបានស្នើឡើងដោយបណ្តាមន្ទីរជំនាញ រដ្ឋបាលក្រុង-ស្រុក បានត្រឹមត្រូវនិងទាន់ពេលវេលាដូចដែលបានកំណត់ក្នុងសូចនាករ
- បានរៀបចំកិច្ចប្រជុំតាមដានវឌ្ឍនភាពការងាររបស់អង្គភាពបានត្រឹមត្រូវ និងទាន់ពេលវេលា ទៅតាមប្រតិទិនការងារដែលបានកំណត់ក្នុងសូចនាករ
- បានធ្វើការបំពាក់ឧបករណ៍បរិក្ខារបច្ចេកទេសក្នុងអង្គភាពបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដូចដែលបានកំណត់ក្នុងផែនការថវិកាប្រចាំឆ្នាំ និងសូចនាករ
- បានធ្វើការជម្រុញការអនុវត្តប្រកាសអន្តរក្រសួង ស្តីពីការផ្តល់សេវាសាធារណៈរបស់បណ្តាមន្ទីរជំនាញ និងការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ប៉ុន្តែការងារនេះលទ្ធផល ការងារមិនបានឆ្លើយតបទៅនឹងសូចនាករដែលបានកំណត់ទេ។

បញ្ហាប្រឈមដែលកើតមានឡើងចំពោះវិស័យនេះ៖

- សមត្ថភាព និងបទពិសោធការងារមន្ត្រីរបស់មន្ទីរជុំវិញខេត្ត មានកម្រិតនៅឡើយ ក្នុងការរៀបចំធ្វើផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំគម្រោងចំណូល-ចំណាយថវិកាប្រចាំឆ្នាំ តាមសកម្មភាពក្នុងការិយាល័យនីមួយៗរបស់ខ្លួនមិនទាន់បាន ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ស្របតាមមុខងារ តួនាទី និងភារកិច្ច
- កិច្ចសហការនៃការអនុវត្តថវិកាជាមួយអាណាប័ករដ្ឋបាលថ្នាក់ក្រោមជាតិ អភិបាលក្រុង-ស្រុក នៅមានកម្រិត មិនទាន់បានល្អប្រសើរនៅឡើយ
- កញ្ចប់ថវិកាចំណាយរដ្ឋបាល និងកញ្ចប់ថវិកាសម្រាប់ការអភិវឌ្ឍន៍របស់សាលាក្រុង-ស្រុក មានកម្រិតទាបនៅឡើយ
- មានការលំបាកសម្រាប់មន្ទីរ អង្គភាពមួយចំនួន ដែលធ្វើតារាងប្រៀបធៀបការកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋ ប្រចាំឆ្នាំ ត្រូវបញ្ជូនឱ្យក្រសួងសាមីពិនិត្យសម្រេចជាមុនសិន ទើបបញ្ជូនមកគណៈកម្មការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ខេត្ត ពិនិត្យនិងសម្រេចជាក្រោយធ្វើឱ្យមានភាពយឺតយ៉ាវមិនទាន់ពេលវេលា
- មន្ទីរអង្គភាព-ក្រុងស្រុកមួយចំនួន មានតែតួលេខកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ប៉ុន្តែទ្រព្យសម្បត្តិរដ្ឋជាក់ស្តែងគ្មាន
- មន្ទីរជុំវិញខេត្ត កង្វះខាតមន្ត្រីដែលមានសមត្ថភាពជំនាញ សម្រាប់អនុវត្តការត្រួតពិនិត្យ វាយតម្លៃ និងរៀបចំរបាយការណ៍សមិទ្ធកម្ម។

បញ្ហាប្រឈមដែលត្រូវដោះស្រាយចំពោះមុខមានដូចខាងក្រោម៖

- ពង្រឹងតួនាទី ភារកិច្ចរបស់មន្ទីរឱ្យកាន់តែប្រសើរ
- ពង្រឹងនិងពង្រីកសមត្ថភាពមន្ត្រីរាជការ
- ពង្រឹងការគ្រប់គ្រងចំណូល និងជម្រុញការបង់ចំណូលមិនមែនសារពើពន្ធ
- ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការគ្រប់គ្រងប្រព័ន្ធ FMIS និងប្រព័ន្ធ NRMIS
- ពង្រឹងការគ្រប់គ្រងចំណាយថវិកាជាតិ ចំទិសដៅ និងសន្សំសំចៃ
- ពង្រឹងការវិភាជន៍ ការផ្ទេរ និងការប្រើប្រាស់ធនធានមូលនិធិក្រុងស្រុក
- បង្កើនសមត្ថភាពគ្រប់គ្រង និងអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅខេត្តកោះកុង
- គាំទ្រនិងសម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅខេត្តកោះកុង ។

១.២.១.១៥ ការវិនិយោគ

ក.ការវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស

ក១. ក្រុមហ៊ុន ដែលបានវិនិយោគទៅលើវិស័យដំណាំកសិកម្ម-ឧស្សាហកម្ម និងដំណាំ កៅស៊ូ រួមមាន៖

- ក្រុមហ៊ុន លឹម លុង ខូអិលធីឌី (LIM LONG Co.Ltd) ស្ថិតនៅឃុំដងពែង ស្រុកស្រែអំបិល
- ក្រុមហ៊ុន អិល វាយ ភី គ្រុប (L.Y.P Group Co.Ltd) ស្ថិតនៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- ក្រុមហ៊ុន CAMAGRA INVESTMENT GROUP Co.Ltd ឃុំដងពែង ស្រុកស្រែអំបិល
- ក្រុមហ៊ុន GREEN RICH GROUP Co.Ltd ស្ថិតនៅឃុំជ្រោយប្រស់ ស្រុកកោះកុង
- ក្រុមហ៊ុន KOH KONG SUGAR INDUSTRY COMPANY LIMITED ស្ថិតនៅក្នុងស្រុកស្រែអំបិល
- ក្រុមហ៊ុន KOH KONG PLANTATION COMPANY LIMITED ស្ថិតនៅឃុំកណ្តោល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ឃុំជីផាត ស្រុកថ្មបាំង និងឃុំជីខលើ ដងពែង ស្រុកស្រែអំបិល
- ក្រុមហ៊ុនស៊ីណូម៉ិចស៊ីមអ៊ិនវេសមិន(SINOMEIMINVESTMENTCo.Ltd)ឃុំអណ្តូងទឹកស្រុកបូទុមសាគរ
- ក្រុមហ៊ុន កោះកុង អេស អ៊ី ហ្សិត (KOH KONG SEZ Co.Ltd) នៅឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ

ក២.ក្រុមហ៊ុនដែលកិច្ចសន្យាជាមួយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជាវិនិយោគទៅលើវិស័យទេសចរណ៍មាន៖

- ក្រុមហ៊ុន UNION DEVELOPMENT GROUP Co.Ltd ស្ថិតនៅស្រុកបូទុមសាគរ និងគិរីសាគរ
- ក្រុមហ៊ុន JW CAMBODIA ECO HOLIDAY ស្ថិតនៅក្នុងស្រុកកោះកុង និងស្រុកគិរីសាគរ
- ក្រុមហ៊ុន BEST TRANSPORT AND SERVICES Co.Ltd ស្ថិតនៅកោះពុតសារកណ្តាល ឃុំត្នីមាស ក្នុងស្រុកគិរីសាគរ
- ក្រុមហ៊ុន FULL MOON ISLAND Co.Ltd ស្ថិតនៅប្រជុំកោះអំពិល ក្នុងស្រុកគិរីសាគរ
- ក្រុមហ៊ុន GILLGANS ISLAND Co.Ltd ស្ថិតនៅកោះសាមិត ឬកោះខ្មោច ក្នុងស្រុកគិរីសាគរ
- ក្រុមហ៊ុន KOH SMACH ISLAND RESORT DEVELOPMENTS Co.Ltd ស្ថិតនៅកោះស្មាច់ ក្នុងស្រុកគិរីសាគរ
- ក្រុមហ៊ុន SHORELINE (CAMBODIA) INVESTMENT Co.Ltd នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- ក្រុមហ៊ុន COAST DEVELOPMENT GROUP Co.Ltd ស្ថិតនៅកោះម្នាស់ ប៉ែកខាងជើង កោះដំឡូងក្នុង និងកោះដំឡូងក្រៅ ក្នុងស្រុកគិរីសាគរ
- ក្រុមហ៊ុន PINEAPPLE DEVELOPMENT GROUP Co.Ltd ស្ថិតនៅកោះម្នាស់ប៉ែកខាងត្បូង និងកោះតាទឹម ក្នុងស្រុកគិរីសាគរ
- ក្រុមហ៊ុន DIRACE INVESTMENT LIMITED ស្ថិតនៅកោះទទឹង ក្នុងស្រុកគិរីសាគរ

ខ.ការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស

តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងខេត្តកោះកុងដែលបានបង្កើតឡើងមានចំនួន៤ទីតាំង ៖

- តំបន់សេដ្ឋកិច្ចពិសេសនាងកុកកោះកុង ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង របស់ក្រុមហ៊ុនអិលវ៉ាយភីគ្រុប(LYP)។ បច្ចុប្បន្នមានរោងចក្រចំនួន ០៦រោងចក្រ ដែលកំពុងតែដំណើរការ មានបុគ្គលិកកម្មករដែលកំពុងបម្រើការងារមានចំនួន១១.៦៤៧នាក់ក្នុងនោះមានស្ត្រីចំនួន៧.៧៦៣នាក់
- តំបន់សេដ្ឋកិច្ចពិសេស កែវ ស៊ូយឆេង ស្ថិតនៅជាប់តំបន់សេដ្ឋកិច្ចពិសេសនាងកុក ខេត្តកោះកុង ក្នុងភូមិសាស្ត្រ ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង នៅមិនទាន់មានសកម្មភាពអ្វីឡើយ
- តំបន់សេដ្ឋកិច្ចពិសេសគិរីសាគរស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ខេត្តកោះកុង បានដំណើរការរៀបចំហេដ្ឋារចនាសម្ព័ន្ធខ្លះៗនៅឡើយ
- តំបន់សេដ្ឋកិច្ចពិសេសជ្រោយស្វាយ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិនេសាទ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង របស់ក្រុមហ៊ុនឆកកំពង់សោម ដែលបច្ចុប្បន្នកំពុងតែស្ថាបនាផ្លូវចូល អគាររោងចក្រ អគារស្នាក់នៅរបស់បុគ្គលិក...។ល។

១.២.១.១៦ ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

ខេត្តកោះកុងបន្តអនុវត្តកិច្ចព្រមព្រៀងស្តីពីការឆ្លងកាត់ព្រំដែនរវាងកម្ពុជា និងថៃ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៥។ ក្នុងស្មារតីនេះ ខេត្តកោះកុងបានសហការជាមួយស្ថាប័នពាក់ព័ន្ធនៅក្រៅប្រទេស និងប្រទេសម្ចាស់ផ្ទះ ដើម្បីជួយសង្គ្រោះ អន្តរាគមន៍ និងធ្វើមាតុភូមិនិវត្តន៍ប្រជាពលរដ្ឋខ្មែរ ជាពិសេសពលករខ្មែរដែលរងគ្រោះ។ ខេត្តបាននឹងកំពុងធ្វើការទំនាក់ទំនង និងបន្តកិច្ចសហប្រតិបត្តិការជាមួយខេត្តត្រាត ប្រទេសថៃ ក្នុងការបង្កើនបរិយាកាសកក់ក្តៅសម្រាប់ការធ្វើអាជីវកម្មរបស់ប្រជាពលរដ្ឋ រវាងប្រទេសទាំងពីរ ។

បន្ថែមលើសនេះទៀតខេត្តកោះកុងបានពង្រីកទំនាក់ទំនងរបស់ខ្លួនជាមួយខេត្តកាម៉ៅ និងគៀនយ៉ាង នៃប្រទេសវៀតណាម និងខេត្តជីលីន ខេត្តយូណាន នៃប្រទេសចិន។ នេះជាកាលានុវត្តភាពការងារថ្មីមួយទៀតដល់ប្រជាពលរដ្ឋ ជាពិសេសផលនេសាទដែលបច្ចុប្បន្ននេះប្រមូលផ្តុំនូវផលិតផលនេសាទសមុទ្រស្រស់ពុំទាន់កែច្នៃយកទៅលក់នៅទីផ្សារនៅប្រទេសថៃ។ ការវិនិយោគរបស់វិស័យឯកជនទាំងក្នុងស្រុក និងក្រៅស្រុក គឺជាកម្លាំងជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ។ រដ្ឋបាលខេត្តបានយកចិត្តទុកដាក់ជាខ្លាំងក្នុងការពង្រឹង និងពង្រីកភាពជាដៃគូក្នុងការអភិវឌ្ឍន៍ជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេសលើវិស័យឯកជន និងសង្គមស៊ីវិល ។

១.២.២ ផ្នែកសង្គមកិច្ច

១.២.២.១ វិស័យអប់រំ យុវជន និងកីឡា

វិស័យអប់រំគឺជាវិស័យអាទិភាពមួយសម្រាប់ស្តារ និងអភិវឌ្ឍធនធានមនុស្ស។ ជាមួយនឹងគោលនយោបាយដ៏ត្រឹមត្រូវ របស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្របតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា ក្រសួងអប់រំយុវជន និងកីឡា ក៏បានរៀបចំខ្លួនយ៉ាងយកចិត្តទុកដាក់បំផុតនូវគោលនយោបាយធំៗចំនួន២ និងបានរៀបចំកំណែទម្រង់លើក៨ចំណុចក្នុងឆ្នាំ២០១៤ និង១៥ចំណុចពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។ វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសជាតិ ទាំងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ កុមារ យុវជន និងមនុស្សពេញវ័យត្រូវបានទទួលការសិក្សា និងការអប់រំពេញមួយជីវិត ដែលមានភាពពាក់ព័ន្ធ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារប្រកបដោយគុណភាពខ្ពស់ និងបរិយាប័ន្នដោយបានកំណត់នូវចក្ខុវិស័យឆ្នាំ២០៣០ ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ ជាប្រទេសអភិវឌ្ឍន៍ ។

ក.១. អនុវិស័យអប់រំកុមារតូច

អនុវិស័យអប់រំកុមារតូច បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជួយកុមារអភិវឌ្ឍផ្នែកទាំង៥ គឺ (១)ការអភិវឌ្ឍផ្នែករាងកាយ និងសុខភាព។ (២)ការអភិឌ្ឍសីលធម៌ និងវប្បធម៌។ (៣)អភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍។ (៤)ការយល់

ដឹង និងការពិចារណា។ (៥)ការអភិវឌ្ឍភាសាដើម្បីពួកគេមានមូលដ្ឋានគ្រឹះរឹងមាំមុនឈានចូលរៀននៅថ្នាក់ទី១នៃសាលាបឋមសិក្សាដែលបច្ចុប្បន្នបាននឹងកំពុងពង្រីកវិសាលភាពធ្វើឡើងតាមរយៈសេវាទាំង៤គឺ៖ មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាឯកជន មត្តេយ្យសិក្សាសហគមន៍ កម្មវិធីអប់រំកុមារតូចតាមផ្ទះ ឬអប់រំមាតាបិតា សេវាអប់រំកុមារតូចបានបង្កើតការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំស្តង់ដាអប្បបរមា សាលា ថ្នាក់ និងសូចនាករដែលបានកំណត់ដើម្បីឆ្លើយតបទៅតម្រូវការបំណិន និងការអភិវឌ្ឍរបស់កុមារ។

តារាងផលធៀបសាលា .ថ្នាក់ . បុគ្គលិក. កុមារគ្រប់កម្មវិធី

បរិយាយ	២០១៧ -២០១៨	២០១៨ -២០១៩	កើន,ថយ(+/-)
១/មត្តេយ្យសិក្សារដ្ឋ			
សាលា	៦២	៦៥	+៣
ថ្នាក់	៧៨	៨៣	+៥
បុគ្គលិក	៨០	៨៤	+៤
ចំនួនកុមារ	២០៨២/១០៤០	២០៧៦/១០១៥	-៦
២/មត្តេយ្យឯកជន			
សាលា	១១	១១	
ថ្នាក់	២២	៣៩	+១៧
បុគ្គលិក	៤៥	៣៩	-៦
ចំនួនកុមារ	៩៥៣/៤៨១	១២៧០/៦០៨	+៣១៧
៣/មត្តេយ្យសិក្សាសហគមន៍			
មណ្ឌល/កន្លែង	១៩	១៤	-៥
ថ្នាក់	១៩	១៤	-៥
បុគ្គលិក	១៩	១៤	-៥
ចំនួនកុមារ	៣២៤/១៥៩	២៧៦/១៣៦	-៤៨
៤/កម្មវិធីអប់រំកុមារតូចតាមផ្ទះ			
ភូមិ	៦១	៥៨	-៣
ឃុំ	២២	២១	-១
ម្តាយបង្គោល	៦១	៥៨	-៣
ប្រធានក្រុមម្តាយ	២៩៧	២៨៥	-១២
សមាជិកម្តាយ	១២៤៧	១១៩៩	-៤៨
ចំនួនកុមារកម្មវិធីអប់រំតាមផ្ទះ	១១៦០/៥៤៧	១២១៩/៥៣៣	+៥៩

ក.២. អនុវិស័យបឋមសិក្សា

ក្នុងឆ្នាំសិក្សាកន្លងមកវិស័យអប់រំ យុវជន និងកីឡាខេត្ត ក៏ដូចជាសាលាបឋមសិក្សានៅតាមក្រុង-ស្រុកទាំង៧បាន និងកំពុងបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំដោយផ្អែកតាមកម្មវិធីសាលាកុមារមេត្រីដែលមានការចូលរួមគាំទ្រពីអង្គការដៃគូរនានា ដើម្បីលើកកម្ពស់គុណភាពអប់រំស្របទៅតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនាឆ្នាំ២០១៦-២០៣០ ។

ក្នុងឆ្នាំសិក្សា ២០១៨-២០១៩ យើងមានគ្រឹះស្ថានបឋមសិក្សារដ្ឋចំនួន១២១កន្លែង ក្នុងនោះសាលារៀនគ្រប់កម្រិត ៩១សាលានិង សាលារៀនមិនគ្រប់កម្រិត (ឧបសម្ព័ន្ធ) ចំនួន២៦កន្លែង មានថ្នាក់រៀនចំនួន ៨០១ថ្នាក់ បន្ទប់រៀនចំនួន ៦៨៧បន្ទប់(ថ្ម ៥៣៣បន្ទប់ និងឈើ ១១៤បន្ទប់) សិស្សសរុបចំនួន ១៦,៧២៥នាក់ ស្រី ៨,០៥៣នាក់ បុគ្គលិកសរុប ៧២១នាក់ ស្រី ៣៨៦នាក់ ក្នុងនោះបុគ្គលិកបង្រៀនចំនួន ៥៨៥នាក់ ស្រី ២៩៥នាក់ បុគ្គលិកមិនបង្រៀន៩៦នាក់ ស្រី ១៧នាក់ គ្រូជាប់កិច្ចសន្យា ៤០នាក់ ស្រី ១៧នាក់ គ្រូបង្រៀនពីរពេល ៩៨នាក់ ស្រី ៣០នាក់ គ្រូបង្រៀនថ្នាក់គួប ១៣៥នាក់ ស្រី ៤៩នាក់ ។

សូចនាករសំខាន់ៗ៖

- អត្រាពិតចូលរៀនថ្មី ៧០.៩០% ស្រី ៧៣.៦០%
- អត្ររួមចូលរៀនថ្មី ៩១.៦០% ស្រី ៩១.៧០%
- អត្រាពិតនៃការសិក្សា ៦៤.៧០% ស្រី ៦៥.២០%
- អត្ររួមនៃការសិក្សា ៨០.៧០% ស្រី ៨០.២០%
- អត្រាឡើងថ្នាក់ ៨៩.៨០% ស្រី ៩០.៣០%
- អត្រាត្រួតថ្នាក់ ៣.៧០% ស្រី ២.៩០%
- អត្រាបោះបង់ ៦.៥០% ស្រី ៦.៨០%
- អត្រាឆ្លងភូមិសិក្សាទៅបឋមភូមិ ៩២.៥០% ស្រី ៩២.៣០%
- អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា៦៤.៦៩% ស្រី ៦៦.២២%
- ផលធៀបសិស្ស-ថ្នាក់ ៣៣.៤០
- ផលធៀបសិស្ស-គ្រូ ១៨.១០

អនុវិស័យអប់រំមធ្យមសិក្សា

ឆ្នាំសិក្សា ២០១៨-២០១៩ ខេត្តកោះកុងមានសាលាមធ្យមសិក្សាចំនួន៣១សាលា ក្នុងនោះ អនុវិទ្យាល័យចំនួន ១៩សាលា វិទ្យាល័យចំនួន ១២សាលា ។ ថ្នាក់រៀនបឋមភូមិ (ទី៧ ដល់ទី៩) ចំនួន ១៣៣ថ្នាក់ បន្ទប់រៀនចំនួន ១៣៧ បន្ទប់ សិស្សសរុបចំនួន ៤៨៧៣នាក់ ស្រីចំនួន ២៤៨៧នាក់ កើនចំនួន ៣៨៧នាក់ ស្រីចំនួន ២១១ នាក់ បុគ្គលិកបម្រើការនៅបឋមភូមិចំនួន ១៤៥នាក់ ស្រីចំនួន ៣៨នាក់ ក្នុងនោះបុគ្គលិកមិនបង្រៀនចំនួន ២៩នាក់ ស្រីចំនួន ០១នាក់ ។សាលាឯកជនបឋមភូមិ មាន៧ថ្នាក់ សិស្សសរុប ៣០១នាក់ ស្រី ១២០នាក់ ។ ថ្នាក់រៀនទុតិយភូមិ (ទី១០ ដល់ទី១២) ចំនួន៥៩ ថ្នាក់ បន្ទប់រៀនចំនួន ៥៥បន្ទប់ សិស្សសរុបចំនួន ២៥២២នាក់ ស្រី ១២០៥នាក់ កើនចំនួន ៩៦នាក់ ស្រី ៧១ នាក់ មានបុគ្គលិកសរុបចំនួន ១៣៩ ស្រី៣៨នាក់ បុគ្គលិកសរុប ចំនួន ១៨៨នាក់ ស្រី៥១នាក់ក្នុងនោះបុគ្គលិកមិនបង្រៀន ១៨នាក់ ស្រី ០២នាក់ ។ មានសាលាឯកជនទុតិយភូមិ ចំនួន ១សាលា មាន៣ថ្នាក់ សិស្សសរុបចំនួន ៣៨នាក់ ស្រីចំនួន ១៦នាក់ ។

លទ្ធផលផ្នែកបឋមភូមិ ដែលទទួលបានក្នុងឆ្នាំកន្លងមក៖

- អត្រាឡើងថ្នាក់ ៧៩% ស្រី ៨០% កើន ៣% ស្រី ៧%
- អត្រាត្រួតថ្នាក់ ៤% ស្រី ៥% ថយ ១% ស្រី ២%
- អត្រាបោះបង់ការសិក្សា ៧% ស្រី ៥% ថយ ៣% ស្រី ៤%
- អត្រាបញ្ចប់ការសិក្សា ៧៦% ស្រី ៧០% កើន ១០% ស្រី ៥%
- អត្រាឆ្លងភូមិសិក្សា ៧០% ស្រី ៧៦% កើន ៣% ស្រី ៧%
- អត្រាពិតនៃការសិក្សា ៣៤% ស្រី ៤២% កើន ៣% ស្រី ២%
- អត្ររួមនៃការសិក្សា ៦៩% ស្រី ៥៥% កើន ៦% ស្រី ៣%

- ភាគរយសិស្សប្រឡងជាប់ ៩១% ស្រី ៩៤% កើន ៤.៣% ស្រី ៧%
- ចំនួនសិស្សថ្នាក់ទី៩ ប្រឡងជាប់ ១១៣៧នាក់ ស្រី ៥៩៩នាក់។

លទ្ធផលផ្នែកទុតិយភូមិ ដែលទទួលបានក្នុងឆ្នាំកន្លងមក៖

- អត្រាឡើងថ្នាក់ ៨៣% ស្រី ៨៤% កើន ៥% ស្រីកើន៩%
- អត្រាត្រួតថ្នាក់ ៣% ស្រី ២% ថយ ២% ស្រី ២%
- អត្រាបោះបង់ការសិក្សា ១៥% ស្រី ៨ % ថយ ២% ស្រី ៤%
- អត្រាបញ្ចប់ការសិក្សា ៧៥% ស្រី ៧៣% កើន ៦% ស្រី ១%
- អត្រាពិតនៃការសិក្សា ៣៥% ស្រី ៣១% កើន ៧% ស្រី ២%
- អត្ររួមនៃការសិក្សា ៧៥% ស្រី ៦៤% កើន១១% ស្រី ១%
- ភាគរយសិស្សប្រឡងជាប់ ៤២% ស្រី ៣៩% កើន ៨% ស្រី ៩%
- ចំនួនសិស្សថ្នាក់ទី១២ប្រឡងជាប់ ២២៤នាក់ ស្រី ១១៣នាក់ ។

ក្នុងឆ្នាំថ្មីនេះ យើងមានសិស្សអាហារូបករណ៍ថវិកាកម្មវិធី PB 1.4 ចំនួន ១៥សាលា សិស្ស ចំនួន ១.៤៧០នាក់ ស្រី ៨៨២នាក់ និងសិស្សអាហារូបករណ៍ឧត្តមសិក្សា ៧សាលា សិស្ស ៣៧នាក់ ស្រី ២៣នាក់ ។

អនុវិស័យអប់រំក្រៅប្រព័ន្ធ

១	អត្រាអក្ខរកម្មមនុស្សពេញវ័យអាយុពី ១៥ ដល់៤៥ ឆ្នាំ	៤.៣៤%
២	ភាគរយប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម	៦.២១%
៣	ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ	១០៩
៤	ភាគរយសិស្សបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនចូលរៀនឡើងវិញ	១០០%
៥	ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូលបឋមសិក្សា	២៧៤
៦	រៀបចំបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ	៨៥%
៧	ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍	០៨

- កម្មវិធីអក្ខរកម្មវិជ្ជាជីវៈបានដំណើរការចំនួន ២០ថ្នាក់អនុវត្តដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ប្រើប្រាស់ថវិកា តាមកម្មវិធីដែលមានសិស្សចូលរៀន ៣៧០ នាក់ ស្រី ២២០នាក់ និងសិស្សបានបញ្ចប់ មាន ២៨០នាក់ ស្រី ១៧២នាក់
- កម្មវិធីក្រោយអក្ខរៈមានមណ្ឌលអាន ចំនួន ៥កន្លែង និងបណ្ណាល័យ ១កន្លែង មិនមានការកើនឡើងសម្រាប់ឆ្នាំនេះ
- កម្មវិធីមជ្ឈមណ្ឌលសិក្សាសហគមន៍យើងទទួលបានសិស្សចូលរៀនសរុបចំនួន ១៣៤នាក់ ស្រីចំនួន ៩០ នាក់ និងបានបញ្ចប់វគ្គដោយជោគជ័យ ចំនួន ១០៩នាក់ស្រី ៨៤នាក់ ដែលសិក្សាលើមុខវិជ្ជា ចិញ្ចឹមខ្យង ចំពុះទា ធ្វើលបត្តាម ភ្លេងពិណពាទ្យ ភ្លេងប្រពៃណី ជួសជុលម៉ាស៊ីនបោកគក់ ទូទឹកកក និងកែសម្ផស្ស
- កម្មវិធីសមមូលបឋមសិក្សាដំណើរការបានចំនួន ០៦ស្រុកគឺ ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកថ្មបាំង ស្រុកកោះកុង ស្រុកស្រែអំបិល និងស្រុកថ្មបាំង មានចំនួន ១៤ថ្នាក់ សិស្សសរុបចំនួន ១៦៣នាក់ ស្រី ៦៥នាក់ បានបញ្ចប់ចំនួន ១៣៩នាក់ស្រី ៥៨នាក់
- កម្មវិធីថ្នាក់បំពេញវិជ្ជាដំណើរការបានតែចំពោះថ្នាក់ទុតិយភូមិ មានចំនួន ០២ថ្នាក់ សិស្សសរុប ៧៥នាក់ ស្រី ២៥នាក់ ជាលទ្ធផលប្រឡងជាប់ចំនួន ៣៣នាក់ ស្រី ១៥នាក់ ស្វែរនចូលរៀន ៤២នាក់ ស្រី ១៨ នាក់ លទ្ធផលប្រឡងជាប់ ២២នាក់ ស្រី ១០នាក់
- កម្មវិធីចូលរៀនឡើងវិញដំណើរការទាំង៦ ក្រុង/ស្រុក មានសិស្សសរុបចំនួន ១៦៧នាក់ ស្រី ៨៨នាក់ ជាលទ្ធផលបញ្ចប់បាន ១៦៧នាក់ ស្រី ៨៨នាក់ ។

ក.៣. អនុវិស័យ យុវជន

- បានជ្រើសរើសយុវជនស្ម័គ្រចិត្តចូលរួមកម្មវិធីប្រកួតប្រជែងស្មាដៃយុវជន ផ្នែកកសិកម្មបែបបច្ចេកទេសថ្នាក់ជាតិ នៅរាជធានីភ្នំពេញ
- បានដឹកនាំយុវជនកាយរឹទ្ធិចូលរួមបោះជំរំកាយរឹទ្ធិរៀមច្បងថ្នាក់ជាតិលើកទី១នៅរមណីយដ្ឋានបឹងសំរិទ្ធខេត្ត កំពង់ធំ
- បើកវគ្គសិក្ខាសាលាបំប៉នស្តីពី ការពង្រឹងក្រុមប្រឹក្សាយុវជន និងកុមារកម្ពុជានៅវិទ្យាល័យកោះកុង ក្រុងខេមរភូមិន្ទ
- បើកវគ្គបណ្តុះបណ្តាលស្តីពី ការយល់ដឹងលើជម្ងឺអេដស៍ និងកាមរោគដល់យុវជន ៣លើក នៅវិទ្យាល័យកោះកុង វិទ្យាល័យចាំយម ក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា
- បានរៀបចំឱ្យមានក្រុមយុវជនកាកបាទក្រហមខេត្ត ក្រុមយុវជនស្ម័គ្រចិត្ត "ក១២"
- បានសហការរៀបចំឱ្យមានក្រុមយុវជនកាកបាទក្រហមខេត្ត ក្រុមយុវជនកាយរឹទ្ធ ក្រុមយុវជនស្ម័គ្រចិត្ត "ក១២" ក្រុមយុវជន១៥៧
- បានរៀបចំទីតាំងបម្រុងសម្រាប់សាងសង់អគារមជ្ឈមណ្ឌលយុវជនខេត្តរួចរាល់
- ចុះបំផុសការងារស្ម័គ្រចិត្តនៅតាមសាលាបានចំនួន ៣លើក នៅស្រុកបូទុមសាគរ គិរីសាគរ និងស្រុកស្រែអំបិល
- បានរៀបចំក្រុមប្រឹក្សាកុមារទូទាំងខេត្តបានចំនួន ១៥៣ក្រុម មាន៥១៩សាខា និង៣២១៤អនុសាខា មានសមាជិកសរុបចំនួន ១២.៥៧៧នាក់ ស្រីចំនួន ៦.២៧៦នាក់ ស្ថិតនៅតាមគ្រឹះស្ថានសិក្សាបឋមសិក្សា និងអនុវិទ្យាល័យ
- បានរៀបចំក្រុមប្រឹក្សាយុវជនទូទាំងខេត្តបានចំនួន ១០ក្រុម មាន៥៩សាខា និង៣៥៤អនុសាខា មានសមាជិកសរុបចំនួន ២.៥១២នាក់ ស្រីចំនួន ១.២២១នាក់ ស្ថិតនៅតាមគ្រឹះស្ថានសិក្សាវិទ្យាល័យ
- ចុះពិនិត្យតាមដានលើការដំណើរការក្រុមប្រឹក្សាយុវជន និងកុមារកម្ពុជាបាន២លើក នៅស្រុកបូទុមសាគរ គិរីសាគរ

ក.៤. អនុវិស័យ អប់រំកាយ និងកីឡា

- ខេត្តបានរៀបចំឱ្យមានការប្រកួតជ្រើសរើសជើងឯកទូទាំងខេត្ត នូវវិញ្ញាសា កីឡាបាល់ទាត់បុរស-នារី កីឡាបាល់ទះបុរស-នារី កីឡាអត្តពលកម្មសម្រាប់សិស្សបឋម និងមធ្យមសិក្សា
- ចងក្រងក្រុមកីឡាមាន ៖ ក្រុមកីឡាបាល់ទាត់ចំនួន ២៥ក្រុម កីឡាបាលទះចំនួន ៣០ក្រុម កីឡាបាល់បោះ ចំនួន ០១ក្រុម និងកីឡាអត្តពលកម្មចំនួន ៦ក្រុម
- បានខិតខំបង្កើនទីលានកីឡា៖ ទីលានបាល់ទាត់ចំនួន ៤១កន្លែង ទីលានបាល់ទះចំនួន ៥៤កន្លែង ទីលានបាល់បោះចំនួន ០៥កន្លែង ទីលានលោតកំពស់ចំនួន ៤៤កន្លែង ទីលានលោតចម្ងាយចំនួន ៤៨កន្លែង ទីលានរត់ល្បឿនចំនួន ៣០កន្លែង និងទីលានចោលដុំដែកចំនួន ១៩កន្លែង

បញ្ហាប្រឈមដែលកើតមានឡើងចំពោះវិស័យអប់រំយុវជននិងកីឡានេះមានដូចតទៅ៖

- **អនុវិស័យអប់រំកុមារតូច**

ការចូលរៀនរបស់កុមារតូចមានវឌ្ឍនភាពវិជ្ជមាន ប៉ុន្តែនៅមានបញ្ហាប្រឈមមួយចំនួនដូចជា កង្វះអាហារូបត្ថម្ភនៅតំបន់ដាច់ស្រយាល ការសម្របសម្រួលស្តាប់បែបពហុវិស័យ កង្វះគ្រូមត្តេយ្យសិក្សា និងហេដ្ឋារចនាសម្ព័នមត្តេយ្យសិក្សារដ្ឋ គុណភាពមត្តេយ្យសិក្សាសហគមន៍មិនទាន់ឆ្លើយតបស្តង់ដាគុណភាព និរន្តរភាព និងគុណភាពនៃកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះ។

- **អនុវិស័យអប់រំនៅបឋមសិក្សា**

ការរក្សាសិស្សឱ្យនៅគង់វង្ស និងបញ្ចប់ការសិក្សា ចាំបាច់ត្រូវធ្វើការកែលម្អ ជាពិសេស ក្រុមកុមារជួបការលំបាក ក្រុមកុមារបាត់បង់ឱកាស។ការចូលរៀននៅបឋមសិក្សាមានកម្រិតខ្ពស់ តែសមាមាត្រកុមារដែលទទួលបានបំណិនជាមូដ្ឋានក្នុងការអាន ការសរសេរ និងការគិត នៅមានគម្លាតនៅឡើយ។

- **អនុវិស័យអប់រំនៅមធ្យមសិក្សា**

ការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិនៅមានកម្រិតខ្ពស់នៅឡើយ។វិធីសាស្ត្របង្រៀនត្រូវពង្រឹងបន្ថែម។គ្រឹះស្ថានមធ្យមសិក្សាភាគច្រើនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស រោងជាង បណ្តាញទឹក អគ្គិសនី និងបង្គន់អនាម័យ ស្របតាមកម្មវិធីសិក្សា។

- **អនុវិស័យអប់រំក្រៅប្រព័ន្ធ**
  + ចំនួនអនក្ខរជននៅមានច្រើន ប៉ុន្តែការផ្តល់ចំនួនគ្រូជាប់កិច្ចសន្យាតិច
  + មជ្ឈមណ្ឌលសិក្សាសហគមន៍នៅមានចំនួនតិច មិនគ្រប់តាមតម្រូវការមូលដ្ឋាន
  + កិច្ចសហការរបស់អាជ្ញាធរក្នុងការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធនៅមានកម្រិត
  + ការផ្តល់ព័ត៌មានពីមូលដ្ឋាននៅមិនទាន់សុក្រិតនៅឡើយ ។

កម្មវិធីអាទិភាពក្នុងវិស័យអប់រំ យុវជន និងកីឡាខេត្តសម្រាប់ឆ្នាំ២០២០-២០២៤

កម្មវិធីពង្រីកការគាំពារ និងអប់រំកុមារតូច៖ ជាមូលដ្ឋានសម្រាប់ការសិក្សានៅភូមិសិក្សាបន្ទាប់ទៀតដោយផ្តល់នូវការអប់រំសុខភាព បំណិន និងចំណេះដឹង ដើម្បីចូលរួមការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈការបង្កើនការចូលរៀនឱ្យបាន ៥៩ភាគរយនៃការអប់រំកុមារតូច នៅតាមសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសិក្សាឯកជន សាលាមត្តេយ្យសិក្សាសហគមន៍ ។

កម្មវិធីអភិវឌ្ឍ និងសាងសង់សាលារៀន ៖ ធានាថាកុមារទាំងអស់បានចូលរៀននៅបឋមសិក្សា និងចូលរៀនកាន់តែច្រើនឡើងនៅមធ្យមសិក្សា តាមរយៈការសាងសង់សាលារៀន(ជាពិសេស ការពង្រីកសាលាបឋមសិក្សាទៅជាអនុវិទ្យាល័យ ឱ្យបានច្រើនតាមឃុំ ស្របតាមកំណើនសិស្ស) ការបណ្តុះបណ្តាលគ្រូបង្រៀននៅវិទ្យាស្ថានគរុកោសល្យ ការផ្គត់ផ្គង់គ្រូ ការផ្តល់សៀវភៅសិក្សាគោល និងបរិក្ខារបណ្ណាល័យ ការបំប៉ននាយកសាលារៀន បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បន្ទប់សិក្សាភាសាបរទេស រោងជាង និងទីលានកីឡា។

កម្មវិធីអភិវឌ្ឍប្រព័ន្ធធានាគុណភាពអប់រំ និងគុណភាពសាលារៀន ៖ សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ការអភិវឌ្ឍក្របខ័ណ្ឌគុណភាព និងឧបករណ៍ ការអភិវឌ្ឍសមត្ថភាពក្នុងការជួយសាលារៀន និងគ្រូបង្រៀន ដើម្បីសម្រេចបានស្តង់ដារគុណភាព និងភាពឆ្លើយតបតាមរយៈការអភិវឌ្ឍកម្មវិធីសិក្សាឱ្យមានភាពឆ្លើយតប សម្ភារៈសិក្សាគ្រប់គ្រាន់ និងការបង្រៀនប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ស្របតាមសម័យកាលអប់រំតាមបែបDigital

កម្មវិធីពង្រឹងប្រព័ន្ធវាយតម្លៃទទួលសិក្សារបស់សិស្ស ៖ ពង្រឹងការធ្វើតេស្តថ្នាក់រៀនជាប្រចាំ និងតេស្តវាយតម្លៃប្រចាំឆ្នាំ ការកែទម្រង់ការប្រឡងថ្នាក់ជាតិ និងការត្រៀមខ្លួនចូលរួមក្នុងកម្មវិធីវាយតម្លៃការសិក្សារបស់សិស្ស តាមរយៈការស្ទង់ពិន្ទុសិស្សតាមកម្រិតថ្នាក់តាមមុខវិជ្ជា និងតាមប្រព័ន្ធTABLETនៅតាមក្រុង/ស្រុក។

កម្មវិធីអាហារូបករណ៍ ៖ ពង្រីកវិសាលភាពដល់បឋមសិក្សានិងមធ្យមសិក្សា និងផ្តោតលើការកំណត់ក្រុមគោលដៅ ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី។

កម្មវិធីគ្រប់គ្រង និងវាយតម្លៃការបំពេញការងាររបស់បុគ្គលិក ៖ បង្កើនគុណភាពនៃការបង្រៀន ការវាយតម្លៃ ការសរសើរ ការលើកទឹកចិត្ត និងការអភិវឌ្ឍវិជ្ជាជីវៈ ។

កម្មវិធីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល ៖កសាង អភិវឌ្ឍសមត្ថភាព និងផ្លាស់ប្តូររបៀបរបបការងារដើម្បី

អនុវត្តការកសាងផែនការ ការរៀបចំថវិកា និងប្រព័ន្ធពិនិត្យតាមដានផ្អែកលើលទ្ធផលនៅថ្នាក់មូលដ្ឋាន។

កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងហិរញ្ញប្បទានសហប្រតិបត្តិការ ៖ អភិវឌ្ឍសមត្ថភាពក្នុងការរៀបចំ និងការអនុវត្តថវិកា ការធ្វើវិមជ្ឈការការងារថវិកាដល់សាលារៀន ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុ និងការពង្រឹងភាពជាម្ចាស់នៃការអនុវត្តរបស់ដៃគូក្នុងប្រព័ន្ធអប់រំ។

កម្មវិធីអក្ខរកម្ម និងរៀនពេញមួយជីវិត ៖ អនុវត្តកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ និងកំណត់យន្តការច្បាស់លាស់សម្រាប់អនុវត្តកម្មវិធីអក្ខរកម្ម និងរៀនពេញមួយជីវិត ដើម្បីបង្កើតធនធានមនុស្សដែលអាចសម្របខ្លួន និងទទួលបានអត្ថប្រយោជន៍ពីឱកាសនានាក្នុងបរិបទសង្គមវប្បធម៌ និងបរិស្ថានសេដ្ឋកិច្ចស្របតាមគោលដៅអភិវឌ្ឍន៍ជាតិឆ្នាំ២០៣០។

កម្មវិធីសម្របសម្រួលក្នុងវិស័យ និងអន្តរវិស័យ ៖ បង្កើតយន្តការប្រតិបត្តិដែលស្អិតរមួត និងរលូនសម្រាប់អនុវិស័យទាំងអស់ ដូចនេះមន្ទីរអប់រំបានបង្កើតក្រុមបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ខេត្ត ដែលមានគណៈអភិបាលនៃអភិបាលខេត្តជាប្រធាន និងប្រធានអង្គភាពជុំវិញខេត្តជាអនុប្រធាន និងជាសមាជិក ។

បញ្ហាឆ្លងវិស័យ ៖ មន្ទីរនឹងបន្តដោះស្រាយបញ្ហាឆ្លងវិស័យនានាដូចជា ១/យេនឌ័រ ដោយផ្តោតសំខាន់លើការអប់រំនៅគ្រប់កម្រិតសិក្សា ជាពិសេសការផ្តល់អាហារូបករណ៍ និងការអភិវឌ្ឍសមត្ថភាពមន្ត្រីជានារី ២/ការកាត់បន្ថយគ្រោះមហន្តរាយ ៣/ការថែរក្សាបរិស្ថានតាមរយៈការធានាថារាល់បញ្ហាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីសិក្សា និង៤/ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈសហការជិតស្និទ្ធជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ៥/សុខភាពសិក្សាផ្តោតទៅលើការផ្តល់ថ្នាំព្រូន និងសាងសង់បង្គន់អនាម័យសម្រាប់សិស្សានុសិស្ស ។

សូចនាករស្នូល

សូចនាករស្នូល	ស្ថានភាពបច្ចុប្បន្ន ២០១៩	ចំណុចដៅ ២០២៣
គោលនយោបាយទី ១ ៖ ***ជានាការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា***		
ភាគរយកុមារអាយុ៥ឆ្នាំ ក្នុងការអប់រំកុមារតូចគ្រប់រូបភាព	៣៦%	៥៩%
ភាគរយកុមារអាយុ៤ឆ្នាំ ក្នុងការអប់រំកុមារតូចគ្រប់រូបភាព	៣៧%	៤៧%
ភាគរយកុមារអាយុ៣ឆ្នាំ ក្នុងការអប់រំកុមារតូចគ្រប់រូបភាព	២០%	៣៤%
អត្រាពិតចូលរៀនថ្មីថ្នាក់ទី១	៧០.៩០%	៩៥%
អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា	៥៩.៦៣%	៦៥%
អត្រាឡើងថ្នាក់	៨៨.៤១%	៩៦%
ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិត ៨០%	០១	០៧
អត្រាឡើងថ្នាក់នៅបឋមភូមិ (ទី៧ ដល់ទី៩)	៨៤.៦២%	៩៥.០%
អត្រាបញ្ចប់ការសិក្សានៅបឋមភូមិ(ថ្នាក់ទី៩)	៣៤.៣%	៤០%
អត្រាឆ្លងភូមិសិក្សា ទៅ ទុតិយភូមិ (ទី៩ ទៅ ទី១០)	៧០.៦០%	៨០%
ភាគរយប្រឡងជាប់(បឋមភូមិ)	៩១.៩៧%	១០០%
អត្រាឡើងថ្នាក់នៅទុតិយភូមិ (ទី១០ ដល់ទី១២)	៧៤.៧២%	៩០%

សូចនាករស្នូល	ស្ថានភាព បច្ចុប្បន្ន ២០១៩	ចំណុចដៅ ២០២៣
អត្រាបញ្ចប់ការសិក្សានៅទុតិយភូមិ(ថ្នាក់ទី១២)	១៧.៨៦%	៣0%
ភាគរយប្រឡងជាប់(ទុតិយភូមិ)	៤0.៨៩%	៧៥%
អត្រាអក្ខរកម្មយុវជន (អាយុ ១៥-២៤)	៨0,៨0%	៩0,0%
អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥-៤៥)	៨១,៧៧%	៩0,0%
ការវាយតម្លៃថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី ៣ ទី ៦ និងទី ៨ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា	៩៥.៣៦%	១00%
អភិវឌ្ឍទីលានកីឡដ្ឋានខេត្ត មានគ្រប់វិញ្ញាសាកីឡា(កន្លែង)	០១	០៣
គោលនយោបាយទី២ ៖ *ជានាភាពសក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*		
ភាគរយការទូទាត់ចំណាយថវិកាកម្មវិធី	៩២.៥៧%	១00%
ចំនួនគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ	២៦៩	៣៣៥
ចំនួនគ្រូបង្រៀនបឋមភូមិមានសញ្ញាបត្របរិញ្ញាបត្រ	២៦	៦0
ចំនួនគ្រូបង្រៀនទុតិយភូមិមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់	០៧	១៥

វឌ្ឍនភាពចំពោះវិស័យអប់រំមានដូចខាងក្រោម៖

ការងារអប់រំ យុវជន និងកីឡាខេត្តកោះកុង មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ដោយមានប្រធានមន្ទីរ០១រូប មានអនុប្រធានមន្ទីរចំនួន០៣រូប ការិយាល័យជំនាញចំណុះមន្ទីរចំនួន ០៩ការិយាល័យ ការិយាល័យអប់រំ យុវជន និងកីឡាក្រុងចំនួន០១ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុកចំនួន០៦។ មានសាលាមត្តេយ្យសិក្សារដ្ឋចំនួន ៦៥ កន្លែង សាលាបឋមសិក្សា ១២១កន្លែង អនុវិទ្យាល័យ១៩កន្លែង និងវិទ្យាល័យ១២កន្លែង។

វិស័យនេះ មានយន្តការការងារច្បាស់លាស់ដោយបានរៀបចំជាប្រព័ន្ធតាមអនុវិស័យ និងការិយាល័យគាំទ្រតាមជំនាញដូចជា ផ្នែករដ្ឋបាល បុគ្គលិក បណ្តុះបណ្តាល អធិការកិច្ច ផែនការ គណនេយ្យជាដើម។យ៉ាងណាមុិញមន្ទីរអប់រំ យុវជន និងកីឡា បានទទួលនូវការវិភាជន៍ថវិការដ្ឋពីរាជរដ្ឋាភិបាលនូវកញ្ចប់ថវិកាកម្មវិធី និងបានអនុវត្តយ៉ាងម៉ឺងម៉ាត់គោរពតាមគោលការណ៍ និងច្បាប់ហិរញ្ញវត្ថុបានយ៉ាងប្រសើរ។ជាមួយគ្នានេះ មន្ទីរបានរៀបចំពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារនិមួយៗពីមួយឆ្នាំទៅមួយឆ្នាំ តាមរៈវគ្គបំប៉ងសមត្ថភាពពីថ្នាក់ក្រសួង អង្គការដៃគូ គម្រោងមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព (Capacity Development Plan Fund)។ នៅក្នុងការប្រមូលកុមារចូលរៀន មន្ទីរអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការដៃគូ សហគមន៍ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពង្រីកតំបន់ទទួលសេវាអប់រំ ទាំងការអប់រំចំណេះទូទៅ និងការអប់រំក្រៅប្រព័ន្ធទៅកាន់តំបន់ដាច់ស្រយាល តំបន់ជួបការលំបាក ទីជនបទ ហើយបានខិតខំគៀរគ សប្បុរសជន ក្នុងការសាង់សង់អគារសិក្សា តាមស្ថានភាពដែលអាចដោះស្រាយបានចំពោះបញ្ហាចម្បងៗ និងបានផ្តល់គ្រូទៅកាន់តំបន់ទាំងនោះ តាមរយៈគ្រូចេញថ្មី និងការជ្រើសរើសគ្រូកិច្ចសន្យានៅនឹងមូលដ្ឋាន។ចំពោះការអប់រំនៅមធ្យមសិក្សា យើងបានពង្រីកពីសាលាបឋមសិក្សាគ្រប់កម្រិត ឱ្យមានថ្នាក់រៀនមធ្យមសិក្សា បង្កើតជាអនុវិទ្យាល័យ និងពង្រីកពីអនុវិទ្យាល័យ ទៅជាវិទ្យាល័យ នៅតាមតំបន់ទីប្រជុំជនដែលមានស្ថេរភាពពិតប្រាកដ។ការអភិវឌ្ឍយុជន ការអប់រំកាយ និងកីឡា មន្ទីរបានរៀបចំឱ្យមាននូវក្រុមយុវជនកាយឫទ្ធិជាតិកម្ពុជាតាំងពីថ្នាក់អនុវិទ្យាល័យដល់វិទ្យាល័យ យុវជនកាកបាទក្រហម ក្រុមយុវជនសហភាពសហព័ន្ធយុវជនកម្ពុជា(សសយក) នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនានា

ក្នុងខេត្ត ដើម្បីចូលរួមជួយក្នុងសកម្មភាពថែរក្សាអនាម័យ បរិស្ថាន ការការពារសុខសុវត្ថិភាពសង្គម កាត់បន្ថយសកម្មភាពអវិជ្ជមានបងធំបងតូច ញៀនថ្នាំ ។ល។រីឯការអប់រំកាយ និងកីឡា មន្ទីរបានរៀបចំឱ្យមានគ្រប់បណ្តាក្រុងស្រុក និងសាលារៀន ដោយតែងតែបានចាត់តាំងឱ្យមានការប្រកួតប្រជែងថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិជាបន្តបន្ទាប់។

ចំណុចខ្សោយ/បញ្ហាប្រឈម

ស្ថិតក្នុងដំណាក់កាលកំពុងអនុវត្តកំណែទម្រង់ការអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង ក៏នៅមានបញ្ហាមួយចំនួនដែលមិនទាន់បានគ្រប់ជ្រុងជ្រោយដូចជា៖

- ការប្រមូលកុមារគ្រប់អាយុ ៧០-៧២ខែឱ្យចូលរៀនមិនទាន់បានអស់១០០%
- កុមារលើសអាយុចូលរៀននៅបឋមសិក្សា នៅមានច្រើន
- សិស្សបោះបង់នៅមានច្រើន
- គុណភាព និងប្រសិទ្ធិភាពនៃការអប់រំ មិនទាន់ឆ្លើយតបទៅនឹងចំណុចដៅរបស់ផែនការ
- លទ្ធផលសិស្សប្រឡងនៅមធ្យមសិក្សាទុតិយភូមិមិនទាន់ដល់ចំណុចដៅរបស់ផែនការអប់រំ
- ការផ្តល់គ្រូដល់តំបន់ដាច់ស្រយាលមិនទាន់បានគ្រប់គ្រាន់តាមតម្រូវការ
- ខ្វះការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ

អាទិភាពសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខ

ដើម្បីឆ្លើយតបទៅនឹងចំណុចដៅរបស់ផែនការដែលបានកំណត់ មន្ទីរអប់រំ យុវជន និងកីឡា បានរៀបចំយន្តការការងារដើម្បីដោះស្រាយបញ្ហាអាទិភាពមួយចំនួន៖

- ពង្រឹងសកម្មភាពផ្សព្វផ្សាយ ធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន និងណែនាំដល់សហគមន៍ អាណាព្យាបាល មាតាបិតា និងអ្នកពាក់ព័ន្ធ ក្នុងការប្រមូលកុមារក្នុងភូមិឱ្យចូលរៀន បានត្រឹមត្រូវតាមប្រភេទអាយុនៃភូមិសិក្សានិមួយៗ
- បន្តបង្កើតឱ្យមានថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សារដ្ឋ
- ពង្រីកសេវាការអប់រំតាមខ្នងផ្ទះ និងការទទួលខុសត្រូវ
- ផ្សព្វផ្សាយ ណែនាំអំពីសារៈសំខាន់នៃការអប់រំ ជូនដល់គ្រប់អ្នកពាក់ព័ន្ធក្នុងការទប់ស្កាត់ការបោះបង់ការសិក្សា និងការចូលរួមថែរក្សាការពារសាលារៀន
- ពង្រឹងការគ្រប់គ្រងរដ្ឋបាល បុគ្គលិក ជូនដល់ នាយកសាលា
- ពង្រឹងការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលា
- ពង្រឹងប្រសិទ្ធិភាពនៃការរៀបចំផែនការអប់រំ ឱ្យឆ្លើយតបទៅនឹងគោលដៅអប់រំជាតិឆ្នាំ២០៣០។

១.២.២.២ វិស័យសុខាភិបាល

វិស័យសុខាភិបាលខេត្ត បាននឹងកំពុងខិតខំយកចិត្តទុកដាក់ធ្វើឱ្យប្រសើរឡើងនូវសុខមាលភាព និង សុខភាពរបស់ប្រជាជន ក្រោមរូបភាពផ្តល់លទ្ធភាពទទួលបាននូវសេវាសុខភាពប្រកបដោយគុណភាព និងសមធម៌ ដើម្បីកែលម្អស្ថានភាពសុខភាព និង សុខមាលភាពប្រជាពលរដ្ឋគ្រប់រូប ផ្តោតលើស្ត្រី កុមារ-ជនក្រីក្រ ជនងាយរងគ្រោះ និង ជនចាស់ជរា តាមរយៈពង្រីកការគ្របដណ្តប់ នៃសេវាអប់រំសុខភាព ពិនិត្យ-ព្យាបាល-ថែទាំ-គាំទ្រ និង ដោះស្រាយនូវបញ្ហាប្រឈមស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល ឆ្នាំ២០១៩-២០២១ ដើម្បីឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលបានកំណត់ដោយរាជរដ្ឋាភិបាល ដូចខាងក្រោម៖

- កំណត់អាទិភាព រៀបចំផែនការ និងយុទ្ធសាស្ត្រសំរាប់អនុវត្តន៍គោលនយោបាយជាតិ និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលសំដៅលើកកម្ពស់សុខភាពនិងសុខមាលភាពរបស់ប្រជាពលរដ្ឋនៅក្នុងខេត្ត
- ពង្រីកវិសាលភាព នៃមូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីឱ្យការផ្តល់សេវា បានកៀកនឹងប្រជាជន ។ពិសេសប្រជាជន ដែលរស់ក្នុងតំបន់ដាច់ស្រយាល និងងាយរងគ្រោះ

- ពង្រាយ និងបែងចែកធនធានមនុស្ស ដែលក្រសួងសុខាភិបាលបានផ្តល់ជូន គិតទៅតាមទីតាំងភូមិសាស្ត្រ និងចំនួនប្រជាជន ដោយគោរពទៅតាមស្តង់ដារបុគ្គលិក តាម CPAនិង MPA
- បែងចែកធនធានសំភារៈឱសថ បរិក្ខារពេទ្យ ដែលក្រសួងសុខាភិបាលបានផ្តល់ជូន គិតទៅតាមតម្រូវការជាក់ស្តែង នៅតាមមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព
- សិក្សារកមធ្យោបាយនានាសំរាប់អភិវឌ្ឍន៏វិស័យសុខាភិបាលក្នុងខេត្ត និងគ្រប់គ្រងបណ្តាធនធាន បុគ្គលិក ទ្រព្យសម្បត្តិរដ្ឋ សំភារ ឱសថ បរិក្ខារ ថវិកា និងព័ត៌មានអោយសមស្របទៅនឹងប្រព័ន្ធសុខាភិបាលសាធារណៈរបស់ក្រសួងសុខភិបាល
- ធានាគុណភាពសេវាសុខាភិបាលសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយយកចិត្តទុកដាក់ និងពង្រឹងត្រួតពិនិត្យច្បាប់ទៅគ្រប់បណ្តាសេវាឯកជនទូទាំងខេត្ត
- អនុវត្តន៍ការតាមដាន ត្រួតពិនិត្យ និងវាយតំលៃការងាររដ្ឋបាល បច្ចេកទេស និងនិតិក្រមវេជ្ជសាស្ត្ររបស់ការិយាល័យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងបណ្តាការិយាល័យទាំងបួនដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរសុខាភិបាលខេត្ត ស្របតាមច្បាប់ លិខិតបទដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា និងប្រកាស សេចក្តីណែនាំ របស់ក្រសួងសុខាភិបាល
- អនុវត្តការចុះពង្រឹងលើការងារបច្ចេកទេសឆ្មប ពិសេសកាត់បន្ថយឲ្យបានជាអតិបរិមានូវមរណៈភាពមាតា-ទារក និងកុមារ
- អនុវត្តការចុះពង្រឹងលើការងារអប់រំប្រជាជន ស្តីពី ជំងឺឆ្លង និងជំងឺរ៉ាំរ៉ៃមិនឆ្លង ដែលបច្ចុប្បន្នជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែម កំពុងតែរីករាលដាលគួរឲ្យកត់សំគាល់
- រៀបចំកម្មវិធីបង្ការ ថែទាំវេជ្ជសាស្ត្រ និងលើកកំពស់សុខភាពសំដៅកាត់បន្ថយអត្រាឈឺ និងស្លាប់
- សម្របសម្រួល និងប្រើប្រាស់ធនធាននានាអោយសមស្របទៅតាមតម្រូវការ និងអោយទទួលបានទិន្នផលល្អប្រសើរ
- ពិនិត្យតាមដានសុវត្ថិភាពចំណីអាហារ គ្រប់គ្រងសេវាឯកជន និងលុបបំបាត់សេវាឯកជនខុសច្បាប់នៅក្នុងខេត្ត

ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិមានតួនាទីចំបងគឺអនុវត្តគោលដៅសុខភាពរបស់ស្រុកប្រតិបត្តិតាមរយៈ

- ផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយសុខាភិបាលជាតិ និងយុទ្ធសាស្ត្ររបស់ខេត្ត-ក្រុង
- ប្រកាន់ភ្ជាប់នូវសេវាមានប្រសិទ្ធភាពប្រសិទ្ធផល និងគ្រប់ជ្រុងជ្រោយ (លើកកំពស់សុខភាព បង្ការ ព្យាបាល និងស្តារនិតិសម្បទា) យោងតាមតំរូវការរបស់សហគមន៍
- ធានាការចែកចាយធនធានមានសមធម៌ និងប្រើប្រាស់ធនធានទាំងអស់នោះមានប្រសិទ្ធផល
- សហការជាមួយអាជ្ញាធររដ្ឋបាលមូលដ្ឋាន គ្រប់លំដាប់ថ្នាក់

វឌ្ឍនភាពអំពីលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៩ (ធៀបសូចនាករគោលដៅដែលបានកំណត់)

វិស័យសុខាភិបាល បានសហការជាមួយនិង អង្គការដៃគូរអភិវឌ្ឍន៏លើវិស័យសុខាភិបាល បន្តលើកកម្ពស់ការចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយបន្តអនុវត្ត ផែនការយុទ្ធសាស្ត្រសុខាភិបាល២០១៤-២០២០ ដើម្បីកែលម្អសូចនាករសុខភាពសំខាន់ៗឱ្យកាន់តែល្អប្រសើរឡើងថែមទៀត ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ ២០២០-២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជានិតិកាលទី៦នៃរដ្ឋសភាជាតិ។ ដូចមានតារាងលទ្ធផលសូចនាករបង្ហាញខាងក្រោម៖

គោលដៅយុទ្ធសាស្ត្រទី ១ (Strategic Objective 1)	លទ្ធផល					គោលដៅចំណុចវិស័យ			
ការប្រើប្រាស់សេវាថែទាំសុខភាពមានគុណភាព Overall Access to Quality Health Care Services	២០១៥	២០១៦	២០១៧	២០១៨	២០១៩	២០១៧	២០១៨	២០១៩	២០២០

1. ពិនិត្យពិគ្រោះជំងឺថ្មីសម្រាប់ប្រជាជនមួយនាក់ក្នុងមួយឆ្នាំ(ចំនួនលើក) OPD consultations (new cases only) per person per year	០,៦៥	០,៦៧	០,៧១	០,៧២	០,៦៥	០,៧០	០,៧៥	០,៨០	០,៨៥
2. អត្រាប្រើប្រាស់គ្រែ Bed occupancy rate (%)	៧៣	៦៥,៤៧	៥៩,០៧	៧៣,៧០	៩៩,៣០	៩៥	៩៥	៩៥	៩៥
3. អត្រាស្លាប់នៅមន្ទីរពេទ្យ Hospital mortality rate (%)	១,៤០	១,២១	០.៩០	០,៨៥	០,៥៨	<១	<១	<១	<១
4. រយៈពេលមធ្យមនៃការសម្រាកព្យាបាល (ចំនួនថ្ងៃ) Average Length of Stay (no. of days)	៤	៤	៤	៣	៣,៤៤	៥	៥	៥	៥
សុខភាពបន្តពូជ មាតា ទារក កុមារ និងអាហារូបត្ថម្ភ Maternal, Newborn and Child health	លទ្ធផល					គោលដៅចំណុចវិស័យ			
	២០១៥	២០១៦	២០១៧	២០១៨	២០១៩	២០១៧	២០១៨	២០១៩	២០២០
5. អត្រាប្រើវ៉ាឡង់នៃការប្រើប្រាស់វិធីសាស្ត្រពន្យាកំណើតទំនើប Contraceptive prevalence (modern methods) (%)	៥០,៧៥	៤៩,១០	៣២	៣២,១៧	៣១,៥	៤២	៤៣	៤៤,៥	៤៦
6. សមាមាត្រនៃការសំរាលដោយបុគ្គលិកសុខាភិបាលមានជំនាញ Proportion of births delivery by skilled health personnel (%)	៦២,៤៧	៥៩,៨៨	៨៣,១២	៨៨,៩៨	៩៦,៩៣	៨៩	៨៩	៩០	៩០
7. សមាមាត្រនៃការសំរាលនៅមូលដ្ឋានសុខាភិបាល Proportion of births delivery at health facilities	៦៤,៤១	៥៩,៨៨	៨៣,១២	៨៨,០២	៩៦,៨៩	៨៧	៨៨	៨៩	៩០
8. អត្រាសំរាលដោយវិធីវះកាត់(គិតជា % នៃទារកកើតរស់) Caesarean section rate (% of live births)	០,៨៤	១,៣៣	២,១០	៣,៣០	២,៧៥	៧,៥	៨	៩	១០
9. ភាគរយនៃស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាល 4 លើកដោយបុគ្គលិកសុខាភិបាល Percentage of pregnant women who received ANC4 consultation by health personnel	៦៥	៥៧,៩	៧៩	៧៩,១៤	៩៨,៣០	៨៥	៨៧	៨៨	៨៩

10. ភាគរយនៃស្ត្រីសំរាលទទួលការពិនិត្យថែទាំក្រោយសំរាលលើកទី១(មុន៤៨ម៉ោងក្រោយសំរាល) ដោយបុគ្គលិកសុខាភិបាលPercentage of post-partum women who received PNC consultation by health personnel	៦៨	៩៤,៥៨	៨៣,១១	៨៨,៧៧	៩៦,៨៩	៩៦	៩៨	៩៩	១០០
11. ភាគរយនៃកុមារបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងអំឡុងពេលមួយម៉ោងដំបូងក្រោយកំណើត Percentage of infant who were breastfed within 1 hour of birth (as percentage of live births)	០,៣០	០,៤៣	៥៣,៤៨	៤៦,៧	៤៩,០៨	៨៥	៩០	៩៥	>៩៥
12. ភាគរយនៃស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៩០គ្រាប់	៨៤	៨៣	៧៨,៥១	១០២	១០៤,៥១	៧៦	៧៩	៨២	៨៥
13. ភាគរយនៃស្ត្រីក្រោយសំរាលបានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៤២ គ្រាប់	៦៣	៥៧	៦៣,១៨	៩០,១១	៩២,៦៨	៧៥	៨០	៨៥	៩០
14. ភាគរយនៃកុមារអាយុ ៦-៥៩ ខែ បានទទួលគ្រប់ថ្នាំជីវជាតិ អា ក្នុងរយៈពេល ៦ ខែចុងក្រោយ (ជុំទី២) Percentage of children 6-59 months received vitamin A during the last 6 months (Round 2)	R2:104	R2:103	R2:102.2	R2:96.28	R2:96.76	៩២	៩៣	៩៤	៩៥
15. ភាគរយនៃកុមារអាយុ១២-៥៩ ខែ បានទទួលថ្នាំទំលាក់ព្រូន មេបង់ជាហ្សូលក្នុងរយៈពេល ៦ ខែចុងក្រោយ (ជុំទី២) Percentage of children 12-59 months received Mebendazole during the last 6 months (Round 2)	R2:105	R2:104	R2:104.8	R2:94.5	៨៩	៧៦	៧៩	៨២	៨៥
16. អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូស បង្ការជំងឺខាន់ស្លាក់ ស្វិតដៃជើង តេតាណូស រលាកសួត DPT-HepB-Hib 3 coverage rate (%)	៩០,៣៥%	៨៧,៥៧%	៩៤%	៩៨,១១%	១០០%	៩៥	៩៥	៩៥	៩៥
17. ពិនិត្យពិគ្រោះជំងឺករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំម្នាក់ ក្នុងមួយឆ្នាំ(ចំនួនលើក) OPD consultations (new cases only) per children under 5 per year	១,៦៤	១,១២	១,៣	១,៥៥	១,១០	១,៥៤	១,៥៦	១,៥៨	១,៦

ជំងឺឆ្លងនិងជំងឺតំបន់ត្រូពិក Communicable Diseases & NTDs	លទ្ធផល					គោលដៅចំណុចវិស័យ			
	២០១៥	២០១៦	២០១៧	២០១៨	២០១៩	២០១៧	២០១៨	២០១៩	២០២០
18. ភាគរយនៃមនុស្សពេញអាយុលើសពី១៤ឆ្នាំផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ Percentage of adult peoples aged above 14 year-olds living with HIV on ART	៨៧	៨៥	៩៥	៩៩	៩៩	៨៦	៨៨	៩១	៩៤
19. ភាគរយនៃកុមារអាយុក្រោម១៤ឆ្នាំ ផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ Percentage of children aged 0-14 year-olds living with HIV on ART	៩៨	៩២	៩៩	៩៩	១០០	៩៥	>៩៥	>៩៥	>៩៥
20. អត្រាព្យាបាលជោគជ័យនៃជំងឺរបេង TB treatment success rate (%)	៩២	៩៨	៩៦	៩៤	៩៦	>៩0	>៩0	>៩0	>៩0
21. ចំនួនករណីស្រាវជ្រាវជំងឺរបេងដែលបានរាយការណ៍ TB case detected	១.១៤៧	១.១៩៥	១.១៦៤	១.៣៣៧	១.២៧0	៤0៤.000	៤0.៥00	៤0.៦00	៤0.៧00
22. អាំងស៊ីដង់នៃជំងឺគ្រុនចាញ់ក្នុងប្រជាជន ១.000នាក់Malaria Incidence per 1,000 population	២,៦១	២,៥៥	៣,0៧	៣,២៦	0,៨១	១,៦៥	១,៤៥	១,២៥	១,0៥
23. អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់ដែលសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ លើប្រជាជន១00.000នាក់ Inpatient Malaria death per 100,000 population reported in public health facilities (%)	0,00	0,00	0,00	0,00	0,00	0,0៨	0,0៨	0,0៨	0
24. អត្រាស្លាប់ដោយជំងឺគ្រុនឈាម Dengue hemorrhagic fever case fatality rate (%)	៤	0,00	២,៣0	0,00	0,0007	0,៣	0,៣	0,២៥	0,២
25. អាំងស៊ីដង់នៃជំងឺហាន់សិនក្នុងប្រជាជន ១00.000 នាក់ Incidence of Leprosy per 100,000 population	៥,៥៩	២,៣៣	១,៥៤	៣,៨	៥,១៨	១,៤៣	១,២៦	១,១២	១
ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ Non-communicable diseases	លទ្ធផល					គោលដៅចំណុចវិស័យ			
	២០១៥	២០១៦	២០១៧	២០១៨	២០១៩	២០១៧	២០១៨	២០១៩	២០២0

26. ភាគរយនៃប្រជាជនអាយុពី ២៥-៦៤ឆ្នាំ មានជំងឺលើសសម្ពាធឈាមបានទទួលការព្យាបាល[a] Percentage of adults aged 25-64 with hypertension received treatment	៨៧,៤៣	៨,២៨	១១,៨៥	២០,៨២	១៤	៤៥	៥៥	៦៥	៧៥
27. ភាគរយនៃប្រជាជនអាយុពី ២៥-៦៤ឆ្នាំ មានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាល[b] Percentage of adults aged 25-64 with diabetes received treatment	២៥,៤២	០,០៤	៣,៣១	៧,៦៤	៣,៦៧	៣៥	៤៥	៥៥	៦៥
28. ភាគរយនៃស្ត្រីអាយុ ៣០-៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូនយ៉ាងតិចមួយលើក[c] Percentage of women aged 30-49 years screened for cervical cancer at least once	N/A	N/A	N/A	N/A	N/A	៤,៥	៦	៧,៥	៩
29. ចំនួននិងភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួលសេវាព្យាបាល [d] Number and percentage of adult population with depression received treatment	១,០៧%	០,០២%	០,០៥%	០,១៨%	០,០៨%	២0%	៣0%	៤0%	៥0%
30. ចំនួននិងភាគរយនៃប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាល Number and percentage of people with drug used received treatment	N/A	N/A	N/A	N/A	១,៥៥%	៥0%	៦0%	៧0%	៨0%
31. អត្រាវះកាត់ជម្ងឺភ្នែកឡើងបាយក្នុងប្រជាជន១.000000នាក់ Cataract surgical rate per 1,000,000 population	N/A	N/A	N/A	N/A	N/A	១.៩00	២.000	២.៥00	៣.000

១.២.២.៣ វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានបង្កើតកម្មវិធីសង្គ្រោះបន្ទាន់ ដោយផ្អែកតាមផែនការជាយុទ្ធសាស្ត្ររបស់ក្រសួង ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្ត រាយជាយថាហេតុ ផ្សេងៗ។ ដោយមិនទុកឱ្យប្រជាជនណាម្នាក់រងគ្រោះដោយមិនបានជួយយកចិត្តទុកដាក់ ពីស្ថាប័នសមត្ថកិច្ចឡើយ។ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការលើកកម្ពស់សុខុមាលភាពគ្រួសារ ដែលបានបញ្ជាបការងារយេនឌ័រផ្តល់កិច្ចការពារ និងទប់ស្កាត់អំពើជួញដូរមនុស្ស រំលោភបំពាន ធ្វើអាជីវកម្ម កម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ ធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ ការរំលោភបំពាន និង ធ្វើអាជីវកម្មផ្សេងៗ ។ អនុវត្តគោលនយោបាយចំពោះជនពិការគ្រប់ប្រភេទនៅតាម

សហគមន៍ លើកកម្ពស់ សុខុមាលភាពជនពិការ។ លើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល គ្របគ្រង និង លើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជនឱ្យបានទាន់ពេលវេលា ។ ជម្រុញការអនុវត្តកិច្ចការសមាគមមនុស្សចាស់ឱ្យ មានដំណើការល្អ និងមានប្រសិទ្ធភាព ។

បញ្ហាអាទិភាពសំខាន់ៗ ដែលត្រូវដោះស្រាយចំពោះមុខ

- បណ្តុះបណ្តាលមន្ត្រីឱ្យមានជំនាញ ដើម្បីអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាព និងប្រើប្រាស់ធនធានឱ្យ អស់ពីលទ្ធភាព
- បណ្តុះបណ្តាលដល់អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ឱ្យមានការយល់ដឹងក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងជនងាយរងគ្រោះដើម្បីជួយអន្តរាគមន៍ និងផ្តល់សេវាដល់ពួកគាត់ឱ្យបាន ទាន់ពេលវេលា
- ជំរុញបន្តការងារសមាគមមនុស្សចាស់ឱ្យមានដំណើរការប្រសើរឡើង
- ស្វែងរកអង្គការជាដៃគូ ដើម្បីជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះ
- បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលជំនាញវិស័យសង្គមកិច្ច។

១.២.២.៤ វិស័យកិច្ចការនារី

វិស័យកិច្ចការនារីខេត្ត មានភារកិច្ចលើកកម្ពស់ស្ថានភាព ឋានៈ តួនាទីរបស់ស្ត្រី ក្មេងស្រី ជួបបញ្ហាលំបាក ភាពងាយរងគ្រោះ បញ្ហាគ្រួសារ និងសង្គមជាតិ។ ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៥-២០៣០ វិស័យកិច្ចការនារីខេត្ត ផ្តោតសំខាន់ទៅលើវិស័យធំចំនួន៦ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ ស្ត្រី, ការអប់រំស្ត្រី ក្មេងស្រី និងការផ្លាស់ប្តូរឥរិយបថ, សុខភាព អាហាររូបត្ថម្ភ សម្រាប់ស្ត្រី និងកុមារី និងការទប់ស្កាត់ការ រីករាល ដាលនៃមេរោគអេដស៍ និងជម្ងឺអេដស៍, កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារី, ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងការ បញ្ជ្រាបយេនឌ័រ ទៅក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់ របស់រាជរដ្ឋាភិបាល, យេនឌ័រ និងបម្រែប ម្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ ។ ទន្ទឹមនឹងនេះដែរ វិស័យកិច្ចការនារី ជួបនូវ បញ្ហាប្រឈមដូចខាងក្រោម៖

- សកម្មភាពការងារមានទំហំច្រើន ដូច្នេះការចុះអនុវត្តបំពេញការងារមិនបានគ្រប់ជ្រុងជ្រោយ ព្រោះទីកន្លែង ដែលនៅឆ្ងាយ ដាច់ស្រយាល
- សមត្ថភាពរបស់មន្ត្រីខេត្ត ក្រុង ស្រុក មួយចំនួននូវមានកម្រិតក្នុងការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ

អាទិភាពសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខ

- បន្តផ្សព្វផ្សាយគោលនយោបាយនិងច្បាប់ ឲ្យស្របទៅនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បន្តផ្សព្វផ្សាយច្បាប់ និងវិធានការនានាទាក់ទងនិងការទប់ស្កាត់អំពើហឹង្សា ការរំលោភបំពាន ការជួញដូរ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព
- ពៀងគរកដៃគូរសហការ

តារាងចំនួនស្ត្រី ទិស័យមុខងារសាធារណៈ និង នយោបាយ ឆ្នាំ ២០១៩

ល.រ	បរិយាយ	ឆ្នាំ២០១៩			ផ្សេងៗ
		សរុប	ស្ត្រី	ភាគរយ	
១	អភិបាលខេត្ត	១	១	១០០%	
២	អភិបាលរងខេត្ត	៦	១	១៧%	
៣	ប្រធានក្រុមប្រឹក្សាខេត្ត	១	០	០%	
៤	សមាជិកក្រុមប្រឹក្សាខេត្ត	១៨	៤	២២%	
៥	ប្រធានក្រុមប្រឹក្សាក្រុង.ស្រុក	៧	២	២៩%	
៦	សមាជិកក្រុមប្រឹក្សាក្រុង.ស្រុក	៨០	១៧	២១%	

๗	អភិបាលក្រុង.ស្រុក	๗	๐	๐%	
๘	អភិបាលរងក្រុង.ស្រុក	๒๒	๘	๓๖%	
๙	ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត	๒๗	๑	๔%	
๑๐	អនុប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត	๕๗	๑๕	๒๖%	
๑๑	ប្រធានការិ-មន្ទីរ អង្គភាពជុំវិញខេត្ត	๑๐๒	๒๓	๒๓%	
๑๒	អនុប្រធានការី-មន្ទីរ អង្គភាពជុំវិញខេត្ត	๑๕๐	๔๐	๒๗%	
๑๓	មន្ត្រីការិយាល័យ	๒๓๑	๗๙	๓๔%	
๑๔	ប្រធានការិ-ក្រុង ស្រុក	๒๘	๐	๐%	មិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ

๑.๒.๒.๕ វិស័យធម្មការ និងសាសនា

វិស័យព្រះពុទ្ធសាសនា មានតួនាទីសំខាន់ ក្នុងការរួមចំណែកអប់រំសង្គម ឲ្យមានសីលធម៌ ចរិយាធម៌ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រ និងការអភិវឌ្ឍសង្គមជាតិ។ វិស័យព្រះពុទ្ធសាសនា បានយកចិត្តទុកដាក់ផ្តោតសំខាន់ ពង្រឹងតម្លៃគ្រួសារ លើកកម្ពស់សីលធម៌រស់នៅក្នុងសង្គម ពង្រឹងតួនាទីភារកិច្ចក្រមសីលធម៌អាចារ្យ ចៅអធិការ និងថេរសភា ពង្រឹងការថែរក្សាមរតក ប្រពៃណី ទំនៀមទម្លាប់ វិស័យពុទ្ធចក្រ ពង្រឹងវិស័យអប់រំពុទ្ធិកសិក្សាចាប់ពីថ្នាក់បឋមដល់ថ្នាក់វិទ្យាល័យ។ ទាំងនេះជាគោលនយោបាយដែលបានសម្រេចនូវសកម្មភាពអាទិភាពដែលចូលរួមចំណែកការកសាងផែនការអភិវឌ្ឍន៍ ជាពិសេសអនុវត្តន៍ តាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើឱ្យមានកំណើនការងារសមធម៌និងមានប្រសិទ្ធភាពនៅកម្ពុជា សំដៅកាត់បន្ថយភាពក្រីក្រលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរ។

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ខ្ពស់ លើវិស័យព្រះពុទ្ធសាសនា ដោយគោរពសិទ្ធិសេរីភាពខាងជំនឿសាសនា និងលើកស្ទួយព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ហើយបង្កលក្ខណៈសម្បត្តិល្អប្រសើរ សកម្មភាពគោរពប្រតិបត្តិសាសនាផ្សេងៗទៀត ប្រកបដោយសុខុដុមនីយកម្មដែលរួមចំណែកដល់ការរក្សា ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ឱ្យបានល្អ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលបានកំណត់នូវគោលនយោបាយសកម្មភាពអាទិភាពចំពោះវិស័យនេះដើម្បីបន្តជំរុញលើកកម្ពស់យ៉ាងសកម្មនូវរាល់តួនាទីរបស់គ្រួសារ ផ្សារភ្ជាប់ទៅនឹងតម្លៃជាប្រពៃណីនៃព្រះពុទ្ធសាសនា ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅបញ្ចាបការអប់រំ ផ្នែកព្រះពុទ្ធសាសនាទៅដល់គ្រប់ស្រទាប់ សិស្ស និស្សិត យុវជន មហាជនទូទៅដើម្បីបង្កើនការយល់ដឹងពីតម្លៃសីលធម៌រស់នៅក្នុងសង្គមជាតិយើង ហើយបញ្ឈៀសឱ្យផុត ពីការប្រើប្រាស់គ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ អំពើអនាចារ ការកេងប្រវ័ញ្ចផ្លូវភេទ ក្មេងទំនើង ការប្រើប្រាស់គ្រឿងញៀនក្នុងស្រទាប់យុវវ័យចេញឱ្យអស់ពីសង្គមជាតិយើង។

ជំរុញការអនុវត្តន៍សេចក្តីណែនាំ និងលិខិតបទដ្ឋាននានា ចំពោះអង្គការសាសនា វត្តអារាម និកាយសាសនា អង្គការសមាគម ដែលមានចរិតសាសនា ឱ្យប្រតិបត្តិ ធ្វើសកម្មភាពសាសនា ស្របតាមគោលការណ៍ និងច្បាប់របស់រដ្ឋ។ សម្របសម្រួលបរិស័ទគ្រប់សាសនាឱ្យមានសុខុដុមនីយកម្ម លើកទឹកចិត្ត ឱ្យប្រតិបត្តិគោរពក្រឹត្យវិន័យតាមវិធីសាស្ត្រសាសនារៀងៗខ្លួន ដោយរក្សាសាមគ្គីភាពក្នុង ចំណោមអ្នកមានចរិតសាសនា និងអ្នកកាន់សាសនាទាំងអស់។

អនុវត្តបទប្បញ្ញត្តិ លិខិតបទដ្ឋាន សារាចរ សេចក្តីណែនាំរបស់ក្រសួង សហការទំនាក់ទំនងយ៉ាងជិតស្និទ្ធ តាមឋានានុក្រម របស់ព្រះសង្ឃគ្រប់លំដាប់ថ្នាក់នៅតាមមូលដ្ឋាន និងមេដឹកនាំ ឬតំណាងពាហិរសាសនានានា ក្នុងវិស័យធម្មការ និងសាសនាទាំងមូល ជួយសម្របសម្រួលការងារផ្សព្វផ្សាយ សន្ទនាព្រះធម៌ តួនាទីព្រះពុទ្ធសាសនា ផ្សារភ្ជាប់សង្គមឱ្យបានទូលំទូលាយសម្រាប់ការអនុវត្តន៍បន្ត។

តារាងស្ថិតិ វត្ត ព្រះសង្ឃ អាចារ្យ គណៈកម្មការវត្តនិងអ្នកស្នាក់នៅវត្ត ទូទាំងខេត្ត២០១៩

បរិយាយ	ចំនួនវត្តអារាមនិងព្រះសង្ឃទូទាំងខេត្តកោះកុងឆ្នាំ២០១៩				
	សរុបរួម	គណៈមហានិកាយ		គណៈធម្មយុត្តិកនិកាយ	
វត្ត	៥៣វត្ត	៤៧វត្ត		៦វត្ត	
ព្រះសង្ឃ	៤៣៥អង្គ	៣៧៣អង្គ		៦២អង្គ	
បរិយាយ	សរុបរួម (នាក់)	គណៈមហានិកាយ		គណៈធម្មយុត្តិកនិកាយ	
		ប្រុស(នាក់)	ស្រី(នាក់)	ប្រុស(នាក់)	ស្រី(នាក់)
អាចារ្យ-អាចារិនី	១១៥	១០៤	១	៩	១
គណៈកម្មការវត្ត	២០៤	១៨១	១៦	៧	០
តាជីនិងដូនជី	៨០	១៩	៤៨	៥	៨
អ្នកស្នាក់នៅវត្ត	១១៤	១០០	០	៨	៦

ស្ថិតិ៣ហិរិសាសនា(គ្រឹស្ត-ឥស្លាម- ចិន) ឆ្នាំ២០១៩

ឥស្លាម		*គ្រឹស្ត*		*ចិន (ហុងតាសៀន)*		បាហៃ
បរិយាយ	*ចំនួន*	*បរិយាយ*	*ចំនួន*	*បរិយាយ*	*ចំនួន*	*ចំនួន*
វិហារ	៩ កន្លែង	វិហារ	១០ កន្លែង	វិហារ	០១កន្លែង	០១កន្លែង
ស៊ូរ៉ាវ	៧ កន្លែង	ស្នាក់ការថ្វាយបង្គំ	១៥ កន្លែង	សាសនិក	០៨នាក់	៤៤នាក់
មជ្ឈមណ្ឌល	០ កន្លែង	គ្រូគង្វាល	២៥ នាក់			
សាសនិក	១០.៤៥៦នាក់	សាសនិក	៨៩០នាក់			

១.២.២.៦ វិស័យវប្បធម៌ និងវិចិត្រសិល្បៈ

វិស័យវប្បធម៌ និងវិចិត្រសិល្បៈខេត្ត បានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមជាតិ ។ វិស័យវប្បធម៌ខេត្ត មានសក្តានុពលអាចទាក់ទាញភ្ញៀវជាតិ-អន្តរជាតិចូលទស្សនាកំសាន្ត នៅតាមរមណីយដ្ឋានធម្មជាតិ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ រួមមានចេតិយឃុនឆាង ទីលានទាត់សី ព្រះអង្គគោកធ្លក ម្ល្អសបុរាណ អណ្តូងមួយរយ និងស្ថានីយភ្នំខ្នងពើង ស្ថានីយក្បាលអូរសិរមាន់ ស្ថានីយដំណាក់ស្តេច ស្ថានីយភ្នំពែល ស្ថានីយអូរកី ស្ថានីយថ្មចេតិយ ស្ថានីយរោងដំរី ស្ថានីយខ្នងតាធន ស្ថានីយខ្នងស្រល់(រោងជំនាង) ស្ថានីយតាម៉ៅ ស្ថានីយអូរទឹកមុជ ស្ថានីយរូងកុមារ ដែលស្ថិតនៅក្នុងស្រុកថ្មបាំង និងវត្ថុសិល្បៈមួយចំនួនដែលស្រង់ចេញពីសំពៅលិចយកមករក្សាទុកនៅអាគារសារមន្ទីរ។

ជាពិសេសវិស័យវប្បធម៌ មានភារកិច្ចយ៉ាងសំខាន់ក្នុងការសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នមានសមត្ថកិច្ចនានាដែលពាក់ព័ន្ធ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងថែរក្សាតំបន់វប្បធម៌ សិក្សាស្រាវជ្រាវនិងចងក្រងរក្សាទុកឲ្យបានគង់វង្សនូវឯកសារបេតិកភណ្ឌវប្បធម៌គ្រប់ប្រភេទ ដែលមាននៅក្នុងខេត្ត។

សម្បត្តិវប្បធម៌ទាំងនោះត្រូវបានអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ការពារសម្បត្តិបេតិកភណ្ឌជាតិ ប្រាសាទបុរាណទួលប្រវត្តិសាស្ត្រ បេតិកភណ្ឌរូបី និងអរូបី រក្សាការពារសិល្បៈ ល្ខោន យីកេ អាយ៉ៃ ចាប៉ី របាំប្រជាប្រិយ គំនូរ ចម្លាក់ ជំរុញការច្នៃប្រឌិតវប្បធម៌ថ្មីៗ។ សកម្មភាពសំខាន់ដែលត្រូវដោះស្រាយចំពោះមុខមាន៖

- ចុះត្រួតពិនិត្យសកម្មភាពសេវា កម្មវិធីសម្តែងផ្សេងៗ
- ការបញ្ចាំងភាពយន្តវីដេអូ ស្លាកសញ្ញាអាជីវកម្ម អាជីវកម្មសិល្បៈសូនរូប និងសេវាផ្សេងៗ ដែលទាក់ទងនិងវិស័យវប្បធម៌

- ចូលរួមការថែរក្សា អភិរក្ស អភិវឌ្ឍវប្បធម៌ជាតិ ថែរក្សាសិល្បៈប្រពៃណី ទំនៀមទំលាប់ពីបុរាណ
- ធ្វើការផ្សព្វផ្សាយឲ្យប្រជាជនយុវជនយល់ពីតម្លៃសម្បត្តិវប្បធម៌ជាតិ ៣សរិតបន្តឹងការហូរចូលអំពីវប្បធម៌បរទេស ដែលមានលក្ខណៈមិនសមស្រប និង ប្រពៃណីជាតិយើង
- លើកកម្ពស់ការយល់ដឹងការចូលរួមយុវជនក្នុងការអភិវឌ្ឍវប្បធម៌ជាតិ ។

ជាមួយគ្នានេះដែរ វិស័យវប្បធម៌ និងវិចិត្រសិល្បៈខេត្ត មានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការិយាល័យមួយចំនួនពុំទាន់មានប្រធាន និងអនុប្រធានគ្រប់គ្រងនៅឡើយ
- ពុំទាន់មានសារមន្ទីរសម្រាប់ដាក់តាំងនូវវត្ថុបុរាណដែលស្រង់ចេញពីសំពៅលិច (កោះស្តេច) និង នៅតាមជួរភ្នំក្រវាញ
- កង្វះសិល្បករ-សិល្បការិនី សម្រាប់ចេញសម្តែងជូនប្រជាពលរដ្ឋនៅពេលមានកម្មវិធីម្តងៗ
- អាជីវករមួយចំនួនមិនបានមកសុំច្បាប់អនុញ្ញាតធ្វើអាជីវកម្មនៅច្រកចេញចូលតែមួយ។

១.២.២.៧ វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាវិស័យស្នូលមួយយ៉ាងសំខាន់ បានរួមចំណែកយ៉ាងសកម្ម ក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់ឱកាសការងារសមរម្យជូនប្រជាពលរដ្ឋ ការលើកកំពស់លក្ខខណ្ឌការងារ ពង្រឹងសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈរវាងនិយោជក និងកម្មករនិយោជិត ធានាការការពារកម្លាំងពលកម្មដែលបម្រើការងារលើគ្រប់វិស័យ ជាពិសេសទទួលបាននូវសិទ្ធិ និងអត្ថប្រយោជន៍ ស្របតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ សម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទបញ្ញត្តិច្បាប់ស្តីពីការងារ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិនានា និងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាពលរដ្ឋ ជាពិសេសយុវជនដែលមិនមានឱកាសចូលរៀនបន្តនៅឧត្តមសិក្សា និងជនងាយរងគ្រោះដទៃទៀតដោយមិនប្រកាន់ការរើសអើងឡើយ។

ខេត្តកោះកុង មានសក្តានុពលសំខាន់ៗ ដែលអាចទាក់ទាញអ្នកវិនិយោគទុនទាំងក្នុងប្រទេស និងក្រៅប្រទេសមកបោះទុនរកស៊ីក្នុងខេត្តកាន់តែច្រើនឡើងៗ ហើយបានស្រូបយកកម្លាំងពលកម្ម (រាប់ពាន់នាក់) ក្នុងនោះមាន វិស័យឧស្សាហកម្ម រោងចក្រតំឡើងរថយន្ត វាយនភ័ណ្ឌកាត់ដេរសំលៀកបំពាក់ សម្ភារៈកីឡា វិស័យទេសចរណ៍ និងសេវាកម្មផ្សេងៗ។ វិស័យទាំងនេះជំរុញឲ្យមានកំណើនការងារ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ ហើយក៏បានចូលរួមកាត់បន្ថយប្រជាពលរដ្ឋចំណាកស្រុក។ ជាមួយនេះផងដែរ ក្រុមអធិការកិច្ចការងារ ដែលមានតួនាទីយ៉ាងសកម្មក្នុងការជំរុញ និងផ្សព្វផ្សាយឱ្យសហគ្រាសគ្រឹះស្ថាន គោរពតាមគោលការណ៍ច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីធានាបាននូវលក្ខខណ្ឌការងារល្អ និងរក្សាបាននូវសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ ក្នុងគោលបំណងបង្កើន ផលិតភាពស្របតាមស្ថានភាពរីកចម្រើនរបស់ខេត្ត។ គិតមកដល់បច្ចុប្បន្ននេះ សហគ្រាស គ្រឹះស្ថានក្នុងខេត្ត សរុបចំនួន ៧២ សហគ្រាស ដែលបានផ្តល់ការងារធ្វើជូនប្រជាពលរដ្ឋសរុបចំនួន១៤.៨៨៩នាក់ (ស្រីចំនួន៨.៧៩៤នាក់) ក្នុងនោះមាន កម្មករនិយោជិតខ្មែរចំនួន១៣.៦១០នាក់ (ស្រីចំនួន៨.៤១២នាក់) និងពលករបរទេសចំនួន១.២៧៩នាក់ (ស្រីចំនួន ៣៨២ នាក់) ក្នុងនោះ សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតកំពុងបម្រើការងារច្រើន គឺនៅតំបន់សេដ្ឋកិច្ចពិសេសនាងកុកមាន០៧ សហគ្រាស ដូចជា YAZAKI, HYUNDAI, KKN, MIKASA Sport, ៩៩អ៊ីមប្រ៊ីយបឺរី Camco និង HANA ដែលមានកម្មករនិយោជិតសរុបចំនួន១១.៦៤៧នាក់ (ស្រីចំនួន ៧.៧៦៣នាក់) និង ០២ សហគ្រាសទៀតនៅរោងចក្រស្តសរ និងចំការអំពៅ ស្រុកស្រែអំបិលដែលមានកម្មករនិយោជិតសរុបចំនួន៦៧ នាក់ (ស្រីចំនួន០៩ នាក់)។

វិស័យការងារសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់យ៉ាងណាក្តី ក៏នៅមានចំណុចប្រឈមមួយចំនួនដែលទាមទារឲ្យមានការខិតខំដោះស្រាយឲ្យបានជោគជ័យថែមទៀត មានជាអាទិ៍៖

- ក្រុមហ៊ុនមួយចំនួនមិនបានដាក់បំពេញបែបបទស្តីពីសហគ្រាសនិងលក្ខខណ្ឌការងារឲ្យបានត្រឹមត្រូវ
- ប្រជាពលរដ្ឋមួយចំនួនប្រកបមុខរបរមានលក្ខណៈបន្ទាប់បន្សំនិងមិនពិតប្រាកដ ។

បញ្ហាប្រឈមចម្បងៗ ដែលត្រូវដោះស្រាយ៖

- ផ្សព្វផ្សាយច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋាននានា

- ពង្រឹងការចុះអធិការកិច្ចតាមសហគ្រាស គ្រឹះស្ថានក្នុងខេត្តឲ្យបានទៀងទាត់
- បើកវគ្គបណ្តុះបណ្តាលផ្នែកសេវាកម្មរួមមាន អគ្គិសនី ជាងកំបោរ កុំព្យូទ័រឧដ្ឋបាល អេឡិចត្រូនិច ជួសជុលម៉ូតូ និងជាងផ្សារដែក
- បើកវគ្គបណ្តុះបណ្តាលផ្នែកកសិកម្មដូចជា ចិញ្ចឹមមាន់ គោ ជ្រូក និងចាក់វ៉ាក់សាំង ចិញ្ចឹមត្រីអណ្តែង កង្កែប ដំណាំទុរេន ល្អុង ដាំបន្លែចម្រុះ បណ្តុះផ្សិត ស្តែចង្កឹះ ត្រកួន ត្រឡាច ឆៃថាវ និង ល្ពៅ។

១.២.២.៨ វិស័យព័ត៌មាន

វិស័យព័ត៌មានខេត្តកោះកុង ជាអង្គភាពមូលដ្ឋានរបស់ក្រសួងព័ត៌មាន មានតួនាទីជាសេនាធិការទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពរបស់ក្រសួងលើវិស័យព័ត៌មាននិងសោតទស្សន៍ក្នុងក្របខ័ណ្ឌខេត្តកោះកុង ។ ផ្សព្វផ្សាយជាប្រចាំនូវព័ត៌មានតាមរយៈវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី ព្រឹត្តិប័ត្រ ការសែត រូបថត។ល។ ស្តីពីសកម្មភាពក្នុងខេត្តកោះកុង ព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ ។ ចេញលិខិតអនុញ្ញាតការស្នើសុំប្រកបអាជីវកម្មពាក់ព័ន្ធលើវិស័យព័ត៌មាននិងសោតទស្សន៍ ជាសេនាធិការរបស់ក្រសួងព័ត៌មានក្នុងការត្រួតពិនិត្យរោងពុម្ព និងសេវានានាដែលទាក់ទងដល់ការចេញផ្សាយផលិតផលសោតទស្សន៍ជាសេនាការរបស់ក្រសួងព័ត៌មាន ក្នុងការតាមដានព័ត៌មានការសែត ព្រឹត្តិប័ត្រ ទស្សនាវដ្តី និងការចេញផ្សាយផលិតផលបោះពុម្ព គ្រប់គ្រងមន្ត្រីរាជការក្នុងវិស័យនេះ អោយបានត្រឹមត្រូវតាមច្បាប់កំណត់លើកគម្រោងផែនការថវិកា ដើម្បីដំណើរការរបស់កិច្ចការព័ត៌មានខេត្ត គ្រប់គ្រងរដ្ឋបាលបច្ចេកទេសជំនាញ និងថែរក្សាការពារប្រើប្រាស់ទ្រព្យសម្បត្តិមូលដ្ឋានសម្ភារបច្ចេកទេសថវិកា ។ ប្រមូលចំណូលនានាតាមច្បាប់កំណត់ និង អនុវត្តការរាយការណ៍ជូនក្រសួងព័ត៌មាន រដ្ឋបាលខេត្តកោះកុង និងសមត្ថកិច្ចពាក់ព័ន្ធជាប្រចាំ ។

វិស័យព័ត៌មានខេត្ត មានតួនាទីដ៏សំខាន់ក្នុងការនាំមកនូវព័ត៌មានសំខាន់ៗ ជាតិ អន្តរជាតិ ជូនថ្នាក់ដឹកនាំខេត្តនិងប្រជាពលរដ្ឋនៅក្នុងខេត្តបានដឹងបានឃើញនូវភាពរីកចម្រើនរបស់ប្រទេសជាតិ បានដឹងអំពីស្ថានភាពនយោបាយសេដ្ឋកិច្ចរបស់ប្រទេសនានាលើពិភពលោក

វឌ្ឍនភាពចំពោះវិស័យនេះមានដូចតទៅ៖

ផ្អែកលើគោលនយោបាយតាមវិស័យ ដែលចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍជាតិ ក្រសួងព័ត៌មានបានដាក់ចេញនូវគោលនយោបាយអទិភាព៣ចំណុចដូចតទៅនេះ ៖

- ពង្រីកវិសាលភាពនិងប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយផ្តល់ព័ត៌មានការអប់រំ និងការកំសាន្ត ប្រកបដោយគុណភាព និងសមធម៌ ជូនប្រជាពលរដ្ឋ គ្រប់មជ្ឈដ្ឋានឲ្យបាន៩៥% ដល់ ៩៧%
- លើកទឹកចិត្តការអនុវត្ត សេរីភាពសារព័ត៌មាន និងការបញ្ចេញមតិស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស លើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់មនុស្ស
- រួមចំណែកអភិរក្ស និងអភិវឌ្ឍវប្បធម៌ប្រពៃណីដើម្បីលើកកម្ពស់អត្តសញ្ញាណជាតិខ្មែរ និង កិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជា នៅលើឆាកអន្តរជាតិ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ
- រយៈចុងក្រោយនេះ វិស័យព័ត៌មានសម្រេចបាននូវសមិទ្ធិផលជាច្រើនដើម្បីឆ្លើយតបនូវតម្រូវការចាំបាច់ក្នុងការបំពេញការងារប្រចាំថ្ងៃក៏ដូចជាការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋជាក់ស្តែង៖
- បានពង្រឹងរបៀបរបបធ្វើការងារដល់មន្ត្រីរាជការបានល្អប្រសើរឡើងមួយកម្រិតថែមទៀត
- សាងសង់អគាររដ្ឋបាលមន្ទីរថ្មី១ខ្នង២ជាន់រាប់ពីជាន់ផ្ទាល់ដី (សម្រេចបាន១០០%)
- បានធ្វើការកែលំអនូវឧបករណ៍សម្ភារបច្ចេកទេសសម្រាប់យកព័ត៌មានបានប្រសើជាងមុន
- បានធ្វើការកែលម្អរកម្មវិធីផ្សាយវិទ្យុបានល្អប្រសើជាបណ្តើរៗ ដើម្បីបម្រើជូនមិត្តអ្នកស្តាប់ប្រកបដោយគុណភាព ។

បញ្ហាប្រឈមដែលកើតមានឡើងដូចខាងក្រោម៖

ទន្ទឹមនឹងការអបអរសាទរចំពោះសមិទ្ធផលដែលទទួលបានខាងលើនេះ ក៏នៅមានចំណុចខ្វះខាត មួយចំនួន៖ វិសាលភាពប្រព័ន្ធផ្សព្វផ្សាយមិនទាន់បានគ្របដណ្តប់ទូទាំងខេត្តកោះកុងនៅឡើយ ដោយសារតែស្ថានភាព ភូមិសាស្ត្រ

ខេត្តមានការស្មុគស្មាញ មានភ្នំខ្ពស់ៗ ដែលជាហេតុមិនអាចឲ្យរលកសញ្ញាវិទ្យុគ្របដណ្តប់ទៅដល់ស្រុកមួយចំនួន ។ មិនទាន់មានលទ្ធភាពបង្កើតស្ថានីយ៍ទូរទស្សន៍របស់ខេត្តកោះកុងនៅឡើយ សមត្ថភាពមន្ត្រីជំនាញ និងជំនាញបច្ចេកទេសនៅមានកម្រិត ខ្វះខាតនូវសម្ភារបច្ចេកទេស និងមធ្យោបាយសម្រាប់បម្រើការងារព័ត៌មាន ។

បញ្ហាអាទិភាពសំខាន់ៗ ដែលត្រូវដោះស្រាយចំពោះមុខ

ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍខេត្តកោះកុងឲ្យមានការរីកចម្រើនឥតឈប់ឈរនោះ មន្ទីរព័ត៌មានខេត្តកោះកុងនឹងធ្វើការដោះស្រាយបញ្ញាអាទិភាពសំខាន់ៗចំពោះមុខដូចតទៅ ៖

- បន្តពង្រឹងសមត្ថភាពស្ថាប័នទាំងលើកាងារដឹកនាំគ្រប់គ្រង និងជំនាញដោយអនុវត្តគោលនយោបាយយុវភាវូបនីកម្មនិងយេនឌ័រនិងទំនើបកម្មមូលដ្ឋានសម្ភារបច្ចេកទេស ដើម្បីធានាបាននូវ និរន្តរភាព និងប្រសិទ្ធិភាពការងារ
- លើកកម្ពស់គុណភាព នៃកម្មវិធីផ្សាយឱ្យបានសម្បូរបែបគ្រប់ផ្នែក គ្រប់វិស័យ ដើម្បីផ្តល់ព័ត៌មាន ផ្តល់ការអប់រំចំណេះដឹង និងការកំសាន្ត ដោយអនុវត្តតាមពាក្យស្លោក (ប្លែក លឿន ទុកចិត្តបាន នៅទីណាពេលណាក៏បាន)
- ជម្រុញការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន និងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានដោយ ធានាឲ្យ បាននូវសិទ្ធសេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាន លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ
- ជម្រុញលើការបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស ដែលពាក់ព័ន្ធនឹងការងារគ្រប់ផ្នែកគ្រប់ជំនាញឲ្យចូលរួមវគ្គសិក្ខាសាលាដើម្បីបំពាក់បំប៉នបន្ថែម ដល់មន្ត្រីជំនាញ ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃការងារស្របតាមការវិវឌ្ឍន៍យ៉ាងគំហុកនៃព័ត៌មានវិទ្យា
- បន្តលើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយឯកជន ឲ្យខិតខំពង្រឹងសក្តានុពលនៃកាផ្សាយរបស់ខ្លួន ដើម្បីលើកកម្ពស់អត្តសញ្ញាណជាតិ មោទនភាពជាតិខ្មែរ និងកិត្យានុភាព របស់ព្រះរាជាណាចក្រកម្ពុជា នៅលើឆាកអន្តរជាតិ ។

១.២.២.៩ វិស័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចគឺជាការសម្របសម្រួលសហការណ៍ជាមួយអាជ្ញាធរខេត្ត ធ្វើការទំនាក់ទំនងជាមួយសមាជិករដ្ឋសភា-ព្រឹទ្ធសភាក្នុងមណ្ឌលរបស់ខ្លួន។ សិក្សាស្រាវជ្រាវច្បាប់ដែលចូលជាធរមាននិងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល អប់រំផ្សព្វផ្សាយ ជូនប្រជាពលរដ្ឋក្នុងមណ្ឌលខេត្តរបស់ខ្លួនអោយបានយល់ដឹង និងប្រតិបត្តិតាម។ ទទួលពាក្យបណ្តឹង ពិនិត្យសមត្ថកិច្ច អង្កេតស្រាវជ្រាវ និងដោះស្រាយអោយបានត្រឹមត្រូវតាមថេរវេលាកំណត់។ ចុះតាមត្រួតពិនិត្យដានការអនុវត្តច្បាប់ កម្មវិធីនយោបាយថ្មីៗ របស់រាជរដ្ឋាភិបាល អនុក្រឹត្យ អនុសាសន៍របស់នាយករដ្ឋមន្ត្រី និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល ។ ចុះធ្វើអធិការកិច្ចលើគ្រប់វិស័យក្នុងខេត្តដើម្បីរួមចំណែកសម្រេចអោយបាននូវស្នូលនៃយុទ្ធសាស្ត្រចតុកោណ ពោលគឺអភិបាលកិច្ចល្អ។ ជាមួយគ្នានេះផងដែរ មានបញ្ហាប្រឈមដូចជា ខ្វះធនធានមនុស្ស មធ្យោបាយ និងលក្ខណៈ ភូមិសាស្ត្រមានភាពស្មុគស្មាញ ។

១.២.២.១០ វិស័យមុខងារសាធារណៈ

មុខងារសាធារណៈខេត្ត គឺត្រូវអនុវត្តគោលនយោបាយ និងផែនការការរបស់ក្រសួងមុខងារសាធារណៈ ដែលពាក់ព័ន្ធនឹងថ្នាក់ក្រោមជាតិ ដើម្បីធានានូវការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ព្រមទាំងលើកយោបល់ រៀបចំផ្សព្វផ្សាយ សម្របសម្រួល តាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងផែនការការងារក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិជួយគណៈអភិបាល និងក្រុមព្រឹក្សាក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលតាមការធ្វើប្រតិភូអំណាចដល់ថ្នាក់ក្រោមជាតិធ្វើការសហការជាមួយមន្ទីរ/អង្គភាពពាក់ពន្ធ័ អង្គការអន្តរជាតិ និងជាតិ និងដៃគូរអភិវឌ្ឍន៍ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក្របខណ្ឌយុត្តសាស្ត្រស្តីពីកំណែទម្រង់វិសមជ្ឈការ និងវិសហមជ្ឈការ គោលនយោបាយស្តីពីសេវាសាធារណៈ គោលនយោបាយស្តីពីធនធានមនុស្ស ក្នុងរដ្ឋបាលសាធារណៈ គោលនយោបាយស្តីពីការគ្របគ្រង់ និងការអភិវឌ្ឍធនធាន

មនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្របខណ្ឌគតិយុត្តពាក់ពន្ធ័នានា ដើម្បីចរិការអភិវឌ្ឍវិស័យមុខងារសាធារណៈ ហើយធ្វើការបូកសរុបសំណើរផែនការប្រើប្រាស់និងចូលរួមក្នុងដំណើរការជ្រើសរើសមន្ត្រីក្របខណ្ឌ មន្ត្រីជាប់កិច្ចសន្យា នៅថ្នាក់ក្រោមជាតិ ។ ព្រមជាមួយការពារផលប្រយោជន៍មន្ត្រីរាជការស៊ីវិលផ្អែកតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងពិនិត្យផ្ទៀងផ្ទាត់ ផ្តល់យោបល់ គ្រប់គ្រង់ តាមដាន និងត្រួតពិនិត្យ លើសំណើនានាពាក់ពន្ធ័និងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋានគតិយុត្តពាក់ពន្ធ័និងការគ្រប់គ្រង់មន្ត្រីរាជការថ្នាក់ក្រោមជាតិតាមការផ្ទេរសិទ្ធពីក្រសួង និង អនុវត្តការងារផ្សេងទៀតតាមការកំណត់របស់ក្រសួង ។សក្តានុពលវិស័យមុខងារសាធារណៈមានដូចខាងក្រោម:

- មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាទូទាំងខេត្តបានបើកប្រាក់បៀវត្សប្រចាំខែជាទៀងទាត់ក្នុងមួយខែ២ ដង
- ជួយជាជំនួយបច្ចេកទេសក្នុងការរៀបចំកិច្ចការរៀបចំបំរែបំរួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារជូនមន្ត្រីរាជការ
- ជួយជម្រុញការតែងតាំងតួនាទី និងភារៈកិច្ចមន្ត្រីរាជការ
- ចុះត្រួតពិនិត្យបញ្ជីវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទូទាំងខេត្តតាមអនុក្រឹត្យលេខ ៥៦ របស់រាជរដ្ឋាភិបាល ។

<u>បញ្ហាប្រឈម</u>

- ចំនួនមន្ត្រីមានចំនួនតិចមិនទាន់ឆ្លើយតប និងតម្រូវការការងារ
- ខ្វះខាត់មធ្យោបាយធ្វើដំណើរសម្រាប់ចុះបំពេញភារៈកិច្ច

<u>បញ្ហាអាទិភាពសំខាន់ៗ ដែលត្រូវដោះស្រាយចំពោះមុខ</u>

- ការគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
- ការស្នើសុំតែងតាំងមន្ត្រីរាជការ
- ការឡើងថ្នាក់ប្រចាំឆ្នាំមន្ត្រីរាជការ
- ស្នើសុំក្របខណ្ឌថ្មីបន្ថែម

១.២.២.១១ វិស័យផែនការ និងស្ថិតិ

ស្របតាមលក្ខណៈភូមិសាស្ត្រ និងលក្ខណៈអំណោយផលពីធម្មជាតិ ធ្វើឲ្យខេត្តកោះកុង មានសក្តានុពល ជាច្រើន សម្រាប់យកមកកែច្នៃ និងធ្វើការអភិវឌ្ឍន៍ឲ្យមានភាពរីកចំរើនលើគ្រប់វិស័យ ដូចជា វិស័យទេសចរណ៍ វិស័យឧស្សាហកម្ម និងពាណិជ្ជកម្មនេសាទ និង ការដោះដូរទំនិញរវាង ប្រទេសកម្ពុជានិងប្រទេសថៃ ដែលទាំងអស់នេះ ខេត្តចាំបាច់ត្រូវរៀបចំផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គមកិច្ចរយៈវែង និងកម្មវិធីវិនិយោគ បីឆ្នាំរំកិល រាជធានី-ខេត្ត តាមលំដាប់លំដោយដែលចាំបាច់ ត្រូវមានការចូលរួមសហការ និងរៀបចំពីស្ថាប័ន ពាក់ព័ន្ធ ក្នុងខេត្តទាំងមូល។ ជាមួយគ្នានេះដែរ វិស័យនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជម្រុញនូវដំណើរការរៀបចំ ផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិលខេត្ត ស្រុក/ក្រុង និងការផលិតទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ សម្រាប់រៀបចំវេទិកាសមាហរណកម្មថ្នាក់ខេត្ត ក្រុង /ស្រុក ឃុំ/សង្កាត់ និងការអនុវត្តការកំណត់អត្តសញ្ញាកម្មគ្រួសារក្រីក្រជារៀងរាល់ឆ្នាំ ប្រកបដោយប្រសិទ្ធភាព សក្តានុពលចំពោះវិស័យនេះ៖

- ផែនការខេត្ត ត្រូវបានប្រគល់បេសកកម្មអោយទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្ម ភាពការងាររបស់ក្រសួង ដឹកនាំគ្រប់គ្រង សម្របសម្រួលលើការងារ ៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និង កម្មវិធីវិនិយោគបីឆ្នាំរំកិល ទិន្នន័យមូលដ្ឋាន កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមដានត្រួតពិនិត្យវាយតម្លៃ អាហារូបត្ថម្ភ កិច្ចសហប្រតិបត្តិការស្ថិតិ ការងារពាក់ព័ន្ធនិងប្រជាជននិងការអភិវឌ្ឍ សិក្សាស្រាវជ្រាវពីវិទ្យាសាស្ត្របច្ចេកវិទ្យា សម្រាប់ការងារ អភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ

- ដើម្បីរួមចំណែកដល់ការសម្រេចគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល និង ការអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រ អាទិភាពរបស់ក្រសួងផែនការ៖ "អភិវឌ្ឍន៍ និង ជំរុញការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ វិស័យផែនការ ស្ថិតិ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា" វិស័យផែនការនេះ នឹងបន្តផ្តោតការយកចិត្តទុកដាក់បន្ថែមលើសកម្មភាព ជាអាទិភាពសម្រាប់រយៈពេល៥ឆ្នាំ ២០២០-២០២៤ ដូចខាងក្រោម ៖
- ពង្រឹងការគ្រប់គ្រងលើការរៀបចំ និងអនុវត្តការងារផែនការ
- ពង្រឹងការគ្រប់គ្រងការរៀបចំ និងអនុវត្តការងារស្ថិតិ
- ពង្រឹងការគ្រប់គ្រងការរៀបចំ និង អនុវត្តការងារប្រជាជន និងការអភិវឌ្ឍ
- ពង្រឹងការគ្រប់គ្រងការរៀបចំ និង អនុវត្តការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ពង្រឹងការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការ-ស្ថិតិប្រជាជននិងការអភិវឌ្ឍ និង វិទ្យសាស្ត្រ និងបច្ចេកវិទ្យា
- ការគាំទ្រកិច្ចការរដ្ឋបាលទូទៅ និងការគ្រប់គ្រងហិរញ្ញវត្ថុ ។

<u>បញ្ហាប្រឈម</u>

- សមត្ថភាពមន្ត្រីនៅមានកំរិតទាប
- ការប្រមូលទិន្នន័យមូលដ្ឋានមានការយឺតយ៉ាវ
- ខ្វះការចូលរួមគាំទ្រពីបណ្តាមន្ទីរ អង្គភាព វិស័យឯកជន (សិក្ខាសាលាសមាហរណកម្មក្រុងស្រុក)
- ពុំមានការលើកទឹកចិត្ត ខ្វះការចូលរួម និង ជំរុញពីក្រុងស្រុក

<u>បញ្ហាអាទិភាពសំខាន់ៗ ដែលត្រូវដោះស្រាយចំពោះមុខ</u>

- ពង្រឹងការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកសាងផែនការនិងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ
- រៀបចំវគ្គបណ្តុះបណ្តាលការប្រមូលទិន្នន័យនានាស្តីពីការកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិរួមបញ្ចូលទាំងឧបករណ៍ប្រព័ន្ធទិន្នន័យនានា
- ពិនិត្យនិងធ្វើបច្ចុប្បន្នភាពទិន្នន័យនានាទៀងទាត់សម្រាប់ការកសាងផែនការ
- រៀបចំវេទិការពិគ្រោះយោបល់គម្រោងវិនិយោគបីឆ្នាំរំកិល និងដំណើរសិក្ខាសាលា(DIW)
- គាំទ្រការធ្វើអង្កេតសេដ្ឋកិច្ចសង្គម អង្កេតកំលាំងពលកម្មកុមារ និងការអង្កេតនានា...
- គាំទ្រការធ្វើជំរឿនសហគ្រាស លើកទី២ ឆ្នាំ២០២០
- រៀបចំធ្វើបច្ចុប្បន្នភាព ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- ពង្រឹងការគ្រប់គ្រងការរៀបចំ និង អនុវត្តការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ការគ្រប់គ្រងការរៀបចំ និង អនុវត្តការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការអនុវត្តផែនការ-ស្ថិតិ ប្រជាជននិងការអភិវឌ្ឍ និង វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

១.២.៣ ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

១.២.៣.១. វិស័យដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

វិស័យរៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ជាការងារជំនាញមួយ មានតួនាទីដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយ ស្របតាមទិសដៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង បំពេញការងារជាសេនាធិការជូនរដ្ឋបាលខេត្តក្នុងការបំពេញភារកិច្ចស្នូលទាំង ៤ ដូចជា ៖(១) រៀបចំដែនដីនិងនគរូបនីយកម្ម (២)ការងារសំណង់ (៣)ការងាររដ្ឋបាលដីធ្លី និង (៤)ការងារលំនៅឋាន។

ក្នុងដំណើរការនៃការអនុវត្តការងារស្នូលទាំង ៤ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកោះកុង បានចូលរួមចំណែកយ៉ាងសកម្មក្នុងវិស័យរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវលើការងារជំនាញដូចជា៖(១)**ការងារ**

រដ្ឋបាលដីធ្លី គឺជាការផ្តល់ជូនប្រជាពលរដ្ឋនូវកម្មសិទ្ធិ និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ការគ្រប់គ្រងដីធ្លីគ្រប់ប្រភេទ សំដៅលុបបំបាត់ភាពអនាធិបតេយ្យក្នុងការតាំងលំនៅដ្ឋាន និងការកាន់កាប់ដីដោយខុសច្បាប់,ការដោះស្រាយវិវាទដីធ្លីគ្រប់ប្រភេទ,ការអភិវឌ្ឍដីនិងការផ្សព្វផ្សាយច្បាប់ទាក់ទងនិងវិស័យដីធ្លី**(២)ការងារគ្រប់គ្រងសំណង់** គឺជាការផ្តល់ជូននូវលិខិតអនុញ្ញាតសាងសង់ ទាំងសំណង់ឯកជន សំណង់រដ្ឋ និងសំណង់ផ្សេងៗ, ការតាមដានត្រួតពិនិត្យការដ្ឋានសាងសង់,សំណង់គ្មានច្បាប់,សំណង់ខុសច្បាប់ សំដៅធានាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ការត្រួតពិនិត្យគុណភាព, បច្ចេកទេស និងសណ្តាប់ធ្នាប់សំណង់, លុបបំបាត់សំណង់អនាធិបតេយ្យ ,ធានានូវសោភ័ណភាព ជាសុខភាព និងការផ្សព្វផ្សាយច្បាប់ស្តីពីសំណង់**(៣)ការងាររៀបចំដែនដីនិងនគរូបនីយកម្ម**គឺជាការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខេត្ត ស្រុក/ក្រុង និងការធ្វើផែនទីប្រើប្រាស់ដីថ្នាក់ឃុំ/សង្កាត់សំដៅដល់ការប្រើប្រាស់ដីមានប្រសិទ្ធភាពស្របតាមទស្សនវិស័យនាពេលអនាគត **(៤)ការងារលំនៅឋាន** គឺជាការងារចងក្រងទិន្នន័យសំណង់បណ្តោះអាសន្ន ការសិក្សាពីសំណង់មានតម្លៃទាប តម្លៃមធ្យម ក្នុងគោលដៅបម្រើតម្រូវការប្រជាពលរដ្ឋ និងមន្ត្រីរាជការដែលមានចំណូលទាបអាចមានលទ្ធភាពរស់នៅ និងការងារសិក្សាទីតាំងដីសម្បទានសង្គមកិច្ចសំដៅធានាចីរភាព និងសមធម៌សង្គម ។

វឌ្ឍនភាពការងារឆ្នាំ២០១៨ :

១- ការងារច្រកចេញ ចូលតែមួយរបស់វិស័យដែនដី

+ ទទួលបានចំណូលសរុបប្រចាំឆ្នាំ**៧៤៤.០០០.០០០រៀល**ពីសេវាសុរិយោដីនិងសេវាសំណង់ និងពន្ធប្រថាប់ត្រាបង់នៅពន្ធដារខេត្តចំនួន **២.១៦៥.៩៣៩.០០០រៀល** ។

២- ការងាររដ្ឋបាលដីធ្លី

+ **ការងារចុះបញ្ជីជាប្រព័ន្ធ** : គូសក្រាភិច និងបញ្ចូលទិន្នន័យបាន : ១.០៨១ ក្បាលដី
- ចែកប័ណ្ណបានចំនួន : ៧៩ ក្បាលដី
+ **ការងារចុះបញ្ជីដោយដុំ** : ចេញប័ណ្ណគ្រប់ប្រភេទបានចំនួន : ១.០៦៧ ប័ណ្ណ
+ **ដោះស្រាយទំនាស់ដីធ្លី** : ចំនួន១៧ករណីធំៗ(រវាងប្រជាពលរដ្ឋនិងក្រុមហ៊ុន, ប្រជាពលរដ្ឋនិងដីរដ្ឋ)

៣- ការងាររៀបចំដែនដីនិងនគរូបនីយកម្មនិងសំណង់

- ការងារចុះបញ្ជីដីក្រុមហ៊ុន:បាននិងកំពុងអនុវត្តការងារចុះបញ្ជីដីក្រុមហ៊ុនចំនួន០២ក្រុមហ៊ុន នៅស្រុកបូទុមសាគរ ។
- ការងារកសាងប្លង់គោលថ្នាក់ស្រុក/ក្រុង:បាននិងកំពុងបន្តការងារធ្វើផែនទីប្រើប្រាស់ដីថ្នាក់ស្រុកគ្រប់ស្រុក និងបានឆ្លងការអនុម័តពីក្រុមប្រឹក្សាខេត្តក្នុងការចេញប្លង់គោលក្រុងខេមរភូមិន្ទ និងការងារបោះបង្គោលព្រំដីរដ្ឋ និងដីឯកជននៅស្រុកថ្មបាំង ។
- ការងារសំណង់ :បានចេញលិខិតអនុញ្ញាតសាងសង់ចំនួន ៨៨ គម្រោងក្នុងនោះ ៖
  + សំណង់ភូមិគ្រឹះចំនួន ០២ គម្រោង
  + សំណង់ផ្ទះល្វែងចំនួន ២២ គម្រោង
  + សំណង់ចំរុះចំនួន ៥៥ គម្រោង
  + សំណង់ពាណិជ្ជកម្ម និងសេវាកម្មចំនួន០៩ គម្រោង
  + ចេញវិញ្ញាបនប័ត្រលើកដំបូងក្រុមជាង១៣ ក្រុម

៤- ការងារលំនៅឋាន

- ដោយសារការងារលំនៅឋានជាការងារថ្មី និងដោយការផ្តល់បច្ចេកទេសពីប្រទេសជប៉ុន បច្ចុប្បន្នមន្ទីរបានបញ្ជូនមន្ត្រីចូលរួមវគ្គសិក្សា និងសិក្ខាសាលាចំនួន ០៨ លើក ។
- បានចុះស្រង់ទិន្នន័យសំណង់បណ្តោះអាសន្នតាមបណ្តាស្រុក/ក្រុងទាំង ៧ ។

ចំណុចខ្សោយ

- ខ្វះមន្ត្រីជំនាញសុរិយោដីដើម្បីសម្រេចគោលដៅការងារចុះបញ្ជីដីធ្លីជាប្រព័ន្ធ

- បញ្ហាទំនាស់ដីធ្លីមានសកម្មភាពខ្លាំងក្នុងខេត្តកោះកុង ដែលធ្វើឱ្យកកស្ទះការងារផ្សេងៗ
- បញ្ហាអនុក្រឹត្យលេខ ៨០ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃតាតៃ បានគ្របលើដីទីប្រជុំជនក្រុងខេមរភូមិន្ទ និងស្រុកមួយចំនួនដែលជាបញ្ហាលំបាកដល់ប្រជាពលរដ្ឋក្នុងការអនុវត្តសិទ្ធិ
- ការកំណត់ព្រំប្រទល់ដីឧទ្យានជាតិ ,អង្គការ wild aid ជាមួយដីឯកជនមិនទាន់ច្បាស់លាស់

បញ្ហាអាទិភាពសំខាន់ៗ ដែលត្រូវដោះស្រាយចំពោះមុខ

- ខិតខំជំរុញការងារចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងដាច់ដោយដុំឱ្យបានតាមផែនការកំណត់៤២.០០០ក្បាលដី នៅឆ្នាំ២០២១
- ជំរុញការប្រមូលទិន្នន័យគ្រប់គ្រង និងការប្រើប្រាស់ដី ដើម្បីជាមូលដ្ឋានច្បាស់លាស់ក្នុងការកសាងផែនទីប្រើប្រាស់និងបែងចែកដីឱ្យបានត្រឹមត្រូវ។ចំពោះវិស័យសំណង់នឹងខិតខំពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យនេះ ដោយផ្តោតការយកចិត្តទុកដាក់លើលិខិតបទដ្ឋានបច្ចេកទេស និងការទប់ស្កាត់ការសាងសង់មិនមានច្បាប់អនុញ្ញាត
- ជំរុញការកសាងប្លង់គោលក្រុងខេមរភូមិន្ទឱ្យបានឆាប់ចប់
- ការងារលំនៅឋាន បន្តការងារសម្បទានដីសង្គមកិច្ចនៅស្រុកគោលដៅទាំង៣គឺស្រុកបូទុមសាគរ ស្រុកកោះកុង និងស្រុកថ្មបាំង ព្រមទាំងការកសាងផែនទីដើម្បីគ្រប់គ្រងសំណង់បណ្តោះអាសន្នលើដីរដ្ឋ។

១.២.៣.២. វិស័យបរិស្ថាន

ត្រូវចាត់ទុកជាការងារអាទិភាពខ្ពស់ក្នុងការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ចំពោះកិច្ចអភិវឌ្ឍប្រកបដោយចីរភាពសំដៅផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍនសេចកិច្ច សង្គមកិច្ចរបស់សហគមន៍ដែលពាក់ព័ន្ធ។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខានៅឆ្នាំ ២០០៨ ច្បាប់នេះ ធ្វើឲ្យមានការបង្កើតនិតិវិធីគោលការណ៍ណែនាំ និងគោលការណ៍ច្បាប់នានាសម្រាប់ការងាររដ្ឋបាលនិងការគ្រប់គ្រង់លើតំបន់ការពារសម្រាប់ការការពារនូវសិទ្ធិ និងប្រពៃណី ទំនៀមទំម្លាប់របស់ជនជាតិដើមភាគតិច និងសម្រាប់ការបង្កើតតំបន់សហគមន៍ការពារធម្មជាតិដើម្បីស្វែងរកការចូលរួមរបស់ពួកគេក្នុងការគ្រប់គ្រង និងការប្រើប្រាស់ ប្រកបដោយចីរភាពនូវធនធានធម្មជាតិនិងក្នុងការប្រើប្រាស់ជីវចម្រុះ។ចំនួនសត្វព្រៃត្រូវបានសង្កេតឃើញថាមានការកើនឡើងនៅក្នុងតំបន់ការពារមួយចំនួន។

ខេត្តកោះកុងជាខេត្តមួយក្នុងចំណោមខេត្តដែលមានតំបន់ការពារធនធានធម្មជាតិទាំង២៥ខេត្តក្រុង នៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកខេត្តកោះកុងមានតំបន់ការពារធនធានធម្មជាតិចំនួន ៧ តំបន់ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់អគ្គរដ្ឋបាលតំបន់ការពារនៃក្រសួងបរិស្ថាន និងធនធានធម្មជាតិ និងមានការគ្រប់គ្រងផ្ទាល់ដោយមន្ទីរបរិស្ថានខេត្តជាសេនាធិការផ្ទាល់ឲ្យក្រសួង ។

តំបន់ការពារធនធានធម្មជាតិទាំង ៧ តំបន់នោះរួមមាន៖

១. ឧទ្យានជាតិបូទុមសាគរដែលមានទីតាំងស្ថិតនៅក្នុងស្រុក បូទុមសាគរ ស្រុកគីរីសាគរ និងស្រុក កោះកុង ខេត្តកោះកុង ដែលមានផ្ទៃដីទំហំ ១៧១.២៥០ ហិកតា និងមានព្រំប្រទល់ជាង៥០គាគរយ នៃឧទ្យានជាតិស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រខេត្តកោះកុង។ នៅក្នុងឧទ្យានជាតិបូទុមសាគរសំបូរដោយព្រៃស្ថិតនៅក្នុងសភាពល្អនៅឡើយ។

ដើម្បីអភិវឌ្ឍន៍ខាងផ្នែកសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានប្រគល់ដីសម្បទានក្នុងតំបន់ឧទ្យានជាតិដែលមានផ្ទៃដីសរុបចំនួន ៦៨.៨០៨,៥ហិកតាទៅឲ្យក្រុមហ៊ុនចំនួន ៦ សម្រាប់ធ្វើការអភិវឌ្ឍន៍លើវិស័យទេសចរណ៍ និងវិស័យកសិកម្ម។ ក្នុងនោះមានក្រុមហ៊ុន SINOMEXIM INVESTMENT CO.,LTD ក្រុមហ៊ុន JW CAMBODIA ECO HOLIDAY CO.,LTD ក្រុមហ៊ុន L.Y.P GROUP CO.,LTD ក្រុមហ៊ុន KOK KONG SEZ CO.,LTD ក្រុមហ៊ុន UNION DEVELOPMENT GROUP CO.,LTD និងក្រុមហ៊ុន GREEN RICH GROUP CO.,LTD ។ ដោយមានការសហការណ៍ជាមួយអង្គការដៃគូរ គម្រោងច្រករបៀងជីវចម្រុះមហាអនុតំបន់ទន្លេមេគង្គរបស់ធានាគារអភិវឌ្ឍន៍អាស៊ី ក្នុងការបង្កើតជាសហមគន៍តំបន់ការពារធម្មជាតិ និងបានជួយក្នុងការបង្កើតជាផែនការប្រើប្រាស់របស់សហគមន៍នៅក្នុងតំបន់ ដើម្បីជា

ប្រយោជន៍ក្នុងការគ្រប់គ្រងនិងប្រើប្រាស់ប្រកបដោយចីរភាព ។

២. ដែនជម្រកសត្វព្រៃពាមក្រសោបស្ថិតនៅក្នុងស្រុក មណ្ឌលសីមា ស្រុក កោះកុង និងក្រុង ខេមរភូមិន្ទ ដែលមានផ្ទៃដីទំហំ ២៣.៧៥០ ហិកតា ។ តំបន់ដែនជម្រកសត្វព្រៃពាមក្រសោបជាតំបន់សំបូរទៅដោយព្រៃកោងកាងច្រើនជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងជាព្រៃដែលធំបំផុតក្នុងឆ្នេរសមុទ្រកម្ពុជា ។ តំបន់វាំសារ ឬតំបន់ដីសើមស្ថិតនៅកោះកាពិ និងកូនកោះដែលពាក់ព័ន្ធ ជាវាលភក់ដែលជាជម្រកយ៉ាងសំខាន់សម្រាប់ដល់ពពួកជីវចម្រុះ និងសំបូរដោយព្រៃកោងកាង ព្រៃស្មាច់និងឆ្នេរខ្សាច់ តំបន់នេះក៏ជាផ្នែកមួយនៃតំបន់ការពារដែនជម្រកសត្វព្រៃពាមក្រសោបផងដែរ ។ នៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ក្រសួងបរិស្ថាន ក៏បានបង្កើតជាសហគមន៍តំបន់ការពារធម្មជាតិមានជាអាទិ៍ដូចជា ៖ សហគមន៍តំបន់ការពារធម្មជាតិ ពាមក្រសោប សហគមន៍តំបន់ការពារធម្មជាតិ បឹងកាឆាង សហគមន៍តំបន់ការពារធម្មជាតិ កោះស្រឡៅ សហគមន៍តំបន់ការពារធម្មជាតិ កោះកាពិ សហគមន៍តំបន់ការពារធម្មជាតិ ទួលគគីរ និងសហគមន៍តំបន់ការពារធម្មជាតិ ស្ទឹងវែង។ ដោយឡែកគម្រោងច្រករបៀងជីវចំម្រុះមហាអនុតំបន់ទន្លេមេគង្គបានជួយលើសហគមន៍ចំនួនពីរ គឺ សហគមន៍តំបន់ការពារធម្មជាតិ ពាមក្រសោប និងសហគមន៍តំបន់ការពារ ធម្មជាតិ បឹងកាឆាង លើការបោះបង្គោលព្រំប្រទល់ ហេដ្ឋារចនាសម្ព័ន្ធ និងជួយធ្វើផែនការគ្រប់គ្រងប្រកបដោយចីរភាពរបស់សហគមន៍ទាំងពីរ ។

៣. ដែនជំរកសត្វព្រៃភ្នំសំកុសស្ថិតនៅរយៈកំពស់ខ្ពស់ភាគខាងជើងទីរួមខេត្តកោះកុង ជាប់បណ្តោយព្រំដែនកម្ពុជា ថៃ នៅភាគខាងលិច និងជាប់ខេត្តពោធិសាត់នៅភាគខាងជើង ។ តំបន់នេះមានផ្ទៃដី ប្រមាណ ១០.០០០ ហិកតា សំបូរដោយព្រៃ និងមានថនិកសត្វធំៗជាច្រើន។

៤. តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែងស្ថិតនៅក្នុងស្រុក ស្រែអំបិល ខេត្ត កោះកុង ដែលមានផ្ទៃដីសរុបចំនួន ២៧.៧០០ហិកតា ដែលតំបន់ផ្តល់នូវភាពស្ថិតស្ថេរលើប្រភពទឹក ព្រៃឈើ សត្វព្រៃ ត្រី វាលស្មៅ និងការកំសាន្តដោយតម្រូវមានការអភិវឌ្ឍន៏ អភិរក្សធម្មជាតិគោលដៅចម្បងនៃសកម្មភាពសេដ្ឋកិច្ច ដូចនេះរាជរដ្ឋាភិបាលបានប្រគល់ដីសម្បទានចំនួន ៣២១ ហិកតាដល់ក្រុមហ៊ុន LIM LONG CO.,LTD ដើម្បីអភិវឌ្ឍន៏លើវិស័យកសិឧស្សាហកម្ម។ ដោយការមានការចូលរួមពីដៃគូរអភិវឌ្ឍន៏ក៏មានគម្រោងច្រករបៀងជីវចំម្រុះមហាអនុតំបន់ទន្លេមេគង្គ បានជួយក្នុងការបោះបង្គោលព្រំប្រទល់របស់សហគមន៍តំបន់ការពារធម្មជាតិ ជីខលើ និងបានជួយរៀបចំជាផែនការប្រើប្រាស់សម្រាប់សហគមន៍តំបន់ការពារធម្មជាតិ ជីខលើ ប្រកបដោយចីរភាព ។

៥. ដែនជម្រកសត្វព្រៃតាតៃ ស្ថិតនៅក្នុងស្រុក មណ្ឌលសីមា ស្រុក កោះកុង និងស្រុក ថ្មបាំង ដែលមានផ្ទៃដីទំហំ ១៤៤.២៧៥ហិកតា ។ ដែនជម្រកសត្វព្រៃតាតៃសំបូរទៅដោយព្រៃស្រោង និងថនិកសត្វ បក្សាបក្សី កម្រជាច្រើន ។ ដែនជម្រកសត្វព្រៃតាតៃបានសហការជាមួយអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ក្នុងគោលដៅការអភិរក្ស ប្រកបដោយចីរភាព សម្រាប់ការអភិវឌ្ឍន៏លើវិស័យទេសចរណ៏ធម្មជាតិ និងជាប្រភពទឹកសម្រាប់ធ្វើរីអគ្គិសនីផងដែរ ។

៦. ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ស្ថិតនៅក្នុងស្រុក ថ្មបាំង និងមួយផ្នែកភាគខាងជើងនៃឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលជាប់ជាមួយខេត្តពោធិសាត់ ដែលផ្ទៃដីទំហំ ២៣២.២៣១ហិកតា។ ឧទ្យានជាតិជួរភ្នំក្រវាញ កណ្តាល សំបូរទៅដោយព្រៃស្រោង និងថនិកសត្វ បក្សាបក្សី កម្រជាច្រើន ។ ដែនជម្រកសត្វព្រៃតាតៃបានសហការជាមួយអង្គការ C.I ក្នុងគោលដៅការអភិរក្ស ប្រកបដោយចីរភាព សម្រាប់ការអភិវឌ្ឍន៏លើវិស័យទេសចរណ៏ធម្មជាតិ និងជាប្រភពទឹកសម្រាប់ធ្វើរីអគ្គិសនីផងដែរ ។

៧. ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ស្ថិតនៅក្នុងស្រុក ថ្មបាំង ស្រុក កោះកុង ស្រុក បូទុមសាគរ ស្រុក មណ្ឌលសីមា ស្រុក ស្រែអំបិល និងជាប់ជាមួយខេត្ត ព្រះសីហនុ និងខេត្ត កំពង់ស្ពឺ ដែលផ្ទៃដីទំហំ ៣៨៤.៧០១ហិកតា។ ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង សំបូរទៅដោយព្រៃស្រោង និងថនិកសត្វ បក្សាបក្សី កម្រជាច្រើន ។ ដែនជម្រកសត្វព្រៃតាតៃបានសហការជាមួយអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ក្នុងគោលដៅការអភិរក្ស ប្រកបដោយចីរភាព សម្រាប់ការអភិវឌ្ឍន៏លើវិស័យទេសចរណ៏ធម្មជាតិ និងជាប្រភពទឹកសម្រាប់ធ្វើរីអគ្គិសនីផងដែរ ។

ក្រៅពីតំបន់ការពារធម្មជាតិទាំង៧ ខាងលើ វិស័យបរិស្ថានក៏មានការងារតាមដានរាល់ការបំពុល ដោយសំលេង ការបំពុលដោយផ្សែងជាដើមនិងមានការចុះផ្សព្វផ្សាយអប់រំស្តីពីច្បាប់បរិស្ថានទៅដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានផងដែរ ។

បញ្ហាប្រឈមដែលកើតមាន៖

- ដោយសំរាមមានការកើនឡើងជាប្រចាំថ្ងៃ ប្រជាពលរដ្ឋមួយចំនួនរស់នៅតាមបណ្តោយឆ្នេរ និងជាប់មាត់ព្រែកជាហេតុនាំអោយមានការប្រមូលសំរាមមានការលំបាកនិងក្រុមហ៊ុនមិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការប្រមូលសំរាមបច្ចេកទេសពេលវេលានិងកំលាំងពលកម្មគ្រប់គ្រាន់។ ដោយលែកទីលានចាក់សំរាមមានទំហំតូច និងនៅជិតទីប្រជុំជន ដែលមិនអាចផ្តុកសំរាមបានច្រើនទៅតាមតំរូវការរបស់ក្រុងខេមរភូមិន្ទបានទេ
- ចំពោះទីលានចាក់សំរាមគឺយើងមានតែនៅក្នុងក្រុងខេមរភូមិន្ទ និងស្រុកស្រែអំបិល ដែលមានទំហំតូច និងគ្មានលក្ខណៈបច្ចេកទេសក្នុងការគ្រប់គ្រង ចំពោះតាមបណ្តាលស្រុកដទៃទៀតគឺពុំទាន់មានទូវឡើយទេ ។
- បញ្ហាសំណល់រាវដែលចេញពីក្រុងខេមរភូមិន្ទត្រូវបានបង្ហូរចូលទៅក្នុងដៃព្រែក ឬប្រភពទឹកសាធារណៈដោយផ្ទាល់ ជាហេតុអាចនាំឲ្យមានការបំពុលទឹកទៅថ្ងៃអនាគត់
- បទល្មើសព្រៃឈើនៅតែមានជាបន្តបន្ទាប់ ដែលមានលក្ខណៈទ្រង់ទ្រាយតូច ទោះជាមានការល្បាតជាប្រចាំយ៉ាងក៏ ដោយ។ ប្រជាពលរដ្ឋមួយចំនួនតូចនៅមិនទាន់យល់ពីការអភិរក្សដើម្បីជាប្រយោជន៍ទៅថ្ងៃអនាគត់ ។

១.២.៣.៣. ស្ថានភាព នៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការបម្រែបម្រួលអាកាសធាតុ

ពាក់ពន្ធ័ទៅនឹងស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុយើងសង្កេតឃើញថាខេត្តកោះកុងធ្លាប់បានទទួលរងនូវការបាត់បង់ខូចខាតការបំផ្លិចបំផ្លាញ និងការប្រែប្រួលដែលបង្កឡើងដោយសារខ្យល់ព្យុះភ្លើងឆេះផ្ទះ និងការប្រែប្រួលអាកាសធាតុដូចជាភាពរាំងស្ងួតសីតុណ្ហភាពឡើងខ្ពស់ និងការកើនឡើងនៃកម្ពស់ទឹកសមុទ្រ ។ ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនាទស្សវត្សរ៍ចុងក្រោយនេះអាកាសធាតុមានការប្រែប្រួលផ្លាស់ប្តូរជាញឹកញាប់បង្កឡើងនូវគ្រោះមហន្តរាយដូចជាខ្យល់ព្យុះរន្ទះបាញ់អគ្គីភ័យដែលមានផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលចំពោះវិស័យសេដ្ឋកិច្ច-សង្គមកិច្ច ពិសេសការរស់នៅរបស់ប្រជាជន និងបានបំផ្លាញអាយុជីវិតទ្រព្យសម្បត្តិរបស់ប្រជាជនយ៉ាងច្រើន ។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង/ស្រុកឃុំ/សង្កាត់ និងភូមិត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីគ្រប់គ្រងឧបត្ថម្ភគាំទ្រ និងបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋនៅមូលដ្ឋានអំពីផលប៉ះពាល់និងមានវិធានការត្រៀមបង្ការទុកជាមុនដោយ កសាងប្រព័ន្ធផ្តល់ព័ត៌មាន និងបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយជាដើម។ បង្កើនការយល់ដឹងជាសាធារណៈអំពីសារប្រយោជន៍នៃធនធានធម្មជាតិ និងបរិស្ថាន លើកកម្ពស់ការបណ្តុះបណ្តាលយេនឌ័រ និងវប្បធម៌រហ័សរហួនដែលជាសមាសភាគរួមរបស់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ។ សន្តិសុខស្បៀងត្រូវបានបង្កើនសមត្ថភាពធន់ទ្រាំរបស់សហគមន៍ ធ្វើឱ្យមានស្មារតីសាមគ្គីភាពនិងសិល្បៈនៃការចែករំលែករួមសុខរួមទុក្ខនៅក្នុងសហគមន៍។ បង្ការទប់ស្កាត់ និងសង្គ្រោះឱ្យបាននូវគ្រោះភ័យនៃគ្រោះមហន្តរាយដែលបំផ្លិចបំផ្លាញដោយសារខ្យល់ព្យុះ ភ្លើងឆេះផ្ទះ ទឹកជំនន់ គ្រោះថ្នាក់ដោយសារភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនគ្រប់គ្រាន់ ភ្លៀងធ្លាក់ខុសរដូវ ឬច្រើនពេក ។ល។

១.២.៣.៤.សកម្មភាពមីនក្នុងខេត្ត

អនុក្រឹតលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសម្អាតមីន ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច បានកំណត់បន្ថែមនូវការទទួលខុសត្រូវរបស់អាជ្ញាធរមីន អាជ្ញាធរខេត្ត គណៈកម្មាធិការ សកម្មភាពមីនខេត្ត(ភីម៉ាក់) ក្រុមការងារផែនការសកម្មភាពមីន(ម៉ាពូ)ក្រុមការងារសកម្មមីនក្រុងស្រុក និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីសម្របសម្រួលដល់ដំណើរសកម្មភាពមីន។

សង្គ្រាមពីអតីតកាលបានបន្សល់ទុកនូវតំបន់មានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមយ៉ាងច្រើនឥតគណនា បានធ្វើឱ្យមនុស្សស្លាប់ របួស ពិការរាប់ម៉ឺននាក់ និងជាឧបសគ្គដល់ការអភិវឌ្ឍនានា។រហូតមកដល់បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជារួមនឹង ដៃគូរអភិវឌ្ឍន៍ បានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការឆ្លើយតបទៅនឹងតម្រូវការផ្នែកមនុស្សធម៌ និងការ

អភិវឌ្ឍដោយធ្វើការបោស សម្អាតមីនបានច្រើនម៉ឺនហិចតាជូនដល់ប្រជាពលរដ្ឋក្រីក្រនៅតាមសហគមន៍មូលដ្ឋាន។ប៉ុន្តែ ផលប៉ះពាល់ជាអវិជ្ជមានដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតែជាបញ្ហាចម្បងនៅឡើយចំពោះការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដែល នាំឱ្យរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកសកម្មភាពមីនជាអាទិភាពមួយយ៉ាងសំខាន់ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាទី១៨។

វិស័យសកម្មភាពមីនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់យ៉ាងខ្លាំងដោយបានដាក់ចេញជាគោលដៅទី ១៨ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ហើយបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណនិងចាត់ទុកជាសមាសធាតុមួយនៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ដើម្បីឆ្លើយតបនឹងការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល និងការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា អាជ្ញាធរមីនបានរៀបចំផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ប្រកបដោយគុណវុឌ្ឍិ និងបិរយោប័ន្ធ សម្រាប់ធ្វើផែនទីនាំផ្លូវ វិស័យសកម្មភាពមីននៅកម្ពុជា។

ដើម្បីរួមចំណែកអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធអភិវឌ្ឍន៍ជាតិសកម្មភាពមីន ២០១៨-២០២៥ ឱ្យទទួលបានជោគជ័យតម្រូវយុទ្ធសាស្ត្រចតុកោណនិង ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពពីស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ប្រតិបត្តិការបោសសម្អាតមីន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ការបោសសម្អាតមីន ត្រូវបានអនុវត្តតែលើតំបន់ដែលបានស្រាវជ្រាវ និងទិន្នន័យចម្ការមីន មូលដ្ឋាន។ គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត (ភីម៉ាក) មានសមាសភាព លោកអភិបាលរងខេត្តទទួលបន្ទុក ជាប្រធាន និងប្រធានមន្ទីរអង្គភាពជុំវិញខេត្ត អង្គភាព ពាក់ព័ន្ធជុំវិញខេត្ត មន្ត្រីបច្ចេកទេសនិងតំណាងស្ថាប័នថ្នាក់ជាតិ ប្រតិបត្តិការដោះមីន តំណាងភ្នាក់ងារអង្គការមិនមែនរដ្ឋាភិបាល សរុបរដ្ឋាភិបាលសរុប ៣១រូប។

ខេត្តកោះកុង មានគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ហៅកាត់ថា (ភីម៉ាក់) ដែលបង្កើតឡើង ដោយសេចក្តីសម្រេចរបស់រដ្ឋបាលខេត្តលេខ ០០៥/១៨ សសរ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ស្របតាមការណែនាំរបស់អាជ្ញាមីនដែលមានលោក **ផែង ផ្លាមកេសន អភិបាលរង នៃគណៈអភិបាលខេត្ត** ជាប្រធាន និងលោក **អៀត វណ្ណា** ប្រធានមន្ទីរផែនការខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍ ប្រធានមន្ទីរពាក់ព័ន្ធ អនុប្រធាន និងកម្លាំងប្រដាប់អាវុធទាំង ៣ ប្រធានមន្ទីរអង្គភាពពាក់ព័ន្ធជាមាជិក។ គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ហៅកាត់ថា (ភីម៉ាក់) មានភារកិច្ច៖

ជាមួយគ្នានេះគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ហៅកាត់ថា (ភីម៉ាក់) មានក្រុមការងារផែនការសកម្មភាពកំចាត់មីនខេត្ត ហៅកាត់ថា (ម៉ាពូ) ដែលបង្កើតឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលខេត្តលេខ ០៥៦/១៩ សសរ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៩ ជាសេនាធិការ ដោយមានមន្ត្រីចំនួន ០៨ រូប ស្រី ០១ រូប មកពីសាលាខេត្តកោះកុង ០២ រូប ស្រី ០១ រូប មន្ទីរផែនការ ០១ រូប និងមន្ទីរធនធានទឹក និងឧតុនិយម ០១ រូប។ ក្រុមការងារនេះ មាន លោក វ៉ន់ ស៊ីគូ ប្រធានការិយាល័យសរុប និងព័ត៌មានសាលាខេត្ត ជាប្រធាន លោក ប៊ុត ហ៊ន អនុប្រធានមន្ទីរផែនការខេត្ត អនុប្រធានអចិន្ត្រៃយ៍ លោក ឃឹម សម្បត្តិ ប្រធានការិយាល័យឧតុនិយម និងជលសាស្ត្រ នៃមន្ទីរធនធានទឹក និងឧតុនិយមខេត្ត អនុប្រធាន និងលោកស្រី គួយ សុខា មន្ត្រីអង្គភាពច្រក ចេញ ចូលតែមួយសាលាខេត្ត ជាសមាជិក។ ក្រុមការងារផែនការសកម្មភាពកំចាត់មីនខេត្ត ហៅកាត់ថា (ម៉ាពូ) គឺជាក្រុមបច្ចេកទេសអចិន្ត្រៃយ៍ ជាសេនាធិការសម្រាប់ជួយដល់គណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត ក្នុងការទទួលអនុវត្តនូវសេចក្តីសម្រេចនានាដែលចេញដោយគណៈកម្មាធិការសកម្មភាពកំចាត់មីនខេត្ត។

វឌ្ឍនភាពទិន្នន័យចំការមីន និងទំហំផ្ទៃដី

ខេត្តកោះកុង មានចំការមីនចំនួន ៣៦២ ស្មើនឹង ២.៤១២ ហិកតា គ្របដណ្តប់លើស្រុកចំនួន ០៦ មាន ស្រុកមណ្ឌលសីមា ស្រុកថ្មបាំង ស្រុកគីរីសាគរ ស្រុកបូទុមសាគរ ស្រុកកោះកុង និងស្រុកស្រែអំបិល និងឃុំចំនួន ១៥ មាន ឃុំប៉ាក់ខ្លង ឃុំថ្មដូនពៅ ឃុំជីផាត ឃុំជំនាប់ ឃុំថ្មដូនពៅ ឃុំប្រឡាយ ឃុំព្រែកខ្សាច់ ឃុំកោះស្តេច ឃុំតានូន ឃុំអណ្តូងទឹក ឃុំកណ្តោល ឃុំថ្មស ឃុំជ្រោយប្រស់ ឃុំត្រពាំងរូង ឃុំបឹងព្រាវ និងភូមិចំនួន ២១ មាន ភូមិចាំយាម ភូមិកោះប៉ោ ភូមិកោះ ភូមិជាំស្លា ភូមិជីផាត ភូមិជំនាប់ ភូមិព្រែកស្វាយ ភូមិសំរោង ភូមិព្រែកខ្សាច់ ភូមិព្រែកស្មាច់ ភូមិតានូន ភូមិជីត្រែះ ភូមិតាំកន់ ភូមិកណ្តោល ភូមិព្រលាន ភូមិថ្មស ភូមិចំការលើ ភូមិជ្រោយប្រស់ ភូមិត្រពាំងរូង និងភូមិបឹងព្រាវ។

ល.រ	ក្រុងស្រុក	ចំការមីន	ផ្ទៃដី		ផ្សេងៗ
			ឯកតា	បរិមាណ	
១.	ស្រុកមណ្ឌលសីមា	២៧៥ចំការ	ហ.ត	១.៧៧១,២	
	-ចាំយោម	២៦០	ហ.ត	១.៤៧៨,១	
	-កោះប៉ោ	១៥	ហ.ត	២៩៣,១	
២.	ស្រុកថ្មបាំង	១២ចំការ	ហ.ត	៤៨,៧	
	-កោះ	៥	ហ.ត	២២,៩	
	-ព្រៃកស្វាយ	២	ហ.ត	៦,៧	
	-ជាំស្លា	២	ហ.ត	១០,៦	
	-ជីផាត	១	ហ.ត	៥,២	
	-ជំនាប់	១	ហ.ត	០,៧	
	-សំរោង	១	ហ.ត	២,៦	
៣.	ស្រុកគិរីសាគរ	១៥ចំការ	ហ.ត	២៦៧,៦	
	-ព្រៃកខ្សាច់	៩	ហ.ត	១៧០,៨	
	-ព្រៃកស្មាច់	៦	ហ.ត	៩៦,៨	
៤.	ស្រុកបូទុមសាគរ	២៦ចំការ	ហ.ត	១៤៧,៥	
	-តានូន	២	ហ.ត	៣៩,៩	
	-ព្រៃកខ្សង	៤	ហ.ត	២៦,៦	
	-ជីត្រែះ	៤	ហ.ត	៣៤,៨	
	-ជីមាល	៤	ហ.ត	២០,៦	
	-តាំកន់	១	ហ.ត	៥,៥	
	-កណ្តោល	១	ហ.ត	២,៩	
	-ព្រលាន	១	ហ.ត	៥,៧	
	-ថ្មស	៣	ហ.ត	២,៨	
	-ចំការលើ	៦	ហ.ត	៨,៧	
៥.	ស្រុកកោះកុង	៣៣ចំការ	ហ.ត	១៦២,៣	
	-ជ្រោយប្រស់	៣០	ហ.ត	១៤៩,៣	
	-ត្រពាំងរូង	៣	ហ.ត	១៣,០	
៦.	ស្រុកស្រែអំបិល	១ចំការ	ហ.ត	១០,២	
	-បឹងព្រាវ	១	ហ.ត	១០,២	

កិច្ចប្រតិបត្តិការបោសសម្អាតមីន

ក្នុងខេត្តកោះកុង មានប្រតិបត្តិករចំនួន ០១ គឺប្រតិបត្តិករ HALO TRUST បានចូលមកធ្វើប្រតិបត្តិការបោសសម្អាតមីននៅភូមិចាំយោម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា នៅចុងឆ្នាំ២០១៨ ដែលមានបុគ្គលិកចំនួន ១០៩ នាក់ ក្នុងនោះមានក្រុមបោសសម្អាត ១០ ក្រុម, ក្រុមអប់រំផ្សព្វផ្សាយ (EOD) ០៣ ក្រុម និងក្រុមសិក្សាស្រាវជ្រាវ (MRE) ០២ ក្រុម។ ហើយក្នុងឆ្នាំ ២០២០ នឹងបន្ថែមកម្លាំងរហូតដល់ ១៨០ នាក់។ក្នុងឆ្នាំ២០១៩ ប្រតិបត្តិករ HALO TRUST បានធ្វើការបោសសម្អាតចំនួន

០៩ ចម្ការ លើផ្ទៃដីទំហំ ៣៥,៨ ហ.ត ជាលទ្ធផលប្រតិបត្តិករ បោសសម្អាតរួចបានផ្ទៃដីទំហំ ១៥,៩ ហ.ត រកឃើញ និង កម្ទេចមីនប្រឆាំងមនុស្ស (APM) ចំនួន ៩០៣ គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ERW)ចំនួន ៣២គ្រាប់។ (បញ្ជាក់៖ ក្នុងផែនការមានចម្ការមីនសរុបចំនួន ១២ ចម្ការ ផ្ទៃដីទំហំ ៥០,៨ ហ.ត)។

ការអប់រំផ្សព្វផ្សាយយល់ដឹងអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

ក្រុមការងារផែនការសកម្មភាពកំចាត់មីនខេត្ត បានសម្របសម្រួលជាមួយរដ្ឋបាលក្រុង ស្រុក និងបានចូលរួមជាមួយ ប្រតិបត្តិករ HALO TRUST ចុះអប់រំផ្សព្វផ្សាយយល់ដឹងអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមជាបន្តបន្ទាប់។ក្នុងឆ្នាំ២០១៩ ប្រតិបត្តិករ HALO TRUST បានអប់រំ និងផ្សព្វផ្សាយយល់ដឹងអំពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមបានចំនួន ០៨ លើក មានអ្នកចូលរួមស្តាប់ចំនួន ៧៦ នាក់ ស្រី ៤៣ នាក់ ក្នុងនោះកុមារក្នុងសាលា ៦២ នាក់ កុមារក្រៅសាលា ០៨ នាក់ និងចុះ អប់រំតាមផ្ទះចំនួន ១១ នាក់។

ការគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

ចំពោះការគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមកើតឡើង ០១ ករណី នៅថ្ងៃទី២៦/០៣/២០១៩ មានករណីផ្ទុះក្បាលគ្រាប់នៅចំណុចខាងក្រោយមណ្ឌលសុខភាពឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុងបណ្តាលអោយកុមារ ឈ្មោះ ភ័ក្រ ឆាយ៉ា ភេទប្រុស អាយុ៧ឆ្នាំ មានទីលំនៅភូមិត្រពាំងឈើត្រាវឃុំឫស្សីជ្រុំ ស្រុកថ្មបាំង រងរបួសជាច្រើនកន្លែង។ មូលហេតុមកពីក្មេងនោះយកគ្រាប់មកបោះលេង។

ចំនួនអ្នកទទួលផល

ប្រជាពលរដ្ឋដែលទទួលផលផ្ទាល់ពីការបោសសម្អាតមីនក្នុងឆ្នាំ២០១៩ មានប្រមាណ ០៨ គ្រួសារ ស្មើនឹង ៣១ នាក់ ស្រី ១១ នាក់ និងមានសិស្សានុសិស្សប្រមាណ ២០ នាក់ កំពុងសិក្សានៅសាលាភ្នំ ១០០ និងអ្នកទទួលផលប្រយោល មានចំនួន ១.២៥៣ គ្រួសារ ស្មើនឹង ៥.៤៨៥នាក់ ស្រី ១.៨៣៦ នាក់។ ដោយឡែកក្នុងឆ្នាំ២០២០ ប្រជាពលរដ្ឋ នឹងទទួល ផលផ្ទាល់ពីការបោសសម្អាតមីន មានចំនួន ៦៥គ្រួសារ ស្មើនឹង ២៤៦ នាក់ ស្រី ១១៣ នាក់ និងមានសិស្សានុសិស្ស ប្រមាណ ៧៥ នាក់ ដែលកំពុងសិក្សានៅសាលាចំនួន ០២ គឺសាលាបឋមសិក្សាគីរីវង្ស និងសាលាបឋមសិក្សាតាមូនដើមភ្លូ និងអ្នកទទួលផលប្រយោលមានចំនួន ១.២៦១ គ្រួសារ ស្មើនឹង ៧.៣៤២ នាក់ ស្រី ២.៧២២ នាក់។អ្នកទទួលភាគច្រើនជា ប្រជាពលរដ្ឋក្រីក្រ និងគ្រួសារកងទ័ព ដែលធ្វើកសិកម្មនៅតំបន់នោះ។

១.២.៤ ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

១.២.៤.១. ការគ្រប់គ្រងរដ្ឋបាល

ការអនុវត្តផែនរយៈពេលបីឆ្នាំនៃកម្មវិធីជាតិ(ជអ៣)ក្នុងរយៈពេលកន្លងមក បានបង្កើតឱ្យមានសមិទ្ធផលសំខាន់ៗ ជាច្រើនដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការជម្រុញដល់កិច្ចដំណើរការកំណែទម្រង់ប្រកបដោយភាពប្រាកដប្រជា ឆ្ពោះទៅ កាន់គោលដៅអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យ។វឌ្ឍនភាពសំខាន់ៗរួមមានដូចខាងក្រោម៖

- ខេត្តបានទទួលនូវគោលនយោបាយច្បាប់ គោលការណ៍ណែនាំ ឯកសារបណ្តុះបណ្តាលជាច្រើនត្រូវ បានអនុវត្ត និងកំពុងអភិវឌ្ឍ ពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី និងបុគ្គលិកនៅថ្នាក់រដ្ឋ បាលខេត្ត ក្រុងស្រុក ឃុំសង្កាត់ និងអ្នកពាក់ព័ន្ធនានា។ សមត្ថភាពនិងការយល់ដឹងអំពីកំណែទម្រង់វិម ជ្ឈការ និងវិសហមជ្ឈការ កំពុងមានការរីកចំរើនកើនឡើង។
- បានរៀបចំរចនាសម្ព័ន្ធថ្មី និងធ្វើសមាហរណកម្មមន្ត្រី និងបុគ្គលិកទៅក្នុងរចនាសម្ព័ន្ធថ្មី ជាមួយគ្នានេះដែរ ប្រព័ន្ធកសាងផែនការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បានអនុវត្តនៅថ្នាក់ក្រុងស្រុក និងឃុំសង្កាត់។
- រដ្ឋបាលក្រុងស្រុក ជាថ្នាក់រដ្ឋបាលដែលមានតួនាទីជាសំខាន់មួយក្នុងនាមជារដ្ឋបាលមូលដ្ឋានត្រូវបានពង្រឹង នូវការគ្រប់គ្រងចាត់ចែងធនធានមនុស្សសម្រាប់ការអភិវឌ្ឍមូលដ្ឋាននិងការផ្តល់សេវាសាធារណៈ។
- អនុក្រឹតស្តីពីការធ្វើប្រតិភូកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការចាត់ចែងបុគ្គលិកនៅ រដ្ឋ

បាលថ្នាក់ក្រោមជាតិត្រូវបានចាប់ផ្តើមអនុវត្ត។

- ច្បាប់ស្តីពីហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្កើតមូលនិធិក្រុងស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង-ស្រុក បានវិភាជន៍មូលនិធិក្រុង-ស្រុក ទៅឱ្យក្រុង-ស្រុកនីមួយៗ និងការអនុវត្តប្រព័ន្ធមូលនិធិឃុំ-សង្កាត់ ប្រកបដោយជោគជ័យគួរឱ្យកត់សម្គាល់នៃការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុតាមបែបវិមជ្ឈការ ។
- អនុវត្តសេចក្តីណែនាំបច្ចេកទេសស្តីពីវេទិការផ្សព្វផ្សាយនិងពិគ្រោះជាសាធារណៈ និងស្តីពីកិច្ចប្រជុំរបស់ក្រុមក្រុមប្រឹក្សាខេត្ត ក្រុងស្រុកគឺជាការឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការពង្រឹងក្របខ័ណ្ឌគណនេយ្យភាពបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។
- បានធ្វើការគាំទ្រយ៉ាងសកម្មដល់ក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការអនុវត្តប្រព័ន្ធនានារបស់ឃុំសង្កាត់ដូចជា៖ ប្រព័ន្ធផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ប្រព័ន្ធហិរញ្ញវត្ថុ ឃុំសង្កាត់...។ល។

ជាមួយនឹងការសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈខាងលើ ការអនុវត្តជួបប្រទះបញ្ហាប្រឈមជាច្រើនផងដែរ។**បញ្ហាប្រឈមជាចម្បងៗទាំងនោះរួមមាន៖**

- ប្រព័ន្ធការងារសម្រាប់ប្រតិបត្តិការ មានធនធានមនុស្សសម្រាប់ការអនុវត្តប្រព័ន្ធការងារនៅមានកម្រិតនៅឡើយ គួបផ្សំការផ្ទេរធនធាន និងមុខងារនៅមានកម្រិតផងដែរ។
- គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិសំខាន់ៗដើម្បីគាំទ្រ និងផ្តល់លទ្ធភាពក្នុងការពង្រឹងការទទួលខុសត្រូវ ពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិគ្រប់គ្រងមន្ត្រីរាជការបុគ្គលិក ការបង្កើនប្រភពចំណូលបន្ថែមដល់រដ្ឋបាលក្រុងស្រុក ឃុំសង្កាត់ ការរៀបចំយន្តការផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគដល់រដ្ឋបាលខេត្តក្រុងស្រុក ឃុំសង្កាត់ នៅមានកម្រិតនៅឡើយ។
- ការអភិវឌ្ឍសមត្ថភាពដើម្បីកិច្ចប្រតិបត្តិការអនុវត្តមុខងារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស ការធ្វើផែនការអភិវឌ្ឍន៍ ការអនុវត្តគម្រោង ការតាមដានត្រួតពិនិត្យនៅតែជាតម្រូវការអាទិភាពនូវវគ្គបណ្តុះបណ្តាលជាចាំបាច់ដើម្បីអភិវឌ្ឍន៍ស្ថាប័ន។
- ពង្រឹងយន្តការត្រួតពិនិត្យនីតិានុកូលភាព ព្រមទាំងការរៀបចំយន្តការនានាសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការត្រួតពិនិត្យការអនុវត្តការងារក៏ដូចជាការរៀបចំនូវយន្តការដោះស្រាយទំនាស់ នៅមូលដ្ឋាននៅមិនទាន់បានល្អប្រសើរនៅឡើយ។

១.២.៤.២. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

កិច្ចការការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តគឺជាកិច្ចការចម្បង និងចាំបាច់បំផុត។ ការបន្តថែរក្សាពង្រឹងការអនុវត្តច្បាប់ បទបញ្ជានានា ការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសទាំងដែនគោក និង ដែនទឹកត្រូវបាននឹងកំពុងចាត់វិធានការយ៉ាងសស្រាក់សស្រាំជាប់ជាប្រចាំ ។ អាជ្ញាធរខេត្តបានប្រើប្រាស់គ្រប់ធនធាន និងមធ្យោបាយទាំងអស់ដើម្បីបន្តពង្រឹង និងធានាសន្តិសុខកាត់បន្ថយឱ្យបានច្រើននូវបទល្មើសផ្សេងៗ ពង្រឹងការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋក្នុងខេត្ត គ្រប់ទិដ្ឋភាពទាំងអស់ ដើម្បីផ្តល់នូវឱកាស ជូនប្រជាពលរដ្ឋគ្រប់ប្រកបដោយសមធម៌។

នៅថ្នាក់ខេត្ត ក្រុង ស្រុក ដែលជាថ្នាក់រដ្ឋបាលក្រោមជាតិ អនុវត្តយ៉ាងសកម្មនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុងស្រុកខណ្ឌ ។ អនុវត្តដោយគណនេយ្យភាព តម្លាភាព លើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្តល់សេវាសាធារណៈជូនប្រជា ពលរដ្ឋ និងបានដំណើរការអនុវត្តកម្មវិធីតាមការិយាល័យច្រកចេញចូលតែមួយខេត្ត និងនៅក្រុងស្រុកមួយចំនួន ។ អាណត្តិទី២ នៃក្រុមប្រឹក្សាខេត្តកន្លងទៅរដ្ឋបាលខេត្តប្រើប្រាស់យន្តការគណៈបញ្ជាការឯកភាពខេត្តបាន៖

- អនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវទាំងក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ឃុំសង្កាត់ ស្របតាមច្បាប់កំណត់។ បានពង្រឹងការគ្រប់គ្រងដែនដីរបស់រដ្ឋបាលគ្រប់

ថ្នាក់ ដោយផ្តោតទៅលើការអនុវត្តច្បាប់ម្ចាស់ការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់ សោភ័ណភាពនិងការអភិវឌ្ឍដែលមាននិរន្តភាព និងគ្រប់ជ្រុងជ្រោយ តាមរយៈយន្តការក្រុមប្រឹក្សា គណៈអភិបាល គណៈបញ្ជាការឯកភាពរដ្ឋបាល និងគណៈកម្មាធិការនានា ស្របតាមនិតិវិធី ការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល ពិសេសពង្រឹងការផ្តល់សេវាតាមច្រកចេញចូលតែមួយ, ការគ្រប់គ្រងគ្រោះមហន្តរាយ និងដោះស្រាយបញ្ហាបានទាន់ ពេលវេលាជូនប្រជាពលរដ្ឋងាយរងគ្រោះ, ការគ្រប់គ្រងបរិស្ថាន និងដោះស្រាយបញ្ហាសម្រាមនៅគ្រប់ក្រុងស្រុក ។

- ពង្រឹងការអនុវត្តច្បាប់ មានប្រសិទ្ធភាព ធានាសមភាព និងយុត្តិធម៌ សម្រាប់ប្រជាជនចំពោះមុខច្បាប់ រួមទាំងរាំងស្កាត់ រាល់ទម្រង់នៃការប្រើប្រាស់សិទ្ធិអំណាចបំពានលើច្បាប់ និងអំពើហឹង្សាគ្រប់រូបភាព។ លើកស្ទួយសិទ្ធិសេរីភាពរបស់ប្រជាជន ជាអាទិ៍៖ សិទ្ធិមានជីវិតរស់នៅ សិទ្ធិប្រកបរបរចិញ្ចឹមជីវិត សិទ្ធិបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងជំនឿសាសនា... ពង្រឹកកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិលដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ។
- បានលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាជនល្អប្រសើរ ពោលគឺជាសេវាសាធារណៈបានផ្តល់ជូនប្រជាជន ទទួលបានការជឿទុកចិត្តពីប្រជាជន។
- ចូលរួមអនុវត្តយ៉ាងសកម្មដំណើរការកែទម្រង់រដ្ឋដ៏ស៊ីជម្រៅនិងទូលំទូលាយរបស់រាជរដ្ឋាភិបាលរួមមាន៖ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់ដីធ្លី ជលផល ការគ្រប់គ្រងព្រៃឈើ ធនធានធម្មជាតិនិងបរិស្ថាន...។ល។

ទោះបីយើងសម្រេចបានលទ្ធផលល្អគួរជាទីមោទនៈតែយើងនៅមានបញ្ហាប្រឈមគឺ៖

- ការយល់ដឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុកខណ្ឌ និងច្បាប់ផ្សេងៗទៀតរបស់ប្រជាពលរដ្ឋមិនមានលក្ខណៈស៊ីជម្រៅនៅឡើយ
- បរិមានមន្ត្រី បុគ្គលិកដែលបំពេញការងារ មិនសមស្របទៅនឹងទំហំការងារជាក់ស្តែង គុណភាពនិងសមត្ថភាពរបស់មន្ត្រី នៅមានកម្រិត។ ការផ្លាស់ប្តូរផ្នត់គំនិត ទម្លាប់ក្នុងការបំពេញការងារនៅពុំទាន់ជាអ្នកបំរើសេវាសាធារណៈល្អប្រសើរនៅឡើយ។

១.២.៤.៣.ការអប់រំផ្សព្វផ្សាយច្បាប់

តាមរយៈមន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តបានសម្របសម្រួលទំនាក់ទំនងការងារជាមួយសមាជិក រដ្ឋសភា-ព្រឹទ្ធសភា អាជ្ញាធរ គ្រប់លំដាប់ថ្នាក់ និងបានចុះធ្វើអធិការកិច្ច លើគ្រប់វិស័យក្នុងរង្វង់ដែនដីសមត្ថកិច្ច តាមបណ្តាមន្ទីរ អង្គភាពនានា គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ លើវិធានការបង្ក្រាបបង្ការ ទប់ស្កាត់ សំដៅប្រឆាំងអំពើ ពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានាក្នុងជួរមន្ត្រីរាជការស៊ីវិល មន្ត្រីយោធា និងមន្ត្រីនគរបាល ដែលធ្វើ អោយប៉ះពាល់ដល់ការស្ថារនិងការអភិវឌ្ឍ និងអញ្ជើញជនដែលពាក់ព័ន្ធតាមរយៈសមត្ថកិច្ចដែលគ្រប់គ្រងជនទាំងនោះ ដើម្បីបំភ្លឺ សាកសួរ ស្រាវជ្រាវ ព័ត៌មាន ពិនិត្យឯកសារ និងចូលរួមសហការក្នុងសកម្មភាពអធិការកិច្ច។តាមដានរាល់ការអនុវត្តច្បាប់សេចក្តី សម្រេចគោលនយោបាយថ្មីៗ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលចូលជាធរមាន ដើម្បីធានាការអនុវត្តន៍ច្បាប់។ បានផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានទាន់ពេលវេលាជៀសវាងនូវទំនាស់ដែលកើតឡើងរវាងប្រជាពលរដ្ឋ នឹងប្រជាពលរដ្ឋ និងរវាងប្រជាពលរដ្ឋនឹងអាជ្ញាធរ។

ទោះបីមានកិច្ចខិតខំយ៉ាងសកម្មក្តី នៅតែជួបបញ្ហាប្រឈមមួយចំនួនគឺ៖

- ប្រជាពលរដ្ឋខ្វះការយល់ដឹងពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ការយល់ដឹងអំពីច្បាប់ និងការគោរពច្បាប់នៅមានកម្រិតក្នុងចំណោមទូទៅ ដែលបង្កឱ្យរាំងស្ទះដល់ដំណើរការពង្រឹងនីតិរដ្ឋការអនុវត្តច្បាប់មិនបានពេញលេញ
- ការដោះស្រាយទំនាស់របស់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ជូនប្រជាពលរដ្ឋមិនទាន់ពេលវេលា ដែលធ្វើ

ឱ្យទំនាស់ ខ្លះមានភាពអូសបន្លាយរយៈពេលវែង

- ការអនុវត្តច្បាប់របស់មន្ត្រីមានសមត្ថកិច្ចមួយចំនួននៅមានកម្រិត

១.២.៤.៤.អន្តោប្រវេសន៍និងចំណាកស្រុក

ក-អន្តោប្រវេសន៍

- ការគ្រប់គ្រងវត្តមានជនបរទេសដែលស្នាក់នៅក្នុងខេត្ត សំដៅរកឱ្យឃើញមុខសញ្ញាគេរវកម្មឧក្រិដ្ឋកម្មឆ្លងព្រំដែនការស្នាក់នៅខុសច្បាប់ ដើម្បីបង្ក្រាបទាន់ពេលវេលារាល់សកម្មភាពល្មើសច្បាប់ដែលប្រព្រឹត្តឡើងដោយជនបរទេស និងរួមចំណែកថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាពដល់ជនបរទេសដែលចេញចូលស្នាក់អាស្រ័យនៅក្នុងខេត្ត ព្រមទាំងប្រជាពលរដ្ឋ និងសង្គមជាតិកម្ពុជាទាំងមូលចូលរួមលើកស្ទួយវិស័យទេសចរណ៍ សេដ្ឋកិច្ច និងវិស័យផ្សេងៗទៀតជំរុញការអភិវឌ្ឍក្នុងខេត្តឱ្យកាន់តែប្រសើរឡើង ។

ខ-ចំណាកស្រុក

- យោងតាមទិន្នន័យប្រចាំឆ្នាំ២០១៩ ដែលប្រមូលបានពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរបស់ស្នងការដ្ឋាននគរបាលខេត្តកោះកុង មានប្រជាពលរដ្ឋបានធ្វើចំណាកស្រុក សរុបចំនួន១.៥៣៧ នាក់ ស្រី៖៧០៨នាក់ ក្នុងនោះចំណាកស្រុក ស្របច្បាប់មានចំនួន ២២២នាក់ ស្មើនឹង ១៤% និងមិនស្របច្បាប់សរុបចំនួន ១.៣១៥នាក់ ស្មើនឹង ៨៦% បើធៀបទៅនឹងប្រជាពលរដ្ឋដែលចំណាកស្រុក ទៅក្រៅប្រទេសទាំងអស់ ។





សរុបរួម				ស្របច្បាប់		មិនស្របច្បាប់				ជាប់ទំនាក់ទំនង (រយៈពេលលើសពី១ឆ្នាំ)				ត្រឡប់មកវិញ			
សរុប	ស្រី	អនីតិជន		សរុប	ស្រី	សរុប	ស្រី	អនីតិជន		សរុប	ស្រី	អនីតិជន		សរុប	ស្រី	អនីតិជន	
		ប	ស					ប	ស			ប	ស			ប	ស
១៥៣៧	៧០៨	៦៥	៣៤	២២២	១០៨	១៣១៥	៥៥៣	៣៤	២៧	១៨៨	៨៥	១៧	១៧	៥២	២៨	០៥	០៣

ជំពូកទី២

ក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ
សម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាខេត្ត

២.១. ចក្ខុវិស័យអភិវឌ្ឍន៍ខេត្ត

ផែនការអភិវឌ្ឍន៍ខេត្ត អាណត្តិទី៣របស់ក្រុមប្រឹក្សាខេត្ត ដោយផ្អែកទៅតាមឯកសារគោលរបស់ថ្នាក់ជាតិសំខាន់ៗ ចំនួនពីរ ទី១.កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងទី២.ចក្ខុវិស័យរយៈពេលវែង គឺចក្ខុវិស័យ ឆ្នាំ២០៣០ ដែលបង្ហាញពីការចាកចេញរបស់កម្ពុជា ពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានចំណូលកម្រិតខ្ពស់ និងចក្ខុវិស័យឆ្នាំ២០៥០ ដែលកំណត់ថា កម្ពុជានឹងក្លាយជាប្រទេសដែលមានចំណូលខ្ពស់។

ដូច្នេះ ចក្ខុវិស័យរួមរបស់រដ្ឋបាលខេត្តកោះកុង គឺៈ កសាងនូវសង្គមមួយដែលរឹងមាំ មានសន្តិភាព ស្ថិរភាពនយោបាយ មានសន្តិសុខ និងសណ្តាប់ធ្នាប់ល្អ មានការអភិវឌ្ឍប្រកបដោយចីរភាព និងប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស មានការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលប្រជាជននៅក្នុងខេត្ត មានចំណេះដឹងខ្ពស់ និងមានវប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងគ្រួសារ និងសង្គមជាតិ។

តាមចក្ខុវិស័យខាងលើ រដ្ឋបាលខេត្ត យកចិត្តទុកដាក់ជំរុញការផ្លាស់ប្តូរបានសម្ព័ន្ធក្នុងដំណាក់កាលបួនសំខាន់ គឺៈ ១. ការអភិវឌ្ឍធនធានមនុស្ស សំដៅលើកកម្ពស់ ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពល្អ កាយសម្បទារឹងមាំ តួនាទីស្ត្រី និងកិច្ចគាំពារសង្គម។ ២. ការធ្វើពិពិធកម្មសេដ្ឋកិច្ច តែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ទាំងផ្លូវខេត្ត ផ្លូវក្រុង ស្រុក និងផ្លូវឃុំ សង្កាត់ រួមទាំងថាមពល និងទឹកស្អាត ប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និទ្ធបំពេញឲ្យគ្នាទៅវិញទៅមក និងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហ៍កម្ម។ ៣. ការអភិវឌ្ឍវិស័យឯកជន និងការងារ រដ្ឋបាលខេត្តគាំទ្រយ៉ាងពេញទំហឹង នៅការអភិវឌ្ឍសេដ្ឋកិច្ចទីផ្សារ ស្របទៅតាមអភិក្រមបួន គឺៈ ១). ការអភិវឌ្ឍទីផ្សារការងារ ២). ការលើកស្ទួយសហគ្រិនខ្នាតតូច និងមធ្យម ៣).ការរៀបចំ និងអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន និង៤). ការពង្រឹងការប្រកួតប្រជែង។ ៤. ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន រដ្ឋបាលខេត្ត យកចិត្តទុកដាក់លើការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន ដោយជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ ឆ្លើយតបទៅនឹង«**គោលនយោបាយអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា**» ការកំណត់នូវបញ្ហាប្រឈមសំខាន់ៗ កំណើនទាបក្នុងវិស័យកសិកម្ម ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានធម្មជាតិនៅមានកម្រិត ការរីកចម្រើននគរូបនីយកម្មក្នុងសន្ទុះលឿន ដែលមិនទាន់បានធានានូវតុល្យភាព និងភាពចាំបាច់ក្នុងការបង្កើនសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ។ ដូចនេះ រដ្ឋបាលខេត្ត ត្រូវការយកចិត្តទុកដាក់លើៈ ១). លើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ២). អភិវឌ្ឍន៍វិស័យទេសចរណ៍ និងការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ ប្រកបដោយចីរភាព ៣). ពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និង៤). ធានាចីរភាព បរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងប្រែប្រួលអាកាសធាតុ។

២.២. គោលបំណងអភិវឌ្ឍន៍ខេត្ត

«ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ» របស់រដ្ឋបាលខេត្ត ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់នូវចក្ខុវិស័យ ក្របខណ្ឌសេចក្តីណែនាំផ្នែកគោលនយោបាយ ក្របខណ្ឌសម្របសម្រួល និងយន្តការគាំទ្រ សម្រាប់ជំរុញការអភិវឌ្ឍគ្រប់វិស័យ ដើម្បីឲ្យសម្រេចបាននូវចក្ខុវិស័យខាងលើ។ កម្មវត្ថុសំខាន់ក្នុង **«ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ»** គឺ ជំរុញការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមកិច្ច ក្នុងការវិនិយោគរចនាសម្ព័ន្ធរូបវ័ន និងអរូបវ័ន ទាំងផ្នែករឹង និងផ្នែកទន់ ឲ្យសមស្របតាមសក្តានុពលរបស់ខេត្ត ដោយមានការប្រកួតប្រជែង តាមសភាពការណ៍វិវត្តន៍នៃសេដ្ឋកិច្ច។ **«ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ»** ក៏មានគោលបំណងដាក់ចេញនូវវិធានប្រទាក់ក្រឡាគ្នានៃផ្នែកទាំងបួន តាមកម្រិតវិស័យនីមួយៗ និងអន្តរគមន៍ជាក់លាក់ តាមតម្រូវការជាក់ស្តែង ហើយមានវិសាលភាពគ្របដណ្តប់រយៈពេលប្រាំឆ្នាំ(២០២០-២០២៤) និងត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំតាមរយៈកម្មវិធីវិនិយោគបីឆ្នាំរំកិល។

២.២.១. គោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច

រដ្ឋបាលខេត្តនឹងលើកកម្ពស់ការវិនិយោគលើគ្រប់វិស័យនៃផ្នែកសេដ្ឋកិច្ចប្រកបដោយគុណភាពខ្ពស់ ដើម្បីផ្តល់ឱកាសឲ្យប្រជាពលរដ្ឋមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបាននូវផលប្រយោជន៍ ពីវិស័យទាំងនោះ ទៅតាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន ដើម្បីធានាបាននូវបរិមាណស្បៀង និងចំណីអាហារគ្រប់គ្រាន់សម្រាប់ហូបចុកនិងនាំចេញ ព្រមទាំងបន្ថែមមុខរបរ ផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដែលអាចបង្កើនប្រាក់ចំណូលប្រចាំគ្រួសារកាន់តែច្រើន រួមចំណែកកាត់បន្ថយភាពក្រីក្រនៅទូទាំងខេត្ត ដែលរួមមានគោលបំណងដូចខាងក្រោម៖

វិស័យកសិកម្ម

- បង្កើនទិន្នផលកសិកម្មឱ្យប្រសើរឡើង
- ជំរុញការចិញ្ចឹមសត្វ

វិស័យជលផល

- ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

វិស័យធនធានទឹក និងឧតុនិយម

- ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក
- ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត
- ការគ្រប់គ្រងពត៌មានស្តីពីធានធានទឹក និងឧតុនិយម
- ការកែលម្អការគ្រប់គ្រងរដ្ឋបាល និងអភិវឌ្ឍន៍ធនធានមនុស្ស

វិស័យរ៉ែ និងថាមពល

- ពង្រឹកការដឹកជញ្ជូនដីឲ្យមានសណ្តាប់ធ្នាប់ និងមិនឲ្យមានការធ្លាក់រាយប៉ាយនៅលើដងផ្លូវសាធារណៈ
- ជំរុញសេវាកម្មអគ្គិសនីឲ្យផ្តត់ផ្តង់ថាមពលអគ្គិសនីនៅតាមភូមិ ឃុំ ស្រុក បានគ្រប់ភូមិ
- ជំរុញស្តានីយ៍ប្រេង និងឧស្ម័នឥន្ធនៈឲ្យមានច្បាប់អនុញ្ញាតដំណើរការស្តានីយទាំងអស់

វិស័យឧស្សាហកម្មនិងសិប្បកម្ម

- រោងចក្រ សហគ្រាស និងសិប្បកម្ម អាជីវកម្មទឹកស្អាតទាំងអស់ យល់ដឹងអំពីច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ និងជំរុញការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាព

វិស័យសាធារណការ និងដឹកជញ្ជូន

- ការជួសជុល និងកែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធរំដោះទឹក
- ការត្រួតពិនិត្យលើមធ្យោបាយដឹកលើសទម្ងន់តាមផ្លូវគោក

វិស័យទេសចរណ៍

- ត្រូវការចាំបាច់នូវមន្ត្រីជំនាញបម្រើតាមផ្នែកសហគមន៍ ឧស្សហកម្ម ព័ត៌មានទេសចរណ៍ គ្រប់គ្រងឆ្នេរ និងទីក្រុងស្អាតក្នុងវិស័យទេសចរណ៍
- វិស័យទេសចរណ៍ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិរក្សសម្បត្តិវប្បធម៌ ការការពារបរិស្ថានធនធានធម្មជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងសហគមន៍

វិស័យពាណិជ្ជកម្ម

- ពង្រឹង និងជម្រុញការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម

- បង្កើនអនុលោមភាពតាមច្បាប់ដោយស្មគ្រចិត្ត និងកាត់បន្ថយជាអតិបរិមានូវបន្ទុកអ្នកជាប់ពន្ធ ដោយ ផ្តល់សេវាប្រកបដោយគុណភាព

វិស័យពន្ធដារ គយ និងរដ្ឋាករ

- បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ
- បង្កើនការប្រមូលចំណូលពន្ធគយនិងរដ្ឋាករ

វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

- ក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់នៅក្នុងខេត្តនឹងសហការផ្តល់ទិន្នន័យការងារធ្វើសេវាសាងសង់ រុះរើបណ្តាញរបស់ខ្លួនមកមន្ទីរអោយបានជ្រាប
- តំបន់ដាច់ស្រយ៉ាលមួយចំនួននៅក្នុងខេត្តនឹងមានសេវាទូរស័ព្ទប្រើប្រាស់បានគ្រប់គ្រាន់ សម្រាប់២ឃុំក្នុងស្រុកថ្មបាំង
- នឹងមានភ្នាក់ងារប្រៃសណីយ៍ នៅបណ្តាស្រុកទាំង ០៦

វិស័យអភិវឌ្ឍជនបទ

- ប្រជាពលរដ្ឋនៅជនបទនឹងងាយស្រួលក្នុងការធ្វើដំណើរ និងដឹកជញ្ជូន
- នៅឆ្នាំ២០២៤ប្រជាពលរដ្ឋនៅជនបទនឹងមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ និងអនាម័យជនបទត្រូវបានលើកកម្ពស់
- គណៈកម្មការអភិវឌ្ឍន៍ភូមិ និងប្រជាពលរដ្ឋមានចំណេះដឹងក្នុងការរៀបចំផែនការអភិវឌ្ឍន៍ភូមិ និងសហគមន៍សន្សំប្រាក់
- កំណត់អត្តសញ្ញាណជនជាតិដើមភាគតិចនៅក្នុងខេត្តកោះកុង
- ប្រជាពលរដ្ឋនឹងមានជីវភាពប្រសើឡើងតាមរយៈការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលការងារ

វិស័យធនាគារ និងហិរញ្ញវត្ថុ

- ជម្រុញការប្រើប្រាស់ និងការផ្តល់សេវាធនាគារនិងហិរញ្ញវត្ថុអោយមានការរីកចម្រើន
- ជម្រុញការប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយ
- ពង្រឹងការគ្រប់គ្រងអាជីវកម្មប្តូរប្រាក់ឱ្យមានប្រសិទ្ធភាពខ្ពស់
- ទប់ស្កាត់ការចរាចរក្រដាសប្រាក់ក្លែងក្លាយនៅក្នុងខេត្ត
- ពង្រឹងនិងបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងសេដ្ឋកិច្ចនិងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ពង្រឹងនិងបង្កើនស័ក្តិភាពនិងប្រសិទ្ធភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋ
- ធានាបាននូវការបញ្ជូនអាណត្តិបើកប្រាក់របស់មន្ទីរអង្គភាពសាធារណៈបានទាន់ពេលវេលា
- ការវិភាជន៍មូលនិធិជូន ក្រុង ស្រុក ឃុំ សង្កាត់បានទាន់ពេលវេលា

២.២.២. គោលបំណងអភិវឌ្ឍន៍សង្គមកិច្ច

លើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋ តាមរយៈការផ្តល់គុណភាពសេវាសុខាភិបាល ការអប់រំ សង្គមកិច្ច វប្បធម៌ និងយេនឌ័រ ដើម្បីលើកកម្ពស់ចំណេះដឹង ចំណេះធ្វើ ដែលអាចមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលយកនូវបច្ចេកវិទ្យាសម័យទំនើបមកអភិវឌ្ឍន៍សង្គមជាតិ និងរួមចំណែកយ៉ាងសំខាន់ក្នុងការងារសង្គម

ឲ្យមានការរីកចម្រើន ព្រមទាំងរក្សាបាននូវវប្បធម៌ ប្រពៃណី ទំនៀមទំលាប់យ៉ាងខ្ជាប់ខ្ជួន ដែលរួមមានដូចខាងក្រោម៖

វិស័យអប់រំ យុវជន និងកីឡា

- កុមារនៅតំបន់ដាច់ស្រយាលអាយុ3-5ឆ្នាំបានចូលរៀននៅតាមសាលាមត្តេយ្យសិក្សាគ្រប់រូបភាព ដោយមានការចូលរួមពីគណៈកម្មការគ្រប់គ្រងថ្នាក់មត្តេយ្យសម្រាប់ជួយដល់គ្រូមត្តេយ្យ
- តម្រូវការគ្រូបង្រៀន និងអគារសិក្សាស្តង់ដារបន្ថែមនៅតំបន់ដាច់ស្រយាល
- បង្កើតអគារសិក្សា និងកន្លែងស្នាក់នៅរបស់លោកគ្រូ អ្នកគ្រូ និងកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស
- ទិន្នន័យអនក្ខរជនមានភាពត្រឹមត្រូវ និងច្បាស់លាស់ ងាយក្នុងការធ្វើផែនការបណ្តុះបណ្តាល
- ជម្រុញយុវជនចូលរួមជាមួយសង្គម និងលើកកម្ពស់ពីតម្លៃនៃការអប់រំ
- ពង្រឹង និងពង្រីកវិស័យកីឡានៅគ្រប់ភូមិសិក្សាទូទាំងខេត្ត

វិស័យសុខាភិបាល

- កាត់បន្ថយការឈឺ និងស្លាប់របស់មាតា ទារក និងកុមារ
- បន្ថយអត្រាឈឺនិងអត្រាស្លាប់ដោយសារជំងឺអេដស៍ របេង គ្រុនចាញ់និងជំងឺឆ្លងដទៃទៀត
- ពង្រឹងគុណភាពប្រព័ន្ធសុខាភិបាល
- ពង្រឹងពង្រីករបបសន្តិសុខសង្គម សុខុមាលភាពអតីតយុទ្ធជន
- ពង្រឹងពង្រីកសេវាសុខុមាលភាពសង្គម សម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ ជនក្រីក្រខ្លាំង

វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- ពង្រឹងពង្រីកសេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម
- ពង្រឹងពង្រីករបបសន្តិសុខសង្គមសុខុមាលភាពមនុស្សចាស់

វិស័យកិច្ចការនារី

- កាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ
- កាត់បន្ថយ ការរីករាលដាលរបស់យុវវ័យនិងគ្រឿនញៀន(ផលប៉ះពាល់នៃការប្រើប្រាស់)
- ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តមានចំនួនតិចនៅតាមមូលដ្ឋាន(ក្រុង ស្រុក ភូមិ ឃុំ)

វិស័យធម្មការនិងសាសនា

- គ្រប់វត្តអារាមទូទាំងខេត្តត្រូវតែមានសាលាពុទ្ធិកសិក្សា និងធម្មវិន័យ
- ព្រះសង្ឃ និងគ្រហស្ថទទួលបានចំណេះដឹង
- បន្តជំរុញពុទ្ធបរិស័ទដើរតាមមាគ៌ាព្រះពុទ្ធសាសនា
- អាចារ្យ និងអាចារីនីមានការយល់ដឹងខ្ពស់ស្តីពីការរៀបចំកម្មវិធីបុណ្យតាមប្រពៃណីខ្មែរ
- ពាហិរសាសនាខេត្តកោះកុងមានសហប្រតិបត្តិការល្អ
- រៀបចំកែលម្អអង្គភាព និងបំពេញមន្ត្រែបម្រើការក្នុងអង្គភាព

វិស័យវប្បធម៌និងវិចិត្រសិល្បៈ

- លើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌
- លើកកម្ពស់សម្បត្តិបេតិកភណ្ឌអរូបិយ

វិស័យការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

- នៅឆ្នាំ២០២៤ក្រុមហ៊ុននឹងយកចិត្តទុកដាក់ក្នុងការបំពេញបែបបទស្តីពីសហគ្រាស គ្រឹះស្ថាន និងលក្ខខណ្ឌការងារបានត្រឹមត្រូវ
- ប្រជាពលរដ្ឋនឹងមានចំណេះជំនាញបំនិនជីវិតពិតប្រាកដដើម្បីប្រកបមុខរបរចិញ្ចឹមជីវិត

វិស័យព័ត៌មាន

- វិសាលភាពប្រព័ន្ធផ្សព្វផ្សាយបានគ្របដណ្តប់ទូទាំងខេត្តកោះកុង
- ផ្សព្វផ្សាយនិងធ្វើវេទិកាសាធារណៈជូនដល់ប្រជាពលរដ្ឋក្នុងខេត្តឲ្យយល់ដឹងពីច្បាប់នានា

វិស័យទំនាក់ទំនង ព្រឹទ្ធសភារដ្ឋសភា និងអធិការកិច្ច

- ធ្វើអធិការកិច្ចនឹងតាមដានត្រួតពិនិត្យការអនុវត្តច្បាប់តាមបណ្តាមន្ទីរអង្គភាពជុំវិញខេត្ត

វិស័យមុខងារសាធារណៈ

- ការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិ សារាចរណែនាំថ្មីៗរបស់មន្ទីរ និងអង្គភាពជំនាញបានត្រឹមត្រូវ
- ពង្រឹងការគ្រប់គ្រងបញ្ជីវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាការទូទាំងខេត្ត

វិស័យផែនការនិងស្ថិតិ

- អភិវឌ្ឍ និងជំរុញការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ វិស័យផែនការ ស្ថិតិ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

២.២.៣. គោលបំណងអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាននិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ធនធានធម្មជាតិក្នុងខេត្ត ត្រូវបានប្រើប្រាស់ និងថែរក្សាការពារដោយហ្មត់ចត់ ព្រមទាំងធានានូវបរិស្ថានធម្មជាតិ និងបរិស្ថានសង្គមយ៉ាងល្អប្រសើរ ការអភិវឌ្ឍន៍គ្រប់វិស័យនៃផ្នែកនេះត្រូវបានយកចិត្តទុកដាក់ និងគិតដល់ថ្ងៃអនាគត ក្នុងគោលបំណង មិនឲ្យមានការអភិវឌ្ឍន៍ផ្នែកមួយ ដែលជះឥទ្ធិពលទៅលើផ្នែកដ៏ទៃទៀត ដែលរួមគោលបំណងអភិវឌ្ឍដូចខាងក្រោម៖

វិស័យដីធ្លី និងសំណង់

- ការងារចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងជាច់ដោយដុំ

វិស័យបរិស្ថាន

- សំណល់រឹងលែងជាបញ្ហាសម្រាប់ខេត្ត
- សំណល់រាវលែងជាបញ្ហាសម្រាប់ខេត្ត
- កាត់បន្ថយបទល្មើសធនធានធម្មជាតិឱ្យមានកម្រិតតិចតួច

វិស័យព្រៃឈើ

- ការកំណត់ព្រំប្រទល់ព្រៃឈើ និងការធ្វើចំណាត់ថ្នាក់ និងកាចុះបញ្ជិកាបានល្អ
- ការអនុវត្តច្បាប់ព្រៃឈើ ឲ្យបានល្អប្រសើរ
- ការអភិរក្សធនធានព្រៃឈើ និងជីវចំរុះឲ្យបានល្អប្រសើរ
- សហគមន៍ព្រៃឈើនឹងមានចំនួនកើនឡើង

ការគ្រប់គ្រងគ្រោះមហន្តរាយ

- ជំរុញការដោះគ្រាប់មីន និងគ្រាប់យុទ្ធភ័ណ្ឌដែលមិនទាន់ផ្ទុះជូនប្រជាពលរដ្ឋ ឲ្យមានដីប្រើប្រាស់និងអាស្រ័យផល
- ពង្រឹងសមត្ថភាពគណៈកម្មាធិការ គ្រប់គ្រងគ្រោះមហន្តរាយស្រុក ឃុំ និងក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយភូមិ
- ប្រជាពលរដ្ឋទទួលបានព័ត៌មានគ្រោះមហន្តរាយតាមរយៈប្រព័ន្ធប្រកាសអោយដឹងមុន ១២៤

ការប្រែប្រួលអាកាសធាតុ

- កាត់បន្ថយភាពងាយរងគ្រោះដែលបណ្តាលមកពីការបំរែបំរួលអាកាសធាតុ

២.២.៤. គោលបំណងអភិវឌ្ឍន៍រដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

រដ្ឋបាលខេត្តបានយកចិត្តទុកដាក់ក្នុងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គមនៅតាមមូលដ្ឋាន ដើម្បីធានាឲ្យមានសន្តិសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ និងយកចិត្តទុកដាកើលើការពង្រឹងសមត្ថភាពមន្ត្រីរាជការដើម្បីជម្រុញឲ្យមាននៅវប្បធម៌សេវាសាធារណៈជូនប្រជាពលរដ្ឋ ដែលមានគោលបំណងអភិវឌ្ឍដូចខាងក្រោម៖

ការគ្រប់គ្រងរដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ទីចាត់ការផែនការនិងវិនិយោគ

- ពង្រឹងសមត្ថភាពដល់មន្ទីរ អង្គភាព ក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិល ប្រចាំឆ្នាំ
- ពង្រីកកិច្ចសហការ គ្នារវាង រដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង ស្រុក និងភាគីពាក់ព័ន្ធនានា ដើម្បីកៀគរធនធានសម្រាប់គាំទ្រការវិនិយោគ
- ពង្រឹងការអនុវត្តមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់
- បង្កើនប្រសិទ្ធភាពនិងសក្តិសិទ្ធភាពក្នុងការផ្តល់សេវារដ្ឋបាលសាធារណៈនិងសេវាសាធារណៈនៅថ្នាក់ក្រោមជាតិ

ទីចាត់ការហិរញ្ញវត្ថុ

- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ទីចាត់ការរដ្ឋបាល

- ការផ្តល់សេវាសាធារណៈរបស់ខេត្តឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងខេត្តកោះកុង ត្រាត និងការ៉ៅ
- ពង្រឹងសមត្ថភាពកិច្ចការរដ្ឋបាលដល់រដ្ឋបាលក្រុង ស្រុក
- ពង្រីកប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការរៀបចំរបាយការណ៍អោយបានទូលំទូលាយ

លេខាធិការក្រុមប្រឹក្សាខេត្ត

- លើកកម្ពស់ដំណើរការនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងផ្សាភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាប្រភេទផ្សេងគ្នានៅថ្នាក់មូលដ្ឋាន ជាមួយប្រជាពលរដ្ឋ

ទីចាត់ការអន្តរវិស័យ

- ពង្រឹងការគ្រប់គ្រង អង្គការមិនមែនរដ្ឋាភិបាល សមាគម និងសហគមន៍មូលដ្ឋានឲ្យអនុវត្តច្បាប់ និងសហលក្ខន្តិក:
- បន្តសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់បន្តទៀតជូនប្រជាពលរដ្ឋ
- ពង្រឹងការគ្រប់គ្រង មូលដ្ឋានអាជីវកម្ម និងផលិតកម្មគ្រប់ប្រភេទក្នុងខេត្ត

គម្រោងអភិវឌ្ឍតំបន់ឆ្នេរ

- ការលើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌
- មន្ត្រីអនុវត្តច្បាប់យល់ដឹងអំពីគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តនានាដែលកំពុងមានជាធរមាន
- ការគ្រប់គ្រងសំណល់រឹងមានប្រសិទ្ធភាព
- ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ និងជីវចម្រុះមាននិរន្តរភាព
- ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- របាយការណ៍របស់រដ្ឋបាលខេត្តមានទិន្នន័យផ្នែកបរិស្ថានពេញលេញ

ទីចាត់ធនធានមនុស្ស

- មន្ត្រីបំរើការនៅសាលាខេត្ត សាលាក្រុង ស្រុក និងឃុំ សង្កាត់មានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ

អង្គភាពលទ្ធកម្ម

- ពង្រឹងការអនុវត្តនីតិវិធីលទ្ធកម្មឲ្យបានល្អប្រសើរនិងទាន់ពេលវេលាស្របតាមគោលការណ៍ណែនាំ

អង្គភាពច្រកចេញចូលតែមួយ

- ធ្វើអោយប្រជាពលរដ្ឋក្នុងខេត្តយល់ច្បាស់ពីនីតិវិធីនៃការផ្តល់សេវាក្នុងអង្គភាពច្រកចេញចូលតែមួយ
- ធ្វើអោយការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយ កាន់តែប្រសើរឡើង
- ធ្វើអោយនីតិវិធីសម្រាប់ផ្តល់សេវារបស់ក្រសួង ឬមន្ទីរ ដែលបានប្រតិភូកម្មសេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយខេត្តមានភាពងាយស្រួល
- ធ្វើអោយមានប្រព័ន្ធតាមដាន និងគ្រប់គ្រងទិន្នន័យឯកសារដែលប្រជាពលរដ្ឋស្នើសុំសេវាកាន់តែល្អ
- បង្កើតអោយមាននីតិវិធីសម្រាប់បែងចែកប្រាក់រង្វាន់

ការិយាល័យប្រជាពលរដ្ឋ

- ពង្រឹងការផ្តល់សេវារបស់រដ្ឋបាលខេត្ត តាមរយៈការពង្រឹងតួនាទី ភារកិច្ចក្នុងការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលខេត្ត

សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

- ជនបរទេសដែលចូលមកស្នាក់នៅ ធ្វើការក្នុងខេត្ត មានឯកសារត្រឹមត្រូវតាមផ្លូវច្បាប់
- ប្រជាពលរដ្ឋក្នុងខេត្តយល់ដឹងពីច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាចក្រកម្ពុជា ធ្វើឲ្យបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈឹម នៅឆ្នាំ២០២៤ នឹងមានការថយចុះ
- ការប្រើប្រាស់ ការរក្សាទុក និងការជួញដូរ គ្រឿងញៀន សារធាតុញៀន នឹងត្រូវបានទប់ស្កាត់ និងកាត់បន្ថយជាលំដាប់

- ប្រជាពលរដ្ឋក្នុងខេត្តយល់ដឹងពីច្បាប់ចរាចរណ៍ផ្លូវគោក នៃព្រះរាជាចក្រកម្ពុជា ធ្វើឲ្យគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នៅឆ្នាំ២០២៤ នឹងមានការថយចុះ
- ប្រជាពលរដ្ឋក្នុងខេត្ត នឹងយកចិញ្ចើមថ្នល់ និងទីសាធារណៈមកប្រើប្រាស់បានយ៉ាងត្រឹមត្រូវ ស្របតាមអនុក្រឹតលេខ ០៤៣អនក្រ និងសេចក្តីជូនផ្សេងៗ របស់អជ្ញាធរ
- នៅឆ្នាំ ២០២៤ ប្រជាពលរដ្ឋគ្រប់រូប នឹងយល់ដឹងអំពីការការពារពីគ្រោះអគ្គីភ័យ
- ប្រជាពលរដ្ឋក្នុងខេត្តនឹងមានសៀវភៅស្នាក់នៅ(ក២)និងសៀវភៅគ្រួសារ(ក៨) ប្រើប្រាស់បានគ្រប់គ្នា
- ប្រជាពលរដ្ឋក្នុងខេត្ត នឹងត្រូវទទួលបានអត្តសញ្ញាណប័ណ្ណប្រើប្រាស់គ្រប់ៗគ្នា
- ព្រះមហាក្សត្រ ឥស្សរជនជាន់ខ្ពស់ អ្នកការទូត ប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ នៅក្នុងខេត្ត នឹងទទួល បានការការពារសន្តិសុខ សុវត្ថិភាព បានយ៉ាងល្អប្រសើ
- នៅឆ្នាំ២០២៤ ការជួញការមនុស្ស និងការរំលោភសេពសន្តវៈលើស្ត្រី និងកុមារ នឹងមានការថយចុះ

២.៣. គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច គ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងរដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងអភិវឌ្ឍ នៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ រដ្ឋបាលខេត្តបានដាក់ចេញនូវគោលដៅ និងវិធានការនានា ប្រទាក់ក្រឡាគ្នានៃផ្នែកទាំងបួនតាមកម្រិតវិស័យនីមួយៗ និងអន្តរគមន៍ជាក់លាក់ តាមតម្រូវការជាក់ស្តែង ហើយមានវិសាលភាពគ្របដណ្តប់រយៈពេលប្រាំឆ្នាំ(២០២០-២០២៤)ដូចខាងក្រោម៖

២.៣.១. គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច

២.៣.១.១. វិស័យកសិកម្ម

- ជំរុញការដាំដុះដោយប្រើពូជទំនើប (ពូជដែលធន់នឹងជំងឺ និងមានទិន្នផលខ្ពស់)
- ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និង កសិករ
- បង្កើនប្រព័ន្ធស្រោចស្រពអោយគ្រប់គ្រាន់
- កាត់បន្ថយសមាសភាពចង្រៃ
- បង្កើនចំណេះដឹងដល់កសិករ
- ជំរុញការចិញ្ចឹមសត្វតាមបែបកសិពាណិជ្ជកម្ម
- កាត់បន្ថយការស្លាប់ដោយជម្ងឺឆ្លង

២.៣.១.២. វិស័យជលផល

- គ្រប់គ្រងការធ្វើនេសាទ ដើម្បីនិរន្តរភាពធនធានជលផល
- ផ្សព្វផ្សាយច្បាប់ស្តីពីជលផលឲ្យបានទូលំទូលាយដល់ប្រជានេសាទ
- ការការពារ និងអភិរក្សធនធានជលផលឲ្យមាននិរន្តរភាព
- ពង្រឹងការចូលរួម និងបង្កើនសមត្ថភាពសហគមន៍នេសាទ ក្នុងការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព
- ផ្តល់នូវបច្ចេកទេសចិញ្ចឹមត្រី សម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់សាច់ត្រី កែច្នៃផលនេរសាទ និងបង្កើនប្រាក់ចំណូលក្នុងគ្រួសារ

២.៣.១.៣. វិស័យធនធានទឹក និងឧតុនិយម

- គាំទ្រកិច្ចដំណើរការ ការជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ
- ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត
- គាំទ្រសេវាការគ្រប់គ្រងប្រព័ន្ធទិន្នន័យឧតុនិយម និងជលសាស្ត្រ
- ការពង្រឹងសេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងការកសាងសមត្ថភាព

២.៣.១.៤. វិស័យរ៉ែ និងថាមពល

- ពង្រឹកការដឹកជញ្ជូនគ្រប់អោយបានត្រឹមត្រូវ
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មរ៉ែ
- ជំរុញដល់សេវាករធ្វើការពង្រីកបណ្តាញផ្គត់ផ្គង់ថាមពលអគ្គិសនី
- ចុះពិនិត្យបច្ចេកទេសបណ្តាញអគ្គិសនី
- ណែនាំម្ចាស់ស្ថានីយឲ្យយល់ពីច្បាប់ក្នុងការបង្កើតស្ថានីយប្រេងឥន្ធនៈ រឺ ឧស្ម័នឥន្ធនៈ

២.៣.១.៥. វិស័យឧស្សាហកម្ម និងសិប្បកម្ម

- ជំរុញម្ចាស់សហគ្រាស សិប្បកម្ម ទាំងអស់ក្នុងខេត្ត បានយល់ដឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ព្រមទាំងពង្រឹងការគ្រប់គ្រងស្ថិតិ និងធ្វើបញ្ជីបច្ចុប្បន្នភាពរោងចក្រ សហគ្រាស សិប្បកម្ម
- ជំរុញ និងលើកទឹកចិត្តដល់អ្នករួមផ្គត់ផ្គង់ ពង្រីកបណ្តាញទឹកស្អាតក្នុងទីប្រជុំជននានា និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុទ្ធនានាលើការរៀបចំប្រពន្ធគ្រប់គ្រងទឹកស្អាត
- ជំរុញការចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ ឧបករណ៍មាត្រាសាស្ត្រ គុណភាពផលិតផល ទំនិញវេចខ្ចប់ ព្រមទាំងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

២.៣.១.៦.វិស័យសាធារណការ និងដឹកជញ្ជូន

- ចាប់ពីឆ្នាំ២០២០ផ្លូវជាតិលេខ៤៨និងត្រូវធ្វើការផ្លាស់ប្តូរប្រភេទDBSTមកជាប្រភេទផ្លូវបេតុងកៅស៊ូ AC
- ផ្លូវក្រាលគ្រួសក្រហមនិងត្រូវធ្វើការផ្លាស់ប្តូរមកជាប្រភេទផ្លូវDBST
- ផ្លូវលំនិងត្រូវធ្វើការផ្លាស់ប្តូរមកជាប្រភេទផ្លូវក្រាលគ្រួសក្រហម
- រៀបខឿនការពារតួថ្ម្ល់ជាប់ឆ្នេរសមុទ្រនៅប៉ាក់ខ្លង
- គ្រប់គ្រងដីចំណីផ្លូវ ដើម្បីការពារពីប្រជាពលរដ្ឋរំលោភដែលធ្វើឲ្យស្ទះប្រព័ន្ធរំដោះទឹក
- បង្កើតស្ថានីយ៍ជញ្ជីងសម្រាប់ថ្លឹងរថយន្តគ្រប់ប្រភេទ

២.៣.១.៧. វិស័យទេសចរណ៍

- ឆ្លើយតបទៅនិងតំរូវការចាំបាច់នូវធនធានមនុស្សក្នុងការបំរើការងារក្នុងវិស័យទេសចរណ៍
- ឆ្លើយតបទៅនឹងតំរូវការចាំបាច់សំរាប់ការអនុវត្តរបស់មន្ត្រីជំនាញងាយស្រួលរៀបចំសហគមន៍ក្នុងមូលដ្ឋាននិងធ្វើការអភិរក្ស ធនធានធម្មជាតិនូវទីតាំងប្រវត្តិសាស្ត្រនោះ
- ធ្វើយ៉ាងណាអោយកិច្ចដំណើរការរមណីដ្ឋានទេសចរណ៍ឆ្លើយតបការកំណើននិងតំរូវការរបស់ភ្ញៀវទេសចរណ៍ធ្វើការអភិរក្សប្រកបដោយល្អប្រសើរនិងទំនើបកម្ម
- ឆ្លើយតបទៅនិងការគោរពច្បាប់និងអនុវត្តច្បាប់អោយមានប្រសិទ្ធភាពនិងមានការទទួលខុសត្រូវក្នុងការតព្វកិច្ចបង់ពន្ធចូលរដ្ឋ
- រៀបចំវិធានការ ការចុះត្រួតពិនិត្យគ្រប់ប្រភេទសេវាកម្ម អាជីវកម្ម មិនព្រមអនុវត្តតាមគោលការណ៍ច្បាប់ទេសចរណ៍ និងធ្វើការផាកពិន័យ

- ធ្វើការអភិវឌ្ឍន៍ផ្លូវ និងកែរលំអជួសជុលចូលរួមពីស្ថាប័នជំនាញ និង អាជ្ញាធរមូលដ្ឋានក្នុង ឃុំស្រុក ងាយស្រួលក្នុងការធ្វើដំណើរដឹកជញ្ជូន ទៅកាន់តំបន់ទេសចរណ៍កំសាន្ត របស់ភ្ញៀវជាតិ និង អន្តរជាតិ
- ធ្វើអោយប្រសើរឡើងក្នុងការទទួលភ្ញៀវទេសចរណ៍ស្របតាមចលនាប្រឡងប្រណាំង ទីក្រុងស្អាត សេវាកម្មល្អ ទទួលបានការទាក់ទាញពីភ្ញៀវជាតិ និងអន្តរជាតិ
- ម្ចាស់អាជីវកម្ម សេវាកម្មនិមួយៗត្រូវតែមានជំនាញវិជ្ជាជីវៈទេសចរណ៍ ក្នុងការគ្រប់គ្រង និងទទួលខុសត្រូវទៅតាមប្រភេទស្តង់ដាប្រកបដោយលក្ខណៈវិនិច្ឆ័យត្រឹមត្រូវដែលមានចែងជាធរមាន
- ជាការឆ្លើយតបសំខាន់ណាស់ក្នុងការផ្សព្វផ្សាយព័ត៌មាននូវសក្តានុពលទេសចរណ៍ជូនដល់ភ្ញៀវជាតិ និងអន្តជាតិទាំងក្នុងប្រទេសនិងក្រៅប្រទេសមកទស្សនាកំសាន្ត ក្នុងខេត្ត ព្រមទាំង ទទួលបានព័ត៌មានល្អៗសម្រាប់សាធារណៈជន
- ជាការឆ្លើយតបត្រូវការចាំបាច់អ្នកបច្ចេកទេសក្នុងការសម្រេចអោយបានគ្រប់គ្រាន់ក្នុងការបំរើ ការផ្សព្វផ្សាយសម្រាប់ពតមានទេសចរណ៍
- ធ្វើអោយប្រសើរឡើងនូវទីក្រុងស្អាត បរិស្ថានស្អាត ឆ្នេរស្អាតស្របតាមស្តង់ដាទៅតាមសូចនាករនិមួយៗគ្រប់លក្ខណៈវិនិឆ្ឆ័យ

២.៣.១.៨. វិស័យពាណិជ្ជកម្ម

- ការផ្តល់សេវាសាធារណៈ សុំចុះបញ្ជី បញ្ជាក់ទីតាំងក្រុមហ៊ុន សាខាក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្ម ក្រោយពេលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរួច ជម្រុញការដាក់ស្លាកយីហោក្រុមហ៊ុន
- ការធ្វើពិពិធកម្មទីផ្សារ
- ការអភិវឌ្ឍន៍វិស័យឯកជន

២.៣.១.៩. វិស័យពន្ធដារ

- កាត់បន្ថយបន្ទុកផ្សេងៗរបស់អ្នកជាប់ពន្ធ តាមរយៈការរៀបចំនូវប្រព័ន្ធដំណើរការរដ្ឋបាលសារពើពន្ធ ប្រកបដោយ ភាពសាមញ្ញ និងតម្លាភាព
- បង្កើនអនុលោមភាពរបស់អ្នកជាប់ពន្ធ តាមរយៈការផ្តល់សេវាអប់រំ និងផ្សព្វផ្សាយនូវព័ត៌មានដែលមានភាពត្រឹមត្រូវ ឯកភាព ទាន់ពេលវេលា និងតាមគ្រប់មធ្យោបាយ ជូនអ្នកជាប់ពន្ធ
- ពង្រឹងប្រសិទ្ធភាព និងគុណភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដោយទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព

២.៣.១.១០. វិស័យគយ និងរដ្ឋាករ

- បំពាក់ម៉ាស៊ីនស្កែន(Scan)ទំនិញ
- បំពាក់មធ្យោបាយប្រតិបត្តិការបង្ក្រាបផ្លូវទឹក
- ការបន្តពង្រឹងប្រសិទ្ធិភាពនៃការអនុវត្តនីតិវិធីគយតាមការិយាល័យព្រំដែន
- ការពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យរូបវន្តលើទំនិញ
- ការពង្រឹងប្រសិទ្ធភាពការងារបង្ការ និង បង្ក្រាបអំពើរត់ គេចពន្ធ

២.៣.១.១១. វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

- យកចិត្តទុកដាក់ប្រតិបត្តិករ ឲ្យគោរពច្បាប់នៅថ្នាក់មូលដ្ឋាន
- ពង្រីកក្រុមហ៊ុនសេវាទូរស័ព្ទ អោយមានសេវាដល់តំបន់ដាច់ស្រយ៉ាល

- បង្កើតអោយមានភ្នាក់ងារប្រៃសណីយ៍ស្រុកទាំង ០៦ស្រុក

២.៣.១.១២.វិស័យអភិវឌ្ឍន៍ជនបទ

- ផ្លូវនៅជនបទមានការជួលជុល និងថែទាំ
- ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ និងមានការអនុវត្តអនាម័យ
- គណៈកម្មការអភិវឌ្ឍន៍ភូមិ និងប្រជាពលរដ្ឋទទួលបានការបណ្តុះបណ្តាល
- ជនជាតិដើមភាគតិចទទួលបានការផ្សព្វផ្សាយ និងចុះអត្តសញ្ញាណ
- ប្រជាពលរដ្ឋនឹងមានចំណេះជំនាញច្បាស់លាស់ដើម្បីរកចំណូល

២.៣.១.១៣.វិស័យធនាគារជាតិ

- ប្រជាពលរដ្ឋយល់ដឹងពីអត្ថប្រយោជន៍នៃការប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុកាន់តែល្អប្រសើរ
- ផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការសាក់សួរ និងផ្តល់ព័ត៌មានទាក់ទងនិងការប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុ
- ប្រជាពលរដ្ឋយល់ច្បាស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជារបស់ឯកជន មិនមែនជារបស់រដ្ឋ
- បង្កើនជំនឿទុកលើការប្រើប្រាស់រៀល
- ធ្វើអោយប្រជាពលរដ្ឋអាចប្រៀបធៀបពីផលប្រយោជន៍ពីការប្រើប្រាស់ប្រាក់រៀល និងការប្រើប្រាស់រូបិយប័ណ្ណបរទេ
- ធ្វើអោយប្រជាពលរដ្ឋនិយមប្រើប្រាស់រៀល
- ផ្តល់លិខិតអនុញ្ញាប្រកបអាជីវកម្មប្តូរប្រាក់ដល់អាជីវករប្តូរប្រាក់ឱ្យបានគ្រប់ទីតាំងប្រកបអាជីវកម្ម
- អាជីវករប្តូរប្រាក់យល់ដឹងពីច្បាប់នៃការគ្រប់គ្រងអាជីវកម្មប្តូរប្រាក់
- ពង្រឹងការត្រួតពិនិត្យអាជីកម្មប្តូរប្រាក់អោយបានគ្រប់ទីតាំង
- លើកកំពស់ការយល់ដឹងពីលក្ខណៈសម្គាល់នៃប្រភេទក្រដាសប្រាក់ក្លែងក្លាយ

២.៣.១.១៤.វិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- គាំទ្រការគ្រប់គ្រងនិងអភិវឌ្ឍសេដ្ឋកិច្ច
- គ្រប់គ្រងណែនាំអនុវត្តនិងគាំទ្រការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនិងគៀគរចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រង ត្រួតពិនិត្យហិរញ្ញវត្ថុ សម្របសម្រួលតាមដានអនុវត្តថវិការបស់មន្ទីរជំនាញរដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងការងារលទ្ធកម្មសាធារណៈ
- គាំទ្រកិច្ចដំណើរការអង្គភាព និងសម្របសម្រួលការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

២.៣.១.១៥.វិស័យរតនាគារ

- ពង្រឹងស្មារតីក្នុងការបញ្ជូនអាណត្តិបើប្រាក់ទូទាត់ចំណូលចំណាយនានាទាន់ពេលក្នុងឆ្នាំថវិកា សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ពង្រឹងស្មារតីក្នុងការបញ្ជូនអាណត្តិបើប្រាក់ទូទាត់ចំណូលចំណាយនានាទាន់ពេលក្នុងឆ្នាំថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

២.៣.២. គោលដៅអភិវឌ្ឍន៍សង្គមកិច្ច

២.៣.២.១ វិស័យអប់រំ យុវជន និងកីឡា

- រៀបចំឱ្យមានថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមដែលនៅជិតផ្ទះប្រជាពលរដ្ឋ និងការបង្កើតគណៈកម្មការជួយគាំទ្រថ្នាក់មត្តេយ្យ
- ចង់បានគ្រូមត្តេយ្យសិក្សានៅតាមសាលាមត្តេយ្យសិក្សា
- សាងសង់អគារស្នាក់នៅរបស់លោកគ្រូអ្នកគ្រូឱ្យបានសមរម្យ
- ផ្តល់អាហាររូបករណ៍ដល់សិស្សដែលមានជីវភាពក្រីក្រ
- សាងសង់អគារសិក្សា និងកន្លែងស្នាក់នៅជូនលោកគ្រូអ្នកគ្រូនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ
- ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ
- កំណត់ទីតាំង និងគ្រូបង្រៀនអក្ខរកម្ម
- ផ្តល់ជំនាញដល់សិស្សក្រោយអក្ខរកម្ម
- យុវជនគ្រប់រូបបានចូលរួមជាមួយការងារសង្គម
- នៅតាមសាលារៀនមានគ្រូ ក្រុមកីឡា និងទីធ្លាលេងកីឡា (ព្យាយាមលេងកីឡាដើម្បីជៀសឆ្ងាយពីគ្រឿងញៀន)

២.៣.២.២.វិស័យសុខាភិបាល

- លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់មាតាទារក និងកុមារ
- លើកកម្ពស់លទ្ធភាពមកទទួលសេវា សុខភាពបន្តពូជមានគុណភាព
- លើកកម្ពស់លទ្ធភាពមក ទទួលសេវាសុខភាពជាសារវ័ន្ត សម្រាប់មាតានិងទារក និងការប្រព្រឹត្តការថែទាំសុខភាព
- ធានានូវលទ្ធភាពមកទទួលយកសេវាសុខភាពសារវ័ន្តសំរាប់កុមារនិងថែទាំសុខភាពតាមគ្រួសារបានល្អប្រសើរ
- កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃ (HIV)ឲ្យទាបជាង០.៥%
- ពង្រឹងការស្រាវជ្រាវជម្ងឺរបេង បេកាវិជ្ជមានលើសពី៦០% និងរក្សាអត្រាជាសៈស្បើយ កម្រិត៨៥%នៃករណីជំងឺរបេងសួតបេកាវិជ្ជមាន
- រក្សាអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ឲ្យបានក្រោម ០.៤%ក្នុងចំណោមប្រជាជនទូទៅ
- ត្រៀមលក្ខណៈខ្ពស់ដើម្បីទប់ស្កាត់នៃជំងឺឆ្លងថ្មីដទៃទៀតដែលអាចកើតមានជាយថាហេតុ
- កាត់បន្ថយឥរិយាបទគ្រោះថ្នាក់នាំទៅរកជម្ងឺមិនឆ្លង
- ធានាដំណើរការមុខងារសារវ័ន្តនៃសុខភាពសាធារណៈសុខភាពបរិស្ថានសុវត្ថិភាពចំណីអាហារ,ការគ្រប់ គ្រងគ្រោះមហន្តរាយនិងការត្រៀមលក្ខណៈ (សំរាប់គ្រាអាសន្ន)
- ពង្រឹងនិងផ្សារភ្ជាប់គ្នារវាងសេវាសកម្មភាពអប្បបរិមា(សកម្មភាពរបស់មណ្ឌលសុខភាព)និងសេវាសកម្មភាពបង្គ្រប់(សកម្មភាពរបស់មន្ទីរពេទ្យបង្អែក)អមដោយការពង្រឹងសេចក្តីណែនាំគ្លីនិកនិងពិធីសារនៃការព្យាបាលព្រមទាំងប្រមូលផ្តុំកាន់តែខ្លាំងឡើងលើគុណភាព
- ពង្រឹងការផ្តល់ពត៌មានសុខាភិបាល ដែលពាក់ពន្ធ័មានគុណភាពខ្ពស់ និងទាន់ពេលវេលាសំរាប់ជាមូលដ្ឋាន ភស្តុតាងដល់ការដាក់ចេញគោលនយោបាយ ការធ្វើសេចក្តីសំរេចចិត្ត,ការអនុវត្តន៍កម្មវិធី ការត្រួតពិនិត្យតាមដានស្មារដៃការងារនិងការវាយតំលៃ

- ពង្រឹងយន្តការសហប្រតិបត្តិរវាងសេវាសុខាភិបាលរដ្ឋ និងសេវាសុខាភិបាលឯកជនក្នុងភាពជាដៃគូ លើការផ្តល់ព័ត៌មាន និងការផ្តល់អាជ្ញាប័ណ្ណសេវាឯកជនដែលគោរពទៅតាមគោលការណ៍ច្បាប់ស្តីពីវិស័យសេវាឯកជន ប្រកបដោយភាពទទួលខុសត្រូវ ក្នុងវិជ្ជាជីវៈវេជ្ជសាស្ត្រ

២.៣.២.៣.វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- គ្រួសារអតីតយុទ្ធចំនួន៣៧៥គ្រួសារដែលពុំទាន់បានទទួលដីសម្បទាសង្គមកិច្ចដែលមានឈ្មោះនៅក្នុងសេចក្តីសម្រេច និងអភិឌ្ឍន៍សេដ្ឋកិច្ចគ្រួសារអតីតយុទ្ធជនក្រីក្រខ្លាំង ៥០០គ្រួសារ ក្នុងឆ្នាំ២០២៤
- សង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ
- បន្តពង្រឹងសកម្មភាពដោះស្រាយបញ្ហាជនអនាថាចំនួន៦០ក្នុងឆ្នាំ២០២៤ នៅតាមសាធារៈនៅក្នុងខេត្តជារៀងរាល់ឆ្នាំ
- បន្តពង្រឹងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្តារនីតិសម្បទាជនរងគ្រោះឱ្យនៅសល់ត្រឹម០០នាក់នៅក្នុងឆ្នាំ២០២៤
- ផ្តល់កម្មវិធីសង្គ្រោះជនរងគ្រោះ និងជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍នៅតាមសហគមន៍អោយបាន ១៨៥៩លើកនៅក្នុងឆ្នាំ២០២៤
- ការកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះ និងជនងាយរងគ្រោះរបស់អាជ្ញាធរមូលដ្ឋាននៅមានកម្រិតឱ្យបាន៥០វគ្គក្នុងឆ្នាំ២០២៤
- ធ្វើឲ្យមានការជ្រួតជ្រាបដល់សហគមន៍ស្តីពីការថែទាំជំនួសដល់កុមារ និងដល់ការរងផលប៉ះពាល់ការប្រើប្រាស់ពលកម្មកុមារ៣៥លើក និងលើកស្ទួយសុខុមាលភាពកុមាកំព្រា កុមារក្រីក្រតាមសហគមន៍ ៥០០នាក់ នៅក្នុងឆ្នាំ២០២៤
- ពង្រឹងកម្មវិធីអប់រំសិលធម៌ការទប់ស្កាត់អំពើហិង្សា អំពើល្មើសច្បាប់ ការប្រើប្រាស់បំពានសារធាតុញៀននៅក្នុងជួរកុមារ និងយុវកុមារ
- ការស្តារនីតិសម្បទា និងសមាហរណកម្មកុមារទំនាស់នឹងច្បាប់ និងអ្នកញៀនគ្រឿងញៀន ៥០នាក់ក្នុងឆ្នាំ២០២៤
- ជំរុញការការពារ និងលើកកម្ពស់សិទ្ធិកុមារ
- បង្កើនការយល់ដឹងអំពីជនមានពិការភាព ១៥វគ្គ និងជម្រុញការហ្វឹកហ្វឺនវិជ្ជាជីវៈដោះស្រាយការងារនិងមុខរបបជូនជនមានពិការភាព ១០០នាក់ ក្នុងឆ្នាំ២០២៤
- បន្តពង្រឹងពង្រីកសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍)CBR) ជូនជនពិការ និងការចងក្រងក្រុមជួយខ្លួនឯងនៃជនពិការ ៣៥០នាក់នៅឆ្នាំ២០២៤
- ជម្រុញដំណើការសមាគមមនុស្សចាស់ឱ្យកាន់តែប្រសើរទូទាំងខេត្ត និងផ្តល់សេវាគាំទ្រ លើកស្ទួយសុខុមាលភាពមនុស្សចាស់២៥០០នាក់

២.៣.២.៤.វិស័យកិច្ចការនារី

- បុរសបានចូលរួមទទួលព័ត៌មានអំពីច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងជួយជនរងគ្រោះ
- ការអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាបានល្អ
- បង្កើនការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- សាងទំនុកចិត្តដល់ស្ត្រី

- ចំនួនស្ត្រីកើនឡើងនៅជួរថ្នាក់ដឹកនាំ

២.៣.២.៥. វិស័យធម្មការ និងសាសនា

- បង្កើតសាលាពុទ្ធិកបឋមសិក្សា
- បង្កើនការផ្សព្វផ្សាយព្រះធម៌តាមបណ្តាញសង្គមហ្វេសបុគ ផេក
- ជ្រើសរើសព្រះសង្ឃដែលមានការគោរពប្រតិបត្តិ និងមានចំណេះដឹងផ្នែកព្រះពុទ្ធសាសនាដើម្បីតែតាំងគណៈគ្រប់គ្រងវត្ត
- បង្កើតសាលាពុទ្ធិកមធ្យមសិក្សាបឋមភូមិ
- បណ្តុះបណ្តាលគណៈគ្រប់គ្រងវត្តអារាមពីសារសំខាន់នៃការពង្រីកធនធានព្រះសង្ឃ
- ជម្រុញអោយមានគាំទ្រក្នុងការសិក្សារបស់ព្រះសង្ឃ
- បង្កើតអោយមានសាលាពុទ្ធិកសិក្សាគម្រូ និងប័ណ្ណសរសើរ
- ប្រជាពលរដ្ឋកាន់តែយល់ដឹងពីខ្លឹមសារសំខាន់នៃព្រះពុទ្ធសាសនាក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន
- សម្ភារនិយមផ្សាភ្ជាប់និងសាសនា ក្នុងសម័យសាកលភាវូបនីយកម្ម
- បង្កើនការនិមន្តចូលរួមរបស់ព្រះសង្ឃចូលរួមទាំងការងារសង្គមជាតិ មនុស្សធម៌និងសាសនា
- គ្រប់វត្តអារាមត្រូវរៀបចំអោយក្លាយជាវត្តទេសចរណ៍
- ព្រះធម្មកថិកមានការកើនឡើងទាំងសមត្ថភាពនិងបទពិសោធន៍
- អាចារ្យអាចារិនីក្នុងខេត្តមានចំណេះដឹងច្បាស់លាស់ក្នុងការរៀបចំកម្មវិធីបុណ្យប្រពៃណីផ្សេងៗ
- ជម្រុញអោយមានការរៀបរចនាសម្ព័ន្ធ ឬអ្នកគ្រប់គ្រងគ្រឹស្ថសាសនាច្បាស់លាស់
- គ្រូគង្វាលចូលរួមប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាមានការកើនឡើង
- ព្រះវិហារ និងស្មាក់ការថ្វាយបង្គំមានច្បាប់អនុញ្ញាតត្រឹមត្រូវ
- អាជ្ញាធរមូលដ្ឋានយកចិត្តទុកដាក់ខ្ពស់លើកិច្ចការពាហិរសាសនា
- ស្នើសុំបំពេញបន្ថែមក្របខ័ណ្ឌមន្ត្រីរាជការជំនួសមន្ត្រីដែលបានចូលនិវត្តន៍ និងបង្រួបរួចនាសម្ព័ន្ធការិយាល័យនានាចំណុះមន្ទីរ

២.៣.២.៦ វិស័យវប្បធម៌ និងវិចិត្រសិល្បៈ

- រៀបចំថែរក្សាការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ និងរមណីយដ្ឋានប្រវត្តិសាស្ត្រនានាក្នុងខេត្ត
- បង្កើនការផ្សព្វផ្សាយ ដើម្បីការយល់ដឹងពីតម្លៃនៃវប្បធម៌
- បង្កើន និងកសាងសមត្ថភាពចំណេះ ជំនាញ សិល្បៈជូនប្រជាពលរដ្ឋ
- ពង្រឹងការគ្រប់គ្រង និងធ្វើបញ្ជីស្ថិតិវិស័យវប្បធម៌
- ចូលរួមចំណែកក្នុងព្រឹត្តការន៍វប្បធម៌ និងបង្កើនស្មាដៃថ្មី

២.៣.២.៧ វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- 85%នៃសហគ្រាស គ្រឹះស្ថានដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារយល់ដឹងកាន់តែទូលំទូលាយច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុទ្ធនានា
- 85%នៃសហគ្រាស គ្រឹះស្ថាន មានការសហការយ៉ាងល្អជាមួយមន្ទីរ
- ផ្តល់ចំណេះដឹងផ្នែកជំនាញបច្ចេកទេសវិជ្ជាជីវៈជូនដល់ប្រជាពលរដ្ឋស្របតាមទីផ្សារការងារ

២.៣.២.៨ វិស័យព័ត៌មាន

- ការផ្សព្វផ្សាយព័ត៌មានបានឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកស្តាប់និងទស្សនិកជន
- បំពាក់ឧបករណ៍ សម្ភារបច្ចេកទេសឲ្យសមស្របទៅតាមលក្ខណៈបច្ចេកទេសនៃបច្ចេកវិទ្យា។
- មានស្ថានីយ៍ទូរទស្សន៍មួយសមស្របដើម្បីបម្រើជូនទស្សនិកជននៅឡើយ ។
- មានមធ្យោបាយចុះយកព័ត៌មានតាមមូលដ្ឋាន
- ពង្រឹងធនធានមនុស្សឲ្យមានសមត្ថភាពការងារ និងជំនាញបចហាចេកទេស

២.៣.២.៩ វិស័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

- ប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់ដោយសារការផ្សព្វផ្សាយនិងការធ្វើវេទិកាសាធារណៈ
- ស្វែងយល់ពីចម្ងល់ សំណូមពរនិងតម្រូវការនានារបស់ប្រជាពលរដ្ឋ
- បង្ការទប់ស្កាត់នឹងកាត់បន្ថយអំពើពុករលួយការកិបកេងការរំលោភដោយអំណាចនឹងបាតុភាពអសកម្មនានា

២.៣.២.១០ វិស័យមុខងារសាធារណៈ

- ពង្រឹងសមត្ថភាពមន្ត្រីរាជការឲ្យបានយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តិថ្មីៗការងារមុខងារសាធារណៈ
- គ្រប់គ្រងបញ្ជីវត្តមានឲ្យបានត្រឹមត្រូវតាមច្បាប់
- ពង្រឹងសមត្ថភាពមន្ត្រីរាជការ សារាចរណែនាំថ្មីពាក់ព័ន្ធការងារមុខងារសាធារណៈ

២.៣.២.១១ វិស័យផែនការ និងស្ថិតិ

- អភិវឌ្ឍនសមត្ថភាពមន្ត្រីដើម្បីជំរុញការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ វិស័យផែនការ ស្ថិតិ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មានកម្រិតយល់ដឹង៨០% នៅឆ្នាំ២០២៤

២.៣.៣. គោលដៅអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាននិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

២.៣.៣.១ វិស័យដីធ្លី និងសំណង់

- ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធឲ្យបានទូទាំងខេត្ត
- ទប់ស្កាត់ការចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បន្តផ្តល់ដីសម្បទានសង្គមកិច្ចនៅស្រុកបូទុមសាគរ ស្រុកកោះកុង និងស្រុកថ្មបាំង
- ជំរុញប្លង់គោលក្រុងខេមរភូមិន្ទអោយសម្រេចស្ថាពរនៅឆ្នាំ២០២០
- បង្កើនការគ្រប់គ្រងការដ្ឋានសំណង់ទូទាំងខេត្ត
- ពង្រឹងសមត្ថភាព គណៈកម្មាធិការដោះស្រាយទំនាស់ថ្នាក់ខេត្ត ស្រុក ក្រុង ឃុំ សង្កាត់ ប្រកបដោយប្រសិទ្ធភាព

២.៣.៣.២ វិស័យបរិស្ថាន

- ការគ្រប់គ្រងសំណល់រឹងមានប្រសិទ្ធភាព
- មានអ្នកម៉ៅការប្រមូលសំរាម
- ការគ្រប់គ្រងសំណល់រាវមានប្រសិទ្ធភាព
- បញ្ចប់បទល្មើសធនធានធម្មជាតិ

២.៣.៣.៣ វិស័យព្រៃឈើ

- លទ្ធភាពក្នុងការចុះបញ្ជិកា និងកំណត់ព្រំបានល្អ
- ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើអនាធិបតេយ្យ
- ទប់ស្កាត់ភ្លើងឆេះព្រៃ
- រៀបចំស្តារព្រៃឈើ និងដាំឈើឡើងវិញបានល្អ
- លើកំពស់សហគមន៍ព្រៃឈើនៅគ្រប់តំបន់

២.៣.៣.៤. ការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ:

- បោសសំអាតមីន និងគ្រាប់យុទ្ធភ័ណ្ឌដែលមិនទាន់ផ្ទុះ ជូនប្រជាពលរដ្ឋ ឲ្យមានដីប្រើប្រាស់
- ការផ្តល់ព័ត៌មានពាក់ព័ន្ធនិងឲ្យល់ព្យុះ
- ការស្តារឡើងវិញ ក្រោយពីហេតុការណ៍
- លើកកម្ពស់ការទប់ទល់ទៅនឹងការបំផ្លាញស្រទាប់អូហ្សូន
- លើកកម្ពស់ការបន្សាំទៅនឹងការបំរែបំរួលអាកាសធាតុ

២.៣.៣.៥ ការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

- គាំទ្រដល់មន្ទីរអង្គភាព ក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងការអភិវឌ្ឍន៍សមត្ថភាពពីរបៀបធ្វើផែនការ និងរៀបចំគម្រោង
- សិក្ខាសាលាពិគ្រោះយោបល់ជាមួយមន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀគរធនធានសម្រាប់គាំទ្រ គម្រោងវិនិយោគ
- ពង្រឹងកិច្ចសហការគាំទ្រ ដល់ក្រុង ស្រុក និងឃុំ សង្កាត់ក្នុងការកៀគរធនធានតាមមន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា
- ផ្តល់ជំនាញចុះសិក្សាគម្រោងមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ និងគ្រប់គ្រងកិច្ចសន្យា
- ពង្រឹងប្រសិទ្ធភាពនិងគុណភាពហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ និងកាត់បន្ថយរយៈពេលធ្វើដំណើរនិងចំណាយលើការដឹកជញ្ជូន
- គាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ
- ការថែរក្សាបរិស្ថាន និងអនាម័យក្នុងទីប្រជុំជន
- រៀបចំឲ្យមានការិយាល័យច្រកចេញចូលតែមួយ នៅតាមក្រុង ស្រុក
- លើកគម្រោងធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយ(តាមរយៈវេទិកាសាធារណ)
- ការលើកគម្រោងសម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យា(បណ្តាញសង្គម)
- បង្កើនមន្ត្រីសម្រាប់ផ្តល់សេវាអោយបានច្រើន
- ពង្រឹងសមត្ថភាពដល់មន្ត្រីផ្តល់សេវាបន្ថែម
- ធ្វើអោយប្រព័ន្ធលើកទឹកចិត្តបានល្អប្រសើរ
- កែសម្រួលទម្រង់បែបបទអោយត្រូវគ្នា
- កាត់បន្ថយនីតិវិធីនៃការចេញសេចក្តីអនុញ្ញាតពីអង្គភាពពាក់ព័ន្ធ
- បង្កើតអោយមានសេវាជាកញ្ចប់
- បង្កើតប្រព័ន្ធតាមដាន និងគ្រប់គ្រងសេវាច្បាស់លាស់ (វិស័យ និងសេវាមានច្រើន)
- ក្រសួង ឬមន្ទីរអនុវត្តថវិកាអោយដូចគ្នា

- រៀបចំនីតិវិធី កុំអោយមានភាពស្មុគស្មាញ

២.៣.៣.៦ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

- ជនបរទេស ៩៥% ប្រើប្រាស់ឯកសាររដ្ឋបាលកម្ពុជា ស្របច្បាប់
- ជនបរទេសមកស្នាក់នៅក្នុងខេត្តមានឯកសារស្របច្បាប់គ្រប់គ្រាន់ គ្រប់គ្នា
- ប្រជាពលរដ្ឋ ៩០% យល់ដឹងពីគ្រោះថ្នាក់ នៃការប្រើប្រាស់គ្រឿងញៀនគ្រឿងស្រវឹង និង ផលវិបាកនៃការប្រព្រឹត្តល្បែងស៊ីសង ។ល។
- ប្រជាពលរដ្ឋ ដែលមានអាយុចន្លោះពី១៥ ដល់ ៥០ឆ្នាំ នឹងយល់ដឹងច្បាប់ និងផលប៉ះពាល់នៃការ ប្រើអំពើហឹង្សា
- ការផ្សព្វផ្សាយអំពីពលប៉ះពាល់នៃគ្រឿងញៀន នឹងបានជ្រោតជ្រាបដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បទល្មើសគ្រឿងញៀនទាំងឡាយ នឹងត្រូវបាន ទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលា
- អ្នកបើកបរ ៩៥% នឹងយល់ដឹងច្បាប់ ច្បាប់ចរាចរណ៍ផ្លូវគោក នៃព្រះរាជាចក្រកម្ពុជា
- អត្រាគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ការប្រើប្រាស់គ្រឿងស្រវឹងមានការថយចុះ
- ប្រជាពលរដ្ឋគ្រប់រូប នឹងប្រើប្រាស់ចិញ្ចើមថ្នល់ និងការទីសារធារណៈរបស់រដ្ឋបានយ៉ាងត្រឹមត្រូវ ស្របតាមអនុក្រិត និងសេចក្តីជូនដំណឹងផ្សេងៗ
- អ្នកអនុវត្តច្បាប់ នៅតាមបណ្តាមូលដ្ឋាន នឹងខិតខំបំពេញតួនាទី ភារកិច្ចរបស់ខ្លួនបានល្អ សក្តិសមជាអ្នកបំរើប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋ ៩០% យល់ច្បាស់អំពីវិធីបង្ការ និងទប់ស្កាត់បឋមពីគ្រោះអគ្គីភ័យ
- ជំរុញប្រជាពលរដ្ឋ អោយទៅធ្វើឯកសារពាក់ព័ន្ធ ដើម្បីទទួលបានការផ្តល់សៀវភៅស្នាក់នៅ(ក២) និង សៀវភៅគ្រួសារ(ក៨)
- ប្រជាពលរដ្ឋ ដែលមានសៀវភៅស្នាក់នៅ(ក២) និង សៀវភៅគ្រួសារ(ក៨) ដែលខូច រឺក៏បាត់បង់ នឹងទទួលបានការធ្វើឡើងវិញគ្រប់ៗគ្នា
- ប្រជាពលរដ្ឋ ដែលមានអត្តសញ្ញាណប័ណ្ណ ខូច រឺក៏បាត់បង់ នឹងទទួលបានការធ្វើឡើងវិញគ្រប់ៗគ្នា
- ក្រុមឧទ្ធាមផ្តាច់ខ្លួនខាងក្នុង/ខាងក្រៅ និងជនខិលខូចគ្រប់រូបភាព នឹងត្រូវទប់ស្កាត់បាន ១០០% ចំពោះការ អុកឡុក រំខានដល់សន្តិសុខ ការបំពេញបេសកម្មរបស់ព្រះមហាក្សត្រ និងរាជរដ្ឋបាលកម្ពុជា
- អ្នកបំរើសេវាកម្មទេសចរណ៍គ្រប់ប្រភេទ នឹងបញ្ឈប់រាល់សកម្មភាពកេងចំណេញគ្រប់រូបភាពពីភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ
- ភ្ញៀវទេសចរណ៍គ្រប់រូប នឹងត្រូវបញ្ជូន ទៅរកសេវាព្យាបាល សង្គ្រោះ ទាន់ពេលវេលា នៅពេលមានបញ្ហាសុខភាព និងជួបគ្រោះថ្នាក់ដោយយថាហេតុណាមួយ
- អាណាព្យាបាលគ្រប់រូបនឹងទទួលបានការអប់រំផ្សព្វផ្សាយអំពីហានិភ័យនៃបទល្មើសរំលោភសេពសន្តវៈ
- ផ្សព្វផ្សាយអំពីច្បាប់ស្តីពី ការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អោយបានទូលំទូលាយ ដល់គោលដៅដែលងាយរងគ្រោះ

២.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍

២.៤.១. យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

ផ្អែកតាមចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ក្រុមប្រឹក្សាខេត្តអាណត្តិទី៣ បានដាក់ចេញនៅយុទ្ធសាស្ត្រគន្លឹះ ផ្តោតជាសំខាន់ទៅលើការកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ផ្លូវគោគ និងផ្លូវទឹក ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធស្រោចស្រពដំណាំកសិកម្ម ដោយថែទាំជាប្រចាំប្រព័ន្ធទំនប់ការពារទឹកប្រៃ ពន្លឿនក្នុងការពង្រីកបណ្តាញអគ្គិសនី និងការប្រើប្រាស់ទឹកស្អាត ទាក់ទាញដៃគូរឯកជនវិនិយោគលើវិស័យទេសចរណ៍ និងផ្សព្វផ្សាយពីសក្តានុពលសំខាន់ៗរបស់ខេត្ត ដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយនូវភាពក្រីក្រជូនប្រជាពលរដ្ឋក្នុងខេត្ត។ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងផ្នែកសេដ្ឋកិច្ចនេះ ក្រុមប្រឹក្សាខេត្តអាណត្តិទី៣ ដាក់ចេញនូវយុទ្ធសាស្ត្រតាមវិស័យដូចខាងក្រោម៖

២.៤.១.១. វិស័យកសិកម្ម

1. ផ្សព្វផ្សាយពូជដំណាំកសិកម្មដែលមានទិន្នផលខ្ពស់និងការធ្វើបង្ហាញ
2. បណ្តុះបណ្តាលកសិករអោយចេះសម្រឹតសម្រាំងយកពូជសុទ្ធ
3. បណ្តុះបណ្តាលកសិករស្តីពីការប្រើប្រាស់ជីកំប៉ុស្ត
4. បណ្តុះបណ្តាលបច្ចេកទេសកសិកម្មថ្មីៗដល់កសិករ
5. បណ្តុះបណ្តាលពង្រឹងសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ
6. ផ្សព្វផ្សាយបច្ចេកទេសដាំបន្លែដោយប្រើប្រព័ន្ធដំណក់ទឹក ឬផ្ទះសំណាញ់
7. រៀបចំប្រព័ន្ធប្រឡាយជើងភ្នែប
8. ជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម
9. អន្តរាគមន៍ការផ្ទុះឡើងនូវសមាសភាពចង្រៃ
10. ផ្សព្វផ្សាយពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្ម
11. បណ្តុះបណ្តាលកសិករអោយចេះផ្សំនិងប្រើប្រាស់ថ្នាំពុលធម្មជាតិ
12. បណ្តុះបណ្តាលស្តីពីបច្ចេកទេសនៃការចិញ្ចឹមសត្វ
13. បណ្តុះបណ្តាលស្តីពីរបៀបផ្សំចំណី និងការកែច្នៃចំណី
14. បណ្តុះបណ្តាលស្តីពីបច្ចេកទេសនៃការចិញ្ចឹមសត្វ
15. បណ្តុះបណ្តាលស្តីពីរបៀបផ្សំចំណី និងការកែច្នៃចំណី
16. ពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ
17. ផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំង
18. ត្រៀមអន្តរាគមន៍ករណីមានជម្ងឺផ្ទុះឡើង
19. ពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ
20. ត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ

២.៤.១.២. វិស័យជលផល

1. បង្កើនការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល
2. ផ្សព្វផ្សាយប្រកាស់ស្តីពីការកំណត់ឧបករណ៍នេសាទ ដែលអនុញ្ញាតឲ្យប្រើប្រាស់
3. ផ្សព្វផ្សាយច្បាប់ស្តីពីជលផល
4. ផ្សព្វផ្សាយសារសំខាន់នៃការអភិរក្ស និងតំបន់អភិរក្ស
5. ដាំកូនកោងកាង

6. បោះបង្គោលព្រំប្រទល់តំបន់អភិរក្ស
7. បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដល់គណៈកម្មការសហគមន៍នេសាទ
8. បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈ គ្រួសារ
9. បណ្តុះបណ្តាលបច្ចេកទេសកែច្នៃផលនេសាទ

២.៤.១.៣. វិស័យធនធានទឹក និងឧតុនិយម

1. ជួសជុលបន្តប្រព័ន្ធទំនប់ការពារទឹកប្រៃបឹងព្រាវ
2. ជួសជុលប្រព័ន្ធទំនប់ការពារទឹកប្រៃខ្លុង
3. បន្តក្រាលគ្រួសក្រហមលើភ្លឺប្រឡាយជីមាល នៃប្រព័ន្ធទំនប់ការពារទឹកប្រៃជីមាល
4. ជួសជុលថែទាំប្រចាំប្រព័ន្ធទំនប់ការពារទឹកប្រៃជីត្រែះ
5. ជួសជុលថែទាំប្រព័ន្ធទំនប់ការពារទឹកប្រៃតាមាយ
6. ជួសជុលសំណង់ទ្វារទឹកជីត្រែះ
7. ជួសជុល ប្រព័ន្ធទំនប់ការពារទឹកប្រៃថ្មស
8. ជួសជុល-ថែទាំប្រចាំ ប្រព័ន្ធទំនប់ការពារទឹកប្រៃជីមាល
9. ជួសជុល-ថែទាំប្រចាំ ប្រព័ន្ធទំនប់ការពារទឹកប្រៃកណ្តោល
10. ជួសជុល-ថែទាំប្រចាំ ប្រព័ន្ធទំនប់ការពារទឹកប្រៃតានី
11. ជួសជុល-ថែទាំប្រចាំ ប្រព័ន្ធទំនប់ការពារទឹកប្រៃជ្រោយស្វាយ
12. ជួសជុល-ថែទាំប្រចាំ ប្រព័ន្ធទំនប់ការពារទឹកប្រៃបឹងព្រាវ
13. សាងសង់ទំនប់ការពារទឹកប្រៃព្រលាន
14. ជួសជុលទំនប់ការពារទឹកប្រៃដងពែង
15. បន្តស្តារប្រឡាយដោះទឹកជំនន់កណ្តោល និងធ្នង់
16. ស្តារប្រឡាយដោះទឹកជំនន់ជីត្រែះ
17. ស្តារប្រឡាយដោះទឹកជំនន់ជីមាល
18. ស្តារប្រឡាយដោះទឹកជំនន់ខ្លុង
19. ស្តារប្រឡាយដោះទឹកជំនន់ប៊ឹងព្រាវ
20. ប្រមូលពត៌មានទិន្នន័យគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត
21. ការងារជួសជុលនិងថែទាំរថយន្តព្រមទាំងសំភារៈនិងឧបករណ៍រោងជាងជាប្រចាំ
22. ជួសជុល-ថែទាំ ម៉ាស៊ីនបូមទឹកចល័ត ជាប្រចាំ
23. ការងារត្រៀមអន្តរាគមន៍បូមទឹក
24. ចុះប្រមូលពត៌មានប្រព័ន្ធធារាសាស្ត្រដែលមិនទាន់មានក្នុង CISIS
25. ស្រង់ស្ថិតិប្រព័ន្ធធារាសាស្ត្រដែលមានក្នុងខេត្ត និងស្ថានភាពបច្ចុប្បន្ន របស់សំណង់ធារាសាស្ត្រ
26. ការរៀបចំផែនទីប្រព័ន្ធធារាសាស្ត្រ និងផ្ទៃដីដាំដុះតាមប្រព័ន្ធពត៌មានវិទ្យាភូមិសាស្ត្រ (ArcGIS)
27. ការធ្វើជំរឿនផ្ទៃដីដាំដុះស្រូវវស្សាទូទាំខេត្ត
28. តម្លើង-ជួសជុលនិងថែទាំក្តារម៉ែត្រវាស់កំពស់ទឹកជោ-នាចតាមព្រែក
29. ប្រមូលនិងគ្រប់គ្រងទិន្នន័យជលសាស្ត្រ (កំពស់ទឹកជោរ-នាច)

30. ជួសជុលស្ថានីយ៍ឧតុនិយម
31. ជួសជុលប៉ុស្តិ៍តម្រងទឹកភ្លៀង
32. ការប្រមូល និងគ្រប់គ្រងទិន្នន័យទឹកភ្លៀង
33. ចុះធ្វើការសិក្សាស្រាវជ្រាវនិងចងក្រងឯកសារ បរិមាណនៃការប្រើប្រាស់ អណ្តូង -ស្រះ នៅក្នុងខេត្ត
34. ពិនិត្យជួសជុល ថែទាំអគារ និងអនាម័យបរិស្ថានជុំវិញ និងក្នុងមន្ទីរ
35. ការងារបន្ទុកបុគ្គលិក (មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ មន្ត្រីអណ្តែត-មន្ត្រីជាប់កិច្ចសន្យា)
36. ផ្គត់ផ្គង់ ជួសជុល ថែទាំឧបករណ៍ និងសម្ភារៈបរិក្ខារបច្ចេកទេស
37. ជួសជុល ថែទាំមធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ

២.៤.១.៤. វិស័យរ៉ែ និងថាមពល

1. ធ្វើការត្រួតពិនិត្យរាល់រថយន្តដឹកជញ្ជូនមិនបានគ្រប់ត្រឹមត្រូវនិងធ្វើការផាកពិន័យ
2. អប់រំនិងផ្សព្វផ្សាយច្បាប់អោយបានទូលំទូលាយ
3. ជម្រុញនិងសម្របសម្រួលរវាងសេវាករនិងប្រជាពលរដ្ឋដើម្បីពន្លឿនក្នុងការពង្រីកបណ្តាញអគ្គិសនី
4. ចុះត្រួតពិនិត្យបច្ចេកទេសការភ្ជាប់បណ្តាញក្នុងស្តង់ដារសុវត្ថិភាពអគ្គិសនី
5. ចុះណែនាំ និងផ្សព្វផ្សាយច្បាប់ស្តីពិការបង្កើតស្ថានីយប្រេង ឬឧស្ម័នឥន្ធនៈ

២.៤.១.៥. វិស័យឧស្សាហកម្ម និងសិប្បកម្ម

1. បន្តផ្សព្វផ្សាយអំពីច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រសិប្បកម្មនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ ឱ្យបានគ្រប់មូលដ្ឋានទូទាំងខេត្ត
2. បន្តចុះស្រង់និន្នន័យ និងស្ថិតិនិងធ្វើបញ្ជីបច្ចុប្បន្នភាព រោងចក្រសិប្បកម្មទាំងអស់ក្នុងខេត្ត
3. បន្តស្វែងរកទុន និងដៃគូវិនិយោគបន្ថែម ផ្សព្វផ្សាយអំពីគោលនយោបាយទឹកស្អាត និងជំរុញដល់ការពង្រីកបណ្តាញថ្មីបន្ថែម
4. បន្តផ្សព្វផ្សាយអំពីច្បាប់ និងបទដ្ឋានគិយុត្តិពាក់ព័ន្ធនឹងការផលិតទឹកស្អាត ជំរុញនិងលើកទឹកចិត្តឱ្យចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសក្នុងការគ្រប់គ្រងទឹកស្អាត
5. បន្តចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ ឧបករណ៍ ទម្ងន់ និងរង្វាស់រង្វាល់គុណភាពផលិតផលលើទំនិញផលិតទំនិញវេចខ្ចប់ និងគីមីចំណីអាហារ
6. បន្តផ្សព្វផ្សាយច្បាប់ស្តីពីស្តង់ដារ ច្បាប់ស្តីពីមាត្រាសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ណែនាំអំពីផលប្រយោជន៍ និងផល់ប៉ះពាល់នៃគុណភាព សុត្ថិភាព សារធាតុគីមី ព្រមទាំងចុះយកសំណាកគំរូលផលិតទៅវិភាគ

២.៤.១.៦. វិស័យសាធារណៈការ និងដឹកជញ្ជូន

1. សាងសង់ផ្លូវប្រភេទDBST មកជាប្រភេទផ្លូវបេតុងកៅស៊ូ AC
2. សាងសងផ្លូវក្រាលថ្មចាក់កៅស៊ូពីរជាន់ ប្រភេទDBST
3. សាងសងផ្លូវដោយក្រាលក្រួសក្រហម
4. រៀបខឿនការពារច្រាំងសមុទ្រជាបេតុងអាមេរ
5. ជួលជុល ថែទាំប្រព័ន្ធរំដោះទឹក លូ និងប្រឡាយ
6. សាងសង់អគារសម្រាប់ស្ថានីយ៍ថ្លឹងជញ្ជីង

២.៤.១.៧. វិស័យទេសចរណ៍

1. បំពេញបន្ថែមមន្ត្រីក្របខ័ណ្ឌនិងមន្ត្រីជាប់កិច្ចសន្យាបំរើការងារទេសចរណ៍
2. រៀបចំច្បាប់សហគមន៍ទេសចរណ៍ជា អន្តរៈក្រសួងងាយស្រួលជំនាញយកទៅអនុវត្តក្នុងការចូលរួមបង្កើតសហគមន៍
3. ផ្សព្វផ្សាយសក្តានុពលទេសចរណ៍ក្នុងខេត្តដែលមានស្រាប់ដើម្បីធ្វើការទាក់ទាញដៃគូវិនិយោគវិស័យទេសចរណ៍ឯកជន
4. ផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណអោយបានទូលំទូលាយនូវសារាចរណែនាំជូនដំណឹងដល់ម្ចាស់សេវាកម្ម អាជីវកម្ម គ្រប់ប្រភេទ គ្រប់ស្រុកទូទាំងខេត្ត
5. ចាំបាច់អោយអាជីវកម្ម គ្រប់សេវាកម្មទាំងអស់ត្រូវមានតារាងតំលៃនិង ឈ្មោះមុខម្ហូបដាក់តាំងតំលៃអោយបានច្បាស់លាស់ជូនដល់ភ្ញៀវទេសចរណ៍
6. អំពាវនាវដល់សប្បុរសជន អ្នកវិនិយោគដៃគូរឯកជន ក្រុមហ៊ុនទេសចរណ៍ អង្គការក្រៅរដ្ឋាភិបាល និងគម្រោងមន្ទីរ វិស័យដែលបានគាំទ្រ
7. ម្ចាស់អាជីវកម្ម សេវាកម្មទាំងអស់ទទួលយកការណែនាំពីការផ្សព្វផ្សាយ និងចូលរួមវគ្គបណ្តុះបណ្តាល សេវាកម្មផ្សេងៗពីមន្ទីរជំនាញ
8. ម្ចាស់អាជីវកម្ម សេវាកម្ម តាមប្រភេទនិមួយៗត្រូវតែយល់ដឹងពីការវាយតំលៃចំណាប់ថ្នាក់ស្តង់ដាគ្រប់ប្រភេទដែលបានចែងជាធរមាន
9. រៀបចំអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ពន្ធទៅកាន់គោលដៅទេសចរណ៍សំបូរសក្តានុពលទេសចរណ៍ច្រើន
10. ជំរុញការបណ្តុះបណ្តាលបន្ថែមបច្ចេកព័ត៌មានវិទ្យា និងភាសារបរទេស
11. អំពាវនាវដល់វិស័យឯកជន និងអ្នកវិនិយោគទុនចូលរួមអភិវឌ្ឍរួមគ្នាទាំងស្ថាប័នរដ្ឋ ព្រមទាំងប្រតិបត្តិការទេសចរណ៍និងគម្រោងនានាដែលបានគាំទ្រ ក្នុងវិស័យនេះ

២.៤.១.៨. វិស័យពាណិជ្ជកម្ម

1. គ្រប់គ្រងការធ្វើអាជីវកម្មចំពោះអាជីវករ សេវាករ
2. ផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម និងសហការទទួលពាក្យស្នើសុំចុះបញ្ជី បញ្ជាក់ទីតាំងក្រុមហ៊ុន សាខាក្រុមហ៊ុនសហគ្រាសពាណិជ្ជកម្ម ក្រោយពេលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរួច ជម្រុញការដាក់ស្លាកយីហោក្រុមហ៊ុននិងណែនាំនីតិវិធីស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (Form D)
3. ការគ្រប់គ្រងទីផ្សារ
4. ជម្រុញការអភិវឌ្ឍន៍ផលិតផល និងទីផ្សារ
5. ការងារអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម និងវិស័យឯកជន

២.៤.១.៩. វិស័យពន្ធដារ

1. ពន្លឿនការចុះបញ្ជីរបស់អ្នកជាប់ពន្ធថ្មី អោយមានភាពងាយស្រួលនិងសាមញ្ញជាងមុន
2. កែលម្អរការដាក់លិខិតប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំដោយផ្តល់ប័ណ្ណសម្គាល់អត្តសញ្ញាណបង់ពន្ធយានយន្ត
3. កែលម្អរការដាក់លិខិតប្រកាសបង់ពន្ធលើអចលទ្រព្យប្រចាំឆ្នាំដោយផ្តល់ប័ណ្ណសម្គាល់អត្តសញ្ញាណអចលទ្រព្យ

4. រៀបចំប័ណ្ណព័ត៌មានត្រឹមត្រូវ ឯកភាព ស្តីពីសារពើពន្ធដែលមានខ្លឹមសារងាយយល់ សម្រាប់អ្នកជាប់ពន្ធ
5. ប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមនិងមធ្យោបាយផ្សេងៗ)Call Center, Live Chat, GDT App) ដើម្បីផ្សព្វផ្សាយបទបញ្ជាតិស្តីពីសារពើពន្ធផ្សេងៗ ដែលបានធ្វើបច្ចុប្បន្នភាពនិងកំពុងអនុវត្ត ព្រមទាំងដោះស្រាយចម្ងល់ផ្សេងៗជូនអ្នកជាប់ពន្ធអោយបានទាន់ពេលវេលា
6. រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធគ្រប់ប្រភេទ ដែលនៅជាធរមានជូនអ្នកជាប់ពន្ធ
7. ពង្រឹងការចុះបញ្ជី ការចាត់ចែងលិខិតប្រកាស ការធ្វើសវនកម្ម និងស៊ើបអង្កេតបទល្មើសពន្ធដារ
8. រៀបចំកែសម្រួលនិងធ្វើអោយប្រសើរឡើងនូវច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃបរិបទធុរកិច្ចជាតិ និងអន្តរជាតិ តាមរយៈការផ្តល់ធាតុចូលផ្សេងៗស្តីពីពន្ធដារ

២.៤.១.១០.វិស័យគយ និងរដ្ឋាករ

1. ស្នើសុំបំពាក់ម៉ាស៊ីនស្កែននៅមាត់ច្រកត្រួតពិនិត្យចាំយាម
2. ស្នើសុំបំពាក់មធ្យោបាយប្រដេញផ្លូវទឹក
3. ការពង្រឹងសុពលភាពនៃឯកសារនាំចូល-នាំចេញ
4. ការពង្រឹងអនុលោមភាពក្នុងការគិតពន្ធគយ ការប្រមូល និងការបង់ចំណូលគយ និងរដ្ឋាករចុះឃ្លាំមើលអនុលោមភាពនៃនីតិវិធីគយ របស់អង្គភាពគយក្រោមឱវាទ
5. បន្តផ្សព្វផ្សាយរំលឹកដល់វិស័យឯកជនពាក់ព័ន្ធឱ្យបានទៀងទាត់ពាក់ព័ន្ធនឹងនីតិវិធីបែបបទគយ នីតិវិធីនៃការទទួលខុសត្រូវក្នុងការបង់ពន្ធអាករលើទំនិញឱ្យបានតាមបទបញ្ញត្តិជាធរមាន
6. ការអនុវត្តឱ្យបានពេញលេញនូវបទបញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការទទួលខុសត្រូវក្នុងការងារត្រួតពិនិត្យទំនិញ
7. ការពង្រឹង/រំលឹកជាប្រចាំដល់មន្ត្រីត្រួតពិនិត្យគយនូវ ការទទួលខុសត្រូវក្នុងការងារត្រួតពិនិត្យប្រកបដោយជំនាញ វិជ្ជាជីវៈ
8. ការលើកទឹកចិត្តដល់មន្ត្រីគយមានសមត្ថកិច្ចបង្ក្រាបអំពើរត់គេចពន្ធឱ្យអនុវត្តការងាររបស់ខ្លួនតាមរូបភាពភ្លៀង រលឹមនិងប្រកបដោយឆន្ទៈដាច់ខាត
9. លើកកម្ពស់កាតព្វកិច្ចនៃការរក្សាការសម្ងាត់វិជ្ជាជីវៈរបស់មន្ត្រីមានសមត្ថកិច្ច ជាពិសេសព័ត៌មានហានិភ័យសម្ងាត់សម្រាប់សំណូមពរនៃការងារបង្ក្រាបបទល្មើស
10. កសាងផែនការសម្មភាពបង្ក្រាបអំពើរត់ពន្ធដោយឡែក ពីគ្នាតាមសូចនាករ តាមមុខសញ្ញា និងតាមពេលកំណត់នីមួយៗ អនុលោមតាមបទបញ្ញត្តិជាធរមាន

២.៤.១.១១.វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

1. ពង្រឹងការសហការជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងការអនុវត្តច្បាប់ អោយបានត្រឹមត្រូវ
2. បន្តជម្រុញការយកចិត្តទុកដាក់ពង្រីកសេវាអោយមានវិសាលភាពគ្រប់ដណ្តប់ដល់តំបន់ដាច់ស្រយ៉ាលទាំងនោះ
3. ជម្រុញក្រុមហ៊ុន និងប្រតិបត្តិករធ្វើសេវាប្រៃសណីយ៍ យកចិត្តទុកដាក់ផ្សព្វផ្សាយលើគុណភាពសេវាប្រៃសណីយ៍និងឈានទៅពង្រីកសេវារបស់ខ្លួនតាមរយៈការបង្កើតភ្នាក់ងារអោយមានដល់មូលដ្ឋានគ្រប់ស្រុក

២.៤.១.១២.វិស័យអភិវឌ្ឍន៍ជនបទ

1. ជួលជុល និងថែទាំគមនាគមន៍នៅជនបទ
2. ជីកស្រះសម្រាប់ស្តុកទឹក និង អណ្តូង
3. ចុះចែកសម្ភារៈសាងសង់បង្គន់អនាម័យ
4. ចុះបណ្តុះបណ្តាលគណៈកម្មការអភិវឌ្ឍន៍ភូមិស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ភូមិ
5. ចុះផ្សព្វផ្សាយពីដំណើរការនៃការរៀបចំសហគមន៍សន្សំប្រាក់
6. ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីជនជាតិដើមភាគតិច និងកំណត់អត្តសញ្ញាណ
7. បើកវគ្គបណ្តុះបណ្តាលជំនាញតាមតម្រូវការទីផ្សារ

២.៤.១.១៣. វិស័យធនាគារជាតិ

1. ជម្រុញនិងលើកទឹកចិត្តឱ្យគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការទទួលបានសេវាធនាគារ និងហិរញ្ញវត្ថុឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ។ធ្វើការផ្សព្វផ្សាយយុទ្ធនាការ "តោះនិយាយពីលុយ" ។
2. ផ្សព្វផ្សាយពីប្រព័ន្ធទូរសព្ទ Hotline សម្រាប់ទទួលព័ត៌មាន និងដោះស្រាយចម្លល់ស្តីពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ ទៅដល់ក្រុង/ស្រុក
3. ផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមរវាងធនាគារជាតិនៃកម្ពុជា និងក្រសួងហិរញ្ញវត្ថុ និងលិខិតបទដ្ឋានផ្សេងៗនៅតាមបណ្តាលក្រុងស្រុក
4. ផ្សព្វផ្សាយយុទ្ធនាការ "ខ្ញុំស្រឡាញ់ប្រាក់រៀល"
5. កំណត់ឱ្យអាជីវករប្តូរប្រាក់ដាក់បង្ហាញអត្រាប្តូរប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណបរទេសនៅនៅកន្លែងប្រកបអាជីវកម្ម
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ
- បូកសរុបបញ្ហា និងតម្រូវការនានា ដែលស្នើឡើងដោយក្រុង ស្រុក មន្ទីរជំនាញ សង្គមសីវិលវិស័យឯកជន និងអង្គភាពពាក់ព័ន្ធនានានៅក្នុងដែនសម្ថភាពកិច្ចរបស់ក្រុមប្រឹក្សា
- រៀបចំផ្សព្វផ្សាយព័ត៌មានអំពីការសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីរបស់ខេត្ត
- រៀបចំសិក្ខាសាលាវេទិការពិគ្រោះយោបល់ ជាមួយភាគីពាក់ព័ន្ធនានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីរំកិលរបស់ខេត្ត
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- រៀបចំឯកសារពាក់ព័ន្ធនានាសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាខេត្តដើម្បីពិនិត្ស និងអនុម័តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- កែសម្រួល និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោកបីឆ្នាំរំកិលរបស់ខេត្ត

ប្រការ ៣.-

សេចក្តីសម្រេច ឬបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៤.-

លោកជំទាវ នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត និងសាម៊ីខ្លួនដែលមានឈ្មោះក្នុងប្រការ១ខាងលើត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៥៨ ខែ ភាទបទ ឆ្នាំកុរ ព.ស ២៥៦៣
កោះកុង, ថ្ងៃទី ៣០ ខែ ភាទ ឆ្នាំ២០១៩
អភិបាល

មិថុនា តូថង

ចម្លងជូន
.ក្រសួងមហាផ្ទៃ
.ក្រសួងស្ថានប័នពាក់ព័ន្ធ
.លេខាធិការដ្ឋាន គ.ជ.អ.ប
(ដើម្បីជូនជ្រាប)
.ជូចប្រការ៤
(ដើម្បីអនុវត្ត)
.ឯសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី៤

ប្រតិទិនការងារ
កសាងផែនការអភិវឌ្ឍន៍ខេត្តកោះកុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកោះកុង

ប្រតិទិនការងារ
សម្រាប់ការរៀបចំ ផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ (២០២០-២០២៤) និងការរៀបចំ
និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២០-២០២២) របស់រដ្ឋបាលខេត្តកោះកុង

ល.រ	សកម្មភាព	ពេលវេលា	ទីតាំង	អ្នកទទួលខុសត្រូវ	ថវិកា(រៀល)	ផ្សេងៗ
ក.ការរៀបចំផែនការអភិវឌ្ឍន៍ខេត្តរយៈពេល ៥ឆ្នាំ(២០២០-២០២៤)						
ជំហានទី១	**ការរៀបចំនិងផ្សព្វផ្សាយស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ខេត្ត**					
១.១	ដំណាក់កាលមុនកិច្ចប្រជុំផ្សព្វផ្សាយ	01-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
១.២	ដំណាក់កាលក្នុងអំឡុងពេលកិច្ចប្រជុំផ្សព្វផ្សាយ	03-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
១.៣	ដំណាក់កាលក្រោយពេលកិច្ចប្រជុំផ្សព្វផ្សាយ	06-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
ជំហានទី២	**ការរៀបចំនិងផ្សព្វផ្សាយស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ខេត្ត**					
	ដំណាក់កាលទី១					
២.១	ការវិភាគស្ថានភាពខេត្ត	11-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
២.២	ការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍមូលដ្ឋានខេត្ត	16-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.៣	ការរៀបចំកម្មវិធីអភិវឌ្ឍមូលដ្ឋានរយៈពេលប្រាំឆ្នាំ	18-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.៤	ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម	19-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.៥	ការពិនិត្យនិងផ្តល់យោបល់របស់គណៈអភិបាលខេត្ត	23-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.៦	ការពិនិត្យនិងសម្រេចលើសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍ និងកម្មវិធីអភិវឌ្ឍមូលដ្ឋាន	25-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.៧	ការរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃ	26-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.៨	ការរៀបចំស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខេត្ត	27-09-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
	ដំណាក់កាលទី២					
២.៩	ការចងក្រងសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ខេត្ត	03-10-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.១០	កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្ត	09-10-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
២.១១	ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្ត	12-10-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		

ល.រ	សកម្មភាព	ពេលវេលា	ទីតាំង	អ្នកចូលខុសត្រូវ	ថវិកា(រៀល)	ផ្សេងៗ
ជំហានទី៣	**ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ខេត្ត**					
៣.១	ការអនុម័តផែនការអភិវឌ្ឍន៍ខេត្ត	17-10-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
៣.២	ការបោះពុម្ព និងផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍ខេត្ត	31-10-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
ខ. ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២០-២០២២)						
ជំហានទី១	**ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**					
១.១	ការប្រជុំណែនាំពីការប្រមូលតម្រូវការអាទិភាព	01-11-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
១.២	ប្រជុំបូកសរុបតម្រូវការគម្រោង សកម្មភាព និងចាត់អាទិភាព	14-11-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
ជំហានទី២៖	**ការរៀបចំសេចក្តីព្រាង កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**					
២.១	កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត	18-11-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.២	ការពិនិត្យ និងចាត់អាទិភាពគម្រោងកម្មវិធីវិនិយោគបីឆ្នាំរំកិលឡើងវិញ	20-11-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
២.៣	វេទិកាពិគ្រោះយោបល់ក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត	25-11-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
២.៤	ការចុះប្រមូលសិក្ខាសាលាសមាហរណកម្មនៅតាមបណ្តាក្រុង ស្រុក	29-11-2019	ក្រុង ស្រុក	ក្រុមការងារកសាងផែនការនិងអ្នកពាក់ព័ន្ធ		
២.៥	ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តន៍កម្មវិធីវិនិយោគបីឆ្នាំរំកិល	05-12-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.៦	ចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត	12-12-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
២.៧	ការពិនិត្យផ្តល់យោបល់របស់គណៈអភិបាល និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស	18-12-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
ជំហានទី៣	**ការពិនិត្យ អនុម័ត និងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**					
៣.១	កិច្ចប្រជុំពិនិត្យអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត	23-12-2019	សាលាខេត្ត	ក្រុមប្រឹក្សាខេត្ត		
៣.២	ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត	28-12-2019	សាលាខេត្ត	ក្រុមការងារកសាងផែនការ		
សរុបរួម						

ប្រតិទិនការងារសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំ(២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២០-២០២២) ខាងលើ ត្រូវបានក្រុមប្រឹក្សាខេត្តកោះកុង អនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញ លើកទី៣ អាណត្តិទី៣ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩

ថ្ងៃអង្គារ ៥រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ខេត្តកោះកុង ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩

ជំ ក្រុមប្រឹក្សា

ប្រធាន

កាយ សំរួម

ឧបសម្ព័ន្ធទី៥

គោលដៅ និងចំណុចដៅ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក)

គោលដៅ និង ចំណុចដៅ
នៃ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កម្ពុជា (គ.អ.ច.ក.)



គោលដៅទី១៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង

ចំណុចដៅ

១.១ ត្រឹមឆ្នាំ២០៣០លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរសម្រាប់ប្រជាជនគ្រប់រូបនៅគ្រប់ទីកន្លែង វាស់វែងប្រជាជនដែលរស់នៅក្នុងកម្រិតជីវភាពតិចជាង ១,៩០ដុល្លារក្នុងមួយថ្ងៃ។

១.២ កាត់បន្ថយយ៉ាងតិចពាក់កណ្តាលនូវសមាមាត្រនៃបុរស ស្ត្រីនិងកុមារគ្រប់អាយុ ដែលរស់នៅក្នុងភាពក្រីក្រ គ្រប់សមាសភាព ដោយផ្អែកលើនិយមន័យរបស់កម្ពុជា នៅត្រឹមឆ្នាំ២០៣០។

១.៣ អនុវត្តប្រព័ន្ធជាតិគាំពារសង្គមនិងវិធានការផ្សេងៗ ឲ្យបានទូទាំងប្រទេស និងសម្រេចឲ្យបានភាគច្រើននូវភាពគ្របដណ្តប់នៃប្រព័ន្ធនេះ ដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ នៅត្រឹមឆ្នាំ២០៣០។

១.៤ ត្រឹមឆ្នាំ២០៣០ ធានាថា បុរស ស្ត្រីគ្រប់រូប ជាពិសេសប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ច និងក្នុងការទទួលបានសេវាមូលដ្ឋានភាពជាម្ចាស់ និងការគ្រប់គ្រងដីនិងកម្មសិទ្ធិផ្សេងទៀត ធនធានធម្មជាតិ បច្ចេកវិទ្យាថ្មីៗសមស្របនិងសេវាហិរញ្ញវត្ថុ រួមទាំងមីក្រូហិរញ្ញវត្ថុ។

១.៥ ត្រឹមឆ្នាំ២០៣០កសាងភាពធនរបស់ប្រជាជនក្រីក្រ និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ និងកាត់បន្ថយពីភាពងាយគ្រោះថ្នាក់និងភាពងាយរងគ្រោះពីព្រឹត្តការណ៍ធំៗពាក់ព័ន្ធនឹងអាកាសធាតុ និងការភ័យតក់ស្លុតផ្សេងទៀតដោយសារសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន និងគ្រោះមហន្តរាយនានា។

១.a ធានាថា ការកៀរគរធនធានពីប្រភពខុសៗគ្នារួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការសម្រាប់លើកកម្ពស់ការអភិវឌ្ឍ ដើម្បីផ្តល់នូវមធ្យោបាយនិងការព្យាករណ៍គ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍ

ប្រទេសជាតិនានា ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួចសម្រាប់អនុវត្តកម្មវិធីនិងគោលនយោបាយនានាដើម្បីបញ្ចប់ភាពក្រីក្រក្នុងគ្រប់រូបភាព។

១.b បង្កើតក្របខ័ណ្ឌគោលនយោបាយសមស្របនៅកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ ដោយផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍គាំទ្រប្រជាជនក្រីក្រនិងមានលក្ខណៈយេនឌ័រសម្រាប់គាំទ្រដល់ការពន្លឿនការវិនិយោគ ក្នុងផ្នែកលុបបំបាត់ភាពក្រីក្រ។



គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និង លើកកម្ពស់កសិកម្មប្រកបដោយចីរភាព

២.១ ត្រឹមឆ្នាំ២០៣០ បញ្ចប់ភាពអត់ឃ្លាន និងធានានូវការទទួលបានស្ថានភាពនេះដោយប្រជាជនគ្រប់រូប ជាពិសេស ប្រជាជនក្រីក្រនិងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ រួមទាំងកុមារ ឲ្យរួចផុតភ័យ មានម្ហូបអាហារនិងអាហារូបត្ថម្ភគ្រប់គ្រាន់ក្នុងមួយឆ្នាំៗ។

២.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃកង្វះអាហារូបត្ថម្ភ រួមទាំងការសម្រេចបាននៅឆ្នាំ២០២៥ នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្តីពីភាពក្រីននិងភាពស្គមស្គាំងរបស់កុមារអាយុក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះនិងស្ត្រីកំពុងបំបៅដោះកូន និង ស្ត្រីវ័យចាស់។

២.៣ ត្រឹមឆ្នាំ២០៣០ ទទួលបានកំណើនទ្វេដងនៃ ផលិតផលកសិកម្ម និងចំណូលរបស់ផលិតករធនតូច ជាពិសេស ស្ត្រីក្នុងគ្រួសារទុរគត គ្រួសារកសិករ អ្នកគង្វាលនិងអ្នកនេសាទ រួមទាំងតាមរយៈការធានានិងការទទួលបានស្មើភាពគ្នានូវដីធ្លី ធនធានផលិតកម្មផ្សេងទៀតនិងធាតុចូល ចំណេះដឹង សេវាហិរញ្ញវត្ថុ ទីផ្សារនិងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែនកសិកម្ម។

២.៤ ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មម្ហូបអាហារដែលមានចីរភាព អនុវត្តសកម្មភាពកសិកម្មដោយមានមានការឆ្លើយតបនឹងបម្រែបម្រួលអាសធាតុ ដែលជួយឲ្យមានការកើនឡើងនូវផលិតកម្មនិងផលិតផល ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី ជួយពង្រឹងសមត្ថភាពសម្រាប់

បន្សាំនឹងបម្រែបម្រួលអាកាសធាតុអាក្រក់ ភាពរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀត និងធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់គុណភាពដី។

២.៥ ត្រឹមឆ្នាំ២០២០ រក្សាការធ្វើពិពិតកម្មហ្សែននៃគ្រាប់ពូជការធ្វើកសិកម្មនិងចំការ ការផ្សាំពូជសត្វ និងប្រភេទសត្វព្រៃដែលពាក់ព័ន្ធ រួមទាំងតាមរយៈការគ្រប់គ្រងសមស្រប ការធ្វើពិពិធកម្មនិងរក្សាគ្រាប់ពូជ នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ និងលើកកម្ពស់ការទទួលបានចំណែកប្រកបដោយយុត្តិធម៌ និងសមធម៌នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានហ្សែននិងចំណេះដឹងប្រពៃណីយ៉ដែលពាក់ព័ន្ធ ដូចការឯកភាពជាអន្តរជាតិ

២.a បង្កើនការវិនិយោគ រួមទាំងតាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ ការស្រាវជ្រាវនិងសេវាផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍបច្ចេកវិជ្ជានិងធនាគារហ្សែនរុក្ខជាតិនិងសត្វដើម្បីលើកកម្ពស់សមត្ថភាពផលិតក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

២.b កែតម្រូវនិងការពារពាណិជ្ជកម្ម (ទប់ស្កាត់របាំងនិងកំហុសឆ្គងពាណិជ្ជកម្ម) ក្នុងទីផ្សារផលិតផលកសិកម្មពិភពលោក រួមទាំងការលប់បំបាត់គ្រប់ទម្រង់ទាំងអស់នៃឧបត្ថម្ភធនដល់ការនាំចេញផលិតផលកសិកម្ម និងរាល់វិធីសាស្ត្រនាំចេញដែលមានផលប៉ះពាល់ដូចគ្នាដោយផ្អែកតាមអាណត្តិកាលនៃកិច្ចប្រជុំតុមូលពីការអភិវឌ្ឍនៅទីក្រុងដូហា។

២.c ឯកភាពលើវិធានការណ៍នានា ដើម្បីធានាកិច្ចដំណើរការប្រសើរជាងមុននៃទីផ្សារមុខទំនិញម្ហូបអាហារនិងវត្ថុធាតុដើមសម្រាប់ផលិត និងសម្របសម្រួលឲ្យការទទួលបានទាន់ពេលវេលានូវព័ត៌មានពីទីផ្សារ រួមទាំងសេវាម្ហូបអាហារ ដើម្បីជួយទប់ស្កាត់ការប្រែប្រួលខ្លាំងក្លារបស់ថ្លៃម្ហូបអាហារ។



គោលដៅទី៣៖ ធានាឲ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ

៣.១ កម្រិតនៃការអភិវឌ្ឍនៃប្រទេសកម្ពុជា: សុខភាពនិងសុខមាលភាពរបស់ប្រជាពលរដ្ឋ និងបង្ការហានិភ័យហិរញ្ញវត្ថុ។

៣.១ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយអត្រាមរណៈភាពមាតានៅកម្រិតសាកល ឲ្យនៅកម្រិតទាបជាង ៧០ក្នុងចំណោម ១០០ ០០០កំណើតរស់។

៣.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់ការស្លាប់ដែលអាចការពារបាន នៃទារកទើបកើតនិងកុមារអាយុក្រោម ៥ឆ្នាំ ដោយគ្រប់ប្រទេសទាំងអស់មានគោលដៅកាត់បន្ថយមរណភាពទារកទើបកើត ដល់ត្រឹម ១២ ក្នុង ១០០០កំណើតរស់ និងមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ យ៉ាងហោចណាស់ដល់ត្រឹម ២៥ ក្នុងចំណោម ១០០០កំណើតរស់។

៣.៣ ត្រឹមឆ្នាំ២០៣០ បញ្ចប់ការរីករាលដាលមេរោគអេដស៍ ជំងឺរបេង គ្រុនចាញ់ ជំងឺមិនត្រូវបានយកចិត្តទុកដាក់នៅតំបន់ត្រូពិច ជំងឺថ្លើម ជំងឺឆ្លងតាមទឹក និងជំងឺឆ្លងផ្សេងទៀត។

៣.៤ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានមួយភាគបីនៃមរណៈភាពមុនអាយុកាលរំពឹងទុក ពីជំងឺមិនឆ្លង តាមរយៈ ការការពារនិងការព្យាបាល និងលើកកម្ពស់សុខភាពផ្លូវចិត្តនិងសុខុមាលភាព។

៣.៥ ពង្រឹងការបង្ការនិងការព្យាបាលការសេពសារធាតុរួមទាំង ការសេពគ្រឿងញៀន និងការប្រើប្រាស់ជាតិសុរាដែលនាំឲ្យគ្រោះថ្នាក់។

៣.៦ ត្រឹមឆ្នាំ២០២០ កាត់បន្ថយឲ្យបានពាក់កណ្តាលនៃចំនួនមនុស្សស្លាប់ដោយគ្រោះថ្នាក់ចរាចរនៅទូទាំងពិភពលោក។

៣.៧ ត្រឹមឆ្នាំ២០៣០ ធានាថា ការទទួលបានជាសាកលនូវសេវាថែទាំសុខភាពផ្លូវភេទ និងសេវាសុខភាពបន្តពូជ រួមទាំងផែនការគ្រួសារ ព័ត៌មាននិងការអប់រំ និងការធ្វើសមាហរណកម្មសុខភាពបន្តពូជទៅក្នុងកម្មវិធីនិងយុទ្ធសាស្ត្រជាតិ។

៣.៨ សម្រេចឲ្យបាន នូវសុខភាពល្អជាសកល រួមទាំង ការបង្ការហានិភ័យផ្នែកហិរញ្ញវត្ថុ ការទទួលបាននូវសេវាថែទាំសុខភាពចាំបាច់ដែលមានគុណភាព និង ការទទួលបានថ្នាំពេទ្យនិងថ្នាំបង្ការចាំបាច់ដែលមានគុណភាព មានប្រសិទ្ធភាពនិងសុវត្ថិភាព សម្រាប់ប្រជាជនគ្រប់រូប។

៣.៩ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយជាបណ្តើរៗនូវចំនួនមនុស្សស្លាប់និងឈឺ ដោយសារជាតិគីមីនិងខ្យល់ប្រកបដោយគ្រោះថ្នាក់ ការបំពុលទឹកនិងបរិយាកាស និងការចម្លងមេរោគ។

៣.a ពង្រឹងការអនុវត្តក្របខ័ណ្ឌអនុសញ្ញារបស់អង្គការសុខភាពពិភពលោក ស្តីពីការត្រួតពិនិត្យថ្នាំជក់ ឲ្យបានហ្មត់ចត់នៅក្នុងគ្រប់ប្រទេស។

៣.b គាំទ្រដល់ការស្រាវជ្រាវនិងការអភិវឌ្ឍ វ៉ាក់សាំងនិងថ្នាំពេទ្យ សម្រាប់ជំងឺឆ្លងនិងជំងឺមិនឆ្លងដែលមានផលប៉ះពាល់ជាដំបូងដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ ផ្តល់នូវទទួលបាននូវថ្នាំពេទ្យនិងវ៉ាក់សាំងចាំបាច់ ដើម្បីឆ្លើយតបនឹងសេចក្តីប្រកាសទីក្រុងដាហាស្តីពីកិច្ចព្រមព្រៀងស្តីពីទស្សនវិស័យពាក់ព័ន្ធនឹងពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា (TRIPS) និងសុខភាពសាធារណៈ ដែលបញ្ជាក់ពីសិទ្ធិរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការប្រើប្រាស់លក្ខខណ្ឌពេញលេញនៅក្នុងកិច្ចព្រមព្រៀងស្តីពី ទិដ្ឋភាពដែលពាក់ព័ន្ធនឹងអាជីវកម្មដែលមានកម្មសិទ្ធិបញ្ញាដែលឆ្លើយតបនឹងការការពារសុខភាពសាធារណៈ និងជាពិសេស ផ្តល់នូវការទទួលបានថ្នាំពេទ្យសម្រាប់ប្រជាជនទាំងអស់។

៣.c បង្កើនជាបន្តបន្ទាប់ការវិភាជថវិកាលើវិស័យសុខាភិបាល និងជ្រើសរើសការអភិវឌ្ឍការបណ្តុះបណ្តាល និងការជួលបុគ្គលិកផ្នែកសុខាភិបាល នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេស នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងបណ្តារដ្ឋដែនកោះតូចៗ កំពុងអភិវឌ្ឍន៍។

៣.d ពង្រឹងសមត្ថភាពរបស់ប្រទេសទាំងអស់ ជាពិសេស បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ផ្តល់ព័ត៌មានជាមុន ពាក់ព័ន្ធនឹងការកាត់បន្ថយហានិភ័យ និងការគ្រប់គ្រងហានិភ័យសុខភាពនៅកម្រិតជាតិនិងកម្រិតសកល។



គោលដៅទី៤៖ ធានាការអប់រំប្រកបដោយ គុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប

៤.១ ត្រឹមឆ្នាំ២០៣០ ធានាថា កុមារានិងកុមារីទទួលបានការអប់រំពេញលេញប្រកបដោយសមធម៌និងគុណភាព នៅកម្រិតបឋមសិក្សានិងមធ្យមសិក្សាដោយមិនមានការបង់ថ្លៃឈ្នួល ដែលនឹងធ្វើឲ្យលទ្ធផលនៃការសិក្សាមានប្រសិទ្ធភាព។

៤.២ ត្រឹមឆ្នាំ២០៣០ ធានាថា កុមារានិងកុមារីគ្រប់រូបនឹងទទួលបាននូវការអភិវឌ្ឍក្នុងភាពជាកុមារតូច ទាំងការថែរក្សានិងការអប់រំនៅមត្តេយ្យសិក្សា ប្រកបដោយគុណភាព សម្រាប់ត្រៀមខ្លួនគ្រប់គ្រាន់សិក្សានៅកម្រិតបឋមសិក្សា។

៤.៣ ត្រឹមឆ្នាំ២០៣០ ធានាការទទួលបានស្មើភាពគ្នាសម្រាប់បុរសនិងស្ត្រីគ្រប់រូប នូវការបណ្តុះបណ្តាលបច្ចេកទេសមុខវិជ្ជាជីវៈ និងការសិក្សានៅកម្រិតឧត្តមសិក្សា រួមទាំង សាកលវិទ្យាល័យ។

៤.៤ ត្រឹមឆ្នាំ២០៣០ បង្កើនជាបន្តបន្ទាប់នូវចំនួនយុវវ័យនិងប្រជាជនពេញវ័យដែលមានជំនាញរួមទាំងជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ សម្រាប់បំពេញការងារ មុខរបរភាពជាសហគ្រិនសមរម្យ។

៤.៥ ត្រឹមឆ្នាំ២០៣០ លុបបាត់កម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាការទទួលបានភាពស្មើភាពគ្នាក្នុងការអប់រំគ្រប់កម្រិត និងនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ក្រុមជនងាយរងគ្រោះ រួមទាំងក្រុមជនដែលបាត់បង់សមត្ថភាពពលកម្ម ប្រជាជននិងកុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។

៤.៦ ត្រឹមឆ្នាំ២០៣០ ធានាថា យុវវ័យគ្រប់រូប និង~~សមាមាគ្រ~~ភាគច្រើននៃប្រជាជនពេញវ័យ ទាំងបុរសនិងស្ត្រី សម្រេចបាននូវលក្ខខណ្ឌអក្ខរភាព។

៤.៧ ត្រឹមឆ្នាំ២០៣០ ធានាថា អ្នកសិក្សាគ្រប់រូប នឹងទទួលបានចំណេះដឹងនិងជំនាញដែលត្រូវការដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងក្នុងចំណោមប្រជាជនផ្សេងទៀតតាមរយៈការសិក្សាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងជីវភាពពរស់នៅដោយចីរភាព មានសិទ្ធិមនុស្ស មានសមភាពយេនឌ័រ មានលើកកម្ពស់វប្បធម៌សន្តិភាពនិងគ្មានអំពើហិង្សា ប្រជាជាតិនិងការលើកទឹកចិត្តជាសាកលនៃវប្បធម៌ចម្រុះ និងការរួមចំណែករបស់វប្បធម៌ទៅដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

៤.a កសាងនិងធ្វើឲ្យប្រសើរឡើងសម្ភារៈបរិក្ខាអប់រំ ដែលធ្វើឲ្យមានភាពប្រែប្រួលដល់កុមារអ្នកបាត់បង់សមត្ថភាពពលកម្មនិងយេនឌ័រ និងផ្តល់នូវសុវត្ថិភាព គ្មានអំពើហិង្សា មានបរិស្ថាននៃការសិក្សាប្រកបដោយបរិយាប័ន្ននិងមានប្រសិទ្ធភាព សម្រាប់ប្រជាជនគ្រប់រូប។

៤.b ត្រឹមឆ្នាំ២០២០ ពង្រីកជាបន្តបន្ទាប់នូវចំនួនអាហារូបករណ៍ក្នុងសាកលលោកសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច បណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ បណ្តាប្រទេសក្នុងទ្វីបអាហ្វ្រិក សម្រាប់ការសិក្សានៅកម្រិតខ្ពស់ រួមទាំង ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ កម្មវិធីបច្ចេកទេសវិស្វកម្មនិងវិទ្យាសាស្ត្រ នៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។

៤.c ត្រឹមឆ្នាំ២០៣០ បង្កើនឲ្យបានច្រើនការផ្គត់ផ្គង់គ្រូបង្រៀនដែលមានគុណភាព រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងក្នុងបណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍។

គោលដៅទី៥៖ សម្រេចឲ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប

៥.១ បញ្ចប់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីនិងកុមារី នៅគ្រប់ទីកន្លែង។

៥.២ លុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងកុមារី នៅទីសាធារណៈនិងទីកន្លែងឯកជននានា រួមទាំងការជួញដូរ ការធ្វើអាជីវកម្មផ្លូវភេទនិងអាជីវកម្មផ្សេងទៀត។

៥.៣ លុបបំបាត់រាល់ទង្វើដែលមានគ្រោះថ្នាក់ ដូចជាការបង្ខំកុមារឲ្យរៀបអាពាហ៍ពិពាហ៍ និងការធ្វើឲ្យមានរបួសស្នាមប្រដាប់បន្តពូជ។

៥.៤. ទទួលស្គាល់និងផ្តល់តម្លៃដល់ការងារផ្ទះដែលមិនទទួលកម្រៃ តាមរយៈ ការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយគាំពារសង្គម និងលើកកម្ពស់ការរួមចំណែកទទួលខុសត្រូវឲ្យបានសមរម្យ នៅក្នុងសង្គមគ្រួសារនិងសង្គមជាតិ។

៥.៥ ធានាការចូលរួមពេញលេញនិងមានប្រសិទ្ធភាពរបស់ស្ត្រី និងមានឱកាសដូចគ្នាក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិតនៃការធ្វើសេចក្តីសម្រេចក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងជីវិតជាសាធារណៈ។

៥.៦ ធានាការទទួលបានសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ និងសិទ្ធិបន្តពូជជាសកលដូចបានឯកភាពដោយផ្អែកលើកម្មវិធីសកម្មភាពរបស់សន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍនិងផែនការ សកម្មភាពទីក្រុងប៉េកាំង និងឯកសារពាក់ព័ន្ធនានា។

៥.a ដំណើរការកំណែទម្រង់ ដើម្បីផ្តល់ដល់ស្ត្រីនូវសិទ្ធិស្មើភាពគ្នា លើធនធានសេដ្ឋកិច្ច ក៏ដូចជាការទទួលបានភាពជាម្ចាស់និងការគ្រប់គ្រងដីនិងអចលនទ្រព្យផ្សេងទៀត សេវាកម្មហិរញ្ញវត្ថុ ធនធានធម្មជាតិនិងមរតក ដោយផ្អែកលើច្បាប់របស់ប្រទេស។

៥.b បង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ដើម្បីលើកកម្ពស់ភាពអង់អាចដល់ស្ត្រី។

៥.C អនុម័តនិងពង្រឹងគោលនយោបាយនិងបទដ្ឋានគតិយុត្តិនានា សម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងកុមារី នៅគ្រប់កម្រិត។



គោលដៅទី៦៖ ធានាឲ្យមានទឹកនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាព សម្រាប់ប្រជាជនគ្រប់រូប

៦.១ ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានសាកលកម្មនិងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាពនិងតម្លៃសមរម្យ សម្រាប់ប្រជាជនទាំងអស់។

៦.២ ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានគ្រប់គ្រាន់និងសមធម៌នូវអនាម័យ សម្រាប់ប្រជាជនគ្រប់រូប និងបញ្ចប់ការបន្ទោរបង់នៅក្រៅបង្គន់ ផ្តោតការយកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រីនិងកុមារី និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។

៦.៣ ត្រឹមឆ្នាំ២០៣០ ធ្វើឲ្យប្រសើរឡើងគុណភាពទឹក ដោយកាត់បន្ថយការបំពុល លុបបំបាត់ការបោះបង់សំរាម និងកាត់បន្ថយឲ្យនៅកម្រិតទាបបំផុតនៃការបោះបង់ចោលសម្ភារៈនិងសារធាតុជាតិគីមីដែលមានគ្រោះថ្នាក់ កាត់បន្ថយឲ្យនៅពាក់កណ្តាលសមាមាត្រនៃសំណល់រាវដែលមិនបានសម្អាត និងបង្កើនឲ្យបានច្រើនវត្ថុធាតុដើមកកើតឡើងវិញ និងការប្រើប្រាស់ឡើងវិញប្រកបដោយសុវត្ថិភាពជាសកល។

៦.៤ ត្រឹមឆ្នាំ២០៣០ បង្កើនឲ្យបានច្រើននូវប្រសិទ្ធភាពនៃទឹកដែលប្រើប្រាស់នៅគ្រប់វិស័យ និងធានានូវការបូមនិងផ្គត់ផ្គង់ទឹកសាប ដើម្បីដោះស្រាយការខ្វះខាតទឹក និងកាត់បន្ថយឲ្យបានច្រើននូវចំនួនប្រជាជនដែលរងគ្រោះដោយសារការខ្វះខាតទឹក។

៦.៥ ត្រឹមឆ្នាំ២០៣០ អនុវត្តការគ្រប់គ្រងការធ្វើសមាហរណកម្មធនធានទឹកនៅគ្រប់កម្រិត រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនឲ្យបានសមរម្យ។

៦.៦ ត្រឹមឆ្នាំ២០២០ការពារនិងធ្វើឲ្យមានទឹកឡើងវិញ ពាក់ព័ន្ធនឹងប្រព័ន្ធអេកូឡូស៊ី រួមទាំង ភ្នំ ព្រៃដីសើម ទន្លេ និងបឹង។

៦.a ត្រឹមឆ្នាំ២០៣០ ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគាំទ្រការកសាងសមត្ថភាពដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងកម្មវិធីនិងសកម្មភាពពាក់ព័ន្ធនឹងទឹកនិងអនាម័យ រួមទាំងបច្ចេកវិជ្ជា ប្រមូលទឹក បន្សាបទឹកប្រៃប្រសិទ្ធភាពទឹក សម្អាតសំណល់រាវ កែច្នៃនិងប្រើប្រាស់ឡើងវិញ។

៦.b គាំទ្រនិងពង្រឹងការចូលរួមរបស់សហគមន៍មូលដ្ឋាន ក្នុងការធ្វើឲ្យប្រសើរឡើងការគ្រប់គ្រងទឹកនិងអនាម័យ។



គោលដៅទី៧៖ ធានាឲ្យទទួលបានថាមពលដែលមានបច្ចេកទេសទំនើបប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប

៧.១ ត្រឹមឆ្នាំ២០៣០ ធានាការទទួលបានជាសាកលនូវសេវាថាមពលទំនើប អាចទុកចិត្តបាន និងតម្លៃសមរម្យ។

៧.២ ត្រឹមឆ្នាំ២០៣០ បង្កើនចំណែកនៃថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះជាសាកល។

៧.៣ ត្រឹមឆ្នាំ២០៣០ បង្កើនទ្វេរដងនៃអត្រាធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពថាមពលជាសកល។

៧.a ត្រឹមឆ្នាំ២០៣០ លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសម្រួលការទទួលបាន បច្ចេកវិទ្យានិងការស្រាវជ្រាវពីថាមពលស្អាត រួមទាំង ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងបច្ចេកវិទ្យាឥន្ធនៈ ហ្វូស៊ីលស្អាត និងជំរុញការវិនិយោគក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធថាមពលនិងបច្ចេកវិទ្យា ថាមពលស្អាត។

៧.b ត្រឹមឆ្នាំ២០៣០ ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនសមត្ថភាពបច្ចេកទេសសម្រាប់ការផ្គត់ផ្គង់ សេវាថាមពលដែលមានលក្ខណៈទំនើបនិងចីរភាព សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច រដ្ឋជាដៃនកោះតូចៗកំពុងអភិវឌ្ឍន៍ និង បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ពុំមានព្រំដែនជាប់សមុទ្រ ស្របទៅតាមកម្មវិធីសម្រាប់ការគាំទ្ររបស់ប្រទេសនីមួយៗ។



គោលដៅទី៨៖ ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន មានមុខរបរពេញលេញ និងផលិតភាព និងមានការងារសមរម្យ សម្រាប់ប្រជាជនគ្រប់រូប

៨.១ រក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចសម្រាប់មនុស្សម្នាក់ឲ្យស្របតាមលក្ខខណ្ឌជាតិ ជាពិសេសកំណើន ផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំយ៉ាងតិច៧%នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

៨.២ សម្រេចឲ្យបានផលិតភាពសេដ្ឋកិច្ចកម្រិតខ្ពស់ជាងមុន តាមរយៈ ការធ្វើពិពិធកម្ម ការបង្កើនកម្រិតបច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងតាមរយៈ ការផ្តោតការយកចិត្តទុកដាក់លើវិស័យដែលមានតម្លៃបន្ថែមខ្ពស់ និងឧស្សាហកម្មអតិពលកម្ម។

៨.៣ លើកកម្ពស់គោលនយោបាយតម្រង់ទិសការអភិវឌ្ឍដែលគាំទ្រសកម្មភាពផលិតកម្មបង្កើតការងារ សមរម្យ សហគ្រិនភាព ការច្នៃប្រឌិតនិងនវានុវត្តន៍ និងលើកទឹកចិត្តក្នុងការចុះបញ្ជី

ជាផ្លូវការ និងកំណើនសហគ្រាស មីក្រូ~~គូម~~ និងមធ្យម រួមទាំង តាមរយៈ ការទទួលបានសេវាហិរញ្ញវត្ថុ។

៨.៤ រហូតដល់ឆ្នាំ២០៣០ ធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់ ភាពស័ក្តសិទ្ធនៃធនធានជាសកលសម្រាប់ការប្រើប្រាស់និងផលិតកម្ម និងកិច្ចខិតខំប្រឹងដើម្បីបញ្ចៀស កំណើនសេដ្ឋកិច្ចមានផលប៉ះពាល់ដល់បរិស្ថាន ស្របតាមក្របខ័ណ្ឌកម្មវិធីរយៈពេល១០ឆ្នាំ ស្តីពីផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព ដោយនាំមុខដោយបណ្តាប្រទេសអភិវឌ្ឍ។

៨.៥ ត្រឹមឆ្នាំ២០៣០ សម្រេចឲ្យបានការងារពេញលេញប្រកបដោយផលិតភាព និងការងារសមរម្យសម្រាប់ស្ត្រីនិងបុរស រួមទាំងសម្រាប់កម្លាំងពលកម្មវ័យក្មេងនិងប្រជាជនដែលបាត់បង់សមត្ថភាពពលកម្ម និងទទួលបានប្រាក់ឈ្នួលពលកម្មស្មើគ្នាចំពោះប្រភេទពលកម្មស្មើគ្នា។

៨.៦ ត្រឹមឆ្នាំ២០២០ កាត់បន្ថយឲ្យបានច្រើននូវយុវជន ដែលគ្មានការងារធ្វើ គ្មានការអប់រំ ឬគ្មានការ បណ្តុះបណ្តាល។

៨.៧ ចាត់វិធានការនានាជាបន្ទាន់និងមានប្រសិទ្ធភាពដើម្បីលុបបំបាត់ពលកម្មដោយបង្ខំ បញ្ចប់ទាសភាពសម័យទំនើបនិងការជួញដូរមនុស្ស និងធានាការហាមឃាត់និងការលុបបំបាត់ពលកម្មកុមារដោយរួមទាំង ការជ្រើសរើសនិងប្រើប្រាស់យោធាជាកុមារ និងត្រឹមឆ្នាំ២០២៥ បញ្ចប់នូវគ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារ។

៨.៨ ការពារសិទ្ធិនានារបស់កុមារ និងលើកកម្ពស់សុវត្ថិភាពនិងធានាបរិស្ថានការងារសម្រាប់ពលករទាំងអស់ រួមទាំងពលករចំណាកស្រុក ជាពិសេស ជនចំណាកស្រុកជាស្ត្រី និង អ្នកដែលធ្វើការងារមិនជាប់លាប់។

៨.៩ ត្រឹមឆ្នាំ២០៣០ បង្កើតនិងអនុវត្តគោលនយោបាយ សម្រាប់លើកកម្ពស់ទេសចរណ៍ប្រកបដោយចីរភាព ដែលបង្កើតការងារនិងលើកកម្ពស់វប្បធម៌និងផលិតផលក្នុងស្រុក។

៨.១០ ពង្រឹងសមត្ថភាពរបស់ស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ដើម្បីលើកកម្ពស់និងពង្រីកការទទួលបានសេវាធនាគារ សេវាធានារ៉ាប់រង និងសេវាហិរញ្ញវត្ថុ សម្រាប់ប្រជាជនគ្រប់រូប។

៨.a បង្កើនហិរញ្ញប្បទានសម្រាប់គាំទ្រវិស័យពាណិជ្ជកម្មសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច រួមទាំងតាមរយៈក្របខ័ណ្ឌលើកកម្ពស់ការធ្វើសមាហរណកម្មសម្រាប់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្មដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

៨.b ត្រឹមឆ្នាំ២០២០ រៀបចំនិងអនុវត្តយុទ្ធសាស្ត្រសកលសម្រាប់ការងារយុវវ័យ និងអនុវត្តកតិកាសញ្ញាសកលពីមុខរបរ របស់អង្គការពលកម្មអន្តរជាតិ។



គោលដៅទី៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននិងលើកកម្ពស់នវានុវត្តន៍

៩.១ អភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធដែលមានគុណភាព អាចជឿជាក់បាន ធននឹងបម្រែបម្រួលអាកាសធាតុ និងចីរភាព រួមទាំង ហេដ្ឋារចនាសម្ព័ន្ធតំបន់និងឆ្លងកាត់ព្រំដែនប្រទេស ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងជីវភាពរស់នៅរបស់ប្រជាជនប្រសើរ ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើការទទួលបានដោយសមរម្យនិងសមធម៌ សម្រាប់ប្រជាជនគ្រប់រូម។

៩.២ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយបរិយាប័ន្ននិងចីរភាព និងត្រឹមឆ្នាំ២០៣០ បង្កើនឲ្យបានច្រើន ឧស្សាហកម្មដែលរួមចំណែក បង្កើតការងារនិងផលិតផលក្នុងស្រុកសរុប ឲ្យស្របតាមកាលៈទេសៈជាតិ និងបង្កើនការរួមចំណែកនេះទ្វេដង នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

៩.៣ បង្កើនការទទួលបានសេវាហិរញ្ញវត្ថុ នៃឧស្សាហកម្មធុនតូចនិងសហគ្រាសផ្សេងៗទៀត ជាពិសេស នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំង ឥណទានសមស្របនិងការធ្វើសមាហរណកម្មឧស្សាហកម្មនិងសហគ្រាសទាំងនោះ ទៅក្នុងសង្វាក់តម្លៃនិងទីផ្សារ។

៩.៤ ត្រឹមឆ្នាំ២០៣០ បង្កើនសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធនិងបំពាក់បន្ថែមលទ្ធភាពរបស់ឧស្សាហកម្ម ដើម្បីធ្វើឲ្យមានចីរភាព ជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងការទទួលយកបច្ចេកវិទ្យានិងដំណើរការឧស្សាហកម្មសមស្របដែលស្អាត និងមិនប៉ះពាល់ប

វិស្ថាន ដោយគ្រប់ប្រទេសទាំងអស់ត្រូវធ្វើសកម្មភាពឲ្យស្របតាមសមត្ថភាពរបស់គេរៀងៗខ្លួន។

៩.៥ លើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បង្កើនសមត្ថភាពបច្ចេកវិទ្យារបស់វិស័យឧស្សាហកម្មនៅគ្រប់ប្រទេស ជាពិសេស បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងនោះ ត្រឹមឆ្នាំ២០៣០ លើកទឹកចិត្តនវានុវត្តន៍និងបង្កើនចំនួននៃពលករស្រាវជ្រាវនិងការអភិវឌ្ឍ ក្នុងប្រជាជន១លាននាក់ និងការចំណាយដល់ការស្រាវជ្រាវនិងការអភិវឌ្ឍផ្នែកសាធារណៈនិងឯកជន។

៩.a សម្រួលឲ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានភាពបន្សាំ និងប្រកបដោយចីរភាព នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការលើកកម្ពស់ការគាំទ្រហិរញ្ញវត្ថុ បច្ចេកវិទ្យានិងបច្ចេកទេស ដល់បណ្តាប្រទេសនៅទ្វីបអាហ្វ្រិក បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចបណ្តាប្រទេសដែលពុំមានព្រំដែនជាប់សមុទ្រកំពុងអភិវឌ្ឍន៍ និងបណ្តារដ្ឋជាដែនកោះតូចៗកំពុងអភិវឌ្ឍន៍។

៩.b គាំទ្រការអភិវឌ្ឍ ការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិជ្ជាក្នុងស្រុក ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងតាមរយៈការធានានូវការអនុវត្តបរិស្ថានគោលនយោបាយសម្រាប់ ពិពិធកម្មឧស្សាហកម្មនិងការផ្តល់តម្លៃបន្ថែមដល់ទំនិញប្រើប្រាស់។

៩.c បង្កើនឲ្យបានច្រើនការទទួលបានបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងខិតខំប្រឹងប្រែងផ្តល់នូវការទទួលបានឲ្យបានសមរម្យនិងជាសកលនូវសេវាអ៊ិនទឺរណិត ក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ត្រឹមឆ្នាំ២០២០។



គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា

១០.១ ត្រឹមឆ្នាំ២០៣០ សម្រេចឲ្យបានចំណូលរបស់ប្រជាជនចំនួន ៤០%នៃប្រជាជនទាំងអស់ដែលមានចំណូលទាបជាងគេនូវកំណើនជាបន្តបន្ទាប់និងដោយចីរភាពក្នុងអត្រាខ្ពស់ជាងកម្រិតមធ្យមរបស់ជាតិ។

១០.២ ត្រឹមឆ្នាំ២០៣០ ផ្តល់ភាពអង់អាចនិងជំរុញបរិយាប័ន្នសង្គម សេដ្ឋកិច្ច និងនយោបាយ សម្រាប់ប្រជាជនគ្រប់រូប ដោយមិនគិតពីស្ថានភាព អាយុ ភេទ ការបាត់បង់សមត្ថភាពពលកម្ម ពូជសាសន៍ ជនជាតិភាគតិច ជនជាតិដើម សាសនា ឬសេដ្ឋកិច្ច ឬស្ថានភាពផ្សេងទៀត។

១០.៣ ធានាផ្តល់នូវឱកាសស្មើៗគ្នា និងកាត់បន្ថយវិសមភាពនៃលទ្ធផល រួមទាំងតាមរយៈ ការលុបបំបាត់ ច្បាប់ គោលនយោបាយ និងការអនុវត្ត ដែលមានលក្ខណៈរើសអើង និងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ និងការអនុវត្តសកម្មភាព ឲ្យបានត្រឹមត្រូវ។

១០.៤ ឯកភាពលើគោលនយោបាយនានា ជាពិសេស គោលនយោបាយស្តីពីសារពើពន្ធ ប្រាក់បៀវត្សរ៍ ការគាំពារសង្គម និង សម្រេចឲ្យបានជាបន្តបន្ទាប់សមភាពច្រើនជាងមុន។

១០.៥ ធ្វើឲ្យប្រសើរឡើងបញ្ញត្តិ និងការតាមដានស្ថាប័ននិងទីផ្សារហិរញ្ញវត្ថុសាកល និងពង្រឹងការអនុវត្តបទប្បញ្ញត្តិទាំងនេះ។

១០.៦ ធានាការលើកកម្ពស់ភាពជាតំណាងនិងសម្លេង សម្រាប់ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងសេដ្ឋកិច្ចអន្តរជាតិនិងសកល និងស្ថាប័ន ហិរញ្ញវត្ថុនានា ដើម្បីផ្តល់នូវ ស្ថាប័នដែលមាន ប្រសិទ្ធភាព ភាពជឿជាក់ គណនេយ្យភាពនិងមានច្បាប់ពេញលេញ។

១០.៧ សម្របសម្រួលឲ្យប្រជាជនវ័យចាស់ ដែលធ្វើចំណាកស្រុកនិងពុំមានទីលំនៅច្បាស់លាស់ មានសុវត្ថិភាព ត្រឹមត្រូវតាមច្បាប់ និងដោយទទួលខុសត្រូវរួម តាមរយៈ ការអនុវត្តផែនការ និងគោលនយោបាយផ្លាស់ប្តូរទីលំនៅដែលមានការគ្រប់គ្រងល្អ។

១០.a អនុវត្តគោលការណ៍និងប្រព្រឹត្តកម្មពិសេសនិងដោយឡែកសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ឲ្យស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោក។

១០.b លើកទឹកចិត្តចំពោះជំនួយអភិវឌ្ឍន៍ផ្លូវការ និងលំហូរហិរញ្ញវត្ថុ រួមទាំងការវិនិយោគផ្ទាល់ពីបរទេស ដល់បណ្តារដ្ឋដែលមានតម្រូវការជាងគេ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច បណ្តាប្រទេសនៅក្នុងទ្វីបអាហ្វ្រិក បណ្តារដ្ឋដែនកោះតូចៗដែលកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលពុំមានព្រំប្រទល់ជាប់សមុទ្រកំពុងអភិវឌ្ឍន៍ ឲ្យស្របតាមផែនការនិងកម្មវិធីជាតិនានារបស់ប្រទេសនីមួយៗ។

១០.c ត្រឹមឆ្នាំ២០៣០ កាត់បន្ថយថ្លៃឈ្នួលផ្ទេរប្រាក់របស់ជនចំណាកស្រុក ឲ្យនៅទាបជាង ៣% និងលុបបំបាត់ប្រព័ន្ធផ្ទេរប្រាក់ដែលមានថ្លៃឈ្នួល ខ្ពស់ជាង៥%។



គោលដៅទី១១៖ ធ្វើឲ្យទីក្រុង និងទីកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈ បរិយាប័ន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុនិងចីរភាព

១១.១ ត្រឹមឆ្នាំ២០៣០ ធានាឲ្យប្រជាជនគ្រប់រូបទទួលបានផ្ទះសមរម្យ សុវត្ថិភាព គ្រប់គ្រាន់ និងទទួលបានសេវាមូលដ្ឋាននិងលើកកម្ពស់ស្ថានភាពតំបន់លំនៅដ្ឋានមិនទាន់រៀបរយ។

១១.២ ត្រឹមឆ្នាំ២០៣០ ផ្តល់នូវការទទួលបានសម្រាប់ប្រជាជនគ្រប់រូប នូវប្រព័ន្ធដឹកជញ្ជូនដែលសមរម្យ សុវត្ថិភាព និងចីរភាព ធ្វើឲ្យប្រសើរឡើងសុវត្ថិភាពផ្លូវថ្នល់ ជាពិសេសពង្រីកការដឹកជញ្ជូនសាធារណៈ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរបស់ស្ត្រី កុមារ ដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ ប្រជាជនដែលបាត់បង់សមត្ថភាពពលកម្ម និងប្រជាជនវ័យចាស់។

១១.៣ ត្រឹមឆ្នាំ២០៣០ លើកម្ពស់នគរូបនីយកម្មប្រកបដោយបរិយាប័ន្ននិងចីរភាព សមត្ថភាពសម្រាប់ការចូលរួម រៀបចំផែនការនិងគ្រប់គ្រងការតាំងទីលំនៅថ្មីប្រកបដោយចីរភាពនិងសមាហរណកម្ម នៅគ្រប់ប្រទេស។

១១.៤ ពង្រឹងកិច្ចខិតខំប្រឹងប្រែងបង្ការនិងការពារវប្បធម៌និងមរតកធម្មជាតិរបស់ពិភពលោក

១១.៥ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានច្រើនចំនួនមនុស្សស្លាប់ ចំនួនមនុស្សដែលរងផលប៉ះពាល់ពីគ្រោះមហន្តរាយ និងកាត់បន្ថយជាបន្តបន្ទាប់ការបាត់បង់សេដ្ឋកិច្ចដោយផ្ទាល់ ពាក់

ព័ន្ធនឹងផលិតផលក្នុងស្រុកសរុបជាសកល ដោយសារគ្រោះមហន្តរាយ រួមទាំង គ្រោះមហន្តរាយពាក់ព័ន្ធនឹងទឹក ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើ ការការពារប្រជាជនក្រីក្រ និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។

១១.៦ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយការបំពុលបរិស្ថានក្នុងមនុស្សម្នាក់នៅទីក្រុង រួមទាំងតាមរយៈការផ្តោតការយកចិត្តទុកដាក់លើ គុណភាពខ្យល់ និងការគ្រប់គ្រងសំណល់នៅទីក្រុង និងតំបន់ផ្សេងទៀត។

១១.៧ ត្រឹមឆ្នាំ២០៣០ ផ្តល់នូវការទទួលបានការប្រើប្រាស់ជាសកលទីលានសាធារណៈដែលមានពណ៌បៃតង មានសុវត្ថិភាព បរិយាប័ន្ន និងអាចប្រើប្រាស់បាន ជាពិសេស សម្រាប់ស្ត្រីនិងកុមារ ប្រជាជនមនុស្សចាស់ និងប្រជាជនដែលបាត់បង់សមត្ថភាពពលកម្ម។

១១.a គាំទ្រការភ្ជាប់ទំនាក់ទំនងវិជ្ជមាននៃសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន រវាងតំបន់ទីប្រជុំជន និងតំបន់ជនបទដោយពង្រឹងការរៀបចំផែនការអភិវឌ្ឍន៍ជាតិនិងតំបន់។

១១.b ត្រឹមឆ្នាំ២០៣០ បង្កើនឲ្យបានច្រើននូវចំនួនទីក្រុងនិងការតាំងទីលំនៅថ្មី ដែលយល់ព្រមនិងអនុវត្តតាម គោលនយោបាយនិងផែនការសមាហរណកម្មដែលប្រកបដោយបរិយាប័ន្តការប្រើប្រាស់ធនធានមានប្រសិទ្ធភាព បន្ទូរបន្ថយនិងបន្សាំនឹងបម្រែបម្រួលអាកាសធាតុ មានភាពធន់នឹងគ្រោះមហន្តរាយ និងអភិវឌ្ឍនិងអនុវត្តឲ្យស្របតាមក្របខ័ណ្ឌទីក្រុងសេនដាយសម្រាប់កាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ ឆ្នាំ២០១៥-២០៣០ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយទូទៅនៅគ្រប់កម្រិត។

១១.c គាំទ្របណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច រួមទាំងតាមរយៈ ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ក្នុងការកសាងអគារនានាដែលធុនរឹងមាំនិងប្រកបដោយចីរភាព ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក។



គោលដៅទី១២៖ ធានាឲ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម

១២.១ អនុវត្តក្របខ័ណ្ឌ ១០ឆ្នាំ នៃកម្មវិធីផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាពគ្រប់ប្រទេស ត្រូវអនុវត្តសកម្មភាព ដោយមានបណ្តាប្រទេសអភិវឌ្ឍន៍ជាអ្នកដឹកនាំ ដោយផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍ និងសមត្ថភាពនៃការអភិវឌ្ឍរបស់ប្រទេសនានា។

១២.២ ត្រឹមឆ្នាំ២០៣០ ការគ្រប់គ្រងប្រកបដោយចីរភាព និងប្រើប្រាស់ធនធានធម្មជាតិដោយមានប្រសិទ្ធភាព។

១២.៣ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយជាសកលឲ្យបានពាក់កណ្តាលនៃម្ហូបអាហារដែលបោះបង់ចោលក្នុងមនុស្សម្នាក់ នៅម្រិតនៃការលក់រាយនិងនៅកម្រិតប្រើប្រាស់ និងកាត់បន្ថយការបាត់បង់ស្បៀងអាហារក្នុងសង្វាក់ផលិតកម្មនិងផ្គត់ផ្គង់ រួមទាំងការបាត់បង់ក្រោយពេលប្រមូលផល។

១២.៤ ត្រឹមឆ្នាំ២០២០ សម្រេចឲ្យបានការគ្រប់គ្រងបរិស្ថានល្អ ពាក់ព័ន្ធនឹងការបោះបង់ចោលសារធាតុគីមីនិងសំណល់គ្រប់ប្រភេទ តាមរយៈ ការកែច្នៃឡើងវិញ ឲ្យស្របតាមក្របខ័ណ្ឌកិច្ចកិច្ចព្រមព្រៀងអន្តរជាតិ និងកាត់បន្ថយឲ្យបានច្រើននូវការបញ្ចេញសំណល់ទាំងនោះទៅក្នុងបរិយាកាស ក្នុងទឹក និងក្នុងដី ដើម្បីកាត់បន្ថយឲ្យនៅទាបបំផុតនូវផលប៉ះពាល់អវិជ្ជមានរបស់វា លើសុខភាពប្រជាជននិងបរិស្ថាន

១២.៥ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានច្រើន ការបង្កើតសំណល់ តាមរយៈការការពារ ការកាត់បន្ថយ ការកែច្នៃឡើងវិញ និងការប្រើប្រាស់ឡើងវិញ។

១២.៦ លើកទឹកចិត្តក្រុមហ៊ុន ជាពិសេស បណ្តាក្រុមហ៊ុនធំៗនិងក្រុមហ៊ុនអន្តរជាតិ ឲ្យយល់ព្រមការអនុវត្តប្រកបដោយចីរភាព និងបញ្ចូលព័ត៌មានស្តីពីការធ្វើឲ្យមានចីរភាព ទៅក្នុងរបាយការណ៍ជាប្រចាំ។

១២.៧ លើកកម្ពស់ការអនុវត្តសវនកម្មជាសាធារណៈដែលមានចីរភាព ឲ្យស្របតាមគោលនយោបាយនិងអាទិភាពជាតិនានា។

១២.៨ ត្រឹមឆ្នាំ២០៣០ ធានាថា ប្រជាជននៅគ្រប់ទីកន្លែង ទទួលបានព័ត៌មាននិងចំណេះដឹងនានា ដែលពាក់ព័ន្ធនិងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងជីវភាពរស់នៅប្រកបដោយ សុខដុមជាមួយធម្មជាតិ។

១២.a គាំទ្របណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការពង្រឹងសមត្ថភាពវិទ្យាសាស្ត្រនិងបច្ចេកទេស របស់ខ្លួន ដើម្បីឈានឆ្ពោះទៅរកទម្រង់ចីរភាពជាងមុននៃផលិតកម្មនិងការប្រើប្រាស់។

១២.b អភិវឌ្ឍនិងអនុវត្តឧបករណ៍នានា ដើម្បីតាមដានត្រួតពិនិត្យផលប៉ះពាល់នៃការអភិវឌ្ឍន៍ ប្រកបដោយចីរភាព សម្រាប់វិស័យទេសចរណ៍ប្រកបដោយចីរភាព ដែលបង្កើតការងារនិង លើកកម្ពស់វប្បធម៌និងផលិតផលក្នុងស្រុក។

១២.c ពន្យល់បកស្រាយពីភាពគ្មានប្រសិទ្ធភាពនៃការឧបត្ថម្ភធនលើឥន្ធនៈហ្វូស៊ីល ដែលការប្រើ ប្រាស់នាំឲ្យមានសំណល់ច្រើន និងនាំឲ្យទីផ្សារមានការប្រែប្រួល ស្របតាមស្ថានភាពរបស់ ប្រទេសជាតិនីមួយៗ រួមទាំង តាមរយៈ ការការប្រែការបង់ពន្ធ និងបំបាត់ជាបណ្តើរៗនូវការ ឧបត្ថម្ភធនទាំងនោះ នៅទីណាដែលមាន ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់បរិស្ថានពីការ ប្រើប្រាស់ឥន្ធនៈនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ពេញលេញលើតម្រូវការនិងលក្ខខណ្ឌ ជាក់លាក់ របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងកាត់បន្ថយឲ្យនៅកម្រិតទាបបំផុតផលប៉ះ ពាល់ជាអវិជ្ជមានដែលអាចមាន ទៅលើការអភិវឌ្ឍន៍ក្នុងរបៀបដែលការពារប្រជាជនក្រីក្រ និងផលប៉ះពាល់ដល់សហគមន៍។



គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា

១៣.១ ពង្រឹងសមត្ថភាពធនទ្រាំនិងភាពបន្សាំទៅនឹងគ្រោះធម្មជាតិនិងគ្រោះមហន្តរាយពាក់ព័ន្ធនឹង អាកាសធាតុ សម្រាប់គ្រប់ប្រទេស។

១៣.២ ធ្វើសមាហរណកម្មការវាស់វែងបម្រែបម្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយ យុទ្ធ សាស្ត្រ និងផែនការជាតិ។

១៣.៣ លើកកម្ពស់ការអប់រំ ការលើកម្ពស់ការយល់ដឹង និងលើកកម្ពស់សមត្ថភាពមនុស្សនិង ស្ថាប័ន ស្តីពីការបន្ធូរបន្ថយបម្រែបម្រួលអាកាសធាតុការបន្សាំ ការកាត់បន្ថយផលប៉ះពាល់ និង ការផ្តល់នូវការក្រើនរំលឹកឲ្យប្រយ័ត្នជាមុន។

១៣.a ត្រឹមឆ្នាំ២០២០ អនុវត្តនូវការប្តេជ្ញាចិត្ត ដែលជាការអនុវត្តដោយបណ្តាភាគីជាប្រទេសអភិវឌ្ឍ ន៍ ទៅនឹងអនុសញ្ញានៃក្របខ័ណ្ឌសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ ដើម្បី សម្រេចគោលដៅនៃការកៀរគរមូលនិធិរួមគ្នាឲ្យបាន ១០០ពាន់លានដុល្លារក្នុងមួយឆ្នាំ ពី គ្រប់ប្រភព ដើម្បីដោះស្រាយនូវតម្រូវការរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងបរិការណ៍ នៃសកម្មភាពនានាសម្រាប់បន្ធូរបន្ថយនិងមានតម្លាភាពលើការអនុវត្ត និងកិច្ចប្រតិបត្តិការ ពេញលេញនូវ មូលនិធិបរិយាកាសពណ៌ខៀវ តាមរយៈ ការកៀរគរមូលធន ឲ្យបានឆាប់ តាមតែអាចធ្វើទៅបាន

១៣.b ជំរុញយន្តការសម្រាប់លើកកម្ពស់សមត្ថភាព សម្រាប់ឲ្យផែនការនិងការគ្រប់គ្រងបញ្ហានានា ពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងរដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ រួមទាំង ការផ្តោតការយកចិត្តទុដាក់លើ ស្ត្រី យុវវ័យ និង សហគមន៍ប្រជាជនមូលដ្ឋាននិងប្រជាជនភាគតិច។



គោលដៅទី១៤៖ អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

១៤.១ ត្រឹមឆ្នាំ២០៣០ ការពារ និងកាត់បន្ថយឲ្យបានច្រើនការបំពុលគ្រប់ប្រភេទនៅក្នុងសមុទ្រ ជា ពិសេស ពីបណ្តាសកម្មភាពនានាដែលផ្តើមចេញពីលើដី រួមទាំង ការបំពុលដោយ សំណល់ ក្នុងសមុទ្រ និងអាហារបំប៉ន។

១៤.២ ត្រឹមឆ្នាំ២០២០ គ្រប់គ្រងឲ្យបានច្រើន និងការពារប្រព័ន្ធអេកូឡូស៊ីនៅក្នុងសមុទ្រតាមឆ្នេរនិង ទឹកសាបដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមាននានា រួមទាំង តាមរយៈការពង្រឹង ភាពធន់ របស់វា និងដំណើរការសកម្មភាពសម្រាប់ធ្វើឲ្យមានភាពដូចដើមវិញ ដើម្បីសម្រេចឲ្យបាន នូវមហាសាគរនិងដែនទឹកសាបដែលមានផលិតភាពនិងសុខភាព។

១៤.៣ កាត់បន្ថយឲ្យនៅកម្រិតទាបបំផុត និងដោះស្រាយពីផលប៉ះពាល់របស់អាស៊ីតកម្មមហាសមុទ្រ តាមរយៈ ការលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ នៅគ្រប់កម្រិត។

១៤.៤ ត្រឹមឆ្នាំ២០២០ អនុវត្តការប្រមូលផលត្រីត្រឹមត្រូវតាមច្បាប់ប្រកបដោយប្រសិទ្ធភាព និងលុបបំបាត់ការនេសាទលើសកម្រិតការនេសាទខុសច្បាប់គ្មានការអនុញ្ញាតិនិងគ្មានរបាយការណ៍ និងអនុវត្តផែនការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រដើម្បីបង្កើនបរិមាណផលត្រី ក្នុងរយៈពេលខ្លី ដែលអាចធ្វើទៅបាន យ៉ាងហោចណាស់ អាចផលិតបាន ទិន្នផលត្រីក្នុងកម្រិតបរិមាណនិរន្តភាព ដូចបានកំណត់ដោយលក្ខណៈជីវសាស្ត្រ។

១៤.៥ ត្រឹមឆ្នាំ២០២០ អភិរក្សយ៉ាងតិច ១0% នៃតំបន់ឆ្នេរតំបន់ក្នុងសមុទ្រ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ និងផ្អែកលើព័ត៌មានវិទ្យាសាស្ត្រ

១៤.៦ ត្រឹមឆ្នាំ២០២០ ហាមឃាត់នូវទម្រង់ជាក់លាក់នៃការឧបត្ថម្ភធនលើការនេសាទ ដែលនឹងរួមចំណែកដល់ការការនេសាទលើសសមត្ថភាព លុបបំបាត់ការឧបត្ថម្ភធនដែលរួមចំណែកដល់ការនេសាទខុសច្បាប់ មិនផ្តល់របាយការណ៍ និងមិនស្របច្បាប់ និងទប់ទល់នឹងការឧបត្ថម្ភថ្មីៗដែលដូចគ្នានឹងការឧបត្ថម្ភធន ទទួលស្គាល់ថា ការធ្វើប្រព្រឹត្តកម្មផ្សេងៗគ្នានិងដោយឡែកប្រកបដោយសមស្របនិងមានប្រសិទ្ធភាព សម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍និងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច គួរតែត្រូវបានបញ្ចូលទៅក្នុងផ្នែកនៃការចរចាពីការឧបត្ថម្ភធនដល់ការនេសាទ របស់អង្គការពាណិជ្ជកម្មពិភពលោក។

១៤.៧ ត្រឹមឆ្នាំ២០៣0 បង្កើនផលប្រយោជន៍ពីសេដ្ឋកិច្ចដល់បណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍និងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ពីការប្រើប្រាស់ធនធានក្នុងសមុទ្រ ប្រកបដោយចីរភាព រួមទាំងតាមរយៈ ការគ្រប់គ្រងប្រកបដោយចីរភាពនូវការនេសាទ ជលវប្បកម្ម និងទេសចរណ៍។

១៤.a បង្កើនចំណេះដឹងផ្នែកវិទ្យាសាស្ត្រ អភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាសមុទ្រ ផ្តោតការយកចិត្តទុកដាក់លើលក្ខខណ្ឌនិងការណែនាំរបស់គណៈកម្មការអន្តររដ្ឋាភិបាលសាកសាស្ត្រស្តីពីការផ្ទេរបច្ចេកវិទ្យាសមុទ្រ ដើម្បីធ្វើឲ្យប្រសើរឡើងសុខភាពសមុទ្រ និងលើកកម្ពស់ការចូលរួមរបស់ជីវចម្រុះសមុទ្រ ទៅក្នុងការអភិវឌ្ឍនៃបណ្តាប្រទេសកំពុង

អភិវឌ្ឍន៍ ជាពិសេសបណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

១៤.b ផ្តល់នូវការទទួលបានធនធានសមុទ្រនិងទីផ្សារ ចំពោះអ្នកនេសាទទ្រង់ទ្រាយតូច។

១៤.c លើកកម្ពស់ការអភិរក្ស និងការប្រើប្រាស់សមុទ្រនិងធនធានក្នុងសមុទ្រប្រកបដោយចីរភាពតាមរយៈ ការអនុវត្តច្បាប់អន្តរជាតិ ដែលបានបង្ហាញនៅក្នុង UNCLOS ដែលផ្តល់នូវក្របខ័ណ្ឌគតិយុត្ត សម្រាប់ការអភិរក្សនិងប្រើប្រាស់សមុទ្រនិងធនធានក្នុងសមុទ្រ ប្រកបដោយចីរភាព ដូចបានបញ្ជាក់ក្នុងកថាខ័ណ្ឌទី១៥៨ នៃតម្រូវការរបស់យើងនាពេលអនាគត។



គោលដៅទី១៥៖ ការពារ ស្តារ និងបំរុញការប្រប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែន គោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដីបញ្ឈប់ និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឲ្យបាត់បង់ជីជាតិដីនិងជីវចម្រុះ

១៥.១ ត្រឹមឆ្នាំ២០២០ ធានាការអភិរក្ស ការស្តារនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីក្នុងទឹកសាបនៅដែនកោះនិងនៅលើគោក និងសេវា ជាពិសេស ព្រៃឈើ ដីសើម ភ្នំ និងដីសួត ឲ្យស្របតាមកតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិ។

១៥.២ ត្រឹមឆ្នាំ២០២០ លើកកម្ពស់ការអនុវត្តការគ្រប់គ្រងប្រកបដោយចីរភាព នូវព្រៃឈើគ្រប់ប្រភេទ កាត់បន្ថយឲ្យបានពាក់កណ្តាលនូវការបំផ្លាញព្រៃឈើព្រៃឈើដែលបាត់បង់ និងបង្កើនឲ្យបានច្រើនជាសកលការដាំដើមឈើនិងការដាំព្រៃឈើឡើងវិញ

១៥.៣ ត្រឹមឆ្នាំ២០៣០ ប្រយុទ្ធប្រឆាំងនឹងការបំផ្លាញព្រៃឈើ ធ្វើឲ្យដូចដើមឡើងវិញដីដែលបាត់បង់ជីជាតិ រួមទាំង ដីដែលទទួលផលប៉ះពាល់ពី វាលរហោដ្ឋានកម្មភាពរាំងស្ងួត និងទឹកជំនន់ធ្វើឱ្យប្រសើរឡើងនូវ ពិភពលោកដែលមានដីមិនមានការខូចខាត។

១៥.៤ ត្រឹមឆ្នាំ២០៣០ ធានាការអភិរក្សប្រព័ន្ធអេកូឡូស៊ីនៅព្រៃភ្នំ រួមទាំងជីវចម្រុះនៅទីនោះ ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការផ្តល់អត្ថប្រយោជន៍ចាំបាច់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

១៥.៥ អនុវត្តចំណាត់ការចាំបាច់និងជាបន្ទាន់ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើលំនៅដ្ឋានធម្មជាតិ កាត់បន្ថយឲ្យបានពាក់កណ្តាលនូវការបាត់បង់ជីវចម្រុះ និង ត្រឹមឆ្នាំ២០២០ ការពារ និងបង្ការការបាត់បង់ផុតពូជនូវប្រភេទដែលគម្រាមកំហែងផុតពូជ។

១៥.៦ លើកម្ពស់ការបែងចែកដោយសមស្របនិងសមធម៌ នូវផលប្រយោជន៍ទទួលបានពីការប្រើប្រាស់ប្រភពនៃពូជនិងលើកកម្ពស់ការទទួលបានសមរម្យ នូវប្រភពទាំងនោះ ដូចបានឯកភាពជាអន្តរជាតិ

១៥.៧ អនុវត្តសកម្មភាពជាបន្ទាន់ដើម្បីបញ្ចប់ការបរបាញ់និងជួញដូរប្រភេទពូជ រុក្ខជាតិ និងពពួកសត្វដែលត្រូវបានការពារ និងដោះស្រាយទាំងតម្រូវការនិងការផ្គត់ផ្គង់ខុសច្បាប់នៃផលិតផលសត្វព្រៃ។

១៥.៨ ត្រឹមឆ្នាំ២០២០ ដាក់ឲ្យអនុវត្តវិធានការនានា ដើម្បីការពារការដាក់ឲ្យអនុវត្ត និងកាត់បន្ថយផលប៉ះពាល់ការរីករាលដាលនៃប្រភេទរុក្ខាជាតិនិងសត្វពីបរទេស។

១៥.៩ ត្រឹមឆ្នាំ២០២០ បញ្ចូលតម្លៃប្រព័ន្ធអេកូឡូស៊ីនិងជីវចម្រុះ ទៅក្នុងផែនការជាតិនិងផែនការមូលដ្ឋាន ដំណើរការនៃការអភិវឌ្ឍ យុទ្ធសាស្ត្រនិងគណនេយ្យភាពសម្រាប់កាត់បន្ថយភាពក្រីក្រ។

១៥.a កៀរគរនិងបង្កើនឲ្យបានច្រើនធនធានហិរញ្ញវត្ថុពីគ្រប់ប្រភព ដើម្បីអភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពជីវចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។

១៥.b កៀរគរធនធានឲ្យបានច្រើនពីគ្រប់ប្រភពនិងនៅគ្រប់កម្រិត ដើម្បីផ្តល់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងផ្តល់នូវការឧបត្ថម្ភគ្រប់គ្រាន់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអនុវត្តការគ្រប់គ្រងបានល្អប្រសើរ រួមទាំងសម្រាប់ការអភិរក្ស និងការដាំព្រៃឈើឡើងវិញ។

១៥.c លើកកម្ពស់ការគាំទ្រជាសកលដល់កិច្ចខិតខំប្រឹងប្រែងក្នុងការការពារការបរបាញ់ និងការជួញដូរប្រភេទពូជសត្វនិងរុក្ខាជាតិដែលត្រូវបានការពារ រួមទាំង តាមរយៈការបង្កើនសមត្ថភាពដល់សហគមន៍មូលដ្ឋាន ដើម្បីស្វែងរកកាលានុវត្តភាពនៃការរស់នៅប្រកបដោយចីរភាព។



គោលដៅទី១៦៖ លើកកម្ពស់សង្គមដែលមានសន្តិភាព ប្រកបដោយបរិយាប័ន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការចូលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ន នៅគ្រប់កម្រិត

១៦.១ កាត់បន្ថយឲ្យបានច្រើនរាល់ទម្រង់នៃអំពើហិង្សា និងអត្រាមរណភាពដោយអំពើហិង្សា នៅគ្រប់ទីកន្លែង។

១៦.២ លុបបំបាត់ការរំលោភបំពានការធ្វើអាជីវកម្ម ការជួញដូរ និងរាល់ទម្រង់នៃអំពើហិង្សានិងទារុណកម្មប្រឆាំងនឹងកុមារ

១៦.៣ លើកកម្ពស់វិធានការច្បាប់ នៅកម្រិតជាតិនិងអន្តរជាតិ និងធានាការទទួលបានយុត្តិធម៌ស្មើភាពគ្នា សម្រាប់ប្រជាជនគ្រប់រូប។

១៦.៤ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានច្រើននូវលំហូរហិរញ្ញវត្ថុនិងគ្រឿងសព្វាវុធខុសច្បាប់ ពង្រឹងការបានដូចដើមវិញ និងការទទួលបានមកវិញនូវអចលនទ្រព្យដែលត្រូវបានលួច និងប្រយុទ្ធប្រឆាំងនឹងអង្គការឧក្រិដ្ឋកម្មគ្រប់ទម្រង់។

១៦.៥ កាត់បន្ថយឲ្យបានច្រើន រាល់ទម្រង់នៃអំពើពុករលួយនិងការស៊ីសំណូក។

១៦.៦ រៀបចំស្ថាប័នឲ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅគ្រប់កម្រិត។

១៦.៧ ធានានូវការធ្វើសេចក្តីសម្រេច ដោយមានការចូលរួមពីគ្រប់តំណាង ដោយមានការទទួលខុសត្រូវប្រកបដោយបរិយាប័ន្ននៅគ្រប់កម្រិត។

១៦.៨ បើកទូលាយនិងពង្រឹងការចូលរួមរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងស្ថាប័នអភិបាលកិច្ចសកល។

១៦.៩ ត្រឹមឆ្នាំ២០៣០ ផ្តល់អត្តសញ្ញាណផ្លូវច្បាប់ដល់ប្រជាជនគ្រប់រូប រួមទាំង ការចុះបញ្ជីកំណើត។

១៦.១០ ធានាការទទួលបានជាសាធារណៈ នូវព័ត៌មាននិងការការពារសិទ្ធិសេរីភាពមូលដ្ឋាន ឲ្យស្របតាមបទដ្ឋានគតិយុត្តជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិ។

១៦.a ពង្រឹងបណ្តាស្ថាប័នពាក់ព័ន្ធជាតិ រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីកសាងសមត្ថភាពនៅគ្រប់កម្រិតជាពិសេស នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ទប់ស្កាត់អំពើហិង្សា និងប្រយុទ្ធប្រឆាំងនឹងអំពើភាវរកម្មនិងឧក្រិដ្ឋកម្ម។

១៦.b លើកកម្ពស់និងជំរុញការអនុវត្តច្បាប់និងគោលនយោបាយស្តីពី ការមិនរើសអើងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។



គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

១៧.១ ពង្រឹងការកៀរគរធនធានក្នុងស្រុក រួមទាំងតាមរយៈការគាំទ្រពីអន្តរជាតិដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពក្នុងស្រុកសម្រាប់ការប្រមូលពន្ធនិងចំណូលផ្សេងទៀត។

១៧.២ បណ្តាប្រទេសអភិវឌ្ឍន៍ត្រូវអនុវត្តនូវការសន្យារបស់ខ្លួន ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ រួមទាំងការសន្យាដោយបណ្តាប្រទេសអភិវឌ្ឍជាច្រើន ក្នុងការធ្វើឲ្យសម្រេចបានចំណុចដៅនៃការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ០,៧% នៃចំណូលជាតិសរុប ទៅដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងពី ០,១៥% ដល់ ០,២% នៃចំណូលជាតិសរុប ទៅដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច បណ្តាប្រទេសដែលផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ ត្រូវបានផ្តល់ការលើកទឹកចិត្តឲ្យពិចារណាកំណត់ចំណុចដៅ ក្នុងការផ្តល់ជំនួយនេះយ៉ាងតិច ០,២%នៃចំណូលជាតិសរុប ដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

១៧.៣ កៀរគរធនធានហិរញ្ញវត្ថុបន្ថែមទៀតពីប្រភពចម្រុះ សម្រាប់ផ្តល់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

១៧.៤ ជួយដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការទទួលបានប្រកបដោយចីរភាពនូវបំណុលរយៈពេលវែង តាមរយៈគោលនយោបាយសម្របសម្រួល ដែលមានគោលបំណងជំរុញការផ្តល់បំណុលហិរញ្ញវត្ថុ ការបន្ធូរបន្ថយបំណុល ការកែទម្រង់បំណុលតាមតែអាចធ្វើទៅបាន និងដោះស្រាយបំណុលបរទេសរបស់បណ្តាប្រទេសក្រីក្រដែលជំពាក់បំណុលខ្ពស់ ដើម្បីកាត់បន្ថយភាពការភ័យព្រួយពីបំណុល។

១៧.៥ ទទួលយកនិងអនុវត្តរបបជំរុញការវិនិយោគ សម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច។

១៧.៦ លើកកម្ពស់កិច្ចសហប្រតិបត្តិការជើង-ត្បូង កិច្ចសហប្រតិបត្តិការត្បូង-ត្បូង កិច្ចសហប្រតិបត្តិការតំបន់ត្រីកោណនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ លើនិងការទទួលបាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងលើកកម្ពស់ការចែករំលែកការយល់ដឹងស្តីពីទម្រង់នៃការឯកភាពទាំងសងខាង រួមទាំងតាមរយៈការធ្វើឲ្យប្រសើរឡើង ការសម្របសម្រួលក្នុងចំណោមយន្តការដែលមានស្រាប់ ជាពិសេស ក្នុងកម្រិតសហប្រជាជាតិ និងតាមរយៈ យន្តការសម្របសម្រួលបច្ចេកវិទ្យាសកល។

១៧.៧ លើកកម្ពស់ការអភិវឌ្ឍ ការផ្ទេរ ការផ្សព្វផ្សាយ និងការផ្សាយចេញ នូវបច្ចេកវិទ្យាបរិស្ថានសមស្រប ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងទម្រង់អនុគ្រោះ រួមទាំង ទម្រង់សម្បទាននិងការចូលចិត្ត ដូចបានឯកភាពគ្នាទៅវិញទៅមក។

១៧.៨ ត្រឹមឆ្នាំ២០១៧ធ្វើប្រតិបត្តិការពេញលេញ ធនាគារបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ និងយន្តការកសាងសមត្ថភាពពី បច្ចេកវិទ្យានិងនវានុវត្តន៍ សម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាដែលមានសមត្ថភាព ជាពិសេសបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។

១៧.៩ លើកកម្ពស់ការគាំទ្រពីអន្តរជាតិ សម្រាប់ការអនុវត្តការកសាងសមត្ថភាពដែលបានកំណត់ចំណុចដៅនិងមានប្រសិទ្ធភាព ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីគាំទ្រផែនការជាតិក្នុងការអនុវត្តនូវគ្រប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការជើង-ត្បូង កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណ។

១៧.១០ លើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មចម្រុះ ដែលមានលក្ខណៈជាសកលមានមូលដ្ឋានច្បាប់ បើកទូលាយនិងសមធម៌ក្រោមអង្គការពាណិជ្ជកម្មពិភពលោក រួមទាំងតាមរយៈការសន្និដ្ឋាននៃការចរចាក្រោមរបៀបវារៈទីក្រុងដាហាស្តីពីការអភិវឌ្ឍ។

១៧.១១ បង្កើនឲ្យបានច្រើន ការនាំចេញរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស ត្រឹមឆ្នាំ ២០២០ ជាមួយនឹងទិដ្ឋភាពមួយដែលបង្កើនទ្វេដង~~ការ~~ចំណែកនៃការនាំចេញរបស់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ទៅក្នុងការនាំចេញក្នុងសកលលោក។

១៧.១២ ធ្វើឲ្យសម្រេចបានទាន់ពេលនូវការអនុវត្ត ការលើកលែងពន្ធនិង ការទទួលបានកូតាទីផ្សារលើកលែងពន្ធលើមូលដ្ឋានចុងក្រោយ សម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចឲ្យស្របតាមការសម្រេចចិត្តរបស់អង្គការពាណិជ្ជកម្មពិភពលោក រួមទាំងតាមរយៈការធានាថាតួនាទីនៃការអនុគ្រោះ ចំពោះការអនុវត្តដើមដំបូងនៃនាំចេញពីបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច មានលក្ខណៈតម្លាភាព ងាយស្រួល និងរួមចំណែកក្នុងសម្របសម្រួលការទទួលបានទីផ្សារ។

១៧.១៣ លើកកម្ពស់ស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ចសកល រួមទាំង តាមរយៈការសម្របសម្រួលគោលនយោបាយ និងការបន្សុីគោលនយោបាយ។

១៧.១៤ លើកកម្ពស់ការបន្សុីគោលនយោបាយ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

១៧.១៥ គោរពបរិយាកាសនិងការដឹកនាំគោលនយោបាយរបស់ប្រទេសនីមួយៗ ដើម្បីបង្កើតនិងអនុវត្តគោលនយោបាយនានា សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព។

១៧.១៦ លើកកម្ពស់ភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពការបំពេញបន្ថែមដោយភាពជាដៃគូដែលជាអ្នកមានចំណែកពាក់ព័ន្ធចម្រុះ ដែលកៀរគរនិងចែករំលែកចំណេះដឹងជំនាញបច្ចេកវិទ្យានិងធនធានហិរញ្ញវត្ថុ ដើម្បីគាំទ្រការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅគ្រប់ប្រទេស ជាពិសេសបណ្តាទេសកំពុងអភិវឌ្ឍន៍។

១៧.១៧ លើកទឹកចិត្តនិងលើកកម្ពស់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពក្នុងផ្នែកសាធារណៈ រវាងផ្នែកសាធារណៈនិងផ្នែកឯកជន និងជាមួយសង្គមស៊ីវិល កសាងភាពជាដៃគូផ្អែកលើបទពិសោធន៍និងយុទ្ធសាស្ត្រផ្តល់ធនធាននៃភាពជាដៃគូ។

១៧.១៨ ត្រឹមឆ្នាំ២០២០ លើកកម្ពស់ការគាំទ្រការកសាងសមត្ថភាពដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច និងបណ្តារដ្ឋដែនកោះតូចៗ កំពុងអភិវឌ្ឍន៍ ដើម្បីបង្កើនឲ្យបានច្រើន ភាពអាចរកបានទាន់ពេលនៃទិន្នន័យដែលមានគុណភាពខ្ពស់ និងជឿជាក់បាន បំបែកតាមចំណូល យេនឌ័រ អាយុ ជាតិសាសន៍ ជនពិភាគតិច ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅ ការបាត់បង់សមត្ថភាពពលកម្ម ទីតាំងភូមិសាស្ត្រ និងលក្ខណៈផ្សេងទៀតដែលពាក់ព័ន្ធ ក្នុងបរិការណ៍ជាតិ។

១៧.១៩ ត្រឹម២០៣០ កសាងដោយផ្អែកលើការផ្តួចផ្តើមដែលមានស្រាប់ ដើម្បីអភិវឌ្ឍមធ្យោបាយវាស់វែងពីវឌ្ឍនភាពនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលបំពេញផលិតផលក្នុងស្រុកសរុប និងគាំទ្រការកសាងសមត្ថភាពផ្នែកស្ថិតិ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។



គោលដៅទី ១៨៖ ការបោសសម្អាតមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនរងគ្រោះ

១៨.១ បោសសម្អាតផ្ទៃដីចម្ការមីន/ស.ផ.ស.ដែលបានដឹងឲ្យអស់ត្រឹមឆ្នាំ២០៣០។

១៨.២ កាត់បន្ថយគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. នៅតិចជាង១០នាក់ក្នុងមួយឆ្នាំ ត្រឹមឆ្នាំ២០៣០

១៨.៣ លើកកម្ពស់សិទ្ធិ និងគុណភាពជីវិតរបស់ជនពិការដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមឲ្យបានកាន់តែប្រសើរឡើង។

ឧបសម្ព័ន្ធទី៦

តារាង ២.១
បុគ្គលរុបលទ្ធផលវិភាគស្ថានភាពខេត្ត

តារាងបូកសរុប

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
ផ្នែកសេដ្ឋកិច្ច				
មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ				
1	ទិន្នផលដំណាំកសិកម្មនៅមានកំរិត	កសិករប្រើពូជប្រពៃណី	ផ្សព្វផ្សាយពូជដំណាំកសិកម្មដែលមានទិន្នផលខ្ពស់និងការធ្វើបង្ហាញ	មន្ទីរកសិកម្ម
		ចំណេះដឹងរបស់កសិករនៅមានកំរិត	បណ្តុះបណ្តាលបច្ចេកទេសកសិកម្មថ្មីៗដល់កសិករ	
		ខ្វះប្រព័ន្ធស្រោចស្រព	ជំរុញការប្រាស់គ្រឿងយន្តកសិកម្ម	
		មានការកើតឡើងនូវសមាសភាពចង្រៃ	ត្រៀមអន្តរាគមន៍កម្ចាត់សមាសភាពចង្រៃ	
		សមត្ថភាពសហគមន៍កសិកម្មនៅមានកម្រិត	ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម	
		ការប្រែប្រួលអាកាសធាតុ	ផ្សព្វផ្សាយបច្ចេកទេសដាំបន្លែដោយប្រើប្រព័ន្ធដំណក់ទឹក ឬផ្ទះសំណាញ់	
			បណ្តុះបណ្តាលពង្រឹងសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ	
			បណ្តុះបណ្តាលបច្ចេកទេសផលិតនិងប្រើប្រាស់ជីកំប៉ុស្ត	
			ផ្សព្វផ្សាយពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្ម	
2	ការចិញ្ចឹមសត្វមានការធ្លាក់ចុះ	ការយល់ដឹងរបស់កសិករពីបច្ចេកទេសចិញ្ចឹមសត្វនៅមានកម្រិត	បណ្តុះបណ្តាលស្តីពីបច្ចេកទេសនៃការចិញ្ចឹមសត្វដល់កសិករ	មន្ទីរកសិកម្ម
		ការចិញ្ចឹមតាមទំលាប់លែងពាសវាលពាសកាល	បណ្តុះបណ្តាលពីរបៀបផ្សំចំណី និងការកែច្នៃចំណីសត្វដល់កសិករ	
		ខ្វះព័តមានទីផ្សារ	ផ្សព្វផ្សាយពីទីផ្សារកសិកម្ម	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		សត្វងាប់ដោយជម្ងឺឆ្លង	ផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំង	
			ត្រៀមអន្តរាគមន៍ករណីមានជម្ងឺផ្ទុះឡើង	
			ពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ	
			ត្រួតពិនិត្យចលនាសត្វនិងផលិតផលមានដើមកំណើតពីសត្វ	
ខណ្ឌរដ្ឋបាលជលផល				
1	ធនធានជលផលក្នុងធម្មជាតិមិនមាននរន្តរភាព	-ការធ្វើនេសាទដោយខុសច្បាប់នៅតែកើតមាន	បង្កើនការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល	ខណ្ឌជលផល
		-ប្រជាពលរដ្ឋកង្វះជម្រើសមុខរបរ	បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈ គ្រួសារ បណ្តុះបណ្តាលបច្ចេកទេសកែច្នៃផលនេសាទ	
		ខ្វះការយល់ដឹងចំពោះឧបករណ៍នេសាទដែលអនុញ្ញាតឲ្យប្រើប្រាស់ក្នុងដែននេសាទ	ផ្សព្វផ្សាយប្រកាស់ស្តីពីការកំណត់ឧបករណ៍នេសាទ ដែលអនុញ្ញាតឲ្យប្រើប្រាស់	
		ខ្វះការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគោរពច្បាប់ស្តីពីជលផល	ផ្សព្វផ្សាយច្បាប់ស្តីពីជលផល	
		សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទលើការដឹកនាំ និងគ្រប់គ្រងក៏នៅមាន កម្រិត	បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដល់គណៈកម្មការសហគមន៍នេសាទ	
		ខ្វះការយល់ដឹងអំពីការងារអភិរក្សធនធានជលផល	ផ្សព្វផ្សាយសារសំខាន់នៃការអភិរក្ស និងតំបន់អភិរក្ស -ដាំកូនកោងកាង	
		ការគ្រប់គ្រងតំបន់អភិរក្សនៅមិនទាន់បាល្អ	បោះបង្គោលព្រំប្រទល់តំបន់អភិរក្ស	
មន្ទីរធនធានទឹក និងឧតុនិយម				

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
	១-មិនធានាសុវត្ថិភាព គ្មានសុដុមភាព គ្មាននិរន្តរភាព និងគ្មានវឌ្ឍនភាពវប្បធម៌	១.១-មិនចូលរួមថែរក្សាការពារ និងគ្មានការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិឲ្យស្ថិតស្ថេរគង់វង្សជានិរន្តរ៍ឡើយ	១.១.១-ធ្វើបញ្ជីសារពើភណ្ឌ និងធ្វើផែនទីកំណត់ធនធានវប្បធម៌ ១.១.២-ថែទាំនិងលើកស្ទួយវប្បធម៌ជនជាតិដើមភាគតិច ១.១.៣-ពង្រឹង និងពង្រីកវប្បធម៌នៅតាមវត្តអារាម ១.១.៤-សិក្សាស្រាវជ្រាវអំពីបេតិកភណ្ឌវប្បធម៌ដែលកំពុងប្រឈមនិងគ្រោះថ្នាក់ដែលនឹងឈានទៅការបាត់បង់ដើម្បីធ្វើការអភិរក្ស ១.១.៥-ផ្តល់មធ្យោបាយបច្ចេកទេសនិងថវិកាចំពោះគម្រោងសិក្សាស្រាវជ្រាវ និងអភិរក្សបេតិកភណ្ឌ	មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
		១.២-មិនបានរៀបចំផែនការ យន្តការ និងគ្មានបទដ្ឋានគតិយុត្តដើម្បីធានាដល់ការអភិរក្ស និងអភិវឌ្ឍវិស័យវប្បធម៌ទេ	១.២.១-ធ្វើការសិក្សា ផ្សព្វផ្សាយ និងទាមទារយកមកវិញនូវវត្ថុបុរាណខ្មែរដែលត្រូវបានលួច និងកាន់កាប់ដោយខុសច្បាប់នៅក្នុង និងក្រៅប្រទេស ១.២.២-ធ្វើការផ្សព្វផ្សាយច្បាប់បេតិកភណ្ឌដល់សហគមន៍ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍ក្នុងការគ្រប់គ្រង និងអភិរក្ស។	
	២-លើកកម្ពស់សីលធម៌ គុណធម៌ប្រពៃណី	២.១-មិនបានធ្វើការអប់រំ និងបណ្តុះប	២.១.១-ដាក់បញ្ចូលឲ្យមានការបង្រៀនសិល្បៈវប្បធម៌ក្នុងកម្ម	មន្ទីរវប្បធម៌

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
	នឹងពង្រឹងអត្តសញ្ញាណ និងកិត្យានុភាពជាតិ	ណ្តាលដោយឈរលើ គោលការណ៍ (អប់រំដើម្បីវប្បធម៌ វប្ប ធម៌ដើម្បីអប់រំ)ឡើយ	វិធីសិក្សានៅតាមគ្រឹះស្ថាន សិក្សា និងសាលាបណ្តុះបណ្តាលដើម្បីបង្កើតចំណេះដឹងលើវិ ស័យសិល្បវប្បធម៌ និងផ្នត់គំ និតស្រលាញ់សម្បត្តិវប្បធម៌ដល់យុវជនជំនាន់ក្រោយ ២.១.២-បង្កើតគ្រូសិល្បៈឲ្យបានកាន់តែច្រើន និងធ្វើឲ្យស្តាន ភាពការងាររបស់ពួកគាត់កាន់ តេប្រសើរឡើង	និងវិចិត្រសិស្បៈ
		២.២-មិនបានបង្កើតការយកចិត្ត ទុកដាក់លើកកម្ពស់ការងារ ផ្នែកអក្សរសាស្ត្រ និងអក្សរសិល្ប៍	២.២.១-រៀបចំបង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈលើវិស័យ វប្បធម៌ជាអាទ៍ ការនិពន្ធអក្សរ សាស្ត្រ និងអក្សរសិល្ប៍ ផ្នែកសិប្បកម្មវប្បធម៌ និងសិល្បៈនៅ ក្នុងខេត្ត	
		២.៣-មិនបានបង្កើតការយល់ដឹងពិត ពីតម្លៃនៃវប្បធម៌ ប្រពៃ ណី ទំនៀមទម្លាប់របស់ជាតិ និងភាព ផ្សេងៗគ្នានៃ វិញ្ញត្តិវប្បធម៌ទេ	២.៣.១-គាំទ្រការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញសិល្បៈ ចំពោះអ្នកសិល្បៈអាជីព ២.៣.២-លើកកម្ពស់ការចូលរួមរបស់ស្ត្រី ជនពិការ និងជន ជាតិដើមភាគតិចក្នុងវិស័យវប្ប ធម៌	
	៣-រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម	៣.១-មិនបានបង្កើតថ្មីលើផលិតផល វប្បធម៌គ្រប់ប្រភេទ ពិសេសផ្នែក ឧស្សាហកម្មច្នៃប្រឌិត	៣.១.១-គាំទ្រ និងលើកទឹកចិត្តដល់ការបង្កើតស្នាដៃថ្មីមានលើ គ្រប់ផ្នែកដូចជា តន្ត្រី សោត ទស្សន៍ ភាពយន្ត ការបោះពុម្ព សិល្បទស្សនីយភាពសិប្បកម្ម វិចិត្រកម្ម តម្បាញ ប្រពៃណី ការច្នៃម៉ូដ និងស្ថាបត្យកម្ម.....	មន្ទីរវប្បធម៌ និងវិចិត្រសិស្បៈ
		៣.២-គ្មានការរៀបចំព្រឹត្តការណ៍ផ្សេ	៣.២.១-រៀបចំឲ្យបានទៀងទាត់នូវព្រឹត្តការណ៍វប្បធម៌ប្រចាំឆ្នាំ	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		ងៗទាក់ទងនិងវប្បធម៌	ដូចជា ទិវាវប្បធម៌ពិធីបង្ហោះ ខ្លែង មហោស្រពសិល្បៈ មហោស្រពម្ហូបអាហារ ការបង្ហាញម៉ូដ និងការប្រឡងចម្រៀង....	
		៣.៣-គ្មានផលិតនិងមិនរកទីផ្សារវប្បធម៌ឲ្យកាន់តែទូលាយ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនោះទេ	៣.៣.១-សិក្សាជ្រាវជ្រាវជាប្រចាំអំពីស្ថានភាពទីផ្សារខាងវិស័យវប្បធម៌ និងធ្វើការផ្សព្វ ផ្សាយអំពីលទ្ធផលទាំងនោះ ៣.៣.២-ជួយសិល្បករ និងផលិតករក្នុងការរកទីផ្សារ ៣.៣.៣-ជួយសម្របសម្រួលឲ្យសិល្បករនិងផលិតករបង្កើត និងបង្កើនផលិតកម្មវប្បធម៌ តាមតម្រូវការទីផ្សារ ៣.៣.៤-គាំទ្រដល់ការធ្វើពាណិជ្ជកម្មផលិតផលវប្បធម៌ និង ជួយបង្កើតឲ្យមានបណ្តាញ ចែកចាយផលិតផល	
		៣.៤-មិនផ្តល់ឱកាសឲ្យប្រជាជនពិសេសយុវជន និង កុមារមិនឲ្យមានលទ្ធភាពចូលរួមក្នុងសកម្មភាពវប្បធម៌ និងមិនបានទទួលផលពីវិស័យវប្បធម៌ ប្រកបដោយសមធម៌នោះទេ	៣.៤.១-បង្កើតឱកាសការងារលើវិស័យវប្បធម៌ ដើម្បីចូលរួមជួយកាត់បន្ថយភាពក្រីក្ររបស់ ប្រជាជន ៣.៤.២-គាំទ្រនូវគំនិតផ្តួចផ្តើមល្អៗទាំងផ្នែកឯកជន ទាំងសង្គមស៊ីវិល	
មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ				
១	ជីវភាពរបស់ប្រជាពលរដ្ឋនៅមានកម្រិត	-មិនមានការងារធ្វើ	សហការជាមួយគ្រប់ភាគីពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សហគ្រាស គ្រឹះស្ថាន	មន្ទីរការងារ

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
			ក្រុមហ៊ុន រោងចក្រក្នុងខេត្ត សម្របសម្រួល ការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋមានការងារធ្វើ	
២	សហគ្រាស គ្រឹះស្ថានមួយចំនួនមិនទាន់គោរពច្បាប់ស្តីពីការងារ និងលក្ខខណ្ឌការងារ	-ចំណេះដឹងរបស់កម្មករនិយោជិត និងនិយោជក ស្តីពីលក្ខខណ្ឌការងារ និងច្បាប់ស្តីពីការងារនៅមានកម្រិត។ -កម្មករ និយោជិតមួយចំនួនមិនទាន់មានសៀវភៅការងារនៅឡើយ។	-បើកវគ្គបណ្តុះបណ្តាលអគ្គិសនី -បើកវគ្គបណ្តុះបណ្តាលជាងកំបោរ -បើកវគ្គបណ្តុះបណ្តាលកុំព្យូទ័រដ្ឋបាល -បើកវគ្គបណ្តុះបណ្តាលអេឡិចត្រូនិច -បើកវគ្គបណ្តុះបណ្តាលជួសជុលម៉ូតូ -បើកវគ្គបណ្តុះបណ្តាលជាងផ្សារដែក -បើកវគ្គបណ្តុះបណ្តាលចិញ្ចឹមមាន់និងចាក់វ៉ាក់សាំង -បើកវគ្គបណ្តុះបណ្តាលចិញ្ចឹមគោនិងចាក់វ៉ាក់សាំង -បើកវគ្គបណ្តុះបណ្តាលដាំបន្លែចម្រុះ -បើកវគ្គបណ្តុះបណ្តាលចិញ្ចឹមត្រីអណ្តែង -បើកវគ្គបណ្តុះបណ្តាលបណ្តុះផ្សិត -បើកវគ្គបណ្តុះបណ្តាលចិញ្ចឹមកង្កែប -បើកវគ្គបណ្តុះបណ្តាលដំណាំធូរេន -បើកវគ្គបណ្តុះបណ្តាលដំណាំល្ហុង -បើកវគ្គបណ្តុះបណ្តាលដំណាំល្ពៅ -បើកវគ្គបណ្តុះបណ្តាលចិញ្ចឹមជ្រូក និងចាក់វ៉ាក់សាំង	មន្ទីរការងារ
មន្ទីរព័ត៌មាន				
១	១-វិសាលភាពប្រព័ន្ធផ្សព្វផ្សាយមិនទាន់បានគ្របដណ្តប់ទូទាំខេត្ត នៅឡើយ។	១.១ ការផ្សព្វផ្សាយពុំទាន់បានឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកស្តាប់ និងទស្សនិកជន។	១.២.១ កែលម្អកម្មវិធីផ្សាយឲ្យបានសមស្រប ប្រកបដោយគុណភាព ។	មន្ទីរព័ត៌មាន

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		១.១.១ ឧបករណ៍ សម្ភារបច្ចេកទេសនៅមានការខ្វះខាត និងមិនទាន់បានសមស្របទៅតាមលក្ខណៈបច្ចេកទេសនៃបច្ចេកវិទ្យានៅឡើយ។	១.២.២ បំពាក់ឧបករណ៍ សម្ភារបច្ចេកទេសឲ្យបានគ្រប់គ្រាន់ ទំនើបស្របតាមសម័យបច្ចេកវិទ្យា។	
		១.១.២ ពុំទាន់មានស្ថានីយ៍ទូរទស្សន៍មួយសមស្របដើម្បីបម្រើជូនទស្សនិកជននៅឡើយ ។	១.២.៣ តម្រូវឲ្យមានស្ថានីយ៍ទូរទស្សន៍មួយសមរម្យអាចផ្សាយគ្របដណ្តប់ទូទាំងខេត្ត ដើម្បីបម្រើជូនទស្សនិកជន។	
		១.១.៣ ខ្វះមធ្យោបាយចុះយកព័ត៌មានតាមមូលដ្ឋាន ។	១.២.៤ បំពាក់នូវមធ្យោបាយសម្រាប់ចុះយកព័ត៌មាននៅតាមមូលដ្ឋាន	
		១.១.៤ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុនៅមានកម្រិត	១.២.៥ បណ្តុះបណ្តាលមន្ត្រីជំនាញបច្ចេកទេស ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស។	
២	ពង្រីកវិសាលភាពប្រព័ន្ធផ្សព្វផ្សាយបានគ្របដណ្តប់ទូទាំខេត្តនៅឡើយ។	ដើម្បីបម្រើសេវាផ្សព្វផ្សាយជូនប្រជាពលរដ្ឋ	ពង្រីកវិសាលភាពប្រព័ន្ធផ្សព្វផ្សាយបានគ្របដណ្តប់ទូទាំខេត្ត	មន្ទីរព័ត៌មាន
		ឧបករណ៍ សម្ភារបច្ចេកទេសនៅមានការខ្វះខាត និងមិនទាន់បានសមស្របទៅតាមលក្ខណៈបច្ចេកទេសនៃបច្ចេកវិទ្យានៅឡើយ។	បំពាក់ឧបករណ៍ សម្ភារបច្ចេកទេសឲ្យបានគ្រប់គ្រាន់ ទំនើបស្របតាមសម័យបច្ចេកវិទ្យា។	
		ពុំទាន់មានស្ថានីយ៍ទូរទស្សន៍មួយសមស្របដើម្បីបម្រើជូនទស្សនិកជននៅឡើយ ។	តម្រូវឲ្យមានស្ថានីយ៍ទូរទស្សន៍មួយសមរម្យអាចផ្សាយគ្របដណ្តប់ទូទាំងខេត្ត ដើម្បីបម្រើជូនទស្សនិកជន។	
		ខ្វះមធ្យោបាយចុះយកព័ត៌មានតាមមូលដ្ឋាន ។	បំពាក់នូវមធ្យោបាយសម្រាប់ចុះយកព័ត៌មាននៅតាមមូលដ្ឋាន	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុនៅមានកម្រិត	បណ្តុះបណ្តាលមន្ត្រីជំនាញបច្ចេកទេស ដើម្បីអភិវឌ្ឍន៍ធនធានមស្យ។	
មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច				
១	ផ្សព្វផ្សាយ ច្បាប់នានា និងវេទិការសាធារណៈក្នុងខេត្ត	ដោយសារការយល់ដឹង និងគោរពច្បាប់ របស់ប្រជាពលរដ្ឋនៅមានកំរិត	ផ្សព្វផ្សាយច្បាប់នានាដល់មូលដ្ឋាន ជូនប្រជាពលរដ្ឋបានយល់ដឹង និងប្រតិបត្តិតាម	មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា
		ដើម្បីស្វែងយល់ពីចម្ងល់ សំណូមពរ និងតម្រូវការនានារបស់ប្រជាពលរដ្ឋ	ពន្យល់ណែនាំបកស្រាយ និងដោះស្រាយនូវចម្ងល់ សំណូមពរនិងតម្រូវការនានារបស់ប្រជាពលរដ្ឋតាម ស្ថានភាព និងលទ្ធភាពជាក់ស្តែង	
			ពាំនាំនូវចម្ងល់ សំពូមពរនិងតម្រូវការនានារបស់ប្រជាពលរដ្ឋជូនថ្នាក់លើដើម្បីសម្រួលដោះស្រាយ។	
២	ធ្វើអធិការកិច្ចនិងតាមដានត្រួតពិនិត្យការអនុវត្តច្បាប់	បង្ការទប់ស្កាត់និងកាត់បន្ថយអំពើពុករលួយ ការកិបកេង ការរំលោភដោយអំណាច និង បាតុភាពអសកម្មនានា	ចុះធ្វើអធិការកិច្ចលើគ្រប់វិស័យ	មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា
		ដើម្បីពង្រឹងការអនុវត្តច្បាប់មានប្រសិទ្ធភាពការងារ និងប្រសិទ្ធភាពការគ្រប់គ្រង។	ចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានាបទបញ្ជា និងអនុសាសន៍របស់រាជរដ្ឋាភិបាល	
មន្ទីរមុខងារសាធារណៈ				
១	មន្ត្រីរាជការក្រុង/ស្រុកមិនទាន់បានយល់ដឹងលិខិតបទដ្ឋានថ្មី	-ការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តនៅមានកំរិត -ការអនុវត្តនៅមានកំរិត និងមិនទាន់បានគ្របជ្រុងជ្រោយ	ការប្រជុំផ្សព្វផ្សាយ	មន្ទីរមុខងារសាធារណៈ
២	ការគ្រប់គ្រងវត្តមាននៅមានកំរិត	-ការចុះវត្តមានមន្ត្រីរាជការមិនបាន	ការប្រជុំផ្សព្វផ្សាយ	មន្ទីរមុខងារសាធារ

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		ត្រឹមត្រូវ		ណៈ
៣	ការមិនទាន់បានយល់ដឹងពីសេចណែនាំថ្មី	-ការអនុវត្តការងារមិនទាន់គ្រប់ជ្រុងជ្រោយ -ការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តនៅមានកំរិត	ការប្រជុំផ្សព្វផ្សាយ	មន្ទីរមុខងារសាធារណៈ
មន្ទីរផែនការ				
	សមត្ថភាពមន្ត្រីនៅមានកំរិតទាបវិស័យផែនការស្ថិតិ	មន្ត្រីភាគច្រើនថ្មី	រៀបចំវគ្គបណ្តុះបណ្តាល	មន្ទីរផែនការ
	ការប្រមូលទិន្នន័យមូលដ្ឋានមានការយឺតយ៉ាវ	ជាប់រវល់ការកិច្ចច្រើននៅមូលដ្ឋាន	ជំរុញលើកទឹកចិត្ត រៀបចំក្រុមការងារដើម្បីចុះប្រមូល	
	ការចូលរួមគាំទ្រពីបណ្តាមន្ទីរ អង្គភាព វិស័យឯកជន (DIW)	មិនសូវខ្វល់ មិនយល់ពីដំណើរការ	១.ពង្រឹងការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកសាងផែនការនិងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ	
	ពុំមានការលើកទឹកចិត្ត ខ្វះការចូលរួម និងជំរុញពីក្រុងស្រុក		២.រៀបចំវគ្គបណ្តុះបណ្តាលការប្រមូលទិន្នន័យនានាស្តីពីការកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិរួមបញ្ចូលទាំងឧបករណ៍ប្រព័ន្ធទិន្នន័យនានា	
			៣.ពិនិត្យនិងធ្វើបច្ចុប្បន្នភាពទិន្នន័យនានាទៀងទាត់សម្រាប់ការកសាងផែនការ	
			៤.រៀបចំវេទិការពិគ្រោះយោបល់គម្រោងវិនិយោគបីឆ្នាំរំកិលនិងដំណើរសិក្ខាសាលា(DIW)	
			៥.គាំទ្រការធ្វើអង្កេតសេដ្ឋកិច្ចសង្គម អង្កេតកំលាំងពលកម្ម កុមារ និងការអង្កេតនានា...	
			៦.គាំទ្រការធ្វើជំរឿនសហគ្រាស លើកទី២ ឆ្នាំ២០២០	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
			៧.រៀបចំធ្វើបច្ចុប្បន្នភាព ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ	
			៨. និង អនុវត្តការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	
			៩.ការគ្រប់គ្រងការរៀបចំ និង អនុវត្តការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា	
			១០.ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការអនុវត្តផែនការ-ស្ថិតិ ប្រជាជននិងការអភិវឌ្ឍ និង វិទ្យសាស្ត្រនិងបច្ចេកវិទ្យា	
ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ				
មន្ទីរការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី				
១	ការងារចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងដាច់ដោយដុំ	ប្រជាពលរដ្ឋទទួលបានសិទ្ធិពេញលេញក្នុងការកាន់កាប់ដីធ្លី	ចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ	មន្ទីរការរៀបចំដែនដី
២	ការងារដោះស្រាយទំនាស់ដីធ្លី	ទំនាស់ដីធ្លីកើនឡើងនៅស្រុកស្រែអំបិល,ស្រុកបូទុមសាគរ ,ស្រុកគីរីសាគរ..	ក្រុមការងារចុះដោះស្រាយដើម្បីកាត់បន្ថយឬបញ្ចប់ទំនាស់ ដីធ្លី	មន្ទីរការរៀបចំដែនដី
៣	ការចេញលិខិតអនុញ្ញាតសាងសង់ និងវិញ្ញាបនប័ត្រក្រុមជាង	-សំណង់មានច្បាប់អនុញ្ញាតត្រឹមត្រូវ	-ចេញច្បាប់អនុញ្ញាតសាងសង់ជូនប្រជាពលរដ្ឋ	មន្ទីរការរៀបចំដែនដី
		-ទីប្រជុំជនមានសណ្តាប់ធ្នាប់	-ចេញវិញ្ញាបនប័ត្រក្រុមជាងសាងសង់	
		-ជាងមានច្បាប់ ត្រឹមត្រូវជានាសុវត្ថិភាពសំណង់		
៤	ការងាររៀបចំដែនដីនិងនគរូបនីយកម្ម	-ការប្រើប្រាស់ដីមិនត្រឹមត្រូវ ,ហេដ្ឋារចនាសម្ព័ន្ធ គ្មានលក្ខណៈបច្ចេកទេស, ទីប្រជុំជនគ្មាន សណ្តាប់ធ្នាប់	-កសាងផែនទីប្រើប្រាស់ដីធ្លី ឃុំ/សង្កាត់,ស្រុក/ក្រុង	មន្ទីរការរៀបចំដែនដី

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
ខណ្ឌរដ្ឋបាលព្រៃឈើ				
1	1-ដោយពុំទាន់មានព្រំប្រទល់ដែនព្រៃឈើជាសញ្ញាសំគាល់ច្បាស់លាស់ ដែលធ្វើឱ្យមានសកម្មភាពកាប់ រាន ទន្ទ្រានកាន់កាប់រំលោភយកដីព្រៃឈើធ្វើជាកម្មសិទ្ធិ។	1-មានការរំលោភយកដីព្រៃ ឈើ 2-ធ្វើឱ្យមានការបាត់បង់ដីព្រៃឈើ 3-ប្រជាពលរដ្ឋពុំទាន់យល់ច្បាស់លាស់ពីច្បាប់ស្តីពីព្រៃឈើ បទបញ្ជា និងសេចក្តីជូនដំណឹង របស់រាជរដ្ឋាភិបាល និងលិខិត បទដ្ឋានផ្សេងៗទៀត។	1.1.1-បោះបង្គោលព្រំប្រទល់ដែនព្រៃឈើឱ្យបានច្បាស់លាស់។ 1.1.2-ប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទបញ្ជា និងសេចក្តីជូនដំណឹង របស់ រាជរដ្ឋាភិបាល និងលិខិតបទដ្ឋាន ផ្សេងៗទៀត។	ខណ្ឌរដ្ឋបាលព្រៃឈើ
2	2-ធ្វើឱ្យមានទំនាស់ច្រើនរវាងប្រជាពលរដ្ឋ និងប្រជា ពលរដ្ឋ ប្រជាពលរដ្ឋនិងរដ្ឋ។	2.1-ពុំទាន់បានធ្វើចំណាត់ថ្នាក់ច្បាស់លាស់។	2.1.1-ត្រូវតែមានការចុះបញ្ជិកាឱ្យបានច្បាស់លាស់ និងធ្វើផែនទី	ខណ្ឌរដ្ឋបាលព្រៃឈើ
3	3-រាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ ពុំមានលំនឹងបរិស្ថាន មានការប្រែប្រួលអាកាសធាតុ	1-ព្រៃឈើមានការបាត់បង់ច្រើន 2-កាប់បំផ្លាញព្រៃឈើដោយអនាធិបតេយ្យ	3.1.1-ដាំឈើបន្ថែមដើម្បីបង្កើនគំរបព្រៃឈើ(ដីសាធារណៈ សាលារៀន វត្តអារាម ផ្លូវលំ ប្រឡាយទឹក.។ល។ 3.1.2-ដាំឈើ ជាលក្ខណៈគ្រួសារ និងរដ្ឋ	ខណ្ឌរដ្ឋបាលព្រៃឈើ
4	4-មានសកម្មភាពបទល្មើសព្រៃឈើ ក្នុងតំបន់ និងឆ្លងកាត់ ផ្លូវគោក និងផ្លូវទឹក	4.1-អ្នកពាក់ព័ន្ធ និងប្រជាពល រដ្ឋ ពុំទាន់យល់ពី ច្បាប់ស្តីពី ព្រៃឈើ និងលិខិតបទដ្ឋាននានា	4.1.1-ប្រជុំផ្សព្វផ្សាយឱ្យបានទូលំទូលាយគ្រប់មជ្ឈដ្ឋានជាពិសេសជិតតំបន់ព្រៃឈើ	ខណ្ឌរដ្ឋបាលព្រៃឈើ
5	5-មានជនខិលខូចនិងជនឆ្លៀតឱកាសលួចធ្វើសកម្ម ភាព បទល្មើសព្រៃឈើ ក្នុងតំបន់ និងឆ្លងកាត់ ផ្លូវគោក និងផ្លូវទឹក	5.1-មានជនខិលខូចនិងជនឆ្លៀតឱកាស ពុះព្រមគោរពច្បាប់ស្តីពី ព្រៃឈើ និងលិខិតបទដ្ឋាននានា	5.1.1-ទប់ស្កាត់និងពង្រឹងការអនុវត្តច្បាប់ បង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃដូចភ្លៀងរលឹម	ខណ្ឌរដ្ឋបាលព្រៃឈើ
6	6-បាត់បង់ព្រៃឈើ សម្រាប់សហគមន៍ប្រើប្រាស់	6.1-ចង់ការពារព្រៃឈើ 6.2-ទប់ស្កាត់បទល្មើសព្រៃឈើ 6.3-ចង់ដាំដុះព្រៃឈើឡើងវិញ	6.1.1-បង្កើតសហគមន៍ព្រៃឈើឱ្យស្របតាម ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ 6.1.2-មានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ស្របតាមច្បាប់ និង	ខណ្ឌរដ្ឋបាលព្រៃឈើ

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		6.4-ការពារគំរបដី 6.5-ខ្វះកន្លែងឃ្វាលគោ ក្របី	លិខិតបទដ្ឋាន 6.1.3-បង្កើតសហគមន៍ព្រៃឈើឱ្យស្របតាម ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ 6.1.4-មានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ស្របតាមច្បាប់ និងលិខិតបទដ្ឋាន 6.1.5-បង្កើតសហគមន៍ព្រៃឈើឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ 6.1.6-មានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ស្របតាមច្បាប់ និងលិខិតបទដ្ឋាន	
មន្ទីរបរិស្ថាន				
1	សំណល់ រឹង	១.១.គ្មានអ្នកប្រមូលសំរាមគ្រប់គ្រន់	ការដាក់ដេញថ្លៃក្នុងការប្រមូលសំរាម	មន្ទីរបរិស្ថាន
		១.២.ប្រជាពលរដ្ឋមានការយល់ដឹងនូវមានកំរិត	សៀវភៅវបន្ទុកក្នុងការប្រមូលសំរាមនិង កិច្ចសន្យា	
		១.២.១.ភាគច្រើនរស់នៅតំបន់ជាយក្រុង និងមានសណ្ឋានភាពផ្លូវលំបាក	ការត្រួតពិនិត្យ និងការតាមដានរបស់មន្ទីរជំនាញ	
		១.៣.ថ្លៃប្រមូលសំរាមប្រចាំខែមានតម្លៃខ្ពស់	តាមរយៈវិទ្យុ	
		១.៣.១.ការប្រមូលសំរាមធ្វើទៅតាមការស្មាក់ចិត្ត	តាមរយៈទូរទស្សន៏	
		១.៤.មិនមានធុងសំរាមគ្រប់គ្រន់	តាមការអប់រំ នូវសាលារៀន	
		១.៤.១. កង្វះខាត់ស្លាកសញ្ញាអប់រំ	តាមការផ្សព្វផ្សាយនៅតាមបណ្តា ឃុំ សង្កាត់	
		១.៤.២. កង្វះខាត់ភ្នាក់ងារ តាមដាន	មានការថែរក្សា នៅតាមទីសាធារណៈ	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		និងត្រួតពិនិត្យ		
			តម្រូវឲ្យក្រុមហ៊ុនប្រមូលសំរាមដាក់ធុងតាមទីសាធារណៈ	
2	សំណល់ រាវ	២.១.គ្មានអ្នកវិនិយោគ	បង្កើតប្រព័ន្ធបង្ហូរសំណល់រាវ និង អាងប្រព្រឹត្តិកម្មសំណល់រាវ	មន្ទីរបរិស្ថាន
		២.២.ប្រជាពលរដ្ឋខ្វះការយល់ដឹងលើការគ្រប់គ្រងសំណល់រាវ	តបណ្តាញគ្រប់លំនៅដ្ឋាន	
		២.៣.គ្មានបណ្តាញសំរាប់បង្ហូរសំណល់រាវនិង គ្មានអាងប្រព្រឹត្តិកម្មសំណល់រាវ	បង្កើតឲ្យមានសៀវភៅបន្ទុក	
3	បទល្មើសព្រៃឈើ	៣.១.ជនល្មើសលួចកាប់ឈើ	ផ្សព្វផ្សាយច្បាប់បរិស្ថាន	មន្ទីរបរិស្ថាន
		៣.២.មន្ត្រីឧទ្យានុរក្សកង្វះមធ្យោបាយសំរាប់ល្បាតទប់ស្កាត់បទល្មើស	ផ្តល់សម្ភារៈ និង មធ្យោបាយគ្រប់គ្រង់ក្នុងការល្បាត	
		៣.៣.ប្រជាពលរដ្ឋមិនយល់ពីច្បាប់ស្តីពី តំបន់ការពារ	ផ្សព្វផ្សាយច្បាប់ស្តីពី តំបន់ការពារ	
គ្រប់គ្រងគ្រោះមហន្តរាយ				
១	គ្រាប់មីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ	មិនទាន់បានបោសសំអាតមីន និង គ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ជូនប្រជាពលរដ្ឋដែលមានតម្រូវការដីប្រើប្រាស់	ធ្វើការបោសសំអាតគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះជូនប្រជាពលរដ្ឋ	
ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ				
ការគ្រប់គ្រងរដ្ឋបាល				
ទីចាត់ការធនធានមនុស្ស				
១	ការផ្តល់សេវានៅថ្នាក់មូលដ្ឋានមិនទាន់មាន	សាលាស្រុកមួយចំនួនមិនទាន់រៀបចំ	១. បង្កើតឲ្យមានយន្តការច្រកចេញចូលតែមួយតាមសាលា	ទីចាត់ការធនធាន

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
	ភាពល្អប្រសើរនៅឡើយ	ឲ្យមានការិយាល័យច្រកចេញចូលតែមួយ ចំណែកអ្នក ផ្តល់សេវាក៏មិនទាន់យល់ច្បាស់អំពីនីតិវិធីនៃការផ្តល់សេវា	ស្រុកដែលមិនមានការិយា ល័យច្រកចេញចូលតែមួយ ២. បង្កើតការិយាល័យច្រកចេញចូលតែមួយ ៣. បណ្តុះបណ្តាលមន្ត្រីផ្តល់សេវាអំពីនីតិវិធី និងក្រមសិលធម៌នៃការផ្តល់សេវាសាធារណៈ	មនុស្ស
២	មន្ត្រីរាជការនៅថ្នាក់មូលដ្ឋានមកបម្រើការងារមិនបានទៀងទាត់ និងអនុវត្តការងារគ្មានប្រសិទ្ធភាព	ការគ្រប់គ្រងបុគ្គលិកគ្មានប្រសិទ្ធភាព និងមិនយល់ច្បាស់ពីតួនាទីការកិច្ចរបស់បុគ្គលិកម្នាក់ៗ	១. បើកវគ្គបណ្តុះបណ្តាលអំពីនីតិវិធីគ្រប់គ្រងបុគ្គលិក ២. បើកវគ្គបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ៣. រៀបចំឲ្យមានបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក	ទីចាត់ការធនធានមនុស្ស
៣	ការអនុវត្តការងារនៅក្នុងអង្គភាពនីមួយមិនសូវមានប្រសិទ្ធភាព	១. ខ្វះបុគ្គលិកសម្រាប់បំពេញប្រអប់របស់អង្គភាពនីមួយៗ ២.មិនសូវយល់ពីតួនាទីភារកិច្ច និងការបរិយាយលក្ខខ័ណ្ឌការងាររបស់មន្ត្រី	១.ជ្រើសរើសមន្ត្រីបន្ថែមសម្រាប់បំពេញប្រអប់ ២.បើកវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាល	ទីចាត់ការធនធានមនុស្ស
៤	ទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង ស្រុក មិនទាន់មានភាពរលូន	១.ខ្វះការទំនាក់ទំនង និងពិបាកក្នុងការទំនាក់ទំនង ២. ការឆ្លើយតប និងរៀបចំឯកសារមិនបានទាន់ពេលវេលាក្រសួងមហាផ្ទៃកំណត់	រៀបចំឲ្យមានប្រតិទិន និងផែនការកិច្ចប្រជុំប្រចាំខែ ឬប្រចាំត្រីមាស ដើម្បីរៀបចំ និងស្វែងយល់ការងារដែលនៅចន្លោះប្រហោងពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក	ទីចាត់ការធនធានមនុស្ស
៥	ការអនុវត្តការងារផ្នែកបុគ្គលិក នៃរដ្ឋបាលខេត្ត ក្រុង ស្រុក មិនទាន់មានប្រសិទ្ធភាពនៅឡើយ	មន្ត្រីទទួលបន្ទុកបុគ្គលិក នៃរដ្ឋបាលខេត្ត ក្រុង ស្រុក មិនទាន់យល់ច្បាស់ពីនីតិវិធីថ្មីៗ ដែលក្រសួងទំលាក់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ	១. បើកវគ្គរំលឹកឡើងវិញស្តីពីការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ២. បណ្តុះបណ្តាលបន្ថែមពីនីតិវិធីថ្មីៗ ដែលថ្នាក់ជាតិផ្តល់ឲ្យ	ទីចាត់ការធនធានមនុស្ស
៦	កុមារមួយចំនួនខ្វះអាហារូបត្ថម្ភ និងមិនទាន់	អាជ្ញាធរមូលដ្ឋាន និងគកនក ឃុំ	១. បើកវគ្គបណ្តុះបណ្តាលការគ្រប់គ្រងមត្តេយ្យសិក្សាសហ	ទីចាត់ការធនធាន

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
	រៀបចំឲ្យមានមគ្គុយ្យសិក្សាសហគមន៍នៅឃុំ សង្កាត់ឲ្យបានគ្រប់គ្រាន់នៅឡើយ	សង្កាត់ មិនទាន់យល់ពីនីតិវិធីនៃការរៀបចំ និងខ្វះខាតថវិកាក្នុងការរៀបចំសាលាមគ្គេយ្យសហគមន៍ស្តង់ដារ និងសារៈសំខាន់នៃអាហារូបត្ថម្ភសម្រាប់កុមារ	គមន៍សម្រាប់ឃុំ សង្កាត់ ២. ជម្រុញលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋានថ្នាក់ឃុំ សង្កាត់ប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ក្នុងការសាងសង់មគ្គេយ្យសិក្សាសហគមន៍ នៅគ្រប់ ឃុំ សង្កាត់ ៣. ជ្រើសរើសគ្រូបង្រៀនមគ្គេយ្យសហគមន៍ និងបណ្តុះបណ្តាលសមត្ថភាពគ្រូ ៤. បើកវគ្គបណ្តុះបណ្តាលស្តីពីតួនាទី ភារកិច្ច គ.ក.ន.ក ឃុំ សង្កាត់	មនុស្ស
អង្គភាពលទ្ធកម្ម				
៦	ការអនុវត្តនីតិវិធីលទ្ធកម្មមានភាពយឺតយ៉ាវ និងទាន់មិនស្របតាមផែនការ	ឯកសារការងារលទ្ធកម្មមានចំនួនច្រើន និងត្រូវចំណាយពេលត្រួតពិនិត្យឲ្យបានល្អិតល្អន់	ពង្រឹងការអនុវត្តនីតិវិធីលទ្ធកម្ម ឲ្យបានល្អប្រសើរ និងទាន់ពេលវេលាស្របតាមគោលការណ៍ណែនាំ	អង្គភាពលទ្ធកម្ម
អង្គភាពច្រកចេញចូលតែមួយ				
១	ប្រជាពលរដ្ឋក្នុងខេត្តមិនទាន់យល់ច្បាស់ពីនីតិវិធីនៃការផ្តល់សេវាក្នុងអង្គភាពច្រកចេញចូលតែមួយ	- មិនទាន់បានធ្វើការផ្សព្វផ្សាយអោយបាន ទូលំទូលាយ(តាមរយៈវេទិកាសាធារណ) - ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យា (បណ្តាញសង្គម)នៅមានកម្រិត	- រៀបចំវគ្គផ្សព្វផ្សាយស្តីពីនីតិវិធីនៃការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយ - បង្កើនការផ្សព្វផ្សាយ និងស្វែងរកនីតិវិធីបន្ថែមដើម្បីអោយប្រជាពលរដ្ឋបានយល់	អង្គភាពច្រកចេញចូលតែមួយ
២	ការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយ នៅមានកម្រិត	- ខ្វះមន្ត្រីសម្រាប់ផ្តល់សេវា - មន្ត្រីផ្តល់សេវានៅមានកម្រិត	- ស្នើសុំមន្ត្រីបន្ថែម(ពី០៣ ទៅ០៥នាក់) - បណ្តុះបណ្តាលដល់មន្ត្រីបន្ថែម	អង្គភាពច្រកចេញចូលតែមួយ

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		- ប្រព័ន្ធលើកទឹកចិត្តមិនទាន់បានល្អ - ក្រសួង ឬមន្ទីរមួយចំនួនមិនទាន់ផ្ទេរ ការងារមកអស់នៅឡើយ - អ្នកស្នើសុំសេវាមិនទាន់យល់ ឬចេះក្នុងការបំពេញឯកសារ	- លើកទឹកចិត្តដល់មន្ត្រីផ្តល់សេវាបន្ថែម - ស្នើសុំអោយមានវគ្គបណ្តុះបណ្តាល ឬនីតិវិធីនៃការផ្តល់សេវាអោយបានច្បាស់ - ស្នើសុំក្រសួង ឬមន្ទីរពាក់ព័ន្ធផ្តល់សេវាមកអោយអង្គភាពច្រកតាមអនុក្រឹត្យលេខ១៨	
៣	នីតិវិធីសម្រាប់ផ្តល់សេវារបស់ក្រសួង ឬមន្ទីរដែលបានប្រតិភូកម្មមកផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយខេត្តនៅមានភាពស្មុគស្មាញ	- ទម្រង់បែបបទខុសៗគ្នា - ការចេញសេចក្តីអនុញ្ញាតមានការពាក់ព័ន្ធគ្នាច្រើនជំនាញ - មិនមានសេវាជាកញ្ចប់	- ស្នើសុំអោយក្រសួងមហាផ្ទៃសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធចេញទម្រង់បែបបទតែមួយដើម្បីងាយស្រួលផ្តល់សេវា - ស្នើសុំអោយក្រសួងមហាផ្ទៃបង្កើតអោយមានសេវាជាកញ្ចប់	អង្គភាពច្រកចេញចូលតែមួយ
៤	ការតាមដាន និងគ្រប់គ្រងទិន្នន័យឯកសារដែលប្រជាពលរដ្ឋស្នើសុំសេវាមិនទាន់បានល្អ	- សេវាមានច្រើនវិស័យ និងច្រើនសេវា - មិនមានប្រព័ន្ធគ្រប់គ្រងច្បាស់លាស់	- បន្ថែមមន្ត្រីជួយតាមដាន និងគ្រប់គ្រង - បំពាក់ប្រព័ន្ធស្វ័យប្រវត្តិកម្ម(Online)	អង្គភាពច្រកចេញចូលតែមួយ
៥	មិនមាននីតិវិធីសម្រាប់បែងចែកប្រាក់រង្វាន់	- ក្រសួង ឬមន្ទីរមានច្រើនវិស័យ - ការអនុវត្តថវិកាមានភាពខុសៗគ្នា - ការរៀបចំនីតិវិធីមានការស្មុគស្មាញ	- ស្នើសុំក្រសួងមហាផ្ទៃជួយរៀបចំនីតិវិធីនិងស្វែងរកដំណោះស្រាយ - ស្នើសុំក្រសួងមហាផ្ទៃជួយពន្លឿនពីនីតិវិធីបែងចែកប្រាក់រង្វាន់	អង្គភាពច្រកចេញចូលតែមួយ
ទីចាត់ការអន្តរវិស័យ				
ក	**ផ្នែកច្បាប់ និងសុវត្ថិភាពសាធារណៈ**			
ក	ការចូលរួមរបស់អ្នកពាក់ព័ន្ធ មិនទាន់គ្រប់	អង្គការមិនមែនរដ្ឋាភិបាល សមាគម	ពន្លឿនការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល សមាគម និង	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
.១	សមាសភាពនៅឡើយ	និងសហគមន៍មូលដ្ឋានមួយចំនួន មិនទាន់បានចុះបញ្ជីត្រឹមត្រូវជាមួយក្រសួង ឬស្ថាប័ន មានសមត្ថកិច្ច	សហគមន៍មូលដ្ឋាន ជាមួយក្រសួង ឬស្ថាប័ន មានសមត្ថកិច្ច	
ក .២	ការផ្សព្វផ្សាយមិនទាន់ទូលំទូលាយដល់សហគមន៍មូលដ្ឋាន	វេទិកាប្រព្រឹត្តទៅនៅថ្នាក់ក្រុង ស្រុក ហើយប្រជាពលរដ្ឋក្នុងមូលដ្ឋានជាច់ស្រយាល មានការពិបាកក្នុងការមកចូលរួម	ជម្រុញឲ្យមានការចូលរួមពីមន្ទី អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ	
ខ	**ផ្នែកគ្រប់គ្រងការអភិវឌ្ឍ និងសំណង់**			
ខ .១	ក្រុមហ៊ុនមួយចំនួន ទទួលសិទ្ធិសម្បទានដីពីរាជរដ្ឋាភិបាល ដើម្បីវិនិយោគ ហើយមានទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ (ទំនាស់រ៉ាំរ៉ៃ)	– ក្រុមហ៊ុនមួយចំនួនបានដោះស្រាយសំណងគោលនយោបាយជូនប្រជាពលរដ្ឋម្ចាស់ដីមិនបានសហការជាមួយអាជ្ញាធរពាក់ព័ន្ធឱ្យបានច្បាស់លាស់ ទើបធ្វើឱ្យទំនាស់រីករាលដាលកាន់តែធំ – មានជនអគតិ និងអង្គការ សមាគមមួយចំនួន ដើរញុះញង់ឲ្យប្រជាពលរដ្ឋក្រោកឡើងតវ៉ាទាមទារបន្តទៀត	– ស្នើឲ្យក្រុមហ៊ុនបន្តសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់បន្តទៀតជូនប្រជាពលរដ្ឋ – ពង្រឹងការសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គកា សមាគម និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួល និងដោះស្រាយទៅតាមលិខិតបទដ្ឋានគតិយុត្ត	
ខ .២	សំណង់ផ្ទះ ឬតូបអាជីវកម្មមួយចំនួនសាងសង់ លើចិញ្ចើមផ្លូវ លើប្រឡាយទឹក អូរ និងលយចូលព្រៃកជាដើម។ល។	– អាជ្ញាធរមូលដ្ឋានពុំសូវយកចិត្តទុកដាក់ ចំពោះសំណង់ដែលសាងសង់លើប្រឡាយទឹក អូរ និងលយចូលព្រៃក ឬចុះអនុវត្តដៃរបានត្រឹមធ្វើកិច្ចសន្យាជាមួយម្ចាស់សំណង់ប៉ុណ្ណោះ។	– ណែនាំ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ ក្នុងការពង្រឹងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តិ។	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		– ដោយកំណើនភ្ញៀវទេសចរណ៍កាន់តែច្រើន ប្រជាពលរដ្ឋពុំមានទីតាំងលក់ដូរឲ្យបានសមរម្យ ដើម្បីបំពេញតម្រូវការភ្ញៀវទេសចរណ៍។	– ស្នើសុំកំណត់ទីតាំងលក់ដូរសម្រាប់ប្រជាពលរដ្ឋឱ្យបានសមរម្យ។	
ខ.៣	សំណង់ភាគច្រើនពុំទាន់មានលិខិតអនុញ្ញាតសាងសង់ ឬសាងសង់ដំណាលនឹងការស្នើសុំលិខិតអនុញ្ញាតសាងសង់	ប្រជាពលរដ្ឋលើកឡើងអំពីកត្តាលំបាកក្នុងការស្នើសុំដូចជា ខេត្តកោះកុងផ្ទៃដីស្ទើរតែ៨៥% ស្ថិតក្នុងតំបន់ការពារធម្មជាតិ ការផ្តល់សេវាឬការស្នើសុំមានរយៈពេលយូរ...	– ស្នើសុំបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិជាក់ទៅជាតំបន់សហគមន៍ – ស្នើសុំកាត់ធ្វៀលដីចេញពីតំបន់ការពារធម្មជាតិឱ្យបានឆាប់ ដើម្បីប្រជាពលរដ្ឋបានរស់នៅ និងអាស្រ័យផលជាក់ស្តែង – ជំរុញដល់អាជ្ញាធរមូលដ្ឋាន និងមន្ទីរអង្គភាពផ្តល់សេវាពន្លឿនការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានឆាប់ – ជួយសម្របសម្រួលដល់ការស្នើសុំ និងពិនិត្យបច្ចេកទេស ដើម្បីកាត់បន្ថយឱ្យបានខ្ពស់នូវផលប៉ះពាល់	
គ	**ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច**			
គ.១	ការចុះស្រង់ស្ថិតិអំពីមូលដ្ឋានអាជីវកម្ម និងផលិតកម្មគ្រប់ប្រភេទក្នុងខេត្ត មានការលំបាក	ក្រុមហ៊ុន អាជីវករ ឬប្រតិបត្តិករមួយចំនួន មិនទាន់យល់អំពីដំណើរការចុះស្រង់ស្ថិតិ និងខ្វះការចូលរួមនិងផ្តល់	សហការជាមួយមន្ទីរ អង្គភាព ពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានចុះផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីដំណើរការចុះស្រង់ស្ថិតិជាមុន ដល់ក្រុមហ៊ុន ប្រតិបត្តិករ អាជីវករ ដើម្បី ពន្លឿន	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		ព័ត៌មានឬឯកសារពាក់ព័ន្ធ ដែលជាហេតុដំណើរការចុះស្រង់ ស្ថិតិនេះមានការអូសបន្លាយពេលយូរ	ដំណើរការ	
គ.២	ក្រុមហ៊ុន អាជីវកម្ម ឬប្រតិបត្តិកម្មដំនួញមួយចំនួន មិនមានច្បាប់ប្រកបអាជីវកម្ម	ក្រុមហ៊ុន អាជីវករ ឬប្រតិបត្តិករមួយចំនួន មិនទាន់មកចុះបញ្ជី ឬសុំច្បាប់ធ្វើអាជីវកម្ម ឲ្យបានត្រឹមត្រូវនៅឡើយ	(១)គួរបង្កើតក្រុមការងារបច្ចេកទេស ដែលមានសមាសភាពពាក់ព័ន្ធចុះផ្សព្វផ្សាយច្បាប់សុំធ្វើអាជីវកម្ម ដល់ក្រុមហ៊ុន អាជីវករ ឬប្រតិបត្តិករមួយចំនួន មិនទាន់បានសុំច្បាប់ និង (២)មានវិធានការដាក់ពិន័យ ចំពោះក្រុមហ៊ុន អាជីវករ ឬប្រតិបត្តិករ ដែលមិនព្រមមកបំពេញបែបបទអាជីវកម្មឲ្យបានត្រឹមត្រូវ តាមការកំណត់របស់ច្បាប់។	
១	ផលិតកម្មដំលផល និងកសិកម្មថយចុះ	កង្វះបច្ចេកទេស និងបច្ចេកវិទ្យា	រៀបចំឱ្យមានកញ្ចប់ថវិកាសម្រាប់ការស្រាវជ្រាវ	**ទីចាត់ការអន្តរវិស័យ**
		កង្វះកញ្ចប់ថវិកាស្រាវជ្រាវ និងមន្ទីរពិសោធន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ	បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ ឬមន្ទីរពិសោធន៍ផ្នែកកសិកម្ម សមុទ្រ...	
		កង្វះការវាយតម្លៃចំណាត់ថ្នាក់ដី	វាយតម្លៃចំណាត់ថ្នាក់ដីដែលមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ	
១	ការគ្រប់គ្រងសំណល់រឹងនៅមានកម្រិត ជាពិសេសបញ្ហាសំរាម	ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត និងកង្វះការផ្សព្វផ្សាយអំពីផលប៉ះពាល់នៃសំរាម	រៀបចំផែនការដោយឡែកសម្រាប់ការគ្រប់គ្រងសំណល់រឹង រាវខេត្តកោះកុង	
		កំណើនប្រជាជនយ៉ាងឆាប់រហ័ស		
		ការតាំងទីលំនៅឋាននៅលើខ្សែទឹក		
		កង្វះការកែច្នៃសំរាម និងភាគច្រើននៅលាយឡំគ្នា មិនបានញែកឱ្យបានត្រឹមត្រូវ		

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
២	ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ			
	បាតុភូតខ្យល់កន្ត្រាក់ ទឹកជំនន់ រលកកម្តៅកើនឡើង និងគ្រោះរាំងស្ងួត	ការកត់ត្រាទិន្នន័យបង្កមកពីគ្រោះធម្មជាតិមិនទាន់មានភាពជាក់លាក់ និងគ្រប់គ្រាន់នៅឡើយ	ដាក់បញ្ចូលទិន្នន័យទៅក្នុងរបាយការណ៍របស់រដ្ឋបាលខេត្ត	
		កង្វះផែនទីគ្រោះមហន្តរាយ	រៀបចំដំឡើងផែនទីគ្រោះមហន្តរាយ និងកំណត់ច្បាស់លាស់នូវសូចនាករសំខាន់ៗ ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ	
	កង្វះទឹកសាបប្រើប្រាស់នៅទីប្រជុំជន	ការផ្គត់ផ្គង់ទឹកប្រើប្រាស់នៅទីប្រជុំជនពឹងផ្អែកស្ទើតែទាំងស្រុងលើក្រុមហ៊ុនវិនិយោគឯកជន	ជីកស្រះសហគមន៍ អណ្តូង...	
		ប្រភពទឹកធម្មជាតិជាច្រើនត្រូវបានលុបដូចជា ស្រះ ត្រពាំង អណ្តូង ជាដើម ដោយពុំបានស្តារនិង/ឬជីកបន្ថែមនៅទីតាំងផ្សេងតាមកំណើននៃតម្រូវការ	ដំឡើងផែនទីទំនប់ទឹកប្រៃដែលមាននៅមូលដ្ឋានជាក់ស្តែង	
	ការជ្រាបចូលទឹកប្រៃ	ទំនប់ទឹកប្រៃពុំទាន់បានគ្របដណ្តប់តាមបណ្តោយឆ្នេរ ជាក់ស្តែងនៅឃុំជ្រោយស្វាយ		
៣	ការបាត់បង់ជម្រកធម្មជាតិ			
	ការរនេសាទហួសកម្រិត	ការបង្ក្រាបបទល្មើសនេសាទភាគច្រើនពឹងផ្អែកលើគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ	រៀបចំប្លង់គោលប្រើប្រាស់សមុទ្រខេត្ត	
	ការរនេសាទក្នុងជម្រកធម្មជាតិ	កង្វះមធ្យោបាយ និងថវិកាគាំទ្រ	រៀបចំយន្តការថ្នាក់ខេត្តសម្រាប់ការពិនិត្យទូកនេសាទ និងរដ្ឋ	

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		ប្រតិបត្តិការល្អាត	បាលមូលដ្ឋានសម្រាប់ការពិនិត្យឧបករណ៍នេសាទ	
	ការនេសាទប្រើឧបករណ៍ខុសច្បាប់	ប្រព័ន្ធតាមដានទូកនេសាទ និងឧបករណ៍នៅមិនទាន់មានប្រសិទ្ធភាព	ដាក់បញ្ចូលទិន្នន័យបទល្មើសនេសាទទៅក្នុងរបាយការណ៍របស់រដ្ឋបាលខេត្ត	
		ជនប្រព្រឹត្តល្មើសផ្លាស់ប្តូរវិធីសាស្ត្រថ្មីៗ និងមានឧបករណ៍ទំនើបៗ	រៀបចំដំឡើងផែនទីធនធានធម្មជាតិ និងជីវចម្រុះ	
		ការកត់ត្រាបទល្មើសមិនទាន់ជាក់លាក់ (ទំហំបាត់បង់ និងការខូចខាត)		
	ការកាប់ទន្ទ្រានព្រៃធម្មជាតិ ព្រៃលិចទឹក និងកោងកាង	កំណើនប្រជាជនតម្រូវការដីបង្កបង្កើនផល	រៀបចំដំឡើងផែនទីធនធានធម្មជាតិ និងជីវចម្រុះ	
		ទិន្នន័យជីវចម្រុះ និងធនធានធម្មជាតិមិនទាន់បានធ្វើបច្ចុប្បន្នភាព ឬមិនមានទិន្នន័យ	រៀបចំកំណត់តំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិនៅខេត្តទាំងអស់	
		ការរៀបចំប្លង់គោលប្រើប្រាស់ដីនៅមានកម្រិត និងមិនមានប្លង់គោលប្រើប្រាស់សមុទ្រ	ជំរុញការបង្កើត និងពង្រឹងការគ្រប់គ្រងសហគមន៍ការពារធម្មជាតិ និងសហគមន៍អេកូទេសចរណ៍	
		ព្រំប្រទល់តំបន់ការពារធម្មជាតិ និងការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិមិនទាន់បានកំណត់ច្បាស់លាស់	ស្នើសុំគ្រឿងឥស្សរិយសជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ផ្នែកការពារ និងអភិរក្សបរិស្ថាន	
		ចំនួនសហគមន៍ការពារធម្មជាតិមិនមានការកើនឡើង ការគ្រប់គ្រងនៅមានកម្រិត និងសមាជិកសហគមន៍		

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		ភាគច្រើនមានជីវភាពក្រីក្រ		
		មិនទាន់មានយន្តការលើកទឹកចិត្តមន្ត្រីអនុវត្តន៍ច្បាប់នៅតំបន់ដាច់ស្រយាល ឬប្រឈមខ្ពស់		
	ការទាញយកផលពីធនធានធម្មជាតិមិនប្រកបដោយចីរភាព	ការយល់ដឹងរបស់អ្នកពាក់ព័ន្ធក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅមានកម្រិត	ធ្វើបច្ចុប្បន្នភាព និងប្រមូលទិន្នន័យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន	
		ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនត្រូវបានផ្សព្វផ្សាយទូលំទូលាយ	រៀបចំយន្តការតាមដាន និងពង្រឹងការអនុវត្តរបស់ក្រុមហ៊ុនវិនិយោគឯកជន	
		យន្តការតាមដានអាជ្ញាប័ណ្ណដែលបានផ្តល់ឱ្យក្រុមហ៊ុនវិនិយោគឯកជននៅមានកម្រិត ឬមិនមានប្រសិទ្ធភាព និងមិនទាន់មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅឡើយ		
	ទិន្នន័យសំខាន់ៗសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិពិបាករក	សូចនាករបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលខេត្តពុំមានសូចនាករគ្រប់គ្រាន់នៅឡើយ	វិសោធនកម្មទម្រង់របាយការណ៍ប្រចាំឆ្នាំ ដោយដាក់បញ្ចូលសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ	**ទីចាត់ការអន្តរវិស័យ**
ទីចាត់ការផែនការនិងវិនិយោគ				
១	**ពង្រឹងសមត្ថភាពដល់មន្ទីរ អង្គភាព ក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងការរៀបចំផែនការទៅតាមសេចក្តីណែនាំថ្មី**	**តាមមន្ទីរអង្គភាព ក្រុង ស្រុក និងឃុំ សង្កាត់ មិនទាន់មានការយល់ដឹងពីរបៀបធ្វើផែនការ**	១.បណ្តុះបណ្តាស្តីពីរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិល ប្រចាំឆ្នាំរបស់ខេត្ត	ទីចាត់ការផែនការនិងវិនិយោគ
			២.បណ្តុះបណ្តាស្តីពីរៀបចំផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និង ក្រុមប្រឹក្សា	ទីចាត់ការផែនការនិងវិនិយោគ

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
			សង្កាត់	
			៣.ពិនិត្យនិងលើកអនុសាសន៍ជូនអភិបាលខេត្ត អំពីការធ្វើអនុលោមភាព ផែនការអភិវឌ្ឍន៍របស់ក្រុង ស្រុក ឃុំ និង សង្កាត់	ទីចាត់ការផែនការនិងវិនិយោគ
			៤.បណ្តុះបណ្តាស្តីពីរៀបចំរបាយការណ៍រីកចម្រើនទាក់ទងដល់ការងារផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបសខេត្ត	ទីចាត់ការផែនការនិងវិនិយោគ
			៥.វគ្គបណ្តុះបណ្តាលស្តីពីការធ្វើបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធនិងគម្រោងអភិវឌ្ឍនានា របស់ខេត្ត ក្រុង ស្រុក ឃុំ និង សង្កាត់	ទីចាត់ការផែនការនិងវិនិយោគ
			៦.សហការជាមួនមន្ទីរ អង្គភាព ទាក់ទងនឹងទិន្នន័យ ផែនទី និងសេចក្តីត្រូវការជាអាទិភាពរបស់ ខេត្ត ក្រុង ស្រុក ឃុំ និង សង្កាត់	ទីចាត់ការផែនការនិងវិនិយោគ
២	**ការរៀបចំដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគមិនបានពេញលេញ**	**ខ្វះការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ**	១.រៀបចំវេទិការពីគ្រោះយោបល់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត	ទីចាត់ការផែនការនិងវិនិយោគ
		ខ្វះកិច្ចសហការគាំទ្រ ដល់ក្រុង ស្រុក និងឃុំ សង្កាត់	២.គាំទ្រក្រុង ស្រុកក្នុងការរៀបចំសិក្ខាសាលាសមាហរណកម្មផែនការ	ទីចាត់ការផែនការនិងវិនិយោគ
៣	**សមត្ថភាពនិងចំនួនមន្ត្រីជំនាញក្រុង ស្រុក ឃុំ សង្កាត់នូវមានគមវិត**	**ខ្វះជំនាញសិក្សាគម្រោងនិងរៀបចំគម្រោង**	១.សិក្សាគម្រោងក្រុង ស្រុក ឃុំ សង្កាត់ រៀបចំប្លង ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោង ។	ទីចាត់ការផែនការនិងវិនិយោគ
			២.គ្រប់គ្រងកិច្ចសន្យា និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យានានាក្នុងកម្មវិធីវិនិយោគរបស់ខេត្ត	ទីចាត់ការផែនការនិងវិនិយោគ
ទីចាត់ការរដ្ឋបាល				
១	តាមមន្ទីរអង្គភាព និងក្រុង ស្រុកបញ្ជូល	តាមអង្គភាពនិមួយៗខ្វះការទទួល	១.ចេញសេចក្តីណែនាំដល់មន្ទីរអង្គភាព ក្រុង ស្រុក	ទីចាត់ការរដ្ឋបាល

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
	របាយការណ៍មកយឺត	ខុសត្រូវ		
		តាមតាមមន្ទីរអង្គភាព និងក្រុង ស្រុក មិនយល់ពីរបៀបបំពេញទម្រង់របាយការណ៍	២.បណ្តុះបណ្តាពីរបៀបធ្វើរបាយការណ៍ និងកំណត់ហេតុ	ទីចាត់ការរដ្ឋបាល
សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ				
១	ការចូលមកស្នាក់នៅ និងធ្វើការ ខុសច្បាប់ របស់ ជនបរទេស ។	• ជនបរទេសកាន់កាប់ប្រើប្រាស់ ឯកសាររដ្ឋបាលកម្ពុជា មិនប្រក្រតី ។ •ជនបរទេសស្នាក់នៅក្នុងខេត្ត ដោយគ្មានឯកសារសំគាល់ អត្តសញ្ញាណ និងលិខិតអនុញ្ញាតិផ្សេងៗ ។	បន្តអនុវត្តន៍ផែនការលេខ០១០ផ.ក របស់ក្រសួងមហាផ្ទៃ ដើម្បីចែកប្រកាសទទួលស្គាល់ជនបរទេស បែបអន្តោប្រវេសន៍គ្រប់អាយុ១៨ឆ្នាំ ណែនាំអោយមក សុំប្រកាសទទួលស្គាល់ និងអ្នកមានប្រកាសទទួល ស្គាល់អោយមកដាក់ពាក្យសុំសញ្ជាតិ តូបនីយកម្ម នាពេលខាងមុខ ។	ការិ.គ្រប់គ្រងជនបរទេស
២	ការផ្តល់/រាយការណ៍ទិន្នន័យបច្ចុប្បន្នភាព ពីវត្តមានរបស់ ជនបរទេស នៅមានកម្រិតនៅឡើយ ។	• ម្ចាស់ក្រុមហ៊ុន សហគ្រាស ម្ចាស់ផ្ទះជួល ផ្ទះសំណាក់ សណ្ឋាគារ ។ល។ នៅមានការលាក់លៀម ជនបរទេសដែលបម្រើការងារ និងស្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន ។	ជំរុញ និងពង្រឹងការគ្រប់គ្រងវត្តមានជនបរទេស រយៈពេលខ្លី និងវែង នៅតាមតំបន់ដែលមានជនបរទេសស្នាក់នៅ ។	ការិ.គ្រប់គ្រងជនបរទេស
៣	បទល្មើសឧក្រិដ្ឋ: ឃាតកម្ម រំលោភសេពសន្តវៈ និង បទល្មើសមជ្ឈឹម: អំពើលួច ហឹង្សាដោយចេត្តនា ហឹង្សាក្នុងគ្រួសារ ឆបោក រំលោភលើទំនុកចិត្ត នៅតែបន្ត កើតមាននៅក្នុងខេត្ត។	• ឥទ្ធិពលនៃការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង និង ការបើកលេងល្បែងស៊ីសងខុសច្បាប់ ។ល។ • ឧបករណ៍អេឡិចត្រូនិចចល័ត/អល័ត មានទូរស័ព្ទដៃទំនើប កុំព្យូទ័រ ។ល។ រួមផ្សំនិងការផ្សព្វផ្សាយរឿងអាសអាភាស ស្រើបស្រាលនៃវប្ប	ធ្វើការផ្សព្វផ្សាយអំពីច្បាប់ ក្រមព្រហ្មទ័ណ្ឌ និងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា ឲ្យដល់សហគមន៍ ។	ការិយាល័យកិច្ចការប៉ុស្តិ៍ន.ប.រដ្ឋបាល
			សហការជាមួយអធិការដ្ឋាននគរបាលក្រុង-ស្រុក និងបណ្តាស្ថាប័នពាក់ព័ន្ធ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាប ការបង្កបទល្មើសផ្សេងៗ ពីមុខសញ្ញាចាស់ ថ្មី ។	ផែនព្រហ្មទ័ណ្ឌ

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		ធម៌បទេសពាសពេញបណ្តាញទំនាក់ទំនងសង្គម ។ • ការយល់ដឹងរបស់ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិត ធ្វើឲ្យបង្កនូវអំពើហឹង្សា អំពើទុច្ចរិតផ្សេងៗ ។ល។		
៤	ការប្រើប្រាស់ ការរក្សាទុក និងការជួញដូរគ្រឿងញៀន សារធាតុញៀន ជាបញ្ហាក្តៅត្រូវដោះស្រាយ	• ប្រព័ន្ធផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន មិនទាន់បានទូលំទូលាយ ។ • ការអប់រំរបស់យុវជនមួយចំនួននៅមានកម្រិត • ច្បាប់នៅមានការធូរលុង សំរាប់ដាក់ទោស អ្នកចរាចរ ចែកចាយ និងជួញដូរគ្រឿងញៀនខុសច្បាប់ ។ល។	សហការជាមួយ អជ្ញាធរ នគរបាលក្រុង/ស្រុក ផ្សព្វផ្សាយពីច្បាប់ និងផលប៉ះពាល់នៃគ្រឿងញៀន និងបន្តចាត់វិធានការក្នុងការគ្រប់គ្រងមុខសញ្ញា ប្រើប្រាស់គ្រឿងញៀន មុខសញ្ញាលក់ដូរគ្រឿងញៀន និងមុខសញ្ញាដាំដុះរុក្ខជាតិញៀន ឬផលិតផលកែច្នៃនូវសារធាតិញៀនខុសច្បាប់ ។ល។	ការិ.ប្រឆាំងគ្រឿងញៀន
៥	ករណីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នៅតែកើតមាន ជាបន្តបន្ទាប់ មកដល់ពេលបច្ចុប្បន្ន ។	• ការយល់ដឹងពីច្បាប់ចរាចរណ៍ផ្លូវគោក របស់អ្នកបើកបរ នៅមានកម្រិត ។ • អ្នកបើកបរខ្លះ បើកបំពានច្បាប់ • ការបំពាក់ស្លាកសញ្ញា គំនូសសញ្ញាភ្លើងសញ្ញាចរាចរណ៍នៅតាមដងផ្លូវពិសេសនៅតំបន់ងាយនឹងបង្កគ្រោះថ្នាក់ បានតិចតួចនៅឡើយ ។ • បើកបរដោយការប្រើប្រាស់គ្រឿង	សហការជាមួយអធិការដ្ឋាននគរបាលក្រុង/ស្រុក ធ្វើការផ្សព្វផ្សាយតាមវិទ្យុ និងចែកឯកសារដែលពាក់ព័ន្ធ និងច្បាប់ចរាចរផ្លូវគោក តំបន់ផ្លូវដែលងាយបង្កឲ្យមានគ្រោះថ្នាក់ ។ល។ អោយដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និងអ្នកបើកបរនៅតាមដងផ្លូវ រួមនឹងការដាក់ប៉ុស្តិ៍ត្រួតពិនិត្យ ល្បឿនរថយន្ត កម្រិតគ្រឿង ស្រវឹង និងគ្រឿងញៀនជាដើម ។	ការិ.ចរាចរណ៍ផ្លូវគោក

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		ស្រវឹង និងគ្រឿងញៀន។		
៦	ការយកចិញ្ចើមថ្នល់ និងទីសាធារណៈមកប្រើប្រាស់មិនបានត្រឹមត្រូវ ។	• ប្រជាពលរដ្ឋមួយចំនួន មិនទាន់យល់ច្បាស់អំពីច្បាប់ នៃការប្រើប្រាស់ចិញ្ចើមថ្នល់ និងការទីសារធារណៈរបស់រដ្ឋ។ • ការបើកតូបលក់អាហារលក្ខណៈគ្រួសារ គ្មានច្បាប់ពិបាក គ្រប់គ្រង និងហាមឃាត ។ • ភាពធ្វេសប្រហែស និងការធូរលុងរបស់អ្នកអនុវត្តច្បាប់ នៅតាមបណ្តាមូលដ្ឋានរបស់ខ្លួន ។	ដាក់បទបញ្ជាយ៉ាងតឹងរឹងចំពោះ កម្លាំងជំនាញដែលពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋាន អោយខិតខំបំពេញតួនាទី ភារកិច្ចធ្វើការឃោសនា ផ្សព្វផ្សាយអនុក្រឹត្យ លេខ ០៤៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំសណ្តាប់ធ្នាប់ទូទាំងខេត្ត ឲ្យប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបានដឹងគ្រប់ៗគ្នា ។	ការិ.សណ្តាប់ធ្នាប់
៧	គ្រោះថ្នាក់អគ្គីភ័យ និងទំហំមហន្តរាយ បណ្តាល មកពីអគ្គិភ័យនៅក្នុងខេត្ត ។	• ប្រជាពលរដ្ឋមួយចំនួន មិនទាន់យល់ច្បាស់អំពីវិធីបង្ការ និងទប់ស្កាត់បឋមពីគ្រោះអគ្គីភ័យ ។ • ការធ្វេសប្រហែស ការតបណ្តាញអគ្គីសនីគ្មានបច្ចេកទេស • ការប្រែប្រួលអាកាសធាតុ ក្តៅខ្លាំង	បន្តពង្រឹងការផ្សព្វផ្សាយបទដ្ឋានស្តីពី ការទប់ស្កាត់ គ្រោះមហន្តរាយ ដោយសារអគ្គីភ័យ ដោយដល់មូលដ្ឋាន និង ត្រួតពិនិត្យ ការដាក់បំពង់ពន្លត់អគ្គីភ័យ នៅតាមតំបន់ដែលងាយបង្ករ គ្រោះអគ្គីភ័យបំផុត ។ ពិសេស ត្រៀមកម្លាំង ២៤ម៉ោង/២៤ម៉ោង ដើម្បីពន្លត់គ្រោះអគ្គីភ័យជូនប្រជាពលរដ្ឋអោយទាន់ពេលវេលា។	ការិ.បង្ការ សង្គ្រោះ និង ពន្លត់អគ្គីភ័យ
៨	ប្រជាពលរដ្ឋក្នុងខេត្ត មិនមានសៀវភៅស្នាក់នៅ (ក២) និង សៀវភៅគ្រួសារ (ក៨) ប្រើប្រាស់បានគ្រប់គ្នា	• ប្រជាពលរដ្ឋមួយចំនួន មិនបានធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងឯកសារបញ្ជាក់ផ្សេងៗ ។	បន្តពង្រឹងតួនាទី ភារកិច្ច របស់កម្លាំងជំនាញនៅតាមប៉ុស្តិ៍នគរបាលរដ្ឋបាល ផ្នែកធ្វើ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ជូនប្រជាពលរដ្ឋ ដូចជា ខូច បាត់បង់ និងធ្វើថ្មី អោយបានត្រឹមត្រូវ លឿន រហ័ស ។	ការិយាល័យគ្រប់គ្រងការស្នាក់នៅ

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		• ឯកសារមួយចំនួនខូច រឺក៏ បាត់បង់ មិនព្រមទៅធ្វើថ្មី ទាល់តែមានការចាំបាច់ណាមួយទើបមកធ្វើបន្ទាន់ ។ • យន្តការធ្វើសំបុត្រកំណើត និងឯកសារពាក់ព័ន្ធមួយចំនួនទៀត មានភាពសាំញ៉ាំច្រើន ធ្វើឲ្យប្រជាពលរដ្ឋពិបាកធ្វើ		
៩	អត្តសញ្ញាណប័ណ្ណដែល ខូច បាត់ ហួសសុពលភាព ធ្វើថ្មី និងយុវវ័យមានអាយុចាប់ពី ១៥ឡើងត្រូវធ្វើថ្មី ជាបន្តបន្ទាប់ ។	• ប្រជាពលរដ្ឋមួយចំនួន គ្មានសំបុត្រកំណើត និងឯកសារពាក់ព័ន្ធមួយចំនួនមិនច្បាស់លាស់ ដើម្បីយោងធ្វើអត្តសញ្ញាណប័ណ្ណ។ • ការធ្វេសប្រហែសរបស់ប្រជាពលរដ្ឋ ធ្វើអោយបាត់បង់ អត្តសញ្ញាណប័ណ្ណ ជាញឹកញាប់ ។ • យុវជនគ្រប់អាយុ១៥ឆ្នាំ និងប្រជាជនមួយចំនួនទៀត ដែលមិនធ្លាប់ធ្វើពីមុន ចាប់ផ្តើមមកធ្វើជាហូរហែរ ។	បន្តពង្រឹងតួនាទី ភារកិច្ច របស់កម្លាំងជំនាញនៅតាម អធិការដ្ឋាននគរបាលរដ្ឋបាលក្រុង/ស្រុក ត្រៀមខ្លួនគ្រប់ពេលវេលា ០៧ថ្ងៃ ក្នុងមួយសប្តាហ៍ ធ្វើអត្តសញ្ញាណប័ណ្ណ ជូនប្រជាពលរដ្ឋ ដូចជា ខូច បាត់បង់ និងធ្វើថ្មី អោយបានត្រឹមត្រូវលឿន រហ័ស។	ការិយាល័យស្ថិតិ អត្តសញ្ញាណប័ណ្ណ
១០	ពង្រឹងការ ការពារសន្តិសុខ សុវត្ថិភាព ជូនព្រះមហាក្សត្រ ឥស្សរជនជាន់ខ្ពស់ អ្នកការទូត ប្រជាពលរដ្ឋ និង ភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ ។	• ក្រុមឧទ្ទាមផ្តាច់ខ្លួនខាងក្នុង/ខាងក្រៅ និងជនខិលខូចមួយ ចំនួន អាចនឹងបង្កការអុកឡុក រំខានដល់សន្តិសុខ ការបំពេញបេសកម្មរបស់ព្រះមហាក្សត្រ និងរាជរដ្ឋបាលកម្ពុជា	ចាត់តាំងកម្លាំងនគរបាលការពារសុវត្ថិភាព ជួយសម្រួលចរាចរជូន ព្រះមហាក្សត្រ ឥស្សរជនជាន់ខ្ពស់ អ្នកការទូត និងថ្នាក់ដឹកនាំជាតិ/អន្តរជាតិ ដែលមកបំពេញបេសកកម្មក្នុងខេត្ត ឲ្យទទួលបានសុខសុវត្ថិភាព ១០០%	ការិ.អន្តរាគមន៍ និងតម្រួតបទបញ្ជា

ល.រ	បញ្ហា	មូលហេតុ	ដំណោះស្រាយ	អង្គភាពស្នើ
		• ក្រុមចោលួច ឆក់ ប្លន់ មួយក្តាប់តូច នៅតែសកម្មភាព • បញ្ហាក្មេងទំនើង បង្ហោះម៉ូតូ ដាក់បំពង់ស៊ីមុាំងបំពងសំឡេង រំខាន់ដល់ប្រជាពលរដ្ឋ		
		• ការឈ្លាតឱកាស កេងចំណេញ តម្លើងថ្លៃការស្នាក់នៅ ចំណីអាហារ ពីភ្ញៀវទេសចរណ៍ របស់អ្នកបំរើកម្មទេសចរណ៍ • រមនីយដ្ឋានខ្លះ មិនបានដាក់ ធុងសំរាមផ្លាកសញ្ញាបង្ហាញគ្រោះថ្នាក់នានា ។ល។ ដល់ភ្ញៀវទេសចរណ៍ ។ • ភ្ញៀវទេសចរណ៍មានបញ្ហាសុខភាព សុវត្ថិភាព ត្រូវបញ្ជូន ទៅរកសេវាព្យាបាល សង្គ្រោះ ។	ចាត់តាំងកម្លាំងនគរបាលទេសចរណ៍ សហការជាមួយស្ថាប័នពាក់ព័ន្ធ កម្លាំងនគរបាលអធិការដ្ឋាន/ប៉ុស្តិ៍រដ្ឋបាល ចុះត្រួត ពិនិត្យ ការផ្តល់សេវាកម្មរបស់អ្នកផ្តល់សេវាកម្មទេសចរណ៍ និងចុះល្បាតតាមតំបន់កំសាន្តនានា នៅពេលមានកម្មវិធីបុណ្យជាតិអន្តរជាតិ ដើម្បីការពារសុវត្ថិភាពជូនភ្ញៀវទេសចរណ៍ដែលមកកំសាន្ត ។	ការិយាល័យនគរបាលទេសរណ៍
១១	បញ្ឈប់ការជួញដូរមនុស្ស និងការពារអនីតិជន	• ការធ្វេសប្រហែសរបស់អាណាព្យាបាល • ការយល់ដឹងពីច្បាប់ការពារអនិតិជននៅមានកម្រិត • ប្រព័ន្ធផ្សព្វផ្សាយច្បាប់ការពារអនិតិជន និងការជួញដូរមនុស្ស នៅតំបន់ដាច់ស្រយោលមិនទាន់បានទូលំទូលាយ ។	ចុះបិទផ្សព្វផ្សាយខ្លឹមសារច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៅតាមគោលដៅសំខាន់ៗមួយចំនួនដែលដែលងាយប្រព្រឹត្តបទល្មើសនៅទូទាំងខេត្ត និងធ្វើកិច្ចសន្យាដល់ម្ចាស់គោលដៅ ប្រកបអាជីវកម្មទាំងនោះ មិនអោយមានការប្រព្រឹត្តអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវ ភេទជាដាច់ខាត ។	ការិ.ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

ឧបសម្ព័ន្ធធីពុះ

អនុក្រឹត្យនានា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៨៦...អនក្រ-៦៥

សាលាខេត្តកោះកុង
ចូល
លេខ: ៦៦៨៦
ថ្ងៃទី ៦៧ ខែ ៤៨៧ ឆ្នាំ ៦៦៧
បញ្ជូនមក.....

អនុក្រឹត្យ
ស្តីពី
ការបង្កើតដែនជម្រកសត្វព្រៃតាតៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រា១ .-

ត្រូវបានបង្កើតដែនជម្រកសត្វព្រៃតាតៃ ដែលមានផ្ទៃដីទំហំ ១៤៤.២៧៥(មួយសែនបួនម៉ឺនបួនពាន់ពីរយចិតសិបប្រាំ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា(Datum: WGS1984) ដូចខាងក្រោម៖

និយាមកាគោល								
ID	X	Y	ID	X	Y	ID	X	Y
1	333655	1237644	8	320129	1279197	15	279635	1285319
2	334628	1250482	9	313903	1290340	16	283583	1284835
3	333522	1251795	10	308904	1286907	17	287071	1283566
4	340217	1253730	11	290700	1296846	18	288602	1280862
5	337961	1273556	12	284697	1297036	19	297469	1270259
6	326102	1273573	13	280676	1294877	20	306046	1259132
7	311777	1267239	14	277886	1291385			

មាត្រា២ .-

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី ព្រមទាំងធានាឱ្យមានការបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ រុក្ខជាតិ និងជីវៈចម្រុះ
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

មាត្រា៣ .-

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងដែនជម្រកសត្វព្រៃតាតៃ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តកោះកុង ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

មាត្រា៤ .-

អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៤ ស្តីពីការបង្កើតតំបន់ព្រៃការពារសំរាប់អភិរក្សជីវចំរុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៣៧៣ ឆ្នាំ២០១៦

នាយកដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយកដ្ឋមន្ត្រី សូមហត្ថលេខា

ដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ធកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ជូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី ដែនជម្រកសត្វព្រៃ តាតៃ ស្ថិតក្នុងខេត្តកោះកុង

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០១៧

ខេត្តកោះកុង

ស្រុកមណ្ឌលសីមា

ស្រុកថ្មបាំង

ស្រុកខេមរភូមិន្ទ

ស្រុកកោះកុង

ស្រុកស្រែ អំបិល

ស្រុកបុទុមសាគរ

ស្រុកគិរីសាគរ

ID	X_Coord	Y_Coord
1	333655	1237644
2	334628	1250482
3	333522	1251795
4	340217	1253730
5	337961	1273556
6	326102	1273573
7	311777	1267239
8	320129	1279197
9	313903	1290340
10	308904	1286907
11	290700	1296846
12	284697	1297036
13	280676	1294877
14	277886	1291385
15	279635	1285319
16	283583	1284835
17	287071	1283566
18	288602	1280862
19	297469	1270259
20	306046	1259132

និយាមកាគោល

ព្រះរាជាណាចក្រកម្ពុជា

សញ្ញាសម្គាល់

- ចំណុចគោល
- ទីរួមខេត្ត
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ស្រុក
- ផ្លូវ
- តំបន់ការពារធម្មជាតិ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃតាតៃ

គម្របព្រៃឈើ ឆ្នាំ២០១៥

- ព្រៃស្រោង
- ព្រៃគម្ពោធ
- ព្រៃបឹស្សី
- ព្រៃកោងកាង
- វាលស្មៅ
- ទន្លេ បឹង

ផ្ទៃដី ដែនជម្រកសត្វព្រៃតាតៃ សរុប ១៤៤ ២៧៥ ហិកតា

Map Coordinate System:
Unit: meter
System: UTM, Zone 48
Datum: WGS 1984

0 5 10 km

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០១៧

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

បញ្ជាក់៖ ខ្សែបន្ទាត់ព្រំដែននៃផែនទីនេះពុំមានតម្លៃផ្លូវការជាអន្តរជាតិឡើយ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...

សាលាខេត្តកោះកុង
ចូល
លេខ: ...
ថ្ងៃទី...ខែ...ឆ្នាំ...
បញ្ជូនមក...

អនុក្រឹត្យ
ស្តីពី
ការបង្កើតឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រា១ .-

ត្រូវបានបង្កើតឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូងដែលមានផ្ទៃដីទំហំ ៤១០.៣៩២ (បួនរំសែនមួយម៉ឺនបីរយកៅសិបពីរ) ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា(Datum: WGS1984) ដូចខាងក្រោម៖

និយាមកាគោល								
ID	X	Y	ID	X	Y	ID	X	Y
1	273981	1327316	14	392984	1280722	27	338245	1261975
2	289919	1333614	15	397164	1270605	28	338380	1273233
3	302658	1330480	16	396883	1260635	29	326516	1273260
4	310863	1314848	17	388842	1249719	30	324454	1268412
5	311761	1301421	18	395784	1237104	31	312196	1266915
6	326392	1290679	19	379419	1234360	32	320548	1278873
7	336440	1297902	20	372030	1241816	33	314321	1290020
8	346038	1306077	21	365117	1255680	34	308914	1286427
9	351349	1294125	22	364174	1249016	35	291484	1296534
10	340987	1286035	23	359348	1250388	36	278560	1292143
11	351233	1273293	24	352763	1241328	37	271809	1306409
12	367052	1277948	25	341752	1244408			
13	377272	1288840	26	346315	1255323			

មាត្រា២ .-

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីរបស់តំបន់ដែលបានកំណត់សម្រាប់ជាផលប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងតួនាទីមុខងារនៃតំបន់នោះ
- ផ្តល់ជាមូលដ្ឋានសម្រាប់ការកំសាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះពុំបង្កការគំរាមកំហែងដល់បរិស្ថានធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

មាត្រា៣ .-

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងឧទ្យានជាតិជួរភ្នំក្រវាញត្បូង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តពោធ៍សាត់ និងខេត្តកំពង់ស្ពឺ ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

មាត្រា៤ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ១៧៧ ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ធកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ជូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី ឧទ្យានជាតិ ជួរភ្នំក្រវាញខាងត្បូង ស្ថិតក្នុងខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៩.អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ៣៤៧ ឆ្នាំ២០១៦



និយាមកាគោល		
ID	X	Y
1	273981	1327316
2	289919	1333614
3	302658	1330480
4	310863	1314848
5	311761	1301421
6	326392	1290679
7	336440	1297902
8	346038	1306077
9	351349	1294125
10	340987	1286035
11	351233	1273293
12	367052	1277948
13	377272	1288840
14	392984	1280722
15	397164	1270605
16	396883	1260635
17	388842	1249719
18	395784	1237104
19	379419	1234360
20	372030	1241816
21	365117	1255680
22	364174	1249016
23	359348	1250388
24	352763	1241328
25	341752	1244408
26	346315	1255323
27	338245	1261975
28	338380	1273233
29	326516	1273260
30	324454	1268412
31	312196	1266915
32	320548	1278873
33	314321	1290020
34	308914	1286427
35	291484	1296534
36	278560	1292143
37	271809	1306409



សញ្ញាសម្គាល់

- ចំណុចគោល
- ទីរួមខេត្ត
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ស្រុក
- ផ្លូវ
- តំបន់ការពារ និងព្រៃការពារ
- ព្រំប្រទល់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង

គម្របព្រៃឈើ ឆ្នាំ២០១៥

- ព្រៃស្រោង
- ព្រៃស្បោះ
- ព្រៃស្រល់
- ព្រៃគម្ពោធ
- ព្រៃប្រស្សី
- ព្រៃកោងកាង
- វាលស្មៅ
- ទន្លេ បឹង

ផ្ទៃដី ឧទ្យានជាតិ ជួរភ្នំក្រវាញខាងត្បូង សរុប ៤១០ ៣៥២ ហិកតា

Map Coordinate System:
Unit: meter
System: UTM, Zone 48
Datum: WGS 1984

0 10 20 km

N S E W

បញ្ជាក់៖ ខ្សែបន្ទាត់ព្រំដែននៃដែនទីនេះពុំមានតម្លៃផ្លូវការជាអន្តរជាតិទ្បើយ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៣៤៧ ឆ្នាំ២០១៦

ជ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៨១...អនក្រ.បក

សាលាខេត្តកោះកុង
ចូល
លេខ:...
ថ្ងៃទី...ខែ...ឆ្នាំ...
បញ្ជូនមក.....

អនុក្រឹត្យ
ស្តីពី
ការបង្កើតឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រា១ .-

ត្រូវបានបង្កើតឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ដែលមានផ្ទៃដីទំហំ ៤០១.៣១៣ (បួនសែនមួយពាន់បីរយដប់បី)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា(Datum: WGS1984) ដូចខាងក្រោម៖

និយាមកាគោល								
ID	X	Y	ID	X	Y	ID	X	Y
1	302246	1330806	14	366633	1278272	27	348773	1340824
2	311340	1301719	15	371451	1284900	28	347729	1342509
3	318398	1300809	16	376851	1289153	29	347226	1347470
4	324985	1295695	17	374781	1292207	30	346239	1349545
5	326362	1294875	18	374529	1309300	31	344393	1352278
6	325962	1291064	19	373286	1326361	32	344135	1353338
7	344184	1304987	20	370302	1334979	33	343841	1355758
8	345606	1306401	21	368424	1332849	34	342773	1359998
9	346904	1304778	22	364808	1333640	35	333527	1362699
10	350167	1301687	23	362012	1334553	36	323826	1365894
11	344069	1286886	24	358629	1329500	37	313904	1357440
12	340568	1286359	25	356018	1328962	38	309435	1358923
13	358513	1276581	26	354765	1339075			

មាត្រា២ .-

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីរបស់តំបន់ដែលបានកំណត់សម្រាប់ជាផលប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានដីរៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងតួនាទីមុខងារនៃតំបន់នោះ
- ផ្តល់ជាមូលដ្ឋានសម្រាប់ការកំសាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះពុំបង្កការគំរាមកំហែងដល់បរិស្ថានធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព

- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

មាត្រា៣ .-

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

មាត្រា៤ .-

អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារអភិរក្ស ដីជម្រាលជួរភ្នំក្រវាញភាគកណ្តាល និងដីវៈចំរុះ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិសាខ ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ស៊ាយ សំអាល់

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី ឧទ្យានជាតិ ជូរភ្នំក្រវាញកណ្តាល ស្ថិតក្នុងខេត្តកោះកុង ខេត្តពោធិសាត់ និងខេត្តកំពង់ស្ពឺ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៧



និយាមការគោល

ID	X_Coord	Y_Coord
1	302246	1330806
2	311340	1301719
3	318398	1300809
4	324985	1295695
5	326362	1294875
6	325962	1291064
7	344184	1304987
8	345606	1306401
9	346904	1304778
10	350167	1301687
11	344069	1286886
12	340568	1286359
13	358513	1276581
14	366633	1278272
15	371451	1284900
16	376851	1289153
17	374781	1292207
18	374529	1309300
19	373286	1326361
20	370302	1334979
21	368424	1332849
22	364808	1333640
23	362012	1334553
24	358629	1329500
25	356018	1328962
26	354765	1339075
27	348773	1340824
28	347729	1342509
29	347226	1347470
30	346239	1349545
31	344393	1352278
32	344135	1353338
33	343841	1355758
34	342773	1359998
35	333527	1362699
36	323826	1365894
37	313904	1357440
38	309435	1358923

ព្រះរាជាណាចក្រកម្ពុជា



សញ្ញាសម្គាល់

- ចំណុចគោល
- ទីរួមខេត្ត
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ស្រុក
- ផ្លូវ
- តំបន់ការពារធម្មជាតិ
- ព្រំប្រទល់ឧទ្យានជាតិជូរភ្នំក្រវាញកណ្តាល

គម្របព្រៃឈើ ឆ្នាំ២០១៥

- ព្រៃស្រោង
- ព្រៃល្បោះ
- ព្រៃស្រល់
- ព្រៃគម្អាត
- ព្រៃឫស្សី
- ព្រៃកោងកាង
- វាលស្មៅ
- ទន្លេ បឹង

Map Coordinate System:
Unit: meter
System: UTM, Zone 48
Datum: WGS 1984

0 10 20 km

ផ្ទៃដី ឧទ្យានជាតិ ជូរភ្នំក្រវាញកណ្តាល សរុប ៤០១ ៣១៣ ហិកតា

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៧

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

បញ្ជាក់៖ ខ្សែបន្ទាត់ព្រំដែននៃផែនទីនេះពុំមានតម្លៃផ្លូវការជាអន្តរជាតិឡើយ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៤.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតឧទ្យានជាតិសមុទ្រកោះរ៉ុង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតឧទ្យានជាតិកោះរុង
- លិខិតលេខ ១១៣២ សជណ.កស ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រា១ ៖

ត្រូវបានបង្កើតឧទ្យានជាតិសមុទ្រកោះរ៉ុងរួមមាន៖ កោះរ៉ុង កោះរ៉ុងសន្លឹម កោះកូន កោះតូច កោះតាទៀម កោះម្នាស់ក្រៅ កោះម្នាស់ក្នុង និងសមុទ្រជុំវិញ ដែលមានផ្ទៃសរុប ៥២.៤៤៨ (ប្រាំម៉ឺនពីរពាន់បួនរយសែសិបប្រាំបី) ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ និងខេត្តកោះកុង ដោយក្នុងនោះមានផ្ទៃដីទំហំ ៥.៣១១ (ប្រាំពាន់បីរយដប់មួយ) ហិកតា និងផ្ទៃទឹកសមុទ្រទំហំ ៤៧.១៣៧ (បួនម៉ឺនប្រាំពីរពាន់មួយរយសាមសិបប្រាំពីរ) ហិកតា ដូចមានផែនទីភ្ជាប់មកជាមួយឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ និងមាននិយាមកា (Datum: WGS1984) ដូចខាងក្រោម៖

និយាមកាគោល								
ID	X	Y	ID	X	Y	ID	X	Y
A	322200	1163660	E	297261	1197311	I	301700	1199941
B	314037	1163586	F	298019	1198464	J	304166	1199465
C	298284	1185597	G	299098	1199348	K	306049	1198612
D	296885	1195136	H	300134	1199772	L	311196	1196584
						M	318742	1192668

មាត្រា២ ៖

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សា និងការពារសោភ័ណភាពធម្មជាតិ វប្បធម៌ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះលើកោះ និងបរិវេណសមុទ្រជុំវិញ
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- រក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

មាត្រា៣ ៖

ផ្ទៃដីអនុក្រឹត្យតំបន់ឧទ្យានជាតិសមុទ្រកោះរ៉ុងនេះមិនបញ្ចូលដីកម្មសិទ្ធិឯកជន និងដីប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

មាត្រា៤ ..

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងឧទ្យានជាតិសមុទ្រកោះរ៉ុង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តព្រះសីហនុ និងខេត្តកោះកុង ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

មាត្រា៥ ..

ក្រសួងបរិស្ថានត្រូវកំណត់ និងបែងចែកដើម្បីការកាត់ឆ្វៀលផ្ទៃដីវិនិយោគ ដីលំនៅដ្ឋាន ដីស្រែ-ចំការ និងដីអាស្រ័យផលជាក់ស្តែងរបស់ប្រជាពលរដ្ឋ នៅលើកោះនានានៃឧទ្យានជាតិសមុទ្រកោះរ៉ុង ដោយអនុលោមតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

មាត្រា៦ ..

អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតឧទ្យានជាតិកោះរ៉ុង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៧ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៨ រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី -ឧទ្យានជាតិសមុទ្រកោះរ៉ុង- ស្ថិតក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង

ច្បាប់សម្គាល់ខ្នង នៃអនុប្រឹក្សជន ១៤ អនុម.បក ចុះថ្ងៃ ច្រហស្បតិ៍ ៨ កើត ខែ មាឃ ឆ្នាំរកា ឧស្ណីស ព.ស.២៥៦១ ឬត្រូវនឹងថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ២០១៨



ថ្ងៃ ច្រហស្បតិ៍ ៨ កើត ខែ មាឃ ឆ្នាំរកា ឧស្ណីស ព.ស.២៥៦១ ថ្ងៃច្រហស្បតិ៍ ៨ កើត ខែ មាឃ ឆ្នាំរកា ឧស្ណីស ព.ស.២៥៦១ ថ្ងៃ សុក្រ ២កើត ខែ ផាល្គុន ឆ្នាំរកា ឧស្ណីស ព.ស.២៥៦១

ខ្ញុំនែនៅក្រុងព្រះសីហនុ ថ្ងៃទី ២៦ ខែ ២មករា ឆ្នាំ២០១៨ ខ្ញុំនែនៅកោះកុង ថ្ងៃទី ២៧ ខែ ២មករា ឆ្នាំ២០១៨ ខ្ញុំនែនៅភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៨

អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ

យន្ត. ចិន

អភិបាល នៃគណៈអភិបាលខេត្តកោះកុង

ចិត្ត ឆ្លាត

ប្រធានក្រុមប្រឹក្សាបណ្តោះអាសន្ន

សាយ សំអាល់

សញ្ញាសម្គាល់

- ចំណុចទីយោងកាត
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ផ្នែកខាងលិចឧទ្យានជាតិសមុទ្រកោះរ៉ុង
- ព្រំប្រទល់ផ្នែកខាងកើតឧទ្យានជាតិសមុទ្រកោះរ៉ុង
- សមុទ្រ
- តំបន់រងគ្រោះ

តម្រុយព្រៃឈើឆ្នាំ២០១៤

- ព្រៃស្រោង
- ផ្ទៃដីពុំមានតម្រុយព្រៃឈើ

ផែនទី -ឧទ្យានជាតិសមុទ្រកោះរ៉ុង- សរុប ៥២.៤៩៨ ហិកតា

ឧបសម្ព័ន្ធទី៨៖

កំណត់ហេតុ
ស្តីពី
កិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣
របស់ក្រុមប្រឹក្សាខេត្តកោះកុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំណត់ហេតុ

ស្តីពី

កិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣
របស់ក្រុមប្រឹក្សាខេត្តកោះកុង

ថ្ងៃព្រហស្បតិ៍ ពីរកោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជពីរពាន់ប្រាំរយហុកសិបបី ត្រូវនឹងថ្ងៃទីប្រាំបួន ខែមេសា **ឆ្នាំពីរពាន់ម្ភៃ** វេលាម៉ោងប្រាំបីនិងសាមសិបនាទីព្រឹក នៅសាលមហោសស្រពខេត្តកោះកុង ក្រុមប្រឹក្សាខេត្តបានបើកកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣របស់ខ្លួន ស្របតាមប្រតិទិន និងលិខិតលេខ ១២០/២០ សជណ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០២០ របស់ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត ស្តីពីការផ្លាស់ប្តូរទីកន្លែងនៃកិច្ចប្រជុំសាមញ្ញលើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ភាយ សំរួម** ប្រធានក្រុមប្រឹក្សាខេត្តកោះកុង។

I- <u>ក្របខ័ណ្ឌប្រជុំ និងសមាសភាពចូលរួមប្រជុំ</u> ៖

ឯកឧត្តមប្រធាន និងឯកឧត្តម លោកជំទាវ សមាជិកក្រុមប្រឹក្សាខេត្ត ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនាថ្ងៃនោះមាន ចំនួន១៩រូប លើចំនួន១៩រូប (គ្រប់ក្របខ័ណ្ឌ កិច្ចប្រជុំអាចដំណើរការបាន)។

អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនាថ្ងៃនោះ មានវត្តមានលោកជំទាវ **មិថុនា ភូថង** អភិបាល នៃគណៈអភិបាលខេត្ត និងលោក **ផៃចូន ផ្លាមកេសន** អភិបាលរងខេត្ត លោក **អ៊ុក រ៉ាត្ថា** អភិបាលរងខេត្ត លោក **ស្រេង ហុង** អភិបាលរងខេត្ត លោក **សុខ សុទ្ធី** អភិបាលរងខេត្ត និងលោក **ង្វៃ សាវុធ** អភិបាលរងខេត្ត ដែលបានអញ្ជើញចូលរួមប្រជុំ។ ដោយឡែកលោកស្រី **ឈុន ង៉ាវុធ** អភិបាលរងខេត្ត បានសុំច្បាប់ឈប់សម្រាកដើម្បីព្យាបាលជំងឺ។

ក្នុងកិច្ចប្រជុំនាថ្ងៃនោះក៏មានការចូលរួមពីលោកប្រធានការិយាល័យប្រជាពលរដ្ឋ លោកនាយក នាយករងរដ្ឋបាល លោកនាយក នាយករងទីចាត់ការ ប្រធានអង្គភាពចំណុះសាលាខេត្ត លោកស្នងការរងនគរបាលខេត្ត លោកអនុប្រធានពន្ធនាគារខេត្ត លោក លោកស្រីប្រធាន អនុប្រធានមន្ទីរអង្គភាពនានាជុំវិញខេត្ត មន្ត្រីរាជការសាលាខេត្ត និងអស់លោក លោកស្រីដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនាថ្ងៃនោះសរុបរួមចំនួន៥៩រូប ដែលបានអញ្ជើញចូលរួមប្រជុំ (ដូចមានបញ្ជីវត្តមានជូនភ្ជាប់ជាមួយ)។

II- <u>របៀបវារៈនៃកិច្ចប្រជុំសាមញ្ញលើកទី១១ របស់ក្រុមប្រឹក្សាខេត្ត</u> ៖

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធាន បានមានមតិសំណេះសំណាល និងស្វាគមន៍ចំពោះវត្តមានរបស់ លោកជំទាវអភិបាលខេត្ត ឯកឧត្តម លោកជំទាវសមាជិកក្រុមប្រឹក្សាខេត្ត លោកអភិបាលរងខេត្ត និងលោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនាថ្ងៃនោះ បន្ទាប់មកឯកឧត្តមប្រធានបានជម្រាបជូនអំពីរបៀបវារៈ ជូនកិច្ចប្រជុំបានជ្រាបដូចខាងក្រោម ៖

១. ពិនិត្យ និងអនុម័ត លើសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញលើកទី១០ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង

២. របាយការណ៍ ស្តីពីសកម្មភាពការងាររបស់គណៈអភិបាលខេត្តកោះកុង គិតចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

៣. របាយការណ៍ ស្តីពីលទ្ធផលការងារប្រចាំខែមីនា ឆ្នាំ២០២០ និងទិសដៅបន្ត របស់ការិយាល័យប្រជាពលរដ្ឋខេត្តកោះកុង

៤. ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៩ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខេត្តកោះកុង

៥. ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំខែមីនា ឆ្នាំ២០២០ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខេត្តកោះកុង

៦. ពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ (២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) របស់រដ្ឋបាលខេត្តកោះកុង

៧. បញ្ហាផ្សេងៗ

III- <u>ការពិនិត្យ និងអនុម័ត</u> ៖

○ ***ពិនិត្យ និងអនុម័ត លើការផ្លាស់ប្តូរទីកន្លែង នៃកិច្ចប្រជុំសាមញ្ញលើកទី១១ ពីសាលប្រជុំ(ខ)សាលាខេត្តកោះកុង មកសាលមហោស្រពខេត្ត***

ដោយពិនិត្យឃើញថា ឯកឧត្តម លោកជំទាវ សមាជិកក្រុមប្រឹក្សាខេត្ត ពុំមានមតិយោបល់ពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីកន្លែងនៃកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត ពីសាលប្រជុំ(ខ)សាលាខេត្ត មកសាលមហោស្រពខេត្តវិញនោះ ឯកឧត្តមប្រធានបានស្នើសុំការអនុម័តដូចខាងក្រោម ៖

កិច្ចប្រជុំបានអនុម័តលើការផ្លាស់ប្តូរទីកន្លែងនៃកិច្ចប្រជុំចំនួន ៖ ១៩សំឡេង លើ១៩សំឡេង។

○ ***ពិនិត្យ និងអនុម័ត លើសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញ លើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង***

ឯកឧត្តម **ឈេង ធិ** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា ជារៀងរាល់ខែឃើញមានរបាយការណ៍របស់ គ.ក.ស.ក. ខេត្តដាក់បញ្ចូលក្នុងរៀបវារៈ ប៉ុន្តែខែនេះមិនឃើញមាន ដូច្នេះបើសិនជាមានរបាយការណ៍ យើងគួរដាក់បញ្ចូលក្នុងរបៀបវារៈដើម្បីឱ្យក្រុមប្រឹក្សាខេត្តបានជ្រាប។

លោកជំទាវ **សរ ស៊ីមអ៊ីម** សមាជិកក្រុមប្រឹក្សាខេត្ត បានជម្រាបជូនថា ពីដំបូងលោកជំទាវបានស្នើសុំដាក់របាយការណ៍ចូលទៅក្នុងសេចក្តីព្រាងរបៀបវារៈនេះដែរ ប៉ុន្តែដោយពិនិត្យឃើញថា សកម្មភាពការងារតិចតួចពេក ហើយម្យ៉ាងវិញទៀតក្នុងខែមីនានេះ ដោយសារតែបញ្ហាកូវីដ-១៩ផងនោះ ដូច្នេះហើយទើបមិនមានសកម្មភាពចុះទៅតាមមូលដ្ឋានដូចសព្វដងទេ អញ្ចឹងទេនៅខែក្រោយលោកជំទាវនឹងរាយការណ៍សរុបជូនក្រុមប្រឹក្សាខេត្តបានជ្រាប។

កិច្ចប្រជុំបានអនុម័តលើសេចក្តីព្រាងរបៀបវារៈចំនួន ៖ ១៩សំឡេង លើ១៩សំឡេង។

○ **<u>របៀបវារៈទី១</u> ៖ *ពិនិត្យ និងអនុម័តលើសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញលើកទី១០ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង***

ដោយពិនិត្យឃើញថា ឯកឧត្តម លោកជំទាវ សមាជិកក្រុមប្រឹក្សាខេត្ត ពុំមានមតិយោបល់ពាក់ព័ន្ធនឹងសេចក្តីព្រាងកំណត់ហេតុខាងលើនេះ ឯកឧត្តមប្រធានបានស្នើសុំការអនុម័ត ដោយមានសំឡេងគាំទ្រដូចខាងក្រោម ៖

កិច្ចប្រជុំបានអនុម័តលើរបៀបវារៈទី១ ៖ ១៩សំឡេង លើ១៩សំឡេង។

○ **<u>របៀបវារៈទី២</u> ៖ *របាយការណ៍ ស្តីពីសកម្មភាពការងាររបស់គណៈអភិបាលខេត្តកោះកុង គិតចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០***

ដោយបានការអនុញ្ញាតពីឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត លោក **ឡេង ប៊ុនឆេង** នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត បានអានទាំងស្រុងនូវខ្លឹមសាររបាយការណ៍លេខ ០៦៦/២០ រ.ប.ក ចុះថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ ជូនអង្គប្រជុំបានជ្រាប។

○ **<u>របៀបវារៈទី៣</u> ៖ *របាយការណ៍ស្តីពីលទ្ធផលការងារប្រចាំខែមីនា ឆ្នាំ២០២០ និងទិសដៅបន្ត របស់ការិយាល័យប្រជាពលរដ្ឋខេត្តកោះកុង***

ដោយបានការអនុញ្ញាតពីឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត លោក **សោម សុធីរ** ប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត បានអានទាំងស្រុងនូវខ្លឹមសារបាយការណ៍លេខ ០០៤/២០ រ.ប.ក ចុះថ្ងៃចន្ទ ៧រកើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ជូនអង្គប្រជុំបានជ្រាប។

លោកជំទាវ **សរ ស៊ីមអ៊ីម** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា ក្រោយពីបានស្តាប់នូវការសង្ខេបរបាយការណ៍របស់លោកប្រធានការិយាល័យប្រជាពលរដ្ឋខេត្តរួចមកឃើញថា ចំណុច២.២. ការទទួលពាក្យបណ្តឹង និងព័ត៌មានផ្សេងៗបាន០១ករណី ប៉ុន្តែជាក់ស្តែងក្នុងរបាយការណ៍សរសេរ ០(សូន្យ)ទៅវិញ សូមកែសម្រួល។ ចំណុច២.៣. ការសម្រុះសម្រួល និងដោះស្រាយបណ្តឹង ក៏ដូចគ្នាដែរ សូមកែសម្រួល។ ចំពោះចំណុច ខ) ការផ្តល់អនុសាសន៍ទៅលើបណ្តឹងលេខ ០០១ របស់លោកស្រី **សួន ចាន់ថុន** បានប្តឹងលោកប្រធានមន្ទីរកសិកម្មខេត្ត ដែលមិនព្រមជួលទីតាំងសត្វឃាតដ្ឋានឱ្យលោកស្រីធ្វើអាជីវកម្មបន្ត ហើយការិយាល័យប្រជាពលរដ្ឋខេត្តបានជួយសម្រុះសម្រួលដោះស្រាយ ដោយភាគីទាំងពីរបានព្រមព្រៀងឯកភាពគ្នាបញ្ចប់រឿងដោយសន្តិវិធីនោះ តើភាគីទាំងពីរត្រូវបញ្ចប់ដោយឱ្យគាត់ជួលបន្ត ឬមានដំណោះស្រាយណាមួយសមស្របទើបគាត់ព្រមបញ្ចប់រឿង?។

លោក **សោម សុធីរ** ប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត បានជម្រាបជូនថា ចំពោះចំណុច២.៣. ក្នុងការសម្រុះសម្រួល និងការដោះស្រាយបណ្តឹង ចំណុច ក)ការសម្រុះសម្រួល បន្ទាប់ពីយើងបានទទួលពាក្យបណ្តឹង គឺយើងដំណើរការសម្រុះសម្រួល រួចបញ្ចប់តែម្តង ដូច្នេះទើបសរសេរ ០(សូន្យ) ដោយឡែកចំណុច ខ) ការស៊ើបអង្កេត បន្ទាប់ពីយើងទទួលបានពាក្យបណ្តឹងហើយ យើងធ្វើការស៊ើបអង្កេត ក្នុងនោះកាលពីខែមុន កំពុងដំណើរការមានទិន្នន័យ១ អញ្ចឹងទេក្នុងខែថ្មីនេះកំពុងដំណើរការ០(សូន្យ) និងបានបញ្ចប់១។ ចំពោះការផ្តល់អនុសាសន៍ទៅលើបណ្តឹងលេខ ០០១ ដែលលោកជំទាវបានសួរខាងលើនេះ លោកសូមជម្រាបជូនថា ដោយកិច្ចការនេះយើងត្រូវលាក់ការណ៍ គឺមិនអាចបញ្ចេញអត្តសញ្ញាណ ឬលទ្ធផលពាក់ព័ន្ធនឹងការសម្រុះសម្រួល និងដោះស្រាយបណ្តឹងផ្សព្វផ្សាយទូលំទូលាយនោះទេ ប៉ុន្តែការិយាល័យប្រជាពលរដ្ឋខេត្ត បានចុះទៅធ្វើកិច្ចការនេះដោយផ្ទាល់ មានទាំងរបាយការណ៍ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរដោយតម្រូវឱ្យរាយការណ៍ជូនចំពោះតែឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត និងលោកជំទាវអភិបាលខេត្តតែប៉ុណ្ណោះ។

ឯកឧត្តម **ភាយ សំរួម** ប្រធានក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា ជាការពិតណាស់ ដូចអ្វីដែលលោកប្រធានការិយាល័យប្រជាពលរដ្ឋបានលើកឡើងខាងលើនេះរួចហើយ គឺក្នុងរបាយការណ៍ដែលយកមកអានជូនក្រុមប្រឹក្សាខេត្តបានជ្រាបនេះ វាមិនមានព័ត៌មានលំអិតនោះទេ គ្រាន់តែចង់បញ្ជាក់អំពីបញ្ហាដែលបានកើតមានជូនអង្គប្រជុំបានជ្រាបតែប៉ុណ្ណោះ ប៉ុន្តែអ្វីដែលជាលទ្ធផលបានបង្ហាញនោះ គឺនៅក្នុងកំណត់ហេតុរបស់ការិយាល័យប្រជាពលរដ្ឋ ដែលបានចុះទៅធ្វើការសម្រុះសម្រួល និងដោះស្រាយផ្ទាល់ ដែលលទ្ធផលនៃការសម្រុះសម្រួលនោះ យើងត្រូវនៅរង់ចាំនីតិវិធីរបស់ក្រសួងធ្វើការណែនាំបន្តទៀត។

ឯកឧត្តម **លី សារ៉ែត** សមាជិកក្រុមប្រឹក្សាខេត្ត បានពិនិត្យឃើញថា នៅក្នុងចំណុច ២.៣. ការសម្រុះសម្រួលនិងការដោះស្រាយបណ្តឹង ក្នុងនោះមានចែកជាពីរចំណុចទៀត គឺចំណុច ១). ជាបណ្តឹងក្នុងសមត្ថកិច្ច និងចំណុច ២). បណ្តឹងក្រៅសមត្ថកិច្ច ដែលបណ្តឹងក្នុងសមត្ថកិច្ចឃើញថា ទិន្នន័យក្នុងខែមាន១ ចំណែកឯបណ្តឹងក្រៅសមត្ថកិច្ច ទិន្នន័យក្នុងខែ០(សូន្យ) ប៉ុន្តែសរុបរួម(១+២)ឃើញថា ទិន្នន័យក្នុងខែ០(សូន្យ) ហើយបូកយោងមានចំនួន១ ដែលចំណុចនេះឯកឧត្តមស្នើសុំឱ្យលោកប្រធានការិយាល័យប្រជាពលរដ្ឋជួយបំភ្លឺបន្ថែម។

លោក **សោម សុធីរ** ប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត បានជម្រាបជូនថា នៅក្នុងខែនេះ ទាំងពាក្យបណ្តឹង ទាំងព័ត៌មាន គឺការិយាល័យប្រជាពលរដ្ឋពុំទទួលបាននោះទេ ប៉ុន្តែនៅក្នុងនោះបូកយោងមាន១ គឺជាទិន្នន័យយោងតាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០មក ហើយបើខែក្រោយនៅតែពុំទទួលបានពាក្យបណ្តឹង និងព័ត៌មានផ្សេងៗទៀតនោះគឺបូកយោងនៅតែមានចំនួន១ដដែល។

○ <u>**របៀបវារៈទី៤**</u> ៖ ***ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៩ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខេត្តកោះកុង***

ឯកឧត្តម **ភាយ សំរួម** ប្រធានក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា របាយការណ៍នេះគឺជារបាយការណ៍ឆ្នាំ ២០១៩ទេ ដោយមានការឆ្លងនីតិវិធីច្រើនរហូតដល់ឆ្លងនៅក្នុងសន្និបាតរបស់រដ្ឋបាលខេត្តយើងទៀត ក្នុងនោះយើងបានចូលរួមទាំងអស់គ្នា ដោយធ្វើការបែងចែកក្រុមពិភាក្សាជា០៣ក្រុម ដែលមានសមាសភាពមន្ទីរជំនាញ៣ក់ព័ន្ធចូលរួមក្នុងការផ្តល់ជាយោបល់ ដូច្នេះហើយវាជាប្រការល្អមួយដែលបង្កលក្ខណៈងាយស្រួលដល់ក្រុមប្រឹក្សាខេត្តក្នុងការពិនិត្យ និងអនុម័តនៅក្នុងថ្ងៃនេះ។

ឯកឧត្តម **អ៊ុច ឥណា** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា របាយការណ៍នេះឃើញថាល្អប្រសើរហើយ ប៉ុន្តែអ្វីដែលឯកឧត្តមចាប់អារម្មណ៍ គឺឧបសម្ព័ន្ធបញ្ជីទ្រព្យសម្បត្តិខេត្តដែលភ្ជាប់ខាងក្រោយរបាយការណ៍នេះ ឃើញថា មានសម្ភារៈបរិក្ខាមួយចំនួនមិនទាន់បានជម្រះ ឬកាត់ចេញនៅឡើយ ខ្លះទីតាំងនៅសាលាសង្កាត់ ខ្លះនៅសាលាខេត្តចាស់ ឬនៅបុគ្គលដែលបានចេញពីអង្គភាពចាស់ទៅហើយ ដូច្នេះបញ្ហានេះយើងគួរតែធ្វើបច្ចុប្បន្នភាពឱ្យបានត្រឹមត្រូវឡើងវិញ។

លោក **ឃុន ប៊ុណ្ណាត** នាយកទីចាត់ការហិរញ្ញវត្ថុ បានជម្រាបជូនថា ឆ្នាំកន្លងមកយើងមិនទាន់ធ្វើការជម្រះចេញពីបញ្ជីសារពើភ័ណ្ឌនៅឡើយ ប៉ុន្តែចំពោះមុខក្នុងឆ្នាំ២០២០នេះ លោកបានឱ្យការិយាល័យគ្រប់គ្រងទ្រព្យរដ្ឋ ចុះពិនិត្យទីតាំងជាក់ស្តែង ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌឱ្យបានត្រឹមត្រូវឡើងវិញ។

លោកជំទាវ **ឈី ន៉ា** សមាជិកក្រុមប្រឹក្សាខេត្ត បានពិនិត្យឃើញនៅក្នុងចំណុច ៣.១.១៥. ការងារទេសចរណ៍ ចំណុចត្រែទី៤ ពាក់ព័ន្ធនឹងការបន្តជូនអាជ្ញាប័ណ្ណដល់អាជីវករចំនួន៧១កន្លែង ប៉ុន្តែទិន្នន័យដែលរាយលំអិតបូកទៅបានត្រឹមតែចំនួន៦៨កន្លែងប៉ុណ្ណោះ និងចំណុចត្រែទី១ ក្នុងទំព័រទី៦០ ទាក់ទងនឹងការចេញលិខិតអនុញ្ញាតសាងសង់ ក្នុងនោះបានចេញចំនួន៣១គម្រោង ប៉ុន្តែទិន្នន័យលំអិតយើងបូកទៅបានត្រឹមតែចំនួន៣០គម្រោងប៉ុណ្ណោះ ដូច្នេះចំណុចទាំងពីរនេះលោកជំទាវស្នើសុំឱ្យក្រុមការងារធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ។ លោកជំទាវស្នើសុំឱ្យអង្គប្រជុំចាប់អារម្មណ៍ទៅលើផ្នែកទី៤ នៃបញ្ហាប្រឈម និងដំណោះស្រាយនៅក្នុងរបាយការណ៍នេះ ក្នុងនោះមានមន្ទីរ អង្គភាពមួយចំនួន គាត់សរសេរថា បញ្ហាប្រឈមគឺពុំមាន ហើយដំណោះស្រាយក៏ពុំមានដែរ ដូច្នេះការអនុវត្តន៍ការងាររយៈពេលមួយឆ្នាំលោកជំទាវគិតថា ពុំមានមន្ទីរអង្គភាពណាមួយដែលគ្មានបញ្ហាប្រឈមទល់តែសោះនោះទេ គឺវាត្រូវតែមាន អាចមានតិចឬមានច្រើន ជាក់ស្តែងដូចជាការងារគ្រប់គ្រងធនធានមនុស្ស នៅក្នុងបញ្ហាប្រឈមគាត់សរសេរពុំមាន ដំណោះស្រាយក៏ពុំមានដែរ ប៉ុន្តែបញ្ហានេះលោកជំទាវសូមទាញចំណាប់អារម្មណ៍ថា កន្លងមកទីចាត់ការនេះធ្លាប់ចេញដីកាតែងតាំងមន្ត្រីដែលក្នុងដីកានេះមានយើងកិច្ចប្រជុំសម្រេចរបស់គណៈអភិបាលដោយកំណត់កាលបរិច្ឆេទច្បាស់លាស់ហើយ ប៉ុន្តែទុករហូតដល់រយៈពេលជាច្រើនថ្ងៃទើបដាក់ជូនលោកជំទាវចុះហត្ថលេខា តើបញ្ហានេះវាខុសពីការណែនាំដែរទេ អញ្ចឹងទេទាំងនេះគឺជាបញ្ហាប្រឈមហើយ បើតាមគំនិតលោកជំទាវគិតថា បញ្ហាប្រឈមនេះអាចមកពីខ្វះមន្ត្រី ឬការិយាធិបតេយ្យច្រើនពេក? ឬដាក់ឆ្លងក្នុងការត្រួតពិនិត្យច្រើនដំណាក់ពេក ឬថ្នាក់ដឹកនាំពុំមានពេលក្នុងការពិនិត្យ និងចុះហត្ថលេខា? ដូច្នេះសម្រាប់លោកជំទាវ បើទោះបីជាក្នុងហេតុផលណាមួយក៏ដោយ ទាំងនេះគឺជាបញ្ហាប្រឈមដែលយើងអាចដាក់បញ្ចូលក្នុងរបាយការណ៍បាន។ ចំពោះការងារហិរញ្ញ និងការងារលទ្ធកម្មសាលាខេត្ត គឺដាក់ពុំមានដូចគ្នា ប៉ុន្តែសម្រាប់លោកជំទាវបានឮជាញឹកញាប់ពាក់ព័ន្ធនឹងការរៀបចំថវិកាបេសកកម្មមានការយឺតយ៉ាវ អញ្ចឹងទេលោកជំទាវសួរថា តើបញ្ហាហ្នឹងយើងអាចដាក់បញ្ចូលទៅក្នុងបញ្ហាប្រឈមបានដែរឬអត់? ហើយចំពោះការងារលទ្ធកម្ម លោកជំទាវស្នើសុំឱ្យលោកប្រធានអង្គភាពលទ្ធកម្មពិនិត្យមើល ថាតើយើងខ្វះធនធានដែរឬទេ? ឬពិនិត្យទៅលើកិច្ចការឯកសារផ្សេងៗ បើសិនជាមានបញ្ហាអ្វីអាចដាក់បញ្ចូលក្នុងបញ្ហាប្រឈមបាន ដើម្បីយើងមានមូលដ្ឋានក្នុងការស្នើសុំនូវដំណោះស្រាយពីថ្នាក់ដឹកនាំ។ ដោយឡែកចំពោះមន្ទីរអង្គភាពមួយចំនួន គាត់មិនមានបញ្ហាប្រឈមតែម្តង ឬមួយគាត់មិនបានបញ្ជូនទិន្នន័យមកសាលាខេត្ត ឬមួយបានបញ្ជូនហើយ ប៉ុន្តែមន្ត្រីបូកសរុបមិនបានដាក់បញ្ចូល? ក្នុងនោះមានមន្ទីរពាណិជ្ជកម្ម ការងារគយនិងរដ្ឋាករ ការងារពន្ធដារ ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការងារគ្រប់គ្រងជនអន្តោប្រវេសន៍ ដែលក្នុងបញ្ហាប្រឈមសរសេរថា "ពុំមាន" ដោយឡែកមន្ទីរអភិវឌ្ឍន៍ជនបទ មានបញ្ហាប្រឈមមួយ ប៉ុន្តែដំណោះស្រាយសរសេរថា "ពុំមាន"។

លោក **សេខ ជាវ៉ា** នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស បានជម្រាបជូនថា ចំពោះសំណួរដែលបានលើកឡើងថា ការដាក់ចេញដីកាដែលមានបេក្ខជនរួចហើយ ហេតុអ្វីទើបប្រើពេលវេលាយូរក្នុងការដាក់ចេញ? ដែលបញ្ហានេះលោកបញ្ជាក់ជូនថា ក្នុងឆ្នាំ២០១៩ គឺជាព្រឹត្តិការណ៍មួយដែលមានបញ្ហាថ្មីៗច្រើនពាក់ព័ន្ធនឹងការងារបុគ្គលិក ជា**ពិសេសពាក់ព័ន្ធទៅនឹងទម្រង់ដីកា** ដែលមកទល់នឹងពេលនេះលោកបានទៅប្រជុំនៅក្រសួងមហាផ្ទៃ៣ដងហើយ **គឺពុំទាន់**មានទម្រង់ដីកាណាមានលក្ខណៈស្តង់ដារទូទាំងប្រទេសនៅឡើយទេ ចំពោះការរៀបចំទម្រង់ដីកា ក្រោយពេលដែលយើងរៀបចំហើយ យើងសុំគោលការណ៍ឯកភាពពីក្រសួងមហាផ្ទៃ ព្រោះការផ្ទេរ ការប្រតិកូតម្មមក គឺមានលក្ខណៈថ្មីៗច្រើន ដូច្នេះហើយទើបមានការយឺតយ៉ាវមួយចំនួនទៅលើការងារបច្ចេកទេសបែបនេះ។

លោកជំទាវ **ឈី ឆ័ា** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា អ្វីដែលលោកជំទាវលើកឡើងពីខាងដើមពាក់ព័ន្ធនឹងការចេញដីកានោះ គឺវាគ្រាន់តែជាឧទាហរណ៍ទេ អញ្ចឹងក្រោយពីការបញ្ជាក់ជូនរបស់លោកនាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សឃើញថា យើងមានបញ្ហាប្រឈមហើយ ដូច្នេះយើងគួរតែដាក់បញ្ចូលបញ្ហាទាំងនោះទៅក្នុង**របាយការណ៍ ដើម្បីយើងមានមូលដ្ឋានក្នុងការស្នើសុំនូវដំណោះស្រាយ** ព្រោះការដែលលោកជំទាវលើកឡើង**ពាក់ព័ន្ធនឹង**ការចេញដីកានេះ ដោយសារថា វាពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់មន្ត្រី បើកាលណាយើងយឺតយ៉ាវក្នុងការចេញដីកានោះមន្ត្រីយើងគាត់ក៏បាត់បង់ផលប្រយោជន៍របស់គាត់ដែរ។

លោក **លី ឥត្ថាខាន់** អនុប្រធានមន្ទីរទេសចរណ៍ បានជម្រាបជូនថា ចំពោះចំណុច ៣.១.១៥. ការងារទេសចរណ៍ ចំណុចត្រទី៤ ពាក់ព័ន្ធនឹងការបន្តជូនអាជ្ញាប័ណ្ណដល់អាជីវករចំនួន៧១កន្លែង ប៉ុន្តែទិន្នន័យដែលរាយលំអិតបូកទៅបានត្រឹមតែចំនួន៦៨កន្លែងដែលលោកជំទាវបានលើកឡើងនោះឃើញថា ទិន្នន័យនេះមិនត្រឹមត្រូវទេ ទិន្នន័យត្រឹមត្រូវចំនួន៧២កន្លែង ដូច្នេះនេះប្រហែលមកពីកំហុសបច្ចេកទេសរបស់មន្ត្រីបូកសរុបហើយ។

លោក ឃុន ប៊ុណ្ណាត នាយកទីចាត់ការហិរញ្ញវត្ថុ បានជម្រាបជូនថា **ចំពោះបញ្ហារបសកកម្មដែលកន្លងមកវាពិតជាមានបញ្ហាប្រាកដមែន** ប៉ុន្តែថ្មីៗនេះ មន្ត្រីការិយាល័យគណនេយ្យ បានខិតខំ និងជម្រុញការងារនេះដើម្បីទូទាត់បានឆាប់រហ័ស ដោយឡែកចំពោះឯកសារទូទាត់ដែលត្រូវបំពេញ ហើយមានការយឺតយ៉ាវនោះ គឺមានតិចតួចប៉ុណ្ណោះ។

លោកជំទាវ **ឈី ឆ័ា** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា ក្នុងពេលបច្ចុប្បន្ននេះលោកបានដោះស្រាយរួចរាល់ហើយ នៅសល់តិចតួចប៉ុណ្ណោះ ប៉ុន្តែនេះជារបាយការណ៍ប្រចាំឆ្នាំ២០១៩ ដូច្នេះលោកនាយកទីចាត់ការហិរញ្ញវត្ថុ គួរតែដាក់បញ្ចាប្រឈមបញ្ចូលទៅក្នុងរបាយការណ៍ ព្រោះកន្លងមកយើងដឹងហើយថា ការងារហិរញ្ញវត្ថុវាមានបញ្ហាប្រឈមអ្វីខ្លះ ដើម្បីស្នើសុំឱ្យថ្នាក់លើដោះស្រាយជូន។

លោក ឃុន ប៊ុណ្ណាត នាយកទីចាត់ការហិរញ្ញវត្ថុ បានជម្រាបជូនថា ការរៀបចំរបាយការណ៍**ឆ្នាំ២០១៩នេះ**លោកបានឱ្យលោកនាយករងទីចាត់ការលោក ជាអ្នកចូលរួមពិនិត្យ និងលើកឡើងនៅក្នុងកិច្ចប្រជុំ ប៉ុន្តែចំពោះមុខគឺមិនឃើញមានការរាយការណ៍ជូនលោក ឬដាក់បញ្ចូលបញ្ហាអ្វីចូលទៅក្នុងរបាយការណ៍នោះទេ ដូច្នេះក្នុងឆ្នាំ**២០១៩ ទីចាត់**ការហិរញ្ញវត្ថុមានបញ្ហាប្រឈមខ្លះៗដែរ ទី១.ការទូទាត់ប្រាក់បេសកកម្មមានការយឺតយ៉ាវ ដោយសារខ្វះថវិកា និង**ទី២.ខ្វះ**មន្ត្រីបំពេញការងារតែម្តង។

លោកជំទាវ **ឈី ឆ័ា** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា សម្រាប់លោកជំទាវផ្ទាល់ **អ្វីដែលលោក**នាយកទីចាត់ការហិរញ្ញវត្ថុបានបញ្ជាក់ជូនខាងលើនេះ វាគឺជាបញ្ហាប្រឈមហើយ ដូច្នេះលោកគួរតែដាក់បញ្ហាទាំងពីរខាងលើនេះចូលទៅក្នុងរបាយការណ៍ ដើម្បីឱ្យថ្នាក់ដឹកនាំមានវិធានការក្នុងការដោះស្រាយជូន។

លោក **ឃុន ប៊ុណ្ណាត** នាយកទីចាត់ការហិរញ្ញវត្ថុ សូមឯកភាពតាមប្រសាសន៍លោកជំទាវ ដោយ**ស្នើសុំដាក់**បញ្ចូលបញ្ហាប្រឈមពាក់ព័ន្ធនឹងការខ្វះមន្ត្រីដើម្បីបំពេញការងារ នៅក្នុងរចនាសម្ព័ន្ធទីចាត់ការហិរញ្ញវត្ថុ ចូលទៅក្នុងរបាយការណ៍នេះ។

លោក **លឹម សាខាន់** នាយករដ្ឋបាលសាលាខេត្ត បានមានប្រសាសន៍គាំទ្រចំពោះការលើកឡើងរបស់លោកជំទាវសមាជិកក្រុមប្រឹក្សាខេត្ត ដែលថា គ្រប់មន្ទីរអង្គភាពទាំងអស់ មិនអាចមានមន្ទីរអង្គភាពណាមួយដែលថាគ្មានបញ្ហា

ប្រឈមនោះទេ ដែលចំណុចនេះលោកនាយកសូមទទួលយក ហើយចំពោះមន្ទីរអង្គភាពដែលមិនបានបញ្ចូលបញ្ហាប្រឈមដូចដែលលោកជំទាវបានលើកឡើងនោះ លោកសូមធ្វើការទំនាក់ទំនងទៅមន្ទីរអង្គភាពទាំងនោះ ដើម្បីពិនិត្យ និងកែសម្រួល ជាពិសេសបំពេញនូវចំណុចខ្វះខាតទាំងនោះឱ្យបានល្អប្រសើរឡើងវិញ។

កិច្ចប្រជុំបានអនុម័តលើរបៀបវារៈទី៤ ៖ ១៩សំឡេង លើ១៩សំឡេង។

○ **<u>របៀបវារៈទី៥</u>** ៖ ***ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំខែមីនា ឆ្នាំ២០២០ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខេត្តកោះកុង***

ឯកឧត្តម **ញ៉ែម ដារ៉ា** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា ក្នុងសេចក្តីព្រាងរបាយការណ៍ប្រចាំខែមីនានេះ ក៏មិនខុសគ្នាពីរបាយការណ៍ប្រចាំឆ្នាំដែរ ឃើញថា ការងារអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺពុំមានបញ្ហាប្រឈមទេ ប៉ុន្តែបញ្ហានេះ កាលសន្និបាតរបស់រដ្ឋបាលខេត្តកន្លងទៅ យើងបានបែងចែកក្រុមពិភាក្សាចេញជា៣ក្រុម ដែលក្រុមរបស់ឯកឧត្តមសម្របសម្រួលដោយលោក **ស្រេង ហុង** អភិបាលរងខេត្ត ក្នុងនោះយើងបានរកឃើញនូវបញ្ហាជាច្រើន៣ក់ព័ន្ធនឹងបញ្ហាខាងលើនេះ។ ចំពោះការគ្រប់គ្រងជនអន្តោប្រវេសន៍ ឃើញថាពុំមានបញ្ហាប្រឈមដែរ ប៉ុន្តែបញ្ហានេះយើងដឹងហើយថា ជនអន្តោប្រវេសន៍ដែលចូលមករស់នៅក្នុងប្រទេសកម្ពុជា គឺក្រុមការងារបានធ្វើជំរឿនតាំងពីឆ្នាំ២០០២ និងឆ្នាំ២០១៤-២០១៥ ដោយកំណត់ចំនួនគ្រួសារ និងចំនួនមនុស្សច្បាស់លាស់ អញ្ចឹងអ្នកដែលមានឈ្មោះទើបអាចរៀបចំបែបបទចូលជាជនអន្តោប្រវេសន៍ស្របច្បាប់បាន ហើយក្នុងនោះក៏មានបញ្ហាប្រឈមច្រើនផងដែរ ដោយសារថាចំនួនជនអន្តោប្រវេសន៍ដែលមាននៅក្នុងបញ្ជីរួចហើយនោះ បានផ្លាស់ប្តូរទីលំនៅ ជនបរទេសមួយចំនួននៅទទួលស្គាល់ថាខ្លួនឯងជាជនជាតិខ្មែរដោយសារតែកាន់ឯកសារខ្មែរមួយចំនួនដែលមិនត្រឹមត្រូវនោះ បានគេចវេសមិនចូលមកបំពេញបែបបទចូលជាជនអន្តោប្រវេសន៍ស្របច្បាប់នោះទេ។

លោក **ឈឹម សាខាន់** នាយករដ្ឋបាលសាលាខេត្ត បានមានប្រសាសន៍ថា ការមិនបានបំពេញបញ្ហាប្រឈមនៅក្នុងរបាយការណ៍ឆ្នាំ២០១៩ដែលក្រុមប្រឹក្សាខេត្តបានអនុម័តហើយនោះ វាជារឿងខ្វះចន្លោះក៏ពិតមែន ប៉ុន្តែសម្រាប់របាយការណ៍ប្រចាំខែមីនា ឆ្នាំ២០២០នេះ មុនដំណើរការកិច្ចប្រជុំក្រុមប្រឹក្សា លោកបានអញ្ជើញមន្ទីរអង្គភាព៣ក់ព័ន្ធទាំងអស់ មកប្រជុំពិនិត្យលើកិច្ចការទាំងនេះ ដូច្នេះសម្រាប់ខែមីនានេះ មន្ត្រីជំនាញលោកបញ្ជាក់ជូនយ៉ាងច្បាស់ថា ការងារអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និងការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺពុំមានបញ្ហាប្រឈមនោះទេ ដូច្នេះសូមអង្គប្រជុំមេត្តាជ្រាប។

កិច្ចប្រជុំបានអនុម័តលើរបៀបវារៈទី៥ ៖ ១៩សំឡេង លើ១៩សំឡេង។

○ **<u>របៀបវារៈទី៦</u>** ៖ ***ពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ (២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) របស់រដ្ឋបាលខេត្តកោះកុង***

លោកជំទាវ **មិថុនា ភូថង** អភិបាលខេត្ត បានមានប្រសាសន៍ថា ក្នុងនាមក្រុមការងារកសាងផែនការអភិវឌ្ឍន៍ខេត្ត និងក្នុងនាមលោកជំទាវអភិបាលខេត្តផ្ទាល់ សូមថ្លែងអំណរគុណចំពោះឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត ដែលបានសម្រេចដាក់បញ្ចូលផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តនាថ្ងៃនេះ ដើម្បីធ្វើការពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីស្នើសុំការអនុលោមភាពពីសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាគោលការណ៍។ ជាមួយគ្នានោះលោកជំទាវអភិបាលខេត្ត បានធ្វើសេចក្តីថ្លែងហេតុ៣ក់ព័ន្ធនឹងដំណើរការនៃការរៀបចំកសាងផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ(ឆ្នាំ២០២០-ឆ្នាំ២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល(ឆ្នាំ២០២០-ឆ្នាំ២០២២)របស់រដ្ឋបាលខេត្ត ដើម្បីឱ្យក្រុមប្រឹក្សាខេត្តមានមូលដ្ឋានក្នុងការពិនិត្យ និងអនុម័ត។

ឯកឧត្តម **ភាយ សំរួម** ប្រធានក្រុមប្រឹក្សាខេត្ត សូមថ្លែងអំណរគុណចំពោះលោកជំទាវអភិបាលខេត្ត និងជាប្រធានក្រុមការងារកសាងផែនការអភិវឌ្ឍន៍ខេត្ត ដែលបានធ្វើនូវសេចក្តីថ្លែងហេតុជូនក្រុមប្រឹក្សាខេត្តបានជ្រាបអំពីដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត។ ដោយផ្អែកតាមច្បាប់

លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំរបស់ក្រុមប្រឹក្សាខេត្តឃើញថា ការអនុវត្តនីតិវិធីនៃការកសាងផែនការខាងលើនេះ មានភាពស្មុគស្មាញច្រើន ទម្រាំឈានមកដល់ដំណាក់កាលនេះ ក្រុមការងារកសាងផែនការបានខិតខំរៀបចំកិច្ចប្រជុំជាច្រើនលើកច្រើនសារ ក្នុងគោលបំណងកែលំអរ ស្វែងរកទិន្នន័យ និងបំពេញធាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីឱ្យផែនការនេះកាន់តែល្អប្រសើរ។ មកដល់អាណត្តិទី៣របស់ក្រុមប្រឹក្សាខេត្តនាពេលនេះ **គឺយើងបានរៀបចំផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ** បានចំនួន៣លើករួចមកហើយ ដូច្នេះវាមិនសូវជាមានបញ្ហាប្រឈមអ្វីច្រើននោះទេ **ដោយសារយើង**មានកំណត់ហេតុប្រជុំគណៈអភិបាល និងកំណត់ហេតុប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត ដែលមានលោកជំទាវអភិបាលខេត្តជាប្រធាន ហើយក្នុងនោះក៏មានសមាសភាពសមាជិកក្រុមប្រឹក្សាខេត្តចំនួន ០៦រូបជាសមាជិកគណៈកម្មាធិការផងដែរ ដូច្នេះឯកឧត្តមប្រធានសូមដាក់ជូនសេចក្តីព្រាងនេះ ជូនឯកឧត្តម លោកជំទាវ សមាជិកក្រុមប្រឹក្សាខេត្តផ្តល់ជាមតិយោបល់បន្ថែម ព្រោះសេចក្តីព្រាងនេះ ក្រុមការងារបានធ្វើការចែកជូនរយៈពេល០១ ខែមុនមកហើយ។

ឯកឧត្តម **អ៊ុន ឆាលី** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា យោងតាមកំណត់ហេតុប្រជុំរបស់ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ស្តីពីការពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ(២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២០-២០២២)របស់រដ្ឋបាលខេត្ត កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០កន្លងទៅ ហើយការចែកជូនសេចក្តីព្រាងនេះក៏ច្រើនថ្ងៃមកហើយដែរ អញ្ចឹងទេឯកឧត្តមបានពិនិត្យ**ឃើញថា ចំពោះការរៀបចំទម្រង់បែបបទឃើញថាត្រឹមត្រូវល្អហើយ** ប៉ុន្តែសម្រាប់តួលេខវិញមិនដឹងថាយ៉ាងម៉េចនោះទេ ព្រោះមិនមានរបាយការណ៍សម្រាប់ធ្វើការផ្ទៀងផ្ទាត់ ដូច្នេះមុននឹងធ្វើការផ្តល់ជាមតិយោបល់ទៅលើសេចក្តីព្រាងនេះ ឯកឧត្តមសូមសំណូមពរឱ្យឯកឧត្តម លោកជំទាវ សមាជិកក្រុមប្រឹក្សាខេត្ត ដែលជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសផ្តល់ជាមតិយោបល់មុន ថាតើការប្រជុំពិនិត្យទៅលើសេចក្តីព្រាងនេះនៅក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកន្លងមកនេះ ឃើញថាមានបញ្ហាអ្វីខ្លះ? តើអាចទទួលយកបាន ឬមិនទទួលយកបាន?។

លោកជំទាវ **សរ ស៊ីមអ៊ីម** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា ក្នុងនាម គ.ក.ស.ក.ខេត្ត ដែលជាសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស លោកជំទាវបានពិនិត្យឃើញថា ការប្រជុំពិនិត្យលើសេចក្តីព្រាងផែនការខាងលើនេះ គឺមានតួលេខ និងទិន្នន័យមួយចំនួននៅក្នុងទំព័រទី២ ទំព័រទី១៥ និងទំព័រទី២៩ ត្រូវធ្វើការកែសម្រួលហើយនៅក្នុងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ក៏មានមន្ទីរមួយចំនួនធ្វើការកែសម្រួលទិន្នន័យផងដែរ ប៉ុន្តែដោយឯកសារនៅក្នុងដៃរបស់លោកជំទាវជាឯកសារចាស់ អញ្ចឹងទេមិនដឹងថាក្រុមការងារបានធ្វើការកែសម្រួលទៅតាមស្មារតីនៃកិច្ចប្រជុំកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ឬយ៉ាងណានោះឡើយ។

ឯកឧត្តម ភាយ សំរួម ប្រធានក្រុមប្រឹក្សាខេត្ត បានជម្រាបជូនថា **សេចក្តីព្រាងនេះ គឺបានចែកជូនមុនច្រើនថ្ងៃមកហើយ** ហើយចំពោះទិន្នន័យដែលត្រូវធ្វើការកែសម្រួលដោយយោងតាមស្មារតីនៃកិច្ចប្រជុំរបស់គណៈ**អភិបាលខេត្ត**ក៏ដូចជាកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គឺក្រុមការងារកសាងផែនការ បានធ្វើ**ការកែសម្រួល**ទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័ររួចរាល់ហើយ គឺកែសម្រួលទៅតាមស្មារតីនៃកិច្ចប្រជុំខាងលើនេះ ដូចមានកំណត់ហេតុជូនភ្ជាប់ជាមួយ។

លោក **ឆេត សោភ័ណ្ឌ** នាយករងទីចាត់ការផែនការ និងវិនិយោគ បានជម្រាបជូនថា ក្រោយពីគណៈអភិបាលលោកមានមតិយោបល់យ៉ាងណានោះ ក្រុមការងារបានអញ្ជើញមន្ទីរអង្គភាពទាំងនោះ មកប្រជុំត្រួតពិនិត្យជាមួយក្រុមការងារកសាងផែនការអភិវឌ្ឍន៍ខេត្តដើម្បីកែសម្រួលឱ្យបានត្រឹមត្រូវ ស្របតាមការណែនាំរបស់គណៈ**អភិបាល** ដូច្នេះចំពោះទិន្នន័យរបស់មន្ទីរអង្គភាពដែលត្រូវធ្វើការកែសម្រួល គឺមាននៅក្នុងកំណត់ហេតុរួចហើយ។

ឯកឧត្តម **អ៊ុន ឆាលី** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា ក្រោយពីបានធ្វើការពិនិត្យទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងបានពិនិត្យលើកំណត់ហេតុប្រជុំរបស់គណៈអភិបាល និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរួចមកឃើញថា ក្រុមការងាររៀបចំបានល្អប្រសើរច្រើន និង

អាចទទួលយកបាន ហើយអ្វីដែលជាចំណុចខ្វះខាតគឺមានតិចតួចប៉ុណ្ណោះ ដូច្នេះក្រុមការងារត្រូវសហការជាមួយមន្ទីរអង្គភាពជំនាញ ដើម្បីធ្វើការបំពេញបន្ថែមនូវចំណុចខ្វះខាតទាំងនោះឱ្យបានត្រឹមត្រូវឡើងវិញ។

ឯកឧត្តម **អ៊ុច ឥណា** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍ថា បន្ទាប់ពីបានទទួលកំណត់ហេតុទាំងពីរស្តីពីការប្រជុំពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ពីក្រុមការងារកសាងផែនការរួចមកឃើញថា ការកែសម្រួលគឺច្រើនតែក្នុងជំពូកទី១តែប៉ុណ្ណោះ ដូច្នេះនៅមានបញ្ហាសេសសល់មួយចំនួនទៀតក៏ត្រូវតែធ្វើការកែសម្រួលទិន្នន័យឱ្យបានត្រឹមត្រូវឡើងវិញ។ នៅក្នុងចង្កោមកសិកម្ម ឃើញថាមានរំលេចតែវិស័យជលផលតែប៉ុណ្ណោះ មិនឃើញមានវិស័យព្រៃឈើនោះទេ ឬចាត់ទុកវិស័យព្រៃឈើមិនស្ថិតក្នុងចង្កោមសេដ្ឋកិច្ច?។

លោកជំទាវ **មិថុនា ភូថង** អភិបាលខេត្ត បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះមតិយោបល់របស់ឯកឧត្តម លោកជំទាវសមាជិកក្រុមប្រឹក្សាខេត្ត ដែលបានចូលរួមជាមតិយោបល់ក្នុងការកែសម្រួលទៅលើសេចក្តីព្រាងផែនការនេះឱ្យកាន់តែល្អប្រសើរថែមមួយកំរិតទៀត។ ដោយសេចក្តីព្រាងនេះ បានប្រជុំពិនិត្យជាច្រើនដំណាក់កាលរួចមកហើយ ហើយចៀសវាងបន្តការយឺតយ៉ាវជាបន្តទៀត លោកជំទាវបានស្នើសុំការអនុម័តជាផ្លូវការពីឱ្យក្រុមប្រឹក្សាខេត្ត ដើម្បីយើងយកសៀវភៅនេះជាគ្រឹះវិស័យ ក្នុងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅក្នុងមូលដ្ឋានខេត្តកោះកុងយើង។

ឯកឧត្តម **អាយ សំអូម** ប្រធានក្រុមប្រឹក្សាខេត្ត សូមថ្លែងអំណរគុណចំពោះការបញ្ចេញមតិយោបល់ របស់ឯកឧត្តម លោកជំទាវ ដើម្បីកែសម្រួលឱ្យផែនការអភិវឌ្ឍន៍ខេត្តកោះកុងយើងក្នុងអាណត្តិទី៣របស់ក្រុមប្រឹក្សានេះ កាន់តែល្អប្រសើរ និងមានគុណភាពបន្ថែមទៀត។ ជាមួយគ្នានោះឯកឧត្តមប្រធាន ស្នើសុំឱ្យក្រុមការងារកសាងផែនការ មេត្តាយកចិត្តទុកដាក់ទៅលើមតិយោបល់របស់ឯកឧត្តម លោកជំទាវខាងលើ និងកែសម្រួលទៅតាមអ្វីដែលជាស្មារតីអង្គប្រជុំបានលើកឡើងឱ្យបានត្រឹមត្រូវ មុននឹងបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីស្នើសុំការអនុលោមភាព។

កិច្ចប្រជុំបានអនុម័តលើរបៀបវារៈទី៦ ៖ ១៩សំឡេង លើ១៩សំឡេង។

- **<u>របៀបវារៈទី៧</u> ៖ *បញ្ហាផ្សេងៗ***

លោកជំទាវ **ឈី ង៉ា** សមាជិកក្រុមប្រឹក្សាខេត្ត បានមានប្រសាសន៍សួរទៅលោកជំទាវអភិបាលខេត្ត ពាក់ព័ន្ធនឹងការផ្អាកការបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរខាងមុខនេះ បើយោងតាមប្រសាសន៍សម្តេចនាយករដ្ឋមន្ត្រី លោកបានឱ្យផ្អាកពិធីបុណ្យចូលឆ្នាំថ្មី ដោយសារតែបញ្ហាជំងឺកូវីដ១៩ ហើយថ្មីៗនេះសម្តេចសង្ឃទាំងពីរគណៈក៏បានចេញលិខិតពាក់ព័ន្ធនឹងការផ្អាកនេះផងដែរ ដូច្នេះតើខេត្តយើងមានគោលការណ៍ផ្សព្វផ្សាយ ឬចេញសេចក្តីណែនាំជូនដល់ប្រជាពលរដ្ឋបានជ្រាបហើយឬនៅ?

លោកជំទាវ **មិថុនា ភូថង** អភិបាលខេត្ត បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលទើបតែនឹងចេញអនុក្រឹត្យពីម្សិលមិញ ដោយក្នុងថ្ងៃបុណ្យចូលឆ្នាំត្រូវនៅធ្វើការដដែល ហើយមុននេះ លោកជំទាវក៏បានចុះហត្ថលេខាលើសេចក្តីណែនាំរួចហើយដែរ ដើម្បីឱ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់អនុវត្តអនុក្រឹត្យរបស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព និងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងសាធារណៈជនទាំងអស់ឱ្យបានជ្រួតជ្រាបផងដែរ ជាពិសេសណែនាំមិនឱ្យមានការជួបជុំ ឬប្រមូលផ្តុំគ្នាទេ ព្រោះស្ថានការណ៍នៃការរីករាលដាលជំងឺកូវីដ១៩ មានការកើនឡើងកាន់តែច្រើនជាបន្តបន្ទាប់។

ឯកឧត្តម **ប៊ុន ម៉ៀវ** សមាជិកក្រុមប្រឹក្សាខេត្ត បានចុះទៅ ឃុំជំនាប់ ឃុំប្រឡាយ និងឃុំថ្មដូនពៅ នៃស្រុកថ្មបាំង ស្របតាមការបែងចែកតួនាទីភារកិច្ច ដើម្បីប្រមូលព័ត៌មាន និងបញ្ហាមួយចំនួននៅមូលដ្ឋាន ដោយក្នុងនោះប្រជាពលរដ្ឋលោកបានសំណូមពរ ពាក់ព័ន្ធនឹងស្ពានឆ្លងស្ទឹងអារ៉ែង ហើយបញ្ហានេះឯកឧត្តម **អ៊ុន ឆាលី** សមាជិកក្រុមប្រឹក្សាខេត្តក៏បានលើកឡើងជាញឹកញាប់ដែរ អញ្ចឹងទេតើបញ្ហានេះ មន្ទីរសាធារណៈការមានដំណោះស្រាយយ៉ាងណាហើយដើម្បីយើងមានមូលដ្ឋានក្នុងការឆ្លើយតបត្រឡប់ទៅពួកគាត់វិញ?។ ប្រជាពលរដ្ឋនៅឃុំតាទៃលើ ស្នើសុំឱ្យមានអគ្គិសនីប្រើប្រាស់ផងដែរ ព្រោះ៨ឃុំក្នុងស្រុកថ្មបាំង លើកលែងតែឃុំជីផាតចេញ គឺឃុំតាទៃលើមិនទាន់មានអគ្គិសនីនៅឡើយទេ។ ជាមួយគ្នានោះប្រជាពលរដ្ឋចំនួន៦នាក់ បានធ្វើអត្តសញ្ញាណប័ណ្ណជាយូរខែហើយ ប៉ុន្តែមិនទាន់បានចេញឱ្យពួកគាត់បានប្រើប្រាស់នៅឡើយទេ។

លោក **អន ជាតុច** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន បានជម្រាបជូនថា ចំពោះស្ពានឆ្លងស្ទឹងអារ៉ែង នេះ លោកបានចុះធ្វើការសិក្សា និងវាស់វែងបឋមបានមួយជំហានហើយ គឺមានប្រវែង១២០ម៉ែត្រ និងមានថ្មនៅខាងក្រោមច្រើន យើងអាចដាំសរសរនៅលើថ្មរួចចាក់ជាបេតុងតែម្តង ឬមួយយើងដាំសរសរួចយើងរៀបជាដែកបាឡែក៏បាន ដូច្នេះគម្រោងលំអិត លោកនឹងចុះធ្វើការសិក្សាឱ្យបានច្បាស់លាស់នៅសប្តាហ៍ក្រោយនេះ។ លោកបានបញ្ជាក់ជូនបន្ថែមថា លោកបានត្រឹមតែជួយសិក្សាជូនតែប៉ុណ្ណោះ ព្រោះគំរបផ្លូវ១ខ្សែនេះ វាស្ថិតនៅក្នុងគម្រោងរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ដូច្នេះលោកមិនអាចទៅរំលោភលើដែនសមត្ថកិច្ចរបស់អង្គភាពផ្សេងបានឡើយ ប៉ុន្តែលោកអាចសិក្សាជូនបាន។

ដោយពិនិត្យឃើញថា ឯកឧត្តម លោកជំទាវ សមាជិកក្រុមប្រឹក្សាខេត្ត ពុំមានមតិយោបល់ពាក់ព័ន្ធនឹងរបៀបវារៈខាងលើ ឯកឧត្តមប្រធានបានធ្វើការបូកសរុបនូវលទ្ធផលនៃកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តដូចខាងក្រោម ៖

១. បានអនុម័ត លើការផ្លាស់ប្តូរទីកន្លែងនៃកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តពីសាលប្រជុំ(ខ)សាលាខេត្ត មកសាលមហោស្រពខេត្ត

២. បានអនុម័តលើសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង

៣. បានអនុម័តលើសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញលើកទី១០ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង

៤. បានស្តាប់របាយការណ៍ ស្តីពីសកម្មភាពការងាររបស់គណៈអភិបាលខេត្តកោះកុង គិតចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

៥. បានស្តាប់របាយការណ៍ ស្តីពីលទ្ធផលការងារប្រចាំខែមីនា ឆ្នាំ២០២០ និងទិដ្ឋៈបន្ត របស់ការិយាល័យប្រជាពលរដ្ឋខេត្តកោះកុង

៦. បានអនុម័ត លើសេចក្តីព្រាងរបាយការណ៍ ប្រចាំឆ្នាំ២០១៩ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខេត្តកោះកុង

៧. បានអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំខែមីនា ឆ្នាំ២០២០ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខេត្តកោះកុង

៨. បានអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ (២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) របស់រដ្ឋបាលខេត្តកោះកុង

៩. បានស្តាប់នូវសេចក្តីរាយការណ៍ មតិយោបល់ និងការសំណូមពរនានាក្នុងបញ្ហាផ្សេងៗ។

ក្រោយពេលបូកសរុបលទ្ធផលរួចមក ឯកឧត្តមប្រធាន បានប្រកាសជូនអង្គប្រជុំជ្រាបថា កិច្ចប្រជុំបន្ទាប់គឺជាកិច្ចប្រជុំសាមញ្ញលើកទី១២ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត នឹងប្រព្រឹត្តទៅនាថ្ងៃចន្ទ ៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ខាងមុខ ហើយឯកឧត្តមប្រធានបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមប្រសិទ្ធិពរជ័យជូនដល់វត្តមានលោកជំទាវអភិបាលខេត្ត ឯកឧត្តម លោកជំទាវ សមាជិកក្រុមប្រឹក្សាខេត្ត លោកអភិបាលរងខេត្ត និងលោក លោកស្រីដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនាថ្ងៃនោះទាំងអស់ និងបានប្រសិទ្ធិពរជ័យឱ្យជួបតែពុទ្ធពរទាំង៤ប្រការគឺ ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងបានប្រកាសបិទកិច្ចប្រជុំ។

កិច្ចប្រជុំសាមញ្ញលើកទី១១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត បានបញ្ចប់នៅវេលាម៉ោង១២និង៣៥នាទី រសៀលនាថ្ងៃខែឆ្នាំដដែល ក្នុងបរិយាកាសយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់។

កំណត់ហេតុនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាខេត្ត នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី១២ អាណត្តិទី៣ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ដោយសំឡេងគាំទ្រចំនួន១៨សំឡេង លើចំនួន១៨សំឡេង។

លេខាកត់ត្រា

ឡង សុផល

បានឃើញ និងឯកភាព

ថ្ងៃ.ពុធ.៧.រោច.....ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ខេត្តកោះកុង ថ្ងៃទី.១៣...ខែឧសភា ឆ្នាំ២០២០

ប្រធានអង្គប្រជុំ

កាយ សំរួម